# សុត្តន្តបិដក





៣០

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ   សគាថវគ្គ
# ទុតិយភាគ
# ៣០



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## SAṂYUTTANIKĀYA

## SAGĀTHAVAGGA

## DUTIYABHĀGA

## 30

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ ៥០០ ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធ ចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំៗ តែងតែបានទទួលយកមកតម្កល់ ទុកធ្វើជាគ្រឹះ ដើម្បី ធ្វើការស្រាវ ជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើម ឡើយគេនាំគ្នា កត់ត្រាលើ ស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈ ក៏មាន លុះចំណេរតមកក៏បាននាំគ្នា បោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ន នេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេស ម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើប យើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុប មិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំ ក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេច ព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួល ពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammayutt Sangkat Chatumuk Khan Daun Penh P.Penh

ទំព័រទទេ

# សេចក្ដីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

## ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្លឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

# សំយុត្តនិកាយ    សគាថវគ្គ

## ទុតិយភាគ

៣០

ព.ស. ២៤០៦

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស សគាថវគ្គោ

## ទុតិយោ ភាគោ

---

## ភិក្ខុនីសំយុត្តំ

### បឋមំ អាឡវិកាសុត្តំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិ-យំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាឡវិកា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ សាវត្ថិ-យំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន អន្ធវនំ តេនុបសង្កមិ វិវេកត្ថិកិនី ។

[២] អថខោ មារោ បាបិមា អាឡវិកាយ ភិក្ខុនិយា ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុ-កាមោ វិវេកម្ហា ចាវេតុកាមោ យេន អាឡវិកា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា អាឡវិកំ ភិក្ខុនឹ គាថាយ អជ្ឈភាសិ ។

# សុត្តន្តបិដក

# សំយុត្តនិកាយ សគាថវគ្គ

# ទុតិយភាគ

---

## ភិក្ខុនីសំយុត្ត

### អាឡវិកាសូត្រទី ១

[១] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ភិក្ខុនីឈ្មោះអាឡវិកា ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងបច្ឆាភត្ត ក៏មានសេចក្តីត្រូវការ ដោយទីស្ងាត់ហើយចូលទៅកាន់អន្ធវ័ន ។

[២] គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យសេចក្តីតក់ស្លុតនិងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាឡវិកាភិក្ខុនី មានប្រាថ្នា ឲ្យនាងឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ ហើយក៏ចូលទៅរកអាឡវិកា-ភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងអាឡវិកាភិក្ខុនីថា

២



នត្ថិ និស្សរណំ លោកេ
កឹ វិវេកេន កាហសិ
ភុញ្ជស្សុ កាមរតិយោ
មាហុ បច្ឆានុតាបិនីតិ ។

[៣] អថខោ អាឡវិកាយ ភិក្ខុនិយា ឯតទហោសិ កោ នុ ខោ អយំ មនុស្សោ វា អមនុស្សោ វា គាថំ ភាសតីតិ ។ អថខោ អាឡវិកាយ ភិក្ខុនិយា ឯតទហោសិ មារោ ខោ អយំ បាបិមា មម ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ វិវេកម្ហា ចាវេតុកាមោ គាថំ ភាសតីតិ ។ អថខោ អាឡវិកា ភិក្ខុនី មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

ធម្មជាតជាគ្រឿងរលាស់ចេញ[១] ក្នុងលោក មិនមានទេ
នាងនឹងធ្វើនូវប្រយោជន៍អ្វី ដោយសេចក្តីស្ងប់ស្ងាត់ ចូរនាង
បរិភោគ នូវសេចក្តីត្រេកអរក្នុងកាម នាងពុំមានសេចក្តីក្តៅ
ក្រហាយ ក្នុងកាលជាខាងក្រោយឡើយ ។

[៣] គ្រានោះ អាឡវិកាភិក្ខុនី មានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលនូវគាថា ។ ទើបអាឡវិកាភិក្ខុនី មានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញឃ្លាតចាកសេចក្តីស្ងប់ស្ងាត់ បានជាពោលនូវគាថា ។ លុះអាឡវិកាភិក្ខុនីស្គាល់ច្បាស់ថា នេះជាមារ មានចិត្តបាប ដូច្នេះហើយ ក៏ពោលគាថាទាំងឡាយ នឹងមារមានចិត្តបាបថា

---

១ ព្រះនិព្វាន ។

អត្ថិ និស្សរណំ លោកេ
បញ្ញាយ មេ សុផុស្សិតំ
បមត្តពន្ធុ បាបិម
ន ត្វំ ជានាសិ តំ បទំ
សត្តិសូលូបមា កាមា
ខន្ធាសំ អធិកុដ្ដនា
យំ ត្វំ កាមរតឹ ព្រូសិ
អរតិ មយ្ហ សា អហូតិ[១] ។

អថខោ មារោ បាបិមា ជានាតិ មំ អាឡវិកា ភិក្ខុនីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## ទុតិយំ សោមាសុត្តំ

[៤] សាវត្ថីនិទានំ ។ អថខោ សោមា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន អន្ធវនំ តេនុបសង្កមិ ទិវា-វិហារាយ អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូ-លេ ទិវាវិហារំ និសីទិ ។

១ ម. មយ្ហំ មា អហូតិ ។

*ធម្មជាតជាគ្រឿងរលាស់ចេញ ក្នុងលោក មាន យើងបាន ពាល់ត្រូវ ដោយបញ្ញា[១] ម្នាលមារមានចិត្តបាប មាន ផៅពង្សជាអ្នកប្រមាទ អ្នកមិនដឹងនូវបទនោះទេ កាមទាំង-ឡាយ ឧបមាដោយលំពែងស្រួច ខន្ធទាំងឡាយជាកន្ទែង សម្រាប់មុត នៃកាមទាំងឡាយនោះ អ្នកពោលនូវសេចក្តី ត្រេកអរ ក្នុងកាមណា សេចក្តីត្រេកអរ ក្នុងកាមនោះ ជាសេចក្តីមិនត្រេកអររបស់យើងទេ ។*

*លំដាប់នោះ មារមានចិត្តបាបដឹងថា អាឡវិកាភិក្ខុនី ស្គាល់អញ ហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។*

# សោមាសូត្រ ទី ២

[៤] *សាវត្ថីនិទាន ។ គ្រានោះ សោមាភិក្ខុនី ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បី បិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកពី បិណ្ឌបាត ក្នុងបច្ឆាភត្ត ក៏ដើរសំដៅទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុង វេលាថ្ងៃ លុះចូលទៅដល់អន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។*

---

១ បច្ចវេក្ខណញ្ញាណ ។

[៥] អថខោ មារោ បាបិមា សោមាយ ភិក្ខុនិយា ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ យេន សោមា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា សោមំ ភិក្ខុនឹ គាថាយ អជ្ឈភាសិ

យន្តំ ឥសីហិ បត្តព្វំ
ឋានំ ទុរភិសម្ភវំ
ន តំ ទ្វង្គុលបញ្ញាយ
សក្កា បប្បោតុមិត្ថិយាតិ ។

[៦] អថខោ សោមាយ ភិក្ខុនិយា ឯតទហោសិ កោ នុ ខោ អយំ មនុស្សោ វា អមនុស្សោ វា គាថំ ភាសតីតិ ។ អថខោ សោមាយ ភិក្ខុនិយា ឯតទហោសិ មារោ ខោ អយំ បាបិមា មម ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ គាថំ ភាសតីតិ ។ អថខោ សោមា ភិក្ខុនី មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

[៥] គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យសេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់សោមាភិក្ខុនី ប្រាថ្នាឲ្យនាងឃ្លាតចាកសមាធិ ក៏ចូលទៅរកសោមាភិក្ខុនី លុះចូលទៅដល់ហើយ ក៏ពោលគាថានឹងសោមាភិក្ខុនីថា

ទី[១]ណា ដែលមានដោយកម្រ ជាទីដែលឥសីទាំងឡាយ
គប្បីដល់ ទីនោះស្ត្រីដែលមានបញ្ញាប្រវែងពីរធ្នាប់ មិនអាច
នឹងដល់បានឡើយ ។

[៦] លំដាប់នោះ សោមាភិក្ខុនីមានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលនូវគាថា ។ ទើបសោមាភិក្ខុនីមានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលនូវគាថា ។ លុះសោមាភិក្ខុនីដឹងច្បាស់ថា នេះជាមារមានចិត្តបាបហើយ ក៏ពោលគាថាទាំងឡាយ នឹងមារមានចិត្តបាបថា

---

១ ព្រះអរហន្ត ។

ឥត្ថីភាវោ កឹ កយិរា
ចិត្តម្ហិ សុសមាហិតេ
ញាណម្ហិ វត្តមានម្ហិ
សម្មា ធម្មំ វិបស្សតោ
យស្ស នូន សិយា ឯវំ
ឥត្ថីហំ បុរិសោតិ វា
កិញ្ចិ វា បន អស្មីតិ
តំ មារោ វត្តុមរហតីតិ ។

អថខោ មារោ បាបិមា ជានាតិ មំ សោមា ភិក្ខុនីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## តតិយំ គោតមីសុត្តំ

[៧] សាវត្ថីនិទានំ ។ អថខោ កិសាគោតមី ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន អន្ធវនំ តេនុបសង្កមិ ទិវាវិហារាយ អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

*កាលបើចិត្ត របស់ស្ត្រីភាពដែលឃើញនូវធម៌[១] ដោយ
ប្រពៃ បានតាំងមាំហើយ[២] កាលបើញាណ[៣] កំពុងប្រ-
ព្រឹត្តទៅ ស្ត្រីភាពនឹងធ្វើអ្វី (ក៏ធ្វើបាន) បើបុគ្គលណា មាន
សេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញជាស្ត្រីឬជាបុរស ឬមួយ
មានកង្វល់ថា អាត្មាអញមាន ដូច្នេះ មារគួរនឹងស្តីថាឲ្យ
បុគ្គលនោះបាន ។*

*លំដាប់នោះមារ មានចិត្តបាប ដឹងថា សោមាភិក្ខុនីស្គាល់អញ ហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះឯង ។*

# គោតមីសូត្រ ទី ៣

[៧] *សាវត្ថីនិទាន ។ គ្រានោះ កិសាគោតមីភិក្ខុនី ស្លៀកស្បង់ ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងបច្ឆាភត្ត ក៏ដើរសំដៅទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់អន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។*

---

១ ចតុសច្ចធម៌ ឬ ខន្ធបញ្ចក: ជាអារម្មណ៍នៃវិបស្សនា ។ ២ ចិត្តដែលតាំងនៅក្នុងសមាធិ ។ ៣ ផលសមាបត្តិញ្ញាណ ។

[៨] អថខោ មារោ បាបិមា ភិក្ខុនិយា ភិក្ខុនិយា ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ យេន ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ភិក្ខុនឹ គាថាយ អជ្ឈភាសិ

កឹ នុ ត្វំ ហតបុត្តា វ[១]
ឯកមាសី រុទម្មុខី
វនមជ្ឈគតា ឯកា
បុរិសំ នុ គវេសសីតិ ។

[៩] អថខោ ភិក្ខុនិយា ភិក្ខុនិយា ឯតទហោសិ កោ នុ អយំ មនុស្សោ វា អមនុស្សោ វា គាថំ ភាសតីតិ ។ អថខោ ភិក្ខុនិយា ភិក្ខុនិយា ឯតទហោសិ មារោ ខោ អយំ បាបិមា មម ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ គាថំ ភាសតីតិ ។ អថខោ ភិក្ខុនី មារោ ខោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

១ ម. មតបុត្តា វ ។

[៨] គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់កិសាគោតមីភិក្ខុនី មានប្រាថ្នាឲ្យព្រះនាងឃ្លាតចាកសមាធិ ក៏ចូលទៅរកកិសាគោតមីភិក្ខុនី លុះចូលទៅដល់ហើយ ក៏ពោលគាថានឹងកិសាគោតមីភិក្ខុនីថា

នាងឯងមានកូនស្លាប់ហើយ មកអង្គុយតែម្នាក់ឯង មាន
មាត់ទួញយំ នៅកណ្តាលព្រៃតែម្នាក់ឯង នាងមកស្វែងរក
ប្រុសឬ ។

[៩] លំដាប់នោះ កិសាគោតមីភិក្ខុនី មានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលគាថា ។ ទើបកិសាគោតមីភិក្ខុនី មានសេចក្តីចូលចិត្ត ដូច្នេះថា នេះពិតជាមារ មានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺ-រោម ឲ្យកើតឡើងដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលគាថា ។ លុះកិសាគោតមីភិក្ខុនីដឹងច្បាស់ថា នេះពិតជាមារ មានចិត្តបាបហើយ ក៏ពោលគាថា នឹងមារមានចិត្តបាបដូច្នេះថា

៧

ភិក្ខុនីសំយុត្តស្ស គោតមីសុត្តេ កិសាគោតមីភិក្ខុនីគាថា

អច្ចន្តំ ហតបុត្តម្ហិ
បុរិសា ឯតទន្តិកា
ន សោចាមិ ន រោទាមិ
ន តំ ភាយាមិ អាវុសោ
សព្វត្ថ វិហតា នន្ទិ
តមោខន្ធោ បទាលិតោ
ជេត្វាន មច្ចុនោ សេនំ
វិហរាមិ អនាសវាតិ ។

អថខោ មារោ បាបិមា ជានាតិ មំ កិសា-គោតមី ភិក្ខុនីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## ចតុត្ថំ វិជយាសុត្តំ

[១០] សាវត្ថីនិទានំ ។ អថខោ វិជយា ភិក្ខុ-នី បុព្វណ្ហសមយំ និវាសេត្វា ។ បេ ។ អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

យើងជាស្ត្រីមានកូនស្លាប់ ជាទីបំផុតត្រឹមនេះ បុរសទាំង-ឡាយ ក៏មានទីបំផុតត្រឹមនេះដែរ ម្នាលអាវុសោ យើង មិនសោកសៅ មិនទួញយំ មិនខ្លាចអ្នកទេ ព្រោះថា សេចក្តីត្រេកអរ ក្នុងវត្ថុទាំងអស់ យើងកម្ចាត់ចោលហើយ គំនរនៃងងឹតគឺអវិជ្ជា យើងទម្លាយបង់បានហើយ យើង ឈ្នះនូវសេនានៃមច្ចុរាជ ជាស្ត្រីមិនមានអាសវៈ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា កិសាគោតមីភិក្ខុនី ស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះឯង ។

# វិជយាសូត្រ ទី ៤

[១០] សាវត្ថីនិទាន ។ គ្រានោះ វិជយាភិក្ខុនី ស្លៀកស្បង់ក្នុងបុព្វណ្ហសម័យ ។ បេ ។ អង្គុយសម្រាកក្នុងវេលាថ្ងៃក្រោមម្លប់ឈើមួយ ។

[១១] អថខោ មារោ បាបិមា វិជយាយ ភិក្ខុនិ-
យា ភយំ ។ បេ ។ សមាធិម្ហា ចាវេតុកាមោ យេន
វិជយា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា វិជយំ
ភិក្ខុនឹ គាថាយ អជ្ឈភាសិ

ទហរា ត្វំ រូបវតី
អហញ្ច ទហរោ សុសុ
បញ្ចង្គិកេន តុរិយេន
ឯហយ្យេភិរមាម្ហសេតិ ។

[១២] អថខោ វិជយាយ ភិក្ខុនិយា ឯតទហោសិ
កោ នុ ខោ អយំ មនុស្សោ វា អមនុស្សោ វា គាថំ
ភាសតីតិ ។ អថខោ វិជយាយ ភិក្ខុនិយា ឯតទហោសិ
មារោ ខោ អយំ បាបិមា ។ បេ ។ គាថំ ភាសតីតិ ។
អថខោ វិជយា ភិក្ខុនី មារោ អយំ បាបិមា ឥតិ
វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

[១១] គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញ៉ាំងភ័យឲ្យកើតឡើង ដល់វិជយាភិក្ខុនី ។ បេ ។ ប្រាថ្នាឲ្យឃ្លាតចាកសមាធិ ក៏ចូលទៅរកវិជយាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងវិជយាភិក្ខុនីថា

នាងជាស្ត្រីក្រមុំមានរូបឆោម យើងក៏កំឡោះក្មេង ម្នាល
នាងម្ចាស់ នាងចូរមក យើងទាំងពីរនាក់ ចូរត្រេកអរជា
មួយគ្នា ដោយតន្ត្រីប្រកបដោយអង្គ ៥[១] ។

[១២] លំដាប់នោះ វិជយាភិក្ខុនីមានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលគាថា ។ ទើបវិជយាភិក្ខុនី មានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប ។ បេ ។ បានជាពោលនូវគាថា ។ លុះវិជយាភិក្ខុនី ដឹងច្បាស់ថា នេះជាមារមានចិត្តបាប ហើយបានពោលគាថាទាំងឡាយ នឹងមារមានចិត្តបាបថា

---

១ អាតតំ ស្គរដែលគេដាសពាសតែម្ខាង ១ វិតតំ ស្គរតូចដែលគេដាសពាសទាំងពីរខាងមានសំភោរជាដើម ១ អាតតវិតតំ ស្គរធំដែលគេដាសពាសទាំងពីរខាងមានស្គរជ័យជាដើម ១ ឃនំ គ្រឿងតូរ្យតន្ត្រីតាន់គ្មានប្រហោង ១ សុសិរំ គ្រឿងតូរ្យតន្ត្រីមានប្រហោង ១ ។

៩

ភិក្ខុនីសំយុត្តស្ស វិជយាសុត្តេ វិជយាភិក្ខុនីគាថា

រូបា សទ្ទា គន្ធា រសា
ផោដ្ឋព្វា ច មនោរមា
និយ្យាតយាមិ តុយ្ហេវ
មារ ន ហិ តេន អត្ថិកា
ឥមិនា បូតិកាយេន
ភិន្ទនេន បភង្គុនា
អដ្ដិយាមិ ហរាយាមិ
កាមតណ្ហា សមូហតា
យេ ច រូបូបគា សត្តា
យេ ច អរូបភាគិនោ
យា ច សន្តា សមាបត្តិ
សព្វត្ថ វិហតោ តមោតិ ។

អថខោ មារោ បាបិមា ជានាតិ មំ វិជយា ភិក្ខុនីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

ភិក្ខុនីសំយុត្ត វិជយាសូត្រ គាថារបស់វិជយាភិក្ខុនី

រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាទីគាប់ចិត្ត យើង ប្រគល់ឲ្យអ្នកទាំងអស់ ម្នាលមារ ដ្បិតយើងមិនត្រូវការ ដោយអារម្មណ៍នោះទេ យើងធុញទ្រាន់ នឿយណាយ ពេកណាស់ ចំពោះកាយស្អុយដែលបែកធ្លាយពុករលួយនេះ កាមតណ្ហាយើងបានដកចោលហើយ សត្វទាំងឡាយណា ដែលទៅកើតក្នុងរូបភពក្តី សត្វទាំងឡាយណា ដែលមាន ចំណែកក្នុងអរូបភពក្តី សមាបត្តិណាដ៏ល្អិតក្តី សេចក្តី ងងឹតក្នុងភពទាំងអស់នោះ យើងកម្ចាត់បង់បានហើយ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា វិជយាភិក្ខុនី ស្គាល់ អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះឯង ។

# បញ្ចមំ ឧប្បលវណ្ណាសុត្តំ

[១៣] សាវត្ថីនិទានំ ។ អថខោ ឧប្បលវណ្ណា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា ។ បេ ។ អញ្ញតរស្មឹ សុបុប្ផិតសាលរុក្ខមូលេ អដ្ឋាសិ ។

[១៤] អថខោ មារោ បាបិមា ឧប្បលវណ្ណាយ ភិក្ខុនិយា ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ យេន ឧប្បលវណ្ណា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ឧប្បលវណ្ណំ ភិក្ខុនឹ គាថាយ អជ្ឈភាសិ

សុបុប្ផិតគ្គំ ឧបគម្ម ភិក្ខុនិ
ឯកា តុវំ តិដ្ឋសិ សាលមូលេ
ន ចត្ថិ តេ ទុតិយា វណ្ណធាតុ
ឥធាគតា តាទិសិកា ភវេយ្យុំ
ពាលេ ន ត្វំ ភាយសិ ធុត្តកានន្តិ ។

# ឧប្បលវណ្ណាសូត្រ ទី ៥

[១៣] *សាវត្ថីនិទាន ។ គ្រានោះ ឧប្បលវណ្ណាភិក្ខុនី ស្លៀកស្បង់ ក្នុងបុព្វណ្ហសម័យ ។ បេ ។ ឋិតនៅក្រោមម្លប់ដើមសាលព្រឹក្សដែលមានផ្ការីកស្គុសស្គាយមួយដើម ។*

[១៤] *គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យសេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់ឧប្បលវណ្ណាភិក្ខុនីមានប្រាថ្នា ឲ្យនាងឃ្លាតចាកសមាធិ ហើយចូលទៅរកឧប្បលវណ្ណា-ភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងឧប្បលវណ្ណាភិក្ខុនីថា*

*ម្នាលភិក្ខុនី នាងអាស្រ័យនៅដើមសាលព្រឹក្ស មានចុងប្រកប*
*ដោយផ្ការីកស្គុសស្គាយ ឋិតនៅតែម្នាក់ឯង ក្រោមម្លប់ដើម*
*សាលព្រឹក្ស ជាតុគឺភេទ[១] ជាគម្រប់ពីររបស់នាងមិនមាន គួរ*
*តែមានស្ត្រីទាំងឡាយ ប្រាកដដូចជានាង មកក្នុងទីនេះផង*
*នាងខ្លាចអំពើពាល របស់ពួកអ្នកលេងឬ ។*

១ ភិក្ខុនី ជាគ្នាមិនមានឡើយ ។

ភិក្ខុនីសំយុត្តស្ស ឧប្បលវណ្ណាសុត្តំ ឧប្បលវណ្ណាភាសនំ

[១៨] អថខោ ឧប្បវណ្ណាយ ភិក្ខុនិយា ឯតទហោសិ កោ នុ ខ្វាយំ មនុស្សោ វា អមនុស្សោ វា គាថំ ភាសតីតិ ។ អថខោ ឧប្បលវណ្ណាយ ភិក្ខុនិយា ឯតទហោសិ មារោ ខោ អយំ បាបិមា មម ភយំ ។ បេ ។ គាថំ ភាសតីតិ ។ អថខោ ឧប្បលវណ្ណា ភិក្ខុនី មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

សតំ សហស្សានិបិ ធុត្តកានំ
ឥធាគតា តាទិសិកា ភវេយ្យុំ
លោមំ ន ឥញ្ជាមិ ន សន្តសាមិ
មារ ន ភាយាមិ តមេកិកាមិ
ឯសា អន្តរធាយាមិ

[១៥] លំដាប់នោះ ឧប្បលវណ្ណាភិក្ខុនី មានសេចក្ដីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្សឬជាអមនុស្ស (មក) ពោលគាថាដូច្នេះ ។ ទើបឧប្បលវណ្ណាភិក្ខុនី មានសេចក្ដីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប ញុំាងភ័យ ។ បេ ។ ដល់អាត្មាអញ បានជាពោលគាថា ។ លុះឧប្បលវណ្ណាភិក្ខុនី ដឹងច្បាស់ថា នេះជាមារមានចិត្តបាបហើយ បានពោលគាថាទាំងឡាយ នឹងមារមានចិត្តបាបថា

អ្នកលេងមួយរយនាក់ក៏ដោយ មួយពាន់នាក់ក៏ដោយ ជនទាំងឡាយប្រាកដដូចជាអ្នកដែលមកក្នុងទីនេះក៏ដោយ យើងក៏មិនព្រឺរោម មិនតក់ស្លុតទេ ម្នាលមារ យើងសូម្បីតែម្នាក់ឯងមែន ក៏មិនខ្លាចអ្នកឡើយ យើងនេះចង់ឲ្យបាត់ទៅក៏បាន

កុច្ឆិ វា បរិសាមិ តេ
បឋមន្តរិកាយម្បិ
តិដ្ឋន្តី មំ ន ទក្ខសិ
ចិត្តស្មឹ វសិភូតម្ហិ
ឥទ្ធិបាទា សុភាវិតា
សព្វពន្ធនមុត្តោម្ហិ
ន តំ ភាយាមិ អាវុសោតិ ។

អថខោ មារោ បាបិមា ជានាតិ មំ ឧប្បលវណ្ណា ភិក្ខុនីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## ឆដ្ឋំ ចាលាសុត្តំ

[១៦] សាវត្ថីនិទានំ ។ អថខោ ចាលា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា ។ បេ ។ អញ្ញតរស្មឹ រុក្ខ-មូលេ ទិវាវិហារំ និសីទិ ។

[១៧] អថខោ មារោ បាបិមា យេន ចាលា ភិក្ខុនី ។ បេ ។ ឧបសង្កមិត្វា ចាលំ ភិក្ខុនឹ ឯតទ-វោច កឹ នុ ខោ ត្វំ ភិក្ខុនិ ន រោចេសីតិ ។ ជាតឹ ខ្វាហំ អាវុសោ ន រោចេមីតិ ។

ចង់ចូលក្នុងពោះអ្នកក៏បាន អ្នកមិនឃើញយើង ដែលកំពុង
ឋិតនៅក្នុងចន្លោះរោមភ្នែកឡើយ យើងជាស្ត្រីស្ទាត់ ក្នុងចិត្ត
ឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយ ដោយប្រពៃ
យើងផុតហើយចាកចំណងទាំងអស់ នៃអាវុសោ យើងមិន
ខ្លាចអ្នកទេ ។

លំដាប់នោះ មារមានចិត្តបាប ដឹងថា ឧប្បលវណ្ណាភិក្ខុនី ស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះឯង ។

# ចាលាសូត្រ ទី ៦

[១៦] សាវត្ថីនិទាន ។ គ្រានោះ ចាលាភិក្ខុនី ស្លៀកដណ្តប់ក្នុងបុព្វណ្ហសម័យ ។ បេ ។ អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។

[១៧] គ្រានោះ មារមានចិត្តបាប ចូលទៅរកចាលាភិក្ខុនី ។ បេ ។ លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងចាលាភិក្ខុនីថា ម្នាលភិក្ខុនី នាងមិនគាប់ចិត្តនឹងអ្វី ។ ម្នាលអាវុសោ យើងមិនគាប់ចិត្តនឹងជាតិ ។

១៣

ភិក្ខុនីសំយុត្តស្ស  ចាលាសុត្តេ  ចាលាភាសនំ

[១៨] កឹ នុ ខោ(១) ជាតឹ ន រោចេសិ
ជាតោ កាមានិ ភុញ្ជតិ
កោ នុ ខោ តំ ឥទមាទបយិ
ជាតិ មា រោច ភិក្ខុនីតិ ។
[១៩] ជាតស្ស មរណំ ហោតិ
ជាតោ ទុក្ខានិ ផស្សតិ
ពន្ធំ វធំ បរិក្លេសំ
តស្មា ជាតឹ ន រោចយេ
ពុទ្ធោ ធម្មមទេសេសិ
ជាតិយា សមតិក្កមំ
សព្វទុក្ខប្បហានាយ
សោ មំ សច្ចេ និវេសយិ
យេ ច រូបូបគា សត្តា
យេ ច អរូបភាគិនោ(២)
និរោធំ អប្បជានន្តា
អាគន្តារោ បុនព្ភវន្តិ ។

---

១ ឱ. ឯត្ថន្តរេ ត្វន្តិ ទិស្សតិ ។ ២ ឱ. ម. អរូបដ្ឋាយិនោ ។

ភិក្ខុនីសំយុត្ត ចាលាសូត្រ ពាក្យពោលរបស់ចាលាភិក្ខុនី

[១៨] ហេតុអ្វីក៏នាងមិនគាប់ចិត្តនឹងជាតិ បុគ្គលមានជាតិ រមែងបរិភោគនូវកាមទាំងឡាយ អ្នកណាបង្គាប់នាងឲ្យប្រកាន់យកនូវអំពើនេះថា ម្នាលភិក្ខុនី ចូរនាងកុំគាប់ចិត្តនឹងជាតិដូច្នេះ ។

[១៩] ចាលាភិក្ខុនីតបថា សត្វកើតហើយ រមែងមានមរណៈ សត្វកើតហើយ រមែងឃើញនូវទុក្ខទាំងឡាយ គឺការចង ការបៀតបៀន និងសេចក្ដីឧបទ្រពផ្សេង ៗ ហេតុដូច្នោះ បុគ្គលមិនត្រូវគាប់ចិត្តនឹងការកើតឡើយ ព្រះពុទ្ធ ទ្រង់សំដែងធម៌ជាគ្រឿងប្រព្រឹត្តកន្លងនូវការកើត ដើម្បីលះបង់នូវទុក្ខទាំង-អស់ ព្រះអង្គញ៉ាំងយើងឲ្យនៅក្នុងសច្ចធម៌ សត្វទាំងឡាយណា កើតក្នុងរូបភពក្ដី សត្វទាំងឡាយណា មានចំណែកក្នុងអរូបភពក្ដី សត្វទាំងអស់នោះ កាលបើមិនដឹងនូវនិរោធទេ រមែងមកកាន់ភពថ្មីទៀត ។

អថខោ មារោ បាបិមា ជានាតិ មំ បាលា ភិក្ខុ-
នីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## សត្តមំ ឧបចាលាសុត្តំ

[២០] សាវត្ថីនិទានំ ។ អថខោ ឧបចាលា ភិក្ខុនី
បុព្វណ្ហសមយំ និវាសេត្វា ។ បេ ។ អញ្ញតរស្មឹ រុក្ខមូ-
លេ ទិវាវិហារំ និសីទិ ។

[២១] អថខោ មារោ បាបិមា ។ បេ ។ ឧបចាលំ
ភិក្ខុនឹ ឯតទវោច កត្ថ នុ ត្វំ ភិក្ខុនិ ឧប្បជ្ជិតុកាមា-
តិ ។ ន ខ្វាហំ អាវុសោ កត្ថចិ ឧប្បជ្ជិតុកាមាតិ ។

[២២] តាវតឹសា ច យាមា ច
តុសិតា ចាបិ ទេវតា
និម្មានរតិនោ ទេវា
យេ ទេវា វសវត្តិនោ
តត្ថ ចិត្តំ បណិធេហិ
រតឹ បច្ចនុភោស្សសីតិ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា ចាលាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្ដីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

# ឧបចាលាសូត្រ ទី ៧

[២០] សាវត្ថីនិទាន ។ គ្រានោះ ឧបចាលាភិក្ខុនី ស្លៀកដណ្ដប់ ក្នុងបុព្វណ្ហសម័យ ។ បេ ។ អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។

[២១] គ្រានោះ មារមានចិត្តបាប ។ បេ ។ បានពោលពាក្យនេះនឹងឧបចាលាភិក្ខុនីថា ម្នាលភិក្ខុនី ហេតុដូចម្ដេច បានជានាងចង់កើត ។ ម្នាលអាវុសោ យើងឥតចង់កើត ក្នុងទីណាមួយទេ ។

[២២] ពួកទេវតាណា ដែលឋិតនៅក្នុងជាន់តាវត្តិង្សក្ដី
ជាន់យាមៈក្ដី ជាន់តុសិតក្ដី ពួកទេវតាដែលឋិតនៅក្នុងជាន់
និម្មានរតីក្ដី ពួកទេវតាដែលឋិតនៅក្នុងជាន់វសវត្តីក្ដី នាងចូរ
តម្កល់ចិត្តក្នុងពួកទេវតានោះ នឹងបានទទួលនូវតម្រេកមិនខាន ។

ភិក្ខុនីសំយុត្តស្ស ឧបចាលាសុត្តេ ឧបចាលាភាសនំ

[២៣] តាវត្តឹសា ច យាមា ច
តុសិតា ចាបិ ទេវតា
និម្មានរតិនោ ទេវា
យេ ទេវា វសវត្តិនោ
កាមពន្ធនពន្ធា តេ
ឯន្តិ មារវសំ បុន
សព្វោ វ អាទិត្តោ លោកោ
សព្វោ លោកោ បធូបិតោ
សព្វោ បជ្ជលិតោ លោកោ
សព្វោ លោកោ បកម្បិតោ
អកម្បិតំ អចលិតំ
អបុថុជ្ជនសេវិតំ
អគតិ យត្ថ មារស្ស
តត្ថ មេ និរតោ មនោតិ ។

អថខោ មារោ ចាបិមា ជានាតិ មំ ឧបចាលា ភិក្ខុនីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

## ភិក្ខុនីសំយុត្ត ឧបចាលាសូត្រ ពាក្យពោលរបស់ឧបចាលាភិក្ខុនី

[២៣] ឧបចាលាភិក្ខុនីតបថា ពួកទេវតាណា ដែលឋិតនៅក្នុងជាន់តាវត្តិង្សក្តី ជាន់យាមៈក្តី ជាន់តុសិតក្តី ពួកទេវតាដែលឋិតនៅក្នុងជាន់និម្មានរតីក្តី ពួកទេវតាដែលឋិតនៅក្នុងជាន់វសវត្តីក្តី ទេវតាទាំងនោះ ចំពាក់ដោយគ្រឿងចងគឺកាម រមែងមកកាន់អំណាចនៃមារទៀត លោកទាំង-អស់ ត្រូវភ្លើងឆេះ[១]ហើយ លោកទាំងអស់ក្តៅក្រហាយ[២] លោកទាំងអស់ភ្លឺប្រាលរន្ទាល[៣] លោកទាំងអស់ញាប់ញ័រហើយ ទីណា ដែលមិនញាប់ញ័រ មិនកក្រើក មិនមែនជាសំណេពនៃបុថុជ្ជន មិនមែនជាដំណើរនៃមារ ចិត្តយើងត្រេកអរហើយក្នុងទីនោះ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា ឧបចាលាភិក្ខុនី ស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

---

១ ភ្លើងកិលេសមានរាគៈជាដើម ភ្លើងទុក្ខមានជាតិទុក្ខជាដើម ។ ២ ក្តៅក្រហាយដោយភ្លើងទាំងពីរនោះឯង ។ ៣ ភ្លឺប្រាលរន្ទាលដោយភ្លើងទាំងពីរនោះឯង ។

# អដ្ឋមំ  សីសុបចាលាសុត្តំ

[២៤] សាវត្ថិយំ... អថខោ សីសុបចាលា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា ។ បេ ។ អញ្ញតរស្មឹ រុក្ខមូ-លេ ទិវាវិហារំ និសីទិ ។

[២៥] អថខោ មារោ បាបិមា យេន សីសុបចាលា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា សីសុបចាលំ ភិក្ខុនឹ ឯតទវោច កស្ស នុ ត្វំ ភិក្ខុនិ បាសណ្ឌំ រោចេសីតិ ។ ន ខ្វាហំ អាវុសោ កស្សចិ បាសណ្ឌំ រោចេមីតិ ។

[២៦] កំ នុ[1] ឧទ្ទិស្ស មុណ្ឌាសិ
សមណី វិយ ទិស្សសិ
ន ច រោចេសិ បាសណ្ឌំ
កិមិវ[2] ចរសិ មោមុហាតិ ។

---

១ កឹ នូតិប្បត្តិ ។ ២ កិមិទន្តិបិ បាឋោ ។

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# សីសុបចាលាសូត្រ ទី ៨

[២៤] *ទៀបក្រុងសាវត្ថី... គ្រានោះ សីសុបចាលាភិក្ខុនីស្លៀកដណ្តប់ ក្នុងបុព្វណ្ហសម័យ ។ បេ ។ អង្គុយសម្រាកក្នុងវេលាថ្ងៃក្រោមម្លប់ឈើមួយ ។*

[២៥] *គ្រានោះ មារមានចិត្តបាប ក៏ចូលទៅរកសីសុបចាលាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងសីសុបចាលាភិក្ខុនីថា ម្នាលភិក្ខុនី នាងគាប់ចិត្តនឹងលទ្ធិរបស់បុគ្គលណា ។ ម្នាលអាវុសោ យើងមិនគាប់ចិត្តនឹងលទ្ធិ របស់បុគ្គលណាមួយទេ ។*

[២៦] *នាងឧទ្ទិសចំពោះបុគ្គលណា បានជាកោរក្បាល*
*ប្រាកដដូចជាសមណី (សមណៈស្រី) បើនាងមិនគាប់ចិត្ត*
*នឹងលទ្ធិ (បុគ្គលណា) ទេ ហេតុអ្វីបានជានាងប្រព្រឹត្តដូច*
*ជាស្រីវង្វេង ។*

# ១៧

ភិក្ខុនីសំយុត្តស្ស  សីសុបចាលាសុត្តេ  សីសុបចាលាភាសនំ

[២៧] ឥតោ  ពហិទ្ធា  បាសណ្ឌា
ទិដ្ឋីសុ  សំសីទន្តិ  តេ
ន  តេសំ  ធម្មំ  រោចេមិ
ន  តេ  ធម្មស្ស  កោវិទា
អត្ថិ  សក្យកុលេ  ជាតោ
ពុទ្ធោ  អប្បដិបុគ្គលោ
សព្វាភិភូ  មារនុទោ
សព្វត្ថ  មបរាជិតោ
សព្វត្ថ  មុត្តោ  អស្សិតោ
សព្វំ  បស្សតិ  ចក្ខុមា
សព្វកម្មក្ខយំ  បត្តោ
វិមុត្តោ  ឧបធិសង្ខយេ
សោ  មយ្ហំ  ភគវា  សត្ថា
តស្ស  រោចេមិ  សាសនន្តិ  ។

អថខោ  មារោ  បាបិមា  ជានាតិ  មំ  សីសុបចាលា ភិក្ខុនីតិ  ទុក្ខី  ទុម្មនោ  តត្ថេវន្តរធាយីតិ  ។

ភិក្ខុនីសំយុត្ត សីសុបចាលាសូត្រ ពាក្យពោលរបស់សីសុបចាលាភិក្ខុនី

[២៧] សីសុបចាលាភិក្ខុនីតបថា បុគ្គលទាំងនោះដែលមានលទ្ធិក្រៅអំពីសាសនានេះ រមែងលិចចុះក្នុងទិដ្ឋិទាំងឡាយ យើងមិនគាប់ចិត្តនឹងធម៌របស់បុគ្គលទាំងនោះទេ ព្រោះថាបុគ្គលទាំងនោះ មិនមែនជាអ្នកឈ្លាសក្នុងធម៌ ព្រះពុទ្ធទ្រង់កើតក្នុងសក្យត្រកូល រកបុគ្គលប្រៀបគ្មាន ទ្រង់គ្របសង្កត់នូវធម៌ទាំងពួង ទ្រង់កម្ចាត់បង់នូវមារ ទ្រង់មិនចាញ់មារទាំងអស់ ទ្រង់ផុតចាកកិលេសទាំងអស់ មិនអាស្រ័យនូវតណ្ហា ទ្រង់មានចក្ខុឃើញធម៌ទាំងអស់ ដល់នូវកិរិយាអស់នៃកម្មទាំងអស់ ទ្រង់មានចិត្តចុះស៊ប់ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិ ព្រះមានព្រះភាគនោះ ជាគ្រូរបស់យើង យើងគាប់ចិត្តនឹងសាសនារបស់ព្រះអង្គ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា សីសុបចាលាភិក្ខុនី ស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

១៨



# នវមំ សេលាសុត្តំ

[២៨] សាវត្ថិយំ... អថខោ សេលា ភិក្ខុនី បុព្វ-ណ្ហសមយំ និវាសេត្វា ។ បេ ។ អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

[២៩] អថខោ មារោ បាបិមា សេលាយ ភិក្ខុនិ-យា ភយំ ។ បេ ។ សេលំ ភិក្ខុនឹ គាថាយ អជ្ឈ-ភាសិ

កេនិទំ បកតំ ពិម្ពំ
ក្វនុ ពិម្ពស្ស ការកោ
ក្វនុ ពិម្ពំ សមុប្បន្នំ
ក្វនុ ពិម្ពំ និរុជ្ឈតីតិ ។

# សេលាសូត្រ ទី ៩

[២៨] ទៀបក្រុងសាវត្ថី... គ្រានោះ សេលាភិក្ខុនី ស្លៀកដណ្ដប់ក្នុងបុព្វណ្ហសម័យ ។ បេ ។ អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។

[២៩] គ្រានោះ មារមានចិត្តបាប ញុំាងភ័យឲ្យកើតឡើងដល់សេលាភិក្ខុនី ។ បេ ។ បានពោលគាថានឹងសេលាភិក្ខុនីថា

ពុម្ព គឺអត្តភាពនេះ អ្នកណាតាក់តែងឡើង បុគ្គលតាក់

តែងនូវពុម្ពឋិតនៅក្នុងទីណាខ្លះ ពុម្ពកើតឡើងក្នុងទីណាខ្លះ

ពុម្ព រលត់ទៅក្នុងទីណាខ្លះ ។

១៩

### ភិក្ខុនីសំយុត្តស្ស សេលាសុត្តេ សេលាភាសនំ

[៣០] អថខោ សេលាយ ភិក្ខុនិយា ឯតទហោសិ កោ នុ ខ្វាយំ មនុស្សោ វា អមនុស្សោ វា គាថំ ភាសតីតិ ។ អថខោ សេលាយ ភិក្ខុនិយា ឯតទហោសិ មារោ ខោ អយំ បាបិមា មម ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ គាថំ ភាសតីតិ ។ អថខោ សេលា ភិក្ខុនី មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

នយិទំ បកតំ ពិម្ពំ[១]
នយិទំ បកតំ អឃំ[២]
ហេតុំ បដិច្ច សម្ភូតំ
ហេតុភង្គា និរុជ្ឈតិ
យថាបិ អញ្ញតរំ ពីជំ
ខេត្តេ វុត្តំ វិរូហតិ
បថវីរសញ្ច អាគម្ម
សិនេហញ្ច តទូភយំ

១ ឱ. ម. អត្តកតំ ពិម្ពំ ។ ២ ឱ. ម. បរកតមឃំ ។

[៣០] លំដាប់នោះ សេលាភិក្ខុនី មានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះ ជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស (មក) ពោលគាថាដូច្នេះ ។ ទើបសេលាភិក្ខុនី មានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាញុំាងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាត្មាអញ មានប្រាថ្នាឲ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលគាថា ។ លុះសេលាភិក្ខុនី ដឹងច្បាស់ថា នេះជាមារមានចិត្តបាប ហើយក៏ពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា

ពុម្ពនេះ ឥតមានអ្នកណាតាក់តែងទេ អឃៈ[១]នេះ ឥតមានអ្នកណាធ្វើទេ កើតឡើងបាន ព្រោះអាស្រ័យហេតុ រលត់ទៅវិញ ព្រោះបែកធ្លាយនៃហេតុ ដូចជាពូជណាមួយដែលគេព្រោះក្នុងស្រែ រមែងដុះឡើងបាន ព្រោះអាស្រ័យ នូវធម្មជាត ២ យ៉ាង គឺរសនៃផែនដី ១ ជ័រ[២] ១ យ៉ាងណាមិញ

---

១ អឃៈ ជាឈ្មោះនៃអត្តភាពដូចគ្នានឹងពុម្ព ។ អឃៈ ប្រែថា ជាទីតាំងនៃសេចក្តីទុក្ខ ។
២ បានដល់រសជាតិឬប្រេងរបស់ពូជនោះៗ ។

ឯវំ ខន្ធា ច ធាតុយោ

ឆ ច អាយតនា ឥមេ

ហេតុំ បដិច្ច សម្ភូតា

ហេតុភង្គា និរុជ្ឈរេតិ ។

អថខោ មារោ បាបិមា ជានាតិ មំ សេលា ភិក្ខុ-
នីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

# ទសមំ វជិរាសុត្តំ

[៣១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
អថខោ វជិរា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្ត-
ចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ សាវត្ថិយំ
បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន
អន្ធវនំ តេនុបសង្កមិ ទិវាវិហារាយ អន្ធវនំ អជ្ឈោគ-
ហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

ធម៌ទាំងនេះគឺ ខន្ធ និងអាយតនៈ ៦ កើតឡើងបាន ព្រោះអាស្រ័យហេតុ រលត់ទៅវិញ ព្រោះបែកធ្លាយនៃហេតុ យ៉ាងនោះឯង ។

លំដាប់នោះ មារមានចិត្តបាបដឹងថា សេលាភិក្ខុនីស្គាល់នូវអញហើយ ក៏មានសេចក្ដីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

## វជិរាសូត្រ ទី ១០

[៣១] ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ វជិរាភិក្ខុនី ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងបច្ឆាភត្ត ក៏ដើរសំដៅទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់អន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។

២១

ភិក្ខុនីសំយុត្តស្ស វជិរាសុត្តេ វជិរាយ បរិវិតក្កនំ

[៣២] អថខោ មារោ បាបិមា វជិរាយ ភិក្ខុនិយា ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ យេន វជិរា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា វជិរំ ភិក្ខុនឹ គាថាយ អជ្ឈភាសិ

កេនាយំ បកតោ សត្តោ
ក្វចិ សត្តស្ស ការកោ
ក្វចិ សត្តោ សមុប្បន្នោ
ក្វចិ សត្តោ និរុជ្ឈតីតិ ។

[៣៣] អថខោ វជិរាយ ភិក្ខុនិយា ឯតទហោសិ កោ នុ ខ្វាយំ មនុស្សោ វា អមនុស្សោ វា គាថំ ភាសតីតិ ។ អថខោ វជិរាយ ភិក្ខុនិយា ឯតទហោសិ មារោ អយំ បាបិមា មម ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ សមាធិម្ហា ចាវេតុកាមោ គាថំ ភាសតីតិ ។ អថខោ វជិរា ភិក្ខុនី មារោ អយំ បាបិមា ឥតិ វិទិត្វា មារំ បាបិមន្តំ គាថាហិ អជ្ឈភាសិ

ភិក្ខុនីសំយុត្ត វជិរាសូត្រ សេចក្តីត្រិះរិះរបស់វជិរាភិក្ខុនី

[៣២] គ្រានោះ មារមានចិត្តបាប មានប្រាថ្នាញុាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់វជិរាភិក្ខុនី មានប្រាថ្នាឲ្យនាងឃ្លាតចាកសមាធិ ក៏ចូលទៅរកវជិរាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងវជិរាភិក្ខុនីថា

សត្វនេះ បុគ្គលណាតាក់តែងឡើង បុគ្គលអ្នកតាក់តែងសត្វ
ឋិតនៅក្នុងទីណា សត្វកើតឡើង ក្នុងទីណា សត្វរលត់
ទៅ ក្នុងទីណា ។

[៣៣] លំដាប់នោះ វជិរាភិក្ខុនី មានសេចក្តីត្រិះរិះ យ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស (មក) ពោលគាថាដូច្នេះ ។ ទើបវជិរាភិក្ខុនីមានសេចក្តីចូលចិត្តថា នេះពិតជាមារមានចិត្តបាប ប្រាថ្នាញុាំងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាត្មាអញ មានប្រាថ្នា ឲ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលគាថា ។ លំដាប់នោះ វជិរាភិក្ខុនីដឹងច្បាស់ថា នេះជាមារមានចិត្តបាប ហើយបានពោលគាថាទាំងឡាយនឹងមារមានចិត្តបាបថា

កឹំ នុ សត្តោតិ បច្ចេតិ

មារ ទិដ្ឋិគតំ នុ តេ

សុទ្ធសង្ខារបុញ្ជោយំ

នយិធ សត្តុបលព្ភតិ

យថា ហិ អង្គសម្ភារា

ហោតិ សទ្ទោ រថោ ឥតិ

ឯវំ ខន្ធេសុ សន្តេសុ

ហោតិ សត្តោតិ សម្មុតិ

ទុក្ខមេវ ហិ សម្ភោតិ

ទុក្ខំ តិដ្ឋតិ វេតិ ច

នាញ្ញត្រ ទុក្ខា សម្ភោតិ

នាញ្ញត្រ ទុក្ខា និរុជ្ឈតីតិ ។

អថខោ មារោ បាបិមា ជានាតិ មំ វជិរា ភិក្ខុនីតិ ទុក្ខី ទុម្មនោ តត្ថេវន្តរធាយីតិ ។

ភិក្ខុនីសំយុត្តំ សមត្តំ ។

ម្នាលមារ ទិដ្ឋិរបស់អ្នកយល់ថា សត្វមែនឬ នេះជាគំនរនៃសង្ខារសុទ្ធទេ ក្នុងគំនរនៃសង្ខារសុទ្ធនេះ អ្នករកសត្វមិនឃើញឡើយ[១] ដូចសព្ទដែលបានឈ្មោះថា រថដូច្នេះ កើតឡើងបាន ព្រោះបរិបូណ៌ដោយអង្គ[២] យ៉ាងណាមិញ កាលបើខន្ធមានហើយ ការសន្មតថា សត្វដូច្នោះក៏មាន យ៉ាងនោះឯង ព្រោះថាសេចក្តីទុក្ខ រមែងកើតឡើង សេចក្តីទុក្ខរមែងឋិតនៅផង វិនាសទៅផង វៀរចាកសេចក្តីទុក្ខ ឥតមានធម៌ដទៃកើតឡើង វៀរចាកសេចក្តីទុក្ខ ឥតមានធម៌ដទៃរលត់ទេ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា វជិរាភិក្ខុនីស្គាល់អញហើយ ក៏មានសេចក្តីទុក្ខ តូចចិត្ត បាត់អំពីទីនោះទៅ ។

ចប់ ភិក្ខុនីសំយុត្ត ។

---

១ នេះជាពាក្យបរិយាយតាមបរមត្ថ ។ ២ អង្គរបស់រថនោះមានកង់ ទូក ប្រេក ជាដើម ។

២៣

ភិក្ខុនីសំយុត្តស្ស វជិរាសុត្តេ ឧទ្ទានំ

## តស្សុទ្ទានំ

អាឡវិកា ច សោមា ច

គោតមី វិជយា សហ

ឧប្បលវណ្ណា ច ចាលា ច

ឧបចាលា សីសុបចាលា

សេលា វជិរាយ តេ ទសាតិ ។

---

# ឧទ្ទាននៃភិក្ខុនីសំយុត្តនោះ ដូច្នេះ

*សូត្រទាំង ១០ នោះ គឺ អាឡវិកាសូត្រ ១ សោមាសូត្រ ១ គោតមីសូត្រ ១ វិជយាសូត្រ ១ ឧប្បលវណ្ណាសូត្រ ១ ចាលាសូត្រ ១ ឧបចាលាសូត្រ ១ សីសុបចាលាសូត្រ ១ សេលាសូត្រ ១ វជិរាសូត្រ ១ ។*

# ព្រហ្មសំយុត្តំ

## បឋមោ អាយាចនវគ្គោ

### បឋមំ អាយាចនសុត្តំ

[៣៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អធិគតោ ខោ ម្យាយំ ធម្មោ គម្ភីរោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ អាលយរាមា ខោ បនាយំ បជា អាលយរតា

# ព្រហ្មសំយុត្ត

## អាយាចនវគ្គ ទី ១

---

## អាយាចនសូត្រ ទី ១

[២៣] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ទើបនឹងបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធ ប្របមាត់ស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្តេចទៅគង់ក្នុងទីស្ងាត់សម្ងំនៅ មានព្រះទ័យត្រិះរិះកើតឡើង យ៉ាងនេះថា ធម៌[១]នេះ អាត្មាអញ បានត្រាស់ដឹងហើយ ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌ដែលសត្វឃើញបានដោយកម្រ ជាធម៌ដែលសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា ជាធម៌ដែលសត្វមិនគប្បីស្ទង់មើល ដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌មានតែអ្នកប្រាជ្ញ ទើបត្រាស់ដឹងបាន ឯពួកសត្វនេះ ជាអ្នកត្រេកត្រអាល ដោយសេចក្តីអាល័យ[២] ត្រេកអរក្នុងសេចក្តីអាល័យ

---

១ សំដៅយកអរិយសច្ចទាំង ៤ ។ ២ បានដល់តណ្ហាវិចរិតទាំង ១០៨ ។

២៨

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ ភគវតោ បរិវិតក្កនំ

អាលយសមុទិតា អាលយរាមាយ ខោ បន បជាយ អាលយរតាយ អាលយសមុទិតាយ ទុទ្ទសំ ឥទំ ឋានំ យទិទំ ឥទប្បច្ចយតា បដិច្ចសមុប្បាទោ ឥទម្បិ ខោ ឋានំ ទុទ្ទសំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប-ដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ អហញ្ចេវ ខោ បន ធម្មំ ទេសេយ្យំ បរេ ច មេ ន អាជានេយ្យុំ សោ មមស្ស កិលមថោ សា មមស្ស វិហេសាតិ ។ អបិស្សុ ភគវន្តំ ឥមា អច្ឆរិយា គាថាយោ បដិភំសុ បុព្វេ អស្សុតបុព្វា

រីករាយក្នុងសេចក្តីអាល័យ មួយទៀត បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានិងគ្នាណា បដិច្ចសមុប្បាទធម៌នោះ ពួកសត្វជាអ្នកត្រេកត្រអាលដោយសេចក្តីអាល័យ ត្រេកអរក្នុងសេចក្តីអាល័យ រីករាយក្នុងសេចក្តីអាល័យ ឃើញបានដោយក្រ មួយទៀត ធម៌ណា សម្រាប់រម្ងាប់សង្ខារទាំងពួង សម្រាប់លះបង់ឧបធិទាំងពួង ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរំលត់សេចក្តីទុក្ខ គឺព្រះនិព្វានធម៌នេះ ពួកសត្វឃើញបាន ដោយក្រដូចគ្នា ប្រសិនបើអាត្មាអញសំដែងធម៌ទៅ ក៏សត្វទាំងឡាយដទៃ មិនគប្បីត្រាស់ដឹងធម៌ របស់អាត្មាអញបានទេ អាត្មាអញនឹងមានតែសេចក្តីលំបាកនោះ អាត្មាអញនឹងមានតែសេចក្តីនឿយព្រួយនោះ (ឥតអំពើ) ។ បានឮថា ព្រះគាថាជាអស្ចារ្យទាំងឡាយនោះ ដែលមិនធ្លាប់បានស្តាប់មកអំពីកាលមុខ ក៏ប្រាកដដល់ព្រះមានព្រះភាគថា

កិច្ឆេន មេ អធិគតំ
ហលន្ទានិ បកាសិតុំ
រាគទោសបរេតេហិ
នាយំ ធម្មោ សុសម្ពុធោ
បដិសោតគាមឹ និបុណំ
គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ
តមោខន្ធេន អាវុតាតិ ។

ឥតិ ភគវតោ បដិសញ្ចិក្ខតោ អប្បោស្សុក្កតា-
យ ចិត្តំ នមតិ នោ ធម្មទេសនាយាតិ ។

[៣៨] អថខោ ព្រហ្មុនោ សហាម្បតិស្ស ភគវតោ
ចេតសា ចេតោបរិវិតក្កមញ្ញាយ ឯតទហោសិ នស្សតិ
វត ភោ លោកោ វិនស្សតិ វត ភោ លោកោ យត្រ
ហិ នាម តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស
អប្បោស្សុក្កតាយ ចិត្តំ នមតិ នោ ធម្មទេសនាយាតិ ។

ឥឡូវនេះ អាត្មាអញ មិនគួរប្រកាសធម៌ ដែលអាត្មាអញ បានត្រាស់ដឹងហើយ ដោយលំបាកទេ ព្រោះថា ធម៌នេះ សត្វទាំងឡាយដែលត្រូវរាគៈ ទោសៈ គ្របសង្កត់ហើយ មិនងាយត្រាស់ដឹងបានទេ សត្វទាំងឡាយត្រេកអរ ដោយរាគៈ មានគំនរងងឹត គឺអវិជ្ជាបិទបាំង រមែងមិនឃើញ នូវធម៌ ដែលប្រព្រឹត្តច្រាសខ្សែទឹក[១] ជាធម៌ល្អិត ជ្រាលជ្រៅ សត្វឃើញបានដោយកម្រ ជាធម៌ដ៏តូចឆ្មារ ។

កាលព្រះមានព្រះភាគ ពិចារណាដូច្នេះហើយ ព្រះទ័យក៏បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីនឹងសំដែងធម៌ឡើយ ។

[៣៥] គ្រានោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះ ក្នុងព្រះទ័យរបស់ព្រះមានព្រះភាគ ដោយចិត្តហើយ ទើបរំពឹងគិតដូច្នេះថា ឱហ្ន៎ សត្វលោកសាបសូន្យ មិនខាន ឱហ្ន៎ សត្វលោកវិនាស មិនខាន ដ្បិតថា ព្រះទ័យរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ បង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅ ដើម្បីសំដែងធម៌ឡើយ ។

១ បានដល់ចតុសច្ចធម៌ ។

២៧

### ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ សហម្បតិព្រហ្មុនោ អាយាចនំ

អថខោ ព្រហ្មា សហម្បតិ សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ ភគវតោ បុរតោ បាតុរហោសិ ។ អថខោ ព្រហ្មា សហម្បតិ ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណជានុ-មណ្ឌលំ បឋវិយំ និហន្ត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច ទេសេតុ ភន្តេ ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ សន្តិ សត្តា អប្បរជក្ខ-ជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោតិ ។ ឥទមវោច ព្រហ្មា សហម្បតិ ឥទំ វត្វា អថាបរំ ឯតទវោច

បាតុរហោសិ មគធេសុ បុព្វេ
ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ
អបាបុរេតំ អមតស្ស ទ្វារំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ
សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ

គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយឆាប់ភ្លាម ដូចបុរសមានកម្លាំង លាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ លំដាប់នោះ សហម្បតិព្រហ្ម ធ្វើនូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង លុតចុះនូវមណ្ឌលនៃជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលី ចំពោះទៅរកព្រះមានព្រះភាគ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ សូមព្រះសុគតទ្រង់សំដែងធម៌ សត្វទាំងឡាយ ដែលមានធូលី[១] ស្រាលស្តើងក្នុងភ្នែក[២] ក៏មានខ្លះដែរ សត្វទាំងនោះ នឹងសាបសូន្យ ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយជាអ្នកត្រាស់ដឹងនូវធម៌គង់មាន ។ សហម្បតិព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ទើបពោលពាក្យនេះ តទៅទៀតថា

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយ
មន្ទិល[៣]តែងគិត ជាធម៌មិនបរិសុទ្ធ កើតប្រាកដក្នុងដែន
មគធៈ សូមព្រះអង្គបើកនូវទ្វារ[៤]នៃព្រះនិព្វាន សត្វទាំង-
ឡាយនឹងស្តាប់នូវធម៌ ដែលព្រះពុទ្ធជាអ្នកប្រាសចាកមន្ទិល
ទ្រង់ត្រាស់ដឹងហើយ បុរសឈរនៅលើកំពូលភ្នំសុទ្ធសឹងថ្ម

---

១ បានខាងកិលេសមានរាគៈជាដើម ។ ២ បានខាងបញ្ញាចក្ខុ ។ ៣ សំដៅយកគ្រូទាំង ៦ ។ ៤ បានខាងអរិយមគ្គ ។

យថាបិ បស្សេ ជនតំ សមន្តតោ

តថូបមំ ធម្មមយំ សុមេធសោ

បាសាទមារុយ្ហ សមន្តចក្ខុ

សោកាវតិណ្ណំ ជនតមបេតសោកោ

អវេក្ខស្សុ ជាតិជរាភិភូតន្តិ[១] ។

ឧដ្ឋេហិ វីរ វិជិតសង្គាម

សត្ថវាហ អនណ វិចរ លោកេ

ទេសេតុ ភគវា ធម្មំ

អញ្ញាតារោ ភវិស្សន្តីតិ ។

[៣៦] អថខោ ភគវា ព្រហ្មុនោ ច អជ្ឈេសនំ វិទិត្វា សត្តេសុ ច ការុញ្ញតំ បដិច្ច ពុទ្ធចក្ខុនា លោកំ វោលោកេសិ ។ អទ្ទសា ខោ ភគវា ពុទ្ធ-ចក្ខុនា លោកំ វោលោកេន្តោ សត្តេ អប្បរជក្ខេ

១ ឥតិសទ្ទោ អយុត្តរូបោ វិយ ទិស្សតិ ។

គប្បីឃើញប្រជុំជនដោយជុំវិញ យ៉ាងណាមិញ បពិត្រព្រះអង្គមានបញ្ញាល្អ មានចក្ខុជុំវិញ ប្រាសចាកសេចក្តីសោក សូមព្រះអង្គឡើងកាន់ប្រាសាទ ដ៏ហើយដោយធម៌ គឺបញ្ញាដូចជាភ្នំនោះ ហើយពិចារណាមើលនូវប្រជុំជន ដែលត្រូវសេចក្តីសោកគ្របសង្កត់ ដែលត្រូវជាតិ ជរា គ្របសង្កត់ ។ បពិត្រព្រះអង្គមានព្យាយាម ទ្រង់ឈ្នះនូវសង្រ្គាម សូមព្រះអង្គក្រោកឡើង បពិត្រព្រះអង្គ ជាអ្នកនាំទៅនូវពពួកសត្វ ព្រះអង្គមិនមានបំណុល សូមទ្រង់ស្តេចទៅក្នុងលោក សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ សត្វទាំងឡាយជាអ្នកត្រាស់ដឹងគង់មាន ។

[៣៦] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនារបស់ព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណា ចំពោះសត្វទាំងឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ។ កាលដែលព្រះមានព្រះភាគ ទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយ មានភ្នែកប្រកបដោយធូលីតិចខ្លះ

២៩

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ ភគវតោ លោកោលោកនំ

មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជ-ភយទស្សាវិនោ វិហរន្តេ ។ សេយ្យថាបិ នាម ឧប្ប-លិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេ-កច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគតានិ អន្តោនិម្មុគ្គបោសីនិ អប្បេកច្ចានិ ឧប្បលានិ វា បទុ-មានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ សមោទកំ ឋិតានិ អប្បេកច្ចានិ ឧប្ប-លានិ វា បទុមានិ វា បុណ្ឌរីកានិ ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកំ អច្ចុគ្គម្ម តិដ្ឋន្តិ អនុប-លិត្តានិ ឧទកេន ឯវមេវ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ

មានភ្នែកប្រកបដោយធូលីច្រើនខ្លះ មានឥន្ទ្រិយក្លាខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការអាក្រក់ខ្លះ ជាសត្វដែលឲ្យត្រាស់ដឹងបានដោយងាយខ្លះ ជាសត្វដែលឲ្យត្រាស់ដឹងបានដោយក្រខ្លះ ជាអ្នកឃើញនូវទោសនិងភ័យ ក្នុងបរលោកខ្លះ ។ ប្រៀបដូចជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូក-សក្តី ក្នុងគុម្ពព្រលិតក្តី គុម្ពឈូកក្រហមក្តី គុម្ពឈូក-សក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹក មានជលជាតិពួកខ្លះ គឺផ្កាព្រ-លិតក្តី ឈូកក្រហមក្តី ឈូក-សក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូក-សក្តី ដុះឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតផុតអំពីទឹក មិនទទឹកដោយទឹក មានឧបមាយ៉ាងណាមិញ កាលដែលព្រះមានព្រះភាគ ទ្រង់រមិលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយ មានភ្នែកប្រកបដោយធូលីតិចខ្លះ មានភ្នែកប្រកបដោយធូលីច្រើនខ្លះ មានឥន្ទ្រិយក្លាខ្លះ មានឥន្ទ្រិយទន់ខ្លះ មានអាការល្អខ្លះ មានអាការអាក្រក់ខ្លះ ជាសត្វដែលឲ្យត្រាស់ដឹងបានដោយងាយខ្លះ

ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ

វិហរន្តេ ទិស្វាន ព្រហ្មានំ សហម្បតឹ គាថាយ បច្ចភាសិ

អបារុតា តេ អមតស្ស ទ្វារា

យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ

វិហឹសសញ្ញី បគុណំ ន ភាសឹ

ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។

[៣៧] អថខោ ព្រហ្មា សហម្បតិ កតាវកាសោ

ខោម្ហិ ភគវតា ធម្មទេសនាយាតិ ភគវន្តំ អភិវាទេត្វា

បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

ជាសត្វដែលឲ្យត្រាស់ដឹងបានដោយក្រខ្វះ ជាអ្នកឃើញនូវទោស និងភ័យ ក្នុងបរលោកខ្វះ លុះទ្រង់ឃើញហើយ បានពោលគាថា តបនឹងសហម្បតិព្រហ្មថា

ទ្វារនៃព្រះនិព្វាននោះតថាគតបានបើកហើយ សត្វទាំងឡាយ
ណា មានសោតប្រសាទ ចូរបញ្ចេញនូវសទ្ធាចុះ ម្នាល
ព្រហ្ម តថាគតសម្គាល់នូវសេចក្តីលំបាក បានជាមិនសំដែង
ធម៌ដែលស្ទាត់ ជាធម៌ដ៏ឧត្តម ដល់ពួកមនុស្សទាំងឡាយ ។

[៣៧] គ្រានោះ សហម្បតិព្រហ្មគិតថា អាត្មាអញជាបុគ្គលដែលមានព្រះមានព្រះភាគ ទ្រង់ធ្វើឱកាសដើម្បីនឹងសំដែងធម៌ហើយ (លុះគិតដូច្នេះហើយ) ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណា ហើយបាត់អំពីទីនោះទៅ ។

# ទុតិយំ គារវសុត្តំ

[៣៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ទុក្ខំ ខោ អគារវោ វិហរតិ អប្បតិស្សោ កំ នុ ខ្វាហំ សមណំ វា ព្រាហ្មណំ វា សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យន្តិ ។

[៣៩] អថខោ ភគវតោ ឯតទហោសិ អបរិបុណ្ណស្ស ខោ សីលក្ខន្ធស្ស ចារិបូរិយា អញ្ញំ សមណំ វា ព្រាហ្មណំ វា សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យំ ន ខោ បនាហំ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អត្តនា សីលសម្បន្នតរំ អញ្ញំ សមណំ វា ព្រាហ្មណំ វា យមហំ សក្កត្វា គរុកត្វា

# គារវសូត្រទី ២

[៣៨] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទើបនឹងបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធ ប្របមាត់ស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅក្នុងទីស្ងាត់ ទ្រង់សម្ងំនៅ មានព្រះបរិវិតក្កៈក្នុងព្រះទ័យកើតឡើង យ៉ាងនេះថា បុគ្គលមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង រមែងនៅជាទុក្ខ អាត្មាអញ គួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅនឹងសមណៈឬព្រាហ្មណ៍ណាហ្ន៎ ។

[៣៩] ទើបព្រះមានព្រះភាគ មានព្រះតម្រិះ យ៉ាងនេះថា អាត្មាអញ គួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅនឹងសមណៈឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវសីលក្ខន្ធ ដែលមិនទាន់ពេញលេញ តែថាក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងសម្មតិទេព និងមនុស្សដ៏សេស អាត្មាអញមិនបានឃើញសមណៈឬព្រាហ្មណ៍ដទៃ ដែលបរិបូណ៌ដោយសីលជាងខ្លួនអញ ដែលអាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព

ឧបនិស្សាយ វិហរេយ្យំ អបរិបុណ្ណស្ស ខោ សមា-
ធិក្ខន្ធស្ស ចារិប្ូរិយា អញ្ញំ សមណំ វា ព្រាហ្មណំ
វា សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យំ ន
ខោ បនាហំ បស្សាមិ សទេវកេ លោកេ ។ បេ ។
អត្តនា សមាធិសម្បន្នតរំ អញ្ញំ សមណំ វា ព្រាហ្ម-
ណំ វា យមហំ សក្កត្វា គរុកត្វា ឧបនិស្សាយ
វិហរេយ្យំ អបរិបុណ្ណស្ស ខោ បញ្ញាខន្ធស្ស ចារិប្ូរិយា
អញ្ញំ សមណំ វា ព្រាហ្មណំ វា សក្កត្វា គរុកត្វា
ឧបនិស្សាយ វិហរេយ្យំ ន ខោ បនាហំ បស្សាមិ ស-
ទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សម-
ណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អត្តនា
បញ្ញាសម្បន្នតរំ អញ្ញំ សមណំ វា ព្រាហ្មណំ វា យមហំ
សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យំ អបរិ-
បុណ្ណស្ស ខោ វិមុត្តិក្ខន្ធស្ស ចារិប្ូរិយា អញ្ញំ សមណំ
វា ព្រាហ្មណំ វា សក្កត្វា គរុកត្វា ឧបនិស្សាយ
វិហរេយ្យំ ន ខោ បនាហំ បស្សាមិ សទេវកេ លោកេ

អាស្រ័យនៅឡើយ អាត្មាអញ គួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅនឹងសមណៈ ឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវសមាធិក្ខន្ធ ដែលមិនទាន់ពេញលេញ តែថា អាត្មាអញ មិនឃើញសមណៈ ឬព្រាហ្មណ៍ដទៃ ដែលបរិបូណ៌ដោយសមាធិជាង់ខ្លួនអញ ក្នុងលោក ព្រមទាំងទេវលោក ។ បេ ។ ដែលអាត្មាអញគួធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅឡើយ អាត្មាអញ គួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាអាស្រ័យនៅនឹងសមណៈ ឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវបញ្ញាខន្ធដែលមិនទាន់ពេញលេញ តែថាក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងសម្មតិទេពនិងមនុស្សដ៏សេស អាត្មាអញ មិនឃើញសមណៈ ឬព្រាហ្មណ៍ដទៃ ដែលបរិបូណ៌ ដោយបញ្ញាជាង់ខ្លួនអញ ដែលអាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅឡើយ អាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅនឹងសមណៈ ឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវវិមុត្តិក្ខន្ធដែលមិនទាន់ពេញលេញ តែថាក្នុងលោកព្រមទាំងទេវលោក

។ បេ ។ អត្តនា វិមុត្តិសម្បន្នតរំ អញ្ញំ សមណំ វា ព្រាហ្មណំ វា យមហំ សក្កត្វា គរុកត្វា ឧបនិស្សា-យ វិហរេយ្យំ អបរិបុណ្ណស្ស ខោ វិមុត្តិញាណទស្ស-នក្ខន្ធស្ស ចារិបូរិយា អញ្ញំ សមណំ វា ព្រាហ្មណំ វា សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យំ ន ខោ បនាហំ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ ស-ទេវមនុស្សាយ អត្តនា វិមុត្តិញាណទស្សនសម្បន្នតរំ អញ្ញំ សមណំ វា ព្រាហ្មណំ វា យមហំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យំ យន្នូនាហំ ស្វាយំ ធម្មោ មយា អភិសម្ពុទ្ធោ តមេវ ធម្មំ សក្កត្វា គរុ-កត្វា ឧបនិស្សាយ វិហរេយ្យន្តិ ។

។ បេ ។ អាត្មាអញ មិនឃើញសមណៈ ឬព្រាហ្មណ៍ដទៃ ដែលបរិបូណ៌ដោយវិមុត្តិជាងខ្លួនអញ ដែលអាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅឡើយ អាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅនឹងសមណៈ ឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវវិមុត្តិញ្ញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញ តែថាក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងសម្មតិទេព និងមនុស្សដ៏សេស អាត្មាអញមិនឃើញសមណៈ ឬព្រាហ្មណ៍ដទៃ ដែលបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈជាងខ្លួនអញ ដែលអាត្មាអញគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅឡើយ បើដូច្នោះ គួរអាត្មាអញធ្វើសក្ការៈ ធ្វើសេចក្តីគោរព អាស្រ័យនៅចំពោះធម៌ ដែលអាត្មាអញបានត្រាស់ដឹងហើយ ។

[៤០] អថខោ ព្រហ្មា សហម្បតិ ភគវតោ ចេត-
សា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា
បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ
វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្ត-
រហិតោ ភគវតោ ចាតុរហោសិ ។ អថខោ ព្រហ្មា
សហម្បតិ ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា
តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច ឯវមេតំ
ភគវា ឯវមេតំ សុគត យេបិ តេ ភន្តេ អហេសុំ
អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេបិ ភគវន្តោ
ធម្មញ្ញេវ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរឹសុ
យេបិ តេ ភន្តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ
សម្មាសម្ពុទ្ធា តេបិ ភគវន្តោ ធម្មញ្ញេវ សក្កត្វា
គរុកត្វា ឧបនិស្សាយ វិហរិស្សន្តិ ភគវាបិ ភន្តេ
ឯតរហិ អរហំ សម្មាសម្ពុទ្ធោ ធម្មញ្ញេវ សក្កត្វា
គរុកត្វា ឧបនិស្សាយ វិហរតូតិ ។

[៤០] លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវព្រះបរិវិតក្កៈក្នុងព្រះទ័យនៃព្រះមានព្រះភាគ ដោយចិត្តហើយ ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយឆាប់ក្រៃ ដូចជាបុរសមានកម្លាំង លាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ ទើបសហម្បតិព្រហ្ម ធ្វើនូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះមានព្រះភាគ ហេតុនុ៎ះ យ៉ាងនេះហើយ បពិត្រព្រះសុគត ហេតុនុ៎ះ យ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគទាំងឡាយណា ជាព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងអតីតកាល ព្រះមានព្រះភាគទាំងនោះ ក៏បានធ្វើសក្ការៈ ធ្វើសេចក្ដីគោរព អាស្រ័យនៅចំពោះធម៌ យ៉ាងនេះដែរ បពិត្រព្រះអង្គដ៏ចម្រើន ទុកជាព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងអនាគតកាល ព្រះមានព្រះភាគទាំងនោះ ក៏នឹងធ្វើសក្ការៈ ធ្វើសេចក្ដីគោរព អាស្រ័យនៅចំពោះធម៌ យ៉ាងនេះដែរ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ ក្នុងកាលឥឡូវនេះ ទ្រង់ធ្វើសក្ការៈ ធ្វើសេចក្ដីគោរព អាស្រ័យនៅចំពោះធម៌ យ៉ាងនេះចុះ ។

៣៥

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ សទ្ធម្មគារវតា

[៤១] ឥទមវោច ព្រហ្មា សហម្បតិ ឥទំ វត្វា អថាបរំ ឯតទវោច

យេ ច អតីតា សម្ពុទ្ធា
យេ ច ពុទ្ធា អនាគតា
យោ ចេតរហិ សម្ពុទ្ធោ
ពហុន្នំ សោកនាសនោ
សព្វេ សទ្ធម្មគរុនោ
វិហរឹសុ វិហរន្តិ ច
អថាបិ វិហរិស្សន្តិ
ឯសា ពុទ្ធាន ធម្មតា
តស្មា ហិ អត្តកាមេន
មហត្តមភិកង្ខតា
សទ្ធម្មោ គរុកាតព្វោ
សរំ ពុទ្ធាន សាសនន្តិ ។

ព្រហ្មសំយុត្ត អាយាចនវគ្គ សេចក្តីគោរពព្រះសទ្ធម្ម

[៤១] សហម្បតិព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ក៏ពោលពាក្យនេះ តទៅទៀតថា

ព្រះសម្ពុទ្ធទាំងឡាយណាជាអតីតក្តី ព្រះសម្ពុទ្ធទាំងឡាយ
ណាជាអនាគតក្តី ព្រះសម្ពុទ្ធណា ក្នុងកាលឥឡូវនេះក្តី
ទ្រង់ធ្វើសេចក្តីសោករបស់ជនទាំងឡាយ ដ៏ច្រើនឲ្យវិនាស
ព្រះសម្ពុទ្ធទាំងអស់នោះ ទ្រង់គោរពព្រះសម្ពុទ្ធក្នុងអតីតកាល
ផង បច្ចុប្បន្នកាលផង អនាគតកាលផង នេះជាធម្មតារបស់
ព្រះពុទ្ធទាំងឡាយ ហេតុដូច្នោះ បុគ្គលអ្នកស្រឡាញ់ខ្លួន
ប្រាថ្នានូវភាពនៃខ្លួនជាធំ កាលរលឹកឃើញសាសនារបស់
ព្រះពុទ្ធទាំងឡាយ គួរធ្វើសេចក្តីគោរពព្រះសទ្ធម្ម ។

# តតិយំ ព្រហ្មទេវសុត្តំ

[៤២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរិស្សា ព្រាហ្មណិយា ព្រហ្មទេវោ នាម បុត្តោ ភគវតោ សន្តិកេ អនគារិយំ បព្វជិតោ ហោតិ ។ អថខោ អាយស្មា ព្រហ្មទេវោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ព្រហ្មទេវោ អរហតំ អហោសិ ។

# ព្រហ្មទេវសូត្រ ទី ៣

[៤២] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអារាមឈ្មោះជេតពន របស់អនាថបិណ្ឌិកគហបតី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង កូនប្រុសរបស់នាងព្រាហ្មណីមួយនាក់ ឈ្មោះព្រហ្មទេព បានចូលទៅកាន់ផ្នួស ក្នុងសំណាក់ព្រះមានព្រះភាគ ។ គ្រានោះ ព្រះព្រហ្មទេពមានអាយុ ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តទាំងឡាយ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ចំពោះអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយមិនយូរប៉ុន្មាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះព្រហ្មទេពមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

[៤៣] អថខោ អាយស្មា ព្រហ្មទេវោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិយំ បិណ្ឌាយ ចាវិសិ សាវត្ថិយំ សបទានំ បិណ្ឌាយ ចរមានោ យេន សកមាតុ និវេសនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន អាយស្មតោ ព្រហ្មទេវស្ស មាតា ព្រាហ្មណី ព្រហ្មុនោ អាហុតឹ និច្ចំ បគ្គណ្ហាតិ ។ អថខោ ព្រហ្មុនោ សហម្បតិស្ស ឯតទហោសិ អយំ ខោ អាយស្មតោ ព្រហ្មទេវស្ស មាតា ព្រាហ្មណី ព្រហ្មុនោ អាហុតឹ និច្ចំ បគ្គណ្ហាតិ យន្នូនាហំ តំ ឧបសង្កមិត្វា សំវេជេយ្យន្តិ ។

[៤៤] អថខោ ព្រហ្មា សហម្បតិ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ អាយស្មតោ ព្រហ្មទេវស្ស មាតុ និវេសនេ ចាតុរហោសិ ។ អថខោ ព្រហ្មា សហម្បតិ វេហាសណ្ឋិតោ អាយស្មតោ ព្រហ្មទេវស្ស មាតរំ ព្រាហ្មណឹ គាថាហិ អជ្ឈភាសិ

[៤៣] ទើបព្រះព្រហ្មទេពមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី កាលកំពុងត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក ក្នុងក្រុងសាវត្ថី ក៏ចូលសំដៅទៅកាន់ផ្ទះមាតារបស់ខ្លួន ។ ក៏ក្នុងសម័យនោះ នាងព្រាហ្មណី ជាមាតារបស់ព្រះព្រហ្មទេពមានអាយុ តែងរៀបចំនូវគ្រឿងបូជា[១] ជានិច្ចដល់ព្រហ្ម ។ លំដាប់នោះ សហម្បតិព្រហ្ម មានសេចក្តីត្រិះរិះ យ៉ាងនេះថា នាងព្រាហ្មណីជាមាតា របស់ព្រះព្រហ្មទេពមានអាយុនេះ តែងរៀបចំនូវគ្រឿងបូជាជានិច្ចដល់ព្រហ្ម បើដូច្នោះ មានតែអាត្មាអញចូលទៅរកនាងនោះ ហើយធ្វើឲ្យកើតសេចក្តីសង្វេគ ។

[៤៤] ទើបសហម្បតិព្រហ្ម បាត់អំពីព្រហ្មលោក មកប្រាកដលើផ្ទះនៃមាតា របស់ព្រះព្រហ្មទេពមានអាយុ ដោយឆាប់រហ័ស ដូចជាបុរសមានកម្លាំង លាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ លំដាប់នោះ សហម្បតិព្រហ្ម ឋិតនៅឰដ៏អាកាស បានពោលគាថាទាំងឡាយ នឹងនាងព្រាហ្មណីជាមាតា របស់ព្រះព្រហ្មទេពមានអាយុថា

---
១ អាហារបិណ្ឌបាត ។

ទូរេ ឥតោ ព្រាហ្មណិ ព្រហ្មលោកោ
យស្សាហុតឹ បគ្គណ្ហាសិ និច្ចំ
នេតាទិសោ ព្រាហ្មណិ ព្រហ្មភក្ខោ
កឹ ជប្បសិ ព្រហ្មបថំ អជានំ
ឯសោ ហិ តេ ព្រាហ្មណិ ព្រហ្មទេវោ
និរូបធិកោ អតិទេវបត្តោ
អកិញ្ចនោ ភិក្ខុ អនញ្ញបោសី
យោ តេ សោ បិណ្ឌាយ ឃរំ បវិដ្ឋោ
អាហុនិយោ[១] វេទគូ ភាវិតត្តោ
នរាន ទេវាន ច ទក្ខិណេយ្យោ
ពាហិត្វា បាបានិ អនូបលិត្តោ

---

១ អាហុនេយ្យោតិ ឥទដ្ឋកថាយំ ទិស្សតិ ។

ម្នាលនាងព្រាហ្មណី នាងរៀបចំនូវគ្រឿងបូជា ជានិច្ច ចំពោះព្រហ្មណា លោករបស់ព្រហ្មនោះ នៅឆ្ងាយ[១] អំពីទីនេះណាស់ ម្នាលនាងព្រាហ្មណី គ្រឿងបូជាប្រាកដដូច្នេះ មិនមែនជាចំណីរបស់ព្រហ្មទេ នាងមិនដឹងនូវផ្លូវ[២] របស់ព្រហ្ម ហើយចរចាដូចម្តេចបាន ម្នាលនាងព្រាហ្មណី ក៏ឯភិក្ខុ ឈ្មោះព្រហ្មទេព (ជាកូន) របស់នាងនេះ ជាអ្នកមិនមានឧបធិ ជាអ្នកដល់នូវភាពជាទេវតា ដ៏ក្រៃលែង មិនមានសេចក្តីកង្វល់ ជាអ្នកមិនចិញ្ចឹមបុគ្គលដទៃ ភិក្ខុនោះចូលមកកាន់ផ្ទះនាងឥឡូវនេះ ដើម្បីបិណ្ឌបាត ជាបុគ្គលគួរដើម្បីទទួលដុំបាយ ដែលគេនាំមកបូជា ជាអ្នកដល់នូវទីបំផុតនៃទុក្ខដោយវេទ[៣] មានខ្លួនអប់រំហើយ ជាបុគ្គលគួរទទួលទាន របស់ពួកមនុស្សនិងទេវតា បានបន្សាត់ចោលនូវបាបទាំងឡាយ មិនប្រឡាក់ដោយជ័រ គឺតណ្ហានិងទិដ្ឋិ

---

១ ថ្មប្រមាណប៉ុនផ្ទះកំពូលធ្លាក់ចុះមកអំពីព្រហ្មលោកមួយថ្ងៃមួយយប់បានចម្ងាយ ៤ ម៉ឺន ៨ ពាន់យោជន៍ ធ្លាក់ចុះមក ៤ ខែទើបដល់ផែនដី នេះជាចម្ងាយ ព្រហ្មលោកជាន់ទាបបំផុត ។ ២ កុសលជ្ឈានទាំង ៤ ជាផ្លូវរបស់ព្រហ្ម វិបាកជ្ឈានទាំង ៤ ជាផ្លូវជីវិតរបស់ព្រហ្ម ។ ៣ សំដៅយកមគ្គទាំង ៤ ។

៣៩

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ សហម្បតិព្រហ្មវចនំ

ឃាសេសនំ ឥរិយតិ សីតិភូតោ

ន តស្ស បច្ឆា ន បុរត្ថមត្ថិ

សន្តោ វិធូមោ អនិឃោ និរាសោ

និក្ខិត្តទណ្ឌោ តសថាវរេសុ

សោ ត្យាហុតឹ ភុញ្ជតុ អគ្គបិណ្ឌំ

វិសេនិភូតោ ឧបសន្តចិត្តោ

នាគោវ ទន្តោ ចរតិ អនេជោ

ភិក្ខុ សុសីលោ សុវិមុត្តចិត្តោ

សោ ត្យាហុតឹ ភុញ្ជតុ អគ្គបិណ្ឌំ

តស្មឹ បសន្នា អវិកម្បមានា

បតិដ្ឋបេហិ ទក្ខិណំ ទក្ខិណេយ្យេ

ជាបុគ្គលមានសេចក្ដីត្រជាក់ តែងប្រព្រឹត្ត នូវការស្វែងរកអាហារ ភិក្ខុនោះ មិនមានសេចក្ដីស្រឡាញ់ខាងក្រោយ(១) មិនមានសេចក្ដីស្រឡាញ់ខាងមុខ(២) បានរម្ងាប់នូវរាគាទិក្កិលេសអស់ហើយ ប្រាសចាកផ្សែងគឺសេចក្ដីក្រោធ មិនមានសេចក្ដីទុក្ខ មិនមានសេចក្ដីប្រាថ្នា ដាក់ចុះនូវដំបងក្នុងពួកសត្វដែលតក់ស្លុត(៣) និងពួកសត្វដែលខ្ជាប់ខ្ជួន(៤) ភិក្ខុនោះ ចូរបរិភោគនូវគ្រឿងបូជា គឺដុំបាយដ៏ប្រសើររបស់នាង ភិក្ខុនោះប្រាសចាកសេនា គឺកិលេស មានចិត្តស្ងប់រម្ងាប់ហើយ មិនមានសេចក្ដីញាប់ញ័រ គឺតណ្ហា តែងត្រាច់ទៅ ដូចដំរីដែលគេទូន្មានបាន មានសីលដ៏ល្អ មានចិត្តរួចស្រឡះហើយ ភិក្ខុនោះចូរបរិភោគនូវគ្រឿងបូជា គឺដុំបាយដ៏ប្រសើររបស់នាងចុះ នាងចូរមានសេចក្ដីជ្រះថ្លាចំពោះភិក្ខុនោះ កុំមានសេចក្ដីញាប់ញ័រ ចូរតម្កល់នូវទានក្នុងទក្ខិណេយ្យបុគ្គល

---

១ សំដៅយកអតីតក្ខន្ធ ។ ២ សំដៅយកអនាគតក្ខន្ធ ។ បានសេចក្ដីថា ភិក្ខុនោះ មិនមានការត្រេកអរក្នុងខន្ធទាំងអម្បាលនោះឡើយ ។ ៣ បានដល់បុថុជ្ជន ។ ៤ បានដល់ព្រះខីណាស្រព ។

ការេហិ បុញ្ញំ សុខមាយតិកំ
ទិស្វា មុនឹ ព្រាហ្មណិ ឱឃតិណ្ណំ
តស្មឹ បសន្នា អវិកម្បមានា
បតិដ្ឋបេសិ ទក្ខិណំ ទក្ខិណេយ្យេ
អកាសិ បុញ្ញំ សុខមាយតិកំ
ទិស្វា មុនឹ ព្រាហ្មណិ ឱឃតិណ្ណន្តិ ។

## ចតុត្ថំ ពកសុត្តំ

[៤៨] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ពកស្ស ព្រហ្មុនោ ឯវរូបំ បាបកំ ទិដ្ឋិ-គតំ ឧប្បន្នំ ហោតិ ឥទំ និច្ចំ ឥទំ ធុវំ ឥទំ សស្សតំ ឥទំ កេវលំ ឥទំ អចវនធម្មំ ឥទំ ហិ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ ឥតោ ច បុនញ្ញំ ឧត្តរឹ និស្សរណំ នត្ថីតិ ។

ម្នាលនាងព្រាហ្មណី ចូរនាងមើល នូវអ្នកប្រាជ្ញកន្ទង់បង់នូវឱឃៈ ហើយធ្វើបុណ្យជាទីនាំមក នូវសេចក្តីសុខចុះ ។ នាងព្រាហ្មណី មានសេចក្តីជ្រះថ្លា មិនញាប់ញ័របំពោះភិក្ខុនោះ បានតម្កល់នូវទានក្នុងទក្ខិណេយ្យបុគ្គល នាងព្រាហ្មណីបានឃើញអ្នកប្រាជ្ញ ដែលកន្ទង់បង់នូវឱឃៈហើយ ធ្វើនូវបុណ្យជាទីនាំមកនូវសេចក្តីសុខ ។

# ពកសូត្រ ទី ៤

[៤៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតី ជិតក្រុងសាវត្ថី ។ សម័យនោះឯងពកព្រហ្មមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងថា ទីនេះទៀង ទីនេះឋិតថេរ ទីនេះមាននៅគ្រប់កាល ទីនេះខ្ជាប់ខ្ជួន ទីនេះមានសភាពមិនច្យុត ព្រោះថា សត្វក្នុងទីនេះ មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ទីដទៃដែលជាគ្រឿងរលាស់ចេញ ដ៏ក្រៃលែងជាងទីរបស់ព្រហ្មនេះ មិនមានឡើយ ។

៤១

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ ព្រហ្មវចនំ

[៤៦] អថខោ ភគវា ពកស្ស ព្រហ្មុនោ ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ តស្មឹ ព្រហ្មលោកេ បាតុរហោសិ ។ អទ្ទសា ខោ ពកោ ព្រហ្មា ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច ឯហិ ខោ មារិស ស្វាគតំ តេ មារិស ចិរស្សំ ខោ មារិស ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ ឥទំ ហិ មារិស និច្ចំ ឥទំ ធុវំ ឥទំ សស្សតំ ឥទំ កេវលំ ឥទំ អចវនធម្មំ ឥទញ្ហិ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតិ ឥតោ ច បនញ្ញំ ឧត្តរឹ និស្សរណំ នត្ថីតិ ។

ព្រហ្មសំយុត្ត អាយាចនវគ្គ ពាក្យរបស់ព្រហ្ម

[៤៦] គ្រានោះ ព្រះមានព្រះភាគ ជ្រាបនូវបរិវិតក្កៈក្នុងចិត្តរបស់ពកព្រហ្ម ដោយព្រះទ័យរបស់ព្រះអង្គហើយ ក៏បាត់អំពីវត្តជេតពន ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ដូចបុរសមានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ ពកព្រហ្មបានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ សូមព្រះអង្គស្តេចមក បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះអង្គស្តេចមកល្អហើយ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះអង្គបានធ្វើបរិយាយ ដើម្បីស្តេចមកក្នុងទីនេះជាយូរអង្វែងហើយ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ទីនេះទៀង ទីនេះឋិតថេរ ទីនេះមាននៅគ្រប់កាល ទីនេះខ្ជាប់ខ្ជួន ទីនេះមានសភាពមិនច្យុត ព្រោះថា សត្វក្នុងទីនេះ មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ទីដទៃដែលជាគ្រឿងរលាស់ចេញ ដ៏ក្រៃលែងជាងទីរបស់ព្រហ្មនេះ មិនមានឡើយ ។

[៤៧] ឯវំ វុត្តេ ភគវា ពកំ ព្រហ្មានំ ឯតទវោច អវិជ្ជាគតោ វត ភោ ពកោ ព្រហ្មា អវិជ្ជាគតោ វត ភោ ពកោ ព្រហ្មា យត្រ ហិ នាម អនិច្ចំយេវ សមានំ និច្ចន្តិ វក្ខតិ អធុវំយេវ សមានំ ធុវន្តិ វក្ខតិ អសស្សតំយេវ សមានំ សស្សតន្តិ វក្ខតិ អកេវលំយេវ សមានំ កេវលន្តិ វក្ខតិ ចវនធម្មំយេវ សមានំ អចវនធម្មន្តិ វក្ខតិ យត្ថ ច បន ជាយតិ ច ជិយ្យតិ ច មិយ្យតិ ច ចវតិ ច ឧបបជ្ជតិ ច តំ តថា វក្ខតិ ឥទំ ហិ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧបបជ្ជតីតិ[១] សន្តញ្ច បនញ្ញំ ឧត្តរឹ និស្សរណំ នត្ថញ្ញំ ឧត្តរឹ និស្សរណន្តិ វក្ខតីតិ ។

១ ឱ. ម. ឥតិ សទ្ទោ នត្ថិ ។

[៤៧] កាលបើពកព្រហ្ម ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះនឹងពកព្រហ្មថា ឱហ្ន៎ ពកព្រហ្មប្រកបដោយអវិជ្ជាហើយ ឱហ្ន៎ ពកព្រហ្មប្រកបដោយអវិជ្ជាហើយ ព្រោះថាគាត់ពោលនូវរបស់ដែលមិនទៀង ថាជារបស់ទៀងវិញ ពោលនូវរបស់ដែលមិនឋិតថេរ ថាជារបស់ឋិតថេរវិញ ពោលនូវរបស់ដែលគ្មាននៅគ្រប់កាល ថាជារបស់មាននៅគ្រប់កាលវិញ ពោលនូវរបស់ដែលមិនខ្ជាប់ខ្ជួន ថាជារបស់ខ្ជាប់ខ្ជួនវិញ ពោលនូវរបស់ដែលមានសភាពច្យុតថាជារបស់មានសភាពមិនច្យុតវិញ មួយទៀត សត្វតែងកើតផង ចាស់ផង ស្លាប់ផង ច្យុតផង បដិសន្ធិផង ក្នុងទីណា គាត់ពោលទីនោះថាសត្វក្នុងទីនេះមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិដូច្នោះវិញ មួយទៀត គាត់ពោលនូវទីដទៃ ជាគ្រឿងរលាស់ចេញដ៏ក្រៃលែង ថាទីដទៃជាគ្រឿងរលាស់ចេញដ៏ក្រៃលែង មិនមានឡើយ ។

៤៣

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ ព្រហ្មវចនំ

[៤៨] ទ្វាសត្តតិ គោតម បុញ្ញកាមា
វសវត្តិនោ ជាតិជរំ អតីតា
អយមន្តិមា វេទគូ ព្រហ្មុបបត្តិ
អស្មាភិជប្បន្តិ ជនា អនេកាតិ ។

[៤៩] អប្បំ ហិ ឯតំ ន ហិ ទីឃមាយុំ
យំ ត្វំ ពក មញ្ញសិ ទីឃមាយុំ
សតំ សហស្សាន និរព្វុទានំ
អាយុំ បជានាមិ ត្វាហំ ព្រហ្មេតិ ។

[៥០] អនន្តទស្សី ភគវាហមស្មិ
ជាតិជរំ សោកមុចាតិវត្តោ
កឹ មេ បុរាណំ វត សីលវត្តំ
អាចិក្ខ មេតំ យមហំ វិជញ្ញាតិ

[៤៨] ពកព្រហ្ម ពោលថា បពិត្រព្រះគោតម យើង ទាំងឡាយជាជន ៧២ នាក់ ជាអ្នកស្រឡាញ់បុណ្យ ញុំាង អ្នកដទៃ ឲ្យប្រព្រឹត្តទៅតាមអំណាច (នៃខ្លួន) កន្លងហើយ នូវជាតិនិងជរា កំណើតក្នុងព្រហ្មនេះជាទីបំផុត ជាធម្មជាត ប្រព្រឹត្តទៅដោយវេទ ជនទាំងឡាយ ដ៏ច្រើន រមែង ស្រឡាញ់យើងទាំងឡាយ ។

[៤៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលពកព្រហ្ម អ្នកសម្គាល់នូវអាយុណាថា វែង អាយុនុ៎ះតិច មិនមែនវែង ឡើយ ម្នាលព្រហ្ម មួយទៀត តថាគតដឹងច្បាស់នូវអាយុ មានប្រមាណ ១ សែន នៃនិរព្វុទៈ[១] ។

[៥០] ពកព្រហ្ម ទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំ ព្រះអង្គឃើញអារម្មណ៍រកទីបំផុតគ្មាន ប្រព្រឹត្តកន្លងហើយ នូវជាតិជរានិងសេចក្តីសោក អើសីលវត្ត មានមកអំពីដើម របស់ខ្ញុំព្រះអង្គដូចម្តេច ខ្ញុំព្រះអង្គអាចដឹងច្បាស់នូវសីលវត្ត ណា សូមព្រះអង្គប្រាប់នូវសីលវត្តនុ៎ះ ដល់ខ្ញុំព្រះអង្គ ។

១ ជាឈ្មោះសំខ្យាមួយយ៉ាង ប្រើលេខ ១ មានពិន្ទុហុកសិបបី ។

[៨១] យំ ត្វំ អចាយេសិ ពហូ មនុស្សេ

បិចាសិតេ ឃម្មនិ សម្បរេតេ

តន្តេ បុភណំ វត សីលវត្តំ

សុត្តប្បពុទ្ធោវ អនុស្សរាមិ

យំ ឯណិកុលស្មឹ ជនតំ កហិតំ

អមោចយី កយ្ហតំ នីយមានំ

តន្តេ បុភណំ វត សីលវត្តំ

សុត្តប្បពុទ្ធោវ អនុស្សរាមិ

កង្គាយ សោតស្មឹ កហីតនាវំ

លុទ្ទេន នាគេន មនុស្សកាម្យា

អមោចយិត្ថ ពលសា បសយ្ហ

[៥១] ព្រះអង្គត្រាស់ថា អ្នកញុំាំងមនុស្សច្រើន ដែលស្រេកទឹក ដែលត្រូវកម្តៅគ្របសង្កត់ ឲ្យផឹកទឹកក្នុងវដ្ដូវប្រាំង[១] ដោយហេតុណា ហេតុនោះ ជាសីលវត្តមានមកអំពីដើមរបស់អ្នក តថាគតរលឹកបានដូចបុគ្គលដេកលក់ហើយភ្ញាក់ឡើង អ្នកញុំាំងប្រជុំជន ដែលត្រូវចោរចាប់ក្នុងឆ្នេរស្ទឹងឈ្មោះឯណិ នាំទៅជាឈ្លើយ ឲ្យរួចបាន ដោយអំពើណា អំពើនោះ ជាសីលវត្តមានមកអំពីដើមរបស់អ្នក តថាគតរលឹកបាន ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង អ្នកញុំាំងទូកដែលនាគរាជកំណាចកំហែងចាប់ដោយកម្លាំង ត្រង់ខ្សែទឹកនៃទន្លេគង្គា ឲ្យរួចបាន ដោយសេចក្តីអនុគ្រោះដល់មនុស្ស

១ គិម្ហរដូវ ។

តន្តេ បុរាណំ វត សីលវត្តំ
សុត្តប្បពុទ្ធោវ អនុស្សរាមិ
កប្បោ ច តេ បជចពោ អហោសិ
សម្ពុទ្ធិវន្តំ វតិនំ អមញ្ញិ
តន្តេ បុរាណំ វត សីលវត្តំ
សុត្តប្បពុទ្ធោវ អនុស្សរាមិ
អទ្ធា បជាណាសិ មមេតមាយុំ
អញ្ញេបិ ជាណាសិ តថា ហិ ពុទ្ធោ
តថា ហិ ត្យាយំ ជលិតានុភាពោ
ឱភាសយំ តិដ្ឋតិ ព្រហ្មលោកន្តិ ។

## បញ្ចមំ អបរាទិដ្ឋិសុត្តំ

[៥២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ព្រហ្មុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ នត្ថិ សោ សមណោ វា ព្រាហ្មណោ វា យោ ឥធ អាគច្ឆេយ្យាតិ ។

អំពើនោះជាសីលវត្តមានមកអំពីដើមរបស់អ្នក តថាគតរលឹកបានដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ពីដើមតថាគតឈ្មោះកប្បៈ ជាកូនសិស្សរបស់អ្នក រាប់អានអ្នកជាបុគ្គលមានប្រាជ្ញាល្អបរិបូណ៌ដោយវត្ត អំពើនោះជាសីលវត្ត មានមកអំពីដើមរបស់អ្នក តថាគតរលឹកបានដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង អ្នកដឹងច្បាស់នូវអាយុនោះ របស់តថាគតដោយពិត មួយទៀត ដឹងច្បាស់នូវជនទាំងឡាយដទៃហាក់ដូចជាព្រះពុទ្ធ នេះជាអានុភាពដ៏រុងរឿងរបស់អ្នក ជាសភាវៈញុំាងព្រហ្មលោកឲ្យភ្លឺស្វាងឋិតនៅ ។

# អបរាទិដ្ឋិសូត្រ ទី ៥

[៥២] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រហ្មមួយអង្គ មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើងថា បុគ្គលដែលមកក្នុងលោកនេះ គ្មានជាសមណៈ ជាព្រាហ្មណ៍ទេ ។

[៤៣] អថខោ ភគវា តស្ស ព្រហ្មុនោ ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ ។ បេ ។ តស្មឹ ព្រហ្មលោកេ ចាតុរហោសិ ។ អថខោ ភគវា តស្ស ព្រហ្មុនោ ឧបរិវេហាសំ បល្លង្កេន និសីទិ តេជោធាតុំ សមាបជ្ជិត្វា ។

[៤៤] អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ កហំ នុ ខោ ភគវា ឯតរហិ វិហរតីតិ ។ អទ្ទសា ខោ អាយស្មា មហាមោគ្គល្លានោ ភគវន្តំ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន តស្ស ព្រហ្មុនោ ឧបរិវេហាសំ បល្លង្កេន និសិន្នំ តេជោធាតុំ សមាបន្នំ ទិស្វាន សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ តស្មឹ ព្រហ្មលោកេ ចាតុរហោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ បុរត្ថិមំ ទិសំ និស្សាយ តស្ស ព្រហ្មុនោ ឧបរិវេហាសំ បល្លង្កេន និសីទិ តេជោធាតុំ សមាបជ្ជិត្វា នីចតរកំ ភគវតោ ។

[៥៣] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបរិវិតក្កៈ ក្នុងចិត្តរបស់ព្រហ្មនោះ ដោយព្រះទ័យហើយ ក៏ដូចបុរសមានកម្លាំង ។ បេ ។ ទៅប្រាកដក្នុងព្រហ្មលោកនោះ ។ ទើបព្រះមានព្រះភាគ ទ្រង់ចូលតេជោធាតុ គង់ផ្គត់ព្រះភ្នែនព្ធដ៏អាកាស ខាងលើព្រហ្មនោះ ។

[៥៤] គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ គង់ក្នុងទីណាហ្ន៎ ។ ព្រះមហាមោគ្គល្លាន មានអាយុ ក៏បានឃើញ នូវព្រះមានព្រះភាគ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា ដែលព្រះអង្គចូលតេជោធាតុ គង់ផ្គត់ព្រះភ្នែនព្ធដ៏អាកាស អំពីខាងលើនៃព្រហ្មនោះ លុះឃើញហើយ ក៏បាត់អំពីវត្តជេតពន ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ដូចបុរសមានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ អាស្រ័យនូវទិសខាងកើត ចូលតេជោធាតុ អង្គុយផ្គត់ភ្នែនព្ធដ៏អាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

[៤៥] អថខោ អាយស្មតោ មហាកស្សបស្ស ឯតទហោសិ កហំ នុ ខោ ភគវា ឯតរហិ វិហរតីតិ ។ អទ្ទសា ខោ អាយស្មា មហាកស្សបោ ភគវន្តំ ទិព្វេន ចក្ខុនា ។ បេ ។ ទិស្វាន សេយ្យថាបិ នាម ពលវា បុរិសោ ។ បេ ។ ឯវមេវ ជេតវនេ អន្តរហិតោ តស្មឹ ព្រហ្មលោកេ បាតុរហោសិ ។ អថខោ អាយស្មា មហាកស្សបោ ទក្ខិណំ ទិសំ និស្សាយ តស្ស ព្រហ្មុនោ ឧបរិវេហាសំ បល្លង្កេន និសីទិ តេជោធាតុំ សមាបជ្ជិត្វា នីចតរកំ ភគវតោ ។

[៤៦] អថខោ អាយស្មតោ មហាកប្បិនស្ស ឯតទហោសិ កហំ នុ ខោ ភគវា ឯតរហិ វិហរតីតិ ។ អថខោ អាយស្មា មហាកប្បិនោ ភគវន្តំ ទិព្វេន ចក្ខុនា ។ បេ ។ ទិស្វាន សេយ្យថាបិ នាម ពលវា បុរិសោ ។ បេ ។ ឯវមេវ ជេតវនេ អន្តរហិ-តោ តស្មឹ ព្រហ្មលោកេ បាតុរហោសិ ។ អថខោ អាយស្មា មហាកប្បិនោ បច្ឆិមំ ទិសំ និស្សាយ

ព្រហ្មសំយុត្ត អាយាចនវគ្គ សេចក្តីបរិវិតក្កៈរបស់មហាកប្បិន[១]

[៥៥] គ្រានោះ ព្រះមហាកស្សបមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណាហ្ន៎ ។ ព្រះមហាកស្សបមានអាយុ បានឃើញព្រះមានព្រះភាគ ដោយទិព្វចក្ខុ ។ បេ ។ លុះឃើញហើយ ក៏ដូចបុរសមានកម្លាំង ។ បេ ។ បាត់អំពីវត្តជេតពន ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ។ លំដាប់នោះ ព្រះមហាកស្សបមានអាយុ អាស្រ័យនូវទិសខាងត្បូង ចូលតេជោធាតុ អង្គុយផ្គត់ភ្នែនព្វដ៏អាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

[៥៦] គ្រានោះ ព្រះមហាកប្បិនមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណាហ្ន៎ ។ គ្រានោះ ព្រះមហាកប្បិនមានអាយុ ឃើញព្រះមានព្រះភាគ ដោយទិព្វចក្ខុ ។ បេ ។ លុះឃើញហើយ ក៏ដូចបុរសមានកម្លាំង ។ បេ ។ បាត់អំពីវត្តជេតពន ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ។ លំដាប់នោះ ព្រះមហាកប្បិនមានអាយុ អាស្រ័យនូវទិសខាងលិច

១-ច្បាប់មុន ព្រះមានព្រះភាគ ។

តស្ស ព្រហ្មុនោ ឧបរិវេហាសំ បល្លង្កេន និសីទិ តេជោធាតុំ សមាបជ្ជិត្វា នីចតរកំ ភគវតោ ។

[៤៧] អថខោ អាយស្មតោ អនុរុទ្ធស្ស ឯតទ-ហោសិ កហំ នុ ខោ ភគវា ឯតរហិ វិហរតីតិ ។ អទ្ទសា ខោ អាយស្មា អនុរុទ្ធោ ។ បេ ។ តេជោធាតុំ សមាបន្នំ និស្វាន សេយ្យថាបិ នាម ពលវា បុរិសោ ។ បេ ។ តស្មឹ ព្រហ្មលោកេ បាតុរហោសិ ។ អថខោ អាយស្មា អនុរុទ្ធោ ឧត្តរំ ទិសំ និស្សាយ តស្ស ព្រហ្មុនោ ឧបរិវេហាសំ បល្លង្កេន និសីទិ តេជោធាតុំ សមាបជ្ជិត្វា នីចតរកំ ភគវតោ ។

[៤៨] អថខោ អាយស្មា មហាមោគ្គល្លានោ ព្រហ្មានំ[១] គាថាយ អជ្ឈភាសិ

អជ្ជាបិ តេ អាវុសោ សា ទិដ្ឋិ
យា តេ ទិដ្ឋិ បុរេ អហុ
បស្សសិ វីតិវត្តន្តំ
ព្រហ្មលោកេ បភស្សរន្តិ[២] ។

---

១ ឱ. ម. តំ ព្រហ្មានំ ។ ២ ឱ. ម. បភស្សរន្តិ ។

ចូលតេជោធាតុ អណ្តែតផុតក្អែនឡើងអាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

[៥៧] គ្រានោះ ព្រះអនុរុទ្ធមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណាហ្ន៎ ។ ទើបព្រះអនុរុទ្ធមានអាយុ បានឃើញ ។ បេ ។ លុះឃើញហើយ ក៏ដូចបុរសមានកម្លាំង ។ បេ ។ ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ។ លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ អាស្រ័យនូវទិសខាងជើង ចូលតេជោធាតុ អណ្តែតផុតក្អែនឡើងអាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

[៥៨] គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ បានពោលគាថានឹងព្រហ្មថា

ម្នាលអាវុសោ ទិដ្ឋិណា របស់អ្នក មានហើយក្នុងកាលមុន
ទិដ្ឋិរបស់អ្នកនោះ មានក្នុងថ្ងៃនេះទៀត អ្នកឃើញនូវរស្មី
របស់ព្រះពុទ្ធ ដែលប្រព្រឹត្តកន្លង នូវរស្មីឯទៀត ក្នុង
ព្រហ្មលោកដែរឬ ។

[៥៩] ន មេ មារិស សា ទិដ្ឋិ
យា មេ ទិដ្ឋិ បុរេ អហុ
បស្សាមិ វីតិវត្តន្តំ
ព្រហ្មលោកេ បភាយនំ
ស្វាហំ អជ្ជ កថំ វជំ
អហំ និច្ចោម្ហិ សស្សតោតិ ។

[៦០] អថខោ ភគវា តំ ព្រហ្មានំ សំវេជេត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ តស្មឹ ព្រហ្មលោកេ អន្តរហិតោ ជេតវនេ បាតុរហោសិ ។ អថខោ ព្រហ្មា អញ្ញតរំ ព្រហ្មបា-រិសជ្ជំ អាមន្តេសិ ឯហិ ត្វំ មារិស យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កម ឧបសង្កមិត្វា អា-យស្មន្តំ មហាមោគ្គល្លានំ ឯវំ វទេហិ អត្ថិ នុ ខោ មារិ-ស មោគ្គល្លាន អញ្ញេបិ តស្ស ភគវតោ សាវកា ឯវំ-មហិទ្ធិកា ឯវំមហានុភាវា សេយ្យថាបិ នាម ភវំ មោគ្គល្លានោ កស្សបោ កប្បិនោ អនុរុទ្ធោតិ ។

[៥៩] ព្រហ្មតបថា បពិត្រលោកនិទ៌ុក្ខ ទិដ្ឋិរបស់ខ្ញុំណា មាន ហើយក្នុងកាលមុន ទិដ្ឋិរបស់ខ្ញុំនោះ មិនមានទេ ខ្ញុំឃើញ នូវព្រះរស្មី ដែលប្រព្រឹត្តកន្លង នូវរស្មីឯទៀត ក្នុងព្រហ្ម-លោកដែរ ឥឡូវនេះ ខ្ញុំនឹងពោល ដោយប្រការដូចម្ដេច ព្រោះថាខ្ញុំជាបុគ្គលទៀង ជាបុគ្គលមាននៅសព្វ ៗ កាល ។

[៦០] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ញុំាងព្រហ្មនោះ ឲ្យសង្វេគ ហើយ ក៏បាត់អំពីព្រហ្មលោកនោះ មកប្រាកដក្នុងវត្តជេតពន ដោយ ឆាប់រហ័ស ដូចបុរសមានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូល នូវដៃដែលលាចេញ ។ លំដាប់នោះ ព្រហ្មក៏ហៅព្រហ្មជាបរិស័ទមួយ អង្គមកថា ម្នាលអ្នកនិទ៌ុក្ខ អ្នកចូរមក អ្នកចូរទៅរកព្រះមហាមោគ្គល្លាន មានអាយុ លុះចូលទៅដល់ហើយ ចូរពោលយ៉ាងនេះ នឹងព្រះមហា-មោគ្គល្លានមានអាយុថា បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ សាវ័កទាំង-ឡាយដទៃទៀត របស់ព្រះមានព្រះភាគនោះ ដែលមានឫទ្ធិច្រើន យ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដូចជាព្រះមហាមោគ្គល្លាន ព្រះកស្សប ព្រះកប្បិន ព្រះអនុរុទ្ធដ៏ចម្រើន នៅមានទៀតដែរឬទេ ។

ឯវំ មារិសាតិ ខោ សោ ព្រហ្មចារិសជ្ជោ តស្ស ព្រហ្មុនោ បដិស្សុណិត្វា សេយ្យថាបិ នាម ពលវា បុរិសោ ។ បេ ។ ឯវមេវ តស្មឹ ព្រហ្មលោកេ អន្តរហិតោ អាយស្មតោ មហាមោគ្គល្លានស្ស បុរតោ បាតុរហោសិ ។

[៦១] អថខោ សោ ព្រហ្មចារិសជ្ជោ អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ សោ ព្រហ្មចារិសជ្ជោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច អត្ថិ នុ ខោ មារិស ។ បេ ។ អនុរុទ្ធោតិ ។

[៦២] អថខោ អាយស្មា មហាមោគ្គល្លានោ ព្រហ្មចារិសជ្ជំ គាថាយ អជ្ឈភាសិ

តេវិជ្ជា ឥទ្ធិបត្តា ច

ចេតោបរិយាយកោវិទា

ខីណាសវា អរហន្តោ

ពហូ ពុទ្ធស្ស សាវកាតិ ។

ព្រហ្មជាបរិស័ទនោះ ទទួលពាក្យព្រហ្មនោះថា អើលោកអ្នកនិទ៌ុក្ខ ដូច្នេះហើយ ក៏បាត់អំពីព្រហ្មលោកនោះ មកប្រាកដក្នុងទីចំពោះមុខព្រះមហាមោគ្គល្លានមានអាយុ ដោយឆាប់រហ័ស ដូចបុរសមានកម្លាំង ។ បេ ។

[៦១] លំដាប់នោះ ព្រហ្មជាបរិស័ទនោះ ក្រាបថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយឋិតនៅ ក្នុងទីដ៏សមគួរ ។ ព្រហ្មជាបរិស័ទនោះ លុះឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមហាមោគ្គល្លានមានអាយុថា បពិត្រលោកអ្នកនិទ៌ុក្ខ ។ បេ ។ ព្រះអនុរុទ្ធ ។

[៦២] គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ បានពោលគាថានឹងព្រហ្មជាបរិស័ទថា

សាវ័កទាំងឡាយរបស់ព្រះពុទ្ធ នៅមានច្រើនអង្គ ជាអ្នក
មានវិជ្ជា ៣ ផង សម្រេចដោយឫទ្ធិផង ឈ្លាសក្នុងវារៈនៃ
ចិត្តផង ជាព្រះអរហន្តខីណាស្រពផង ។

[៦៣] អថខោ សោ ព្រហ្មចារិសជ្ជោ អាយស្មតោ មហាមោគ្គល្លានស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា យេន សោ ព្រហ្មា តេនុបសង្កមិ ឧបសង្កមិត្វា តំ ព្រហ្មានំ ឯតទវោច អាយស្មា មារិស មហាមោគ្គល្លា-នោ ឯវមាហ

តេវិជ្ជា ឥទ្ធិបត្តា ច
ចេតោបរិយាយកោវិទា
ខីណាសវា អរហន្តោ
ពហូ ពុទ្ធស្ស សាវកាតិ ។

[៦៤] ឥទមវោច ព្រហ្មចារិសជ្ជោ អត្តមនោ ច ព្រហ្មា តស្ស ព្រហ្មចារិសជ្ជស្ស ភាសិតំ អភិនន្ទីតិ ។

## ឆដ្ឋំ បមាទសុត្តំ

[៦៥] សាវត្ថីនិទានំ ។ តេន ខោ បន សម-យេន ភគវា ទិវាវិហារគតោ ហោតិ បដិសល្លីនោ ។

[៦៣] លំដាប់នោះ ព្រហ្មជាបរិស័ទនោះ ត្រេកអរ រីករាយនឹងភាសិត របស់ព្រះមហាមោគ្គល្លានមានអាយុហើយ ក៏ចូលទៅរកព្រហ្មនោះ លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងព្រហ្មនោះថា បពិត្រអ្នកនិទ៌ុក្ខ ព្រះមហាមោគ្គល្លានមានអាយុ មានថេរវាចាយ៉ាងនេះថា

សាវ័កទាំងឡាយរបស់ព្រះពុទ្ធ នៅមានច្រើនអង្គ ជាអ្នក
មានវិជ្ជា ៣ ផង សម្រេចដោយឫទ្ធិផង ឈ្លាសក្នុងវារៈនៃ
ចិត្តផង ជាព្រះអរហន្តខីណាស្រពផង ។

[៦៤] ព្រហ្មជាបរិស័ទ បានពោលពាក្យនេះហើយ ចំណែកខាងព្រហ្មជាអ្នកមានសេចក្តីត្រេកអរ ក៏ត្រេកអរនឹងភាសិត របស់ព្រហ្មជាបរិស័ទនោះ ។

# បមាទសូត្រ ទី ៦

[៦៥] សាវត្ថីនិទាន ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់គង់សម្រាក ក្នុងវេលាថ្ងៃ សម្ងំនៅ ក្នុងឈានសមាបត្តិ ។

អថខោ សុព្រហ្មា ច បច្ចេកព្រហ្មា សុទ្ធាវាសោ ច បច្ចេកព្រហ្មា យេន ភគវា តេនុបសង្កមឹសុ ឧប-សង្កមិត្វា បច្ចេកំ ទ្វារពាហំ ឧបនិស្សាយ អដ្ឋំសុ ។ អថខោ សុព្រហ្មា បច្ចេកព្រហ្មា សុទ្ធាវាសំ បច្ចេ-កព្រហ្មានំ ឯតទវោច អកាលោ ខោ តាវ មារិស ភគវន្តំ បយិរុបាសិតុំ ទិវាវិហារគតោ ភគវា បដិ-សល្លីនោ ច អមុ ច ព្រហ្មលោកោ ឥទ្ធោ ចេវ ផីតោ ច ព្រហ្មា ច តត្ថ បមាទវិហារំ វិហរតិ អាយាម មារិស យេន សោ ព្រហ្មលោកោ តេនុបសង្កមិស្សាម ឧប-សង្កមិត្វា តំ ព្រហ្មានំ សំវេជេយ្យាមាតិ ។ ឯវំ មារិសា-តិ ខោ សុទ្ធាវាសោ បច្ចេកព្រហ្មា សុព្រហ្មុនោ បច្ចេ-កព្រហ្មុនោ បច្ចស្សោសិ ។ អថខោ សុព្រហ្មា បច្ចេ-កព្រហ្មា សុទ្ធាវាសោ ច បច្ចេកព្រហ្មា សេយ្យថាបិ នាម ពលវា បុរិសោ ។ បេ ។ ឯវមេវ ភគវតោ បុរតោ អន្តរហិតា តស្មឹ ព្រហ្មលោកេ ចាតុរហេសុំ ។ អទ្ទសា ខោ សោ ព្រហ្មា តេ ព្រហ្មានោ ទូរតោ វ អាគច្ឆន្តេ ទិស្វាន តេ ព្រហ្មានោ ឯតទវោច

លំដាប់នោះឯង មានព្រហ្មមួយអង្គ ឈ្មោះសុព្រហ្មនិងព្រហ្មមួយអង្គទៀត ឈ្មោះសុទ្ធាវាស បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរអែបនឹងសន្ទឹកទ្វារម្ខាងម្នាក់ ។ គ្រានោះ ព្រហ្មមួយអង្គ ឈ្មោះសុព្រហ្ម បាននិយាយនឹងព្រហ្មមួយអង្គ ឈ្មោះសុទ្ធាវាស ដូច្នេះថា នែគ្នាយើង កាលនេះ ជាកាលមិនទាន់គួរ នឹងចូលទៅគាល់ព្រះមានព្រះភាគនៅឡើយទេ ព្រោះព្រះមានព្រះភាគ ទ្រង់គង់សម្រាកក្នុងវេលាថ្ងៃ កំពុងសម្ងំនៅក្នុងឈានសមាបត្តិផង ចំណែកខាងព្រហ្មលោកឯណោះ ស្តុកស្តម្ភ (ដោយឈានសុខ) និង រីក (ដោយផ្កាគឺអភិញ្ញា) ប៉ុន្តែមានព្រហ្មក្នុងព្រហ្មលោកនោះ នៅដោយសេចក្តីប្រមាទផង នែគ្នាយើង មក យើងនឹងចូលទៅឯព្រហ្មលោកនោះវិញ លុះចូលទៅដល់ហើយ ត្រូវញុំាងព្រហ្មនោះ ឲ្យសង្វេគ ។ ព្រហ្មមួយអង្គឈ្មោះសុទ្ធាវាស បានទទួលស្តាប់ព្រហ្មមួយអង្គ ឈ្មោះសុព្រហ្ម ថា យ៉ាងហ្នឹងហើយ គ្នាយើង ។ លំដាប់នោះ ព្រហ្មមួយអង្គឈ្មោះសុព្រហ្មនិងព្រហ្មមួយអង្គ ឈ្មោះសុទ្ធាវាស ក៏ដូចបុរសមានកម្លាំង ។ បេ ។ បាត់អំពីទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ទៅប្រាកដក្នុងព្រហ្មលោកនោះ ។ ព្រហ្មនោះ បានឃើញព្រហ្មទាំងពីរនោះ កំពុងមកអំពីចម្ងាយ លុះឃើញហើយ ក៏សួរព្រហ្មទាំងនោះ យ៉ាងនេះថា

ហន្ទ កុតោ នុ តុម្ហេ មារិសា អាគច្ឆថាតិ ។ អថខោ មយំ មារិស អាគច្ឆាម តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកា កច្ឆសិ[១] បន ត្វំ មារិស តស្ស ភគវតោ ឧបដ្ឋានំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

[៦៦] ឯវំ វុត្តេ[២] ខោ សោ ព្រហ្មា តំ វចនំ អនធិវាសេន្តោ សហស្សក្ខត្តុំ អត្តានំ អភិនិម្មិនិត្វា សុព្រហ្មានំ បច្ចេកព្រហ្មានំ ឯតទវោច បស្សសិ មេ នោ ត្វំ មារិស ឯវរូបំ ឥទ្ធានុភាវន្តិ ។ បស្សាមិ ខោ ត្យាហំ មារិស ឯវរូបំ ឥទ្ធានុភាវន្តិ ។ សោ ខ្វាហំ មារិស ឯវំមហិទ្ធិកោ ឯវំមហានុភាវោ កស្ស អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា ឧបដ្ឋានំ គមិស្សាមីតិ ។

---

១ ឱ. គច្ឆេយ្យាសិ ។ ២ ឱ. ម. ឯវំ វុត្តោ ។

នៃគ្នាយើងទាំងឡាយ អ្នកទាំងឡាយមកអំពីទីណាហ្ន៎ ។ ព្រហ្មទាំង-ពីរក៏ប្រាប់ថា ម្នាលគ្នាយើង យើងទើបនឹងមកអំពីសំណាក់នៃព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ម្នាលគ្នាយើង ចុះអ្នកនឹងទៅកាន់ទីបម្រើព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះឬទេ ។

[៦៦] កាលបើព្រហ្មទាំងពីរ និយាយយ៉ាងនេះហើយ ព្រហ្មនោះអត់ទ្រាំនឹងពាក្យនោះមិនបាន ក៏និម្មិតខ្លួនចំនួនមួយពាន់ ហើយនិយាយនឹងព្រហ្មមួយអង្គ ឈ្មោះសុព្រហ្មយ៉ាងនេះថា ម្នាលគ្នាយើង អ្នកឃើញឥទ្ធានុភាពរបស់ខ្ញុំ មានសភាពយ៉ាងនេះឬទេ ។ សុព្រហ្មតបថា ម្នាលគ្នាយើង ខ្ញុំឃើញឥទ្ធានុភាពរបស់អ្នក មានសភាពយ៉ាងនោះហើយ ។ ព្រហ្មនោះតបថា ម្នាលគ្នាយើង ខ្ញុំនោះឯង មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ ខ្ញុំនឹងទៅកាន់ទីបម្រើសមណៈ ឬព្រាហ្មណ៍ដទៃណាទៀត ម្ដេចបាន ។

[៦៧] អថខោ សុព្រហ្មា បច្ចេកព្រហ្មា ទ្វិស-
ហស្សក្ខត្តុំ អត្តានំ អភិនិម្មិនិត្វា ព្រហ្មានំ ឯតទវោច
បស្សសិ មេ នោ ត្វំ មារិស ឯវរូបំ តំ ឥទ្ធានុភាវន្តិ ។
បស្សាមិ ខោ ត្យាហំ មារិស ឯវរូបំ ឥទ្ធានុភាវន្តិ ។
តយា ច ខោ មារិស មយា ច ស្វេវ ភគវា មហិទ្ធិ-
កតរោ ចេវ មហានុភាវោ ច អាគច្ឆេយ្យាសិ ត្វំ
មារិស តស្ស ភគវតោ ឧបដ្ឋានំ អរហតោ សម្មា-
សម្ពុទ្ធស្សាតិ ។

[៦៨] អថខោ សោ ព្រហ្មា សុព្រហ្មានំ បច្ចេក-
ព្រហ្មានំ គាថាយ អជ្ឈភាសិ

តយោ សុបណ្ណា[១] ចតុរោ ច ហំសា
ព្យគ្ឃីនិសា បញ្ចសតា ច ឈាយិនោ
តយិទំ វិមានំ ជលតេ ច ព្រហ្មេ
ឱភាសយំ ឧត្តរស្សំ ទិសាយន្តិ ។

១ តីណិ សុបណ្ណរូបសតានីតិ អដ្ឋកថាយំ វុត្តំ ។

[៦៧] លំដាប់នោះឯង ព្រហ្មមួយអង្គ ឈ្មោះសុព្រហ្ម និម្មិតខ្លួនចំនួនពីរពាន់ ហើយនិយាយនឹងព្រហ្មយ៉ាងនេះថា ម្នាលគ្នាយើង អ្នកឃើញឥទ្ធានុភាពរបស់ខ្ញុំនោះ មានសភាពយ៉ាងនេះឬទេ ។ ព្រហ្មនោះតបថា ម្នាលគ្នាយើង ខ្ញុំឃើញឥទ្ធានុភាពរបស់អ្នក មានសភាពយ៉ាងនោះហើយ ។ សុព្រហ្មតបថា ម្នាលគ្នាយើង ព្រះមានព្រះភាគអង្គនោះ ព្រះអង្គមានឫទ្ធិច្រើនបំផុត ទាំងមានអានុភាពច្រើនជាងអ្នកផង ជាងខ្ញុំផង ម្នាលគ្នាយើង អ្នកគួរមកកាន់ទីបម្រើព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

[៦៨] លំដាប់នោះឯង ព្រហ្មនោះ បានពោលនូវគាថាចំពោះព្រហ្មមួយអង្គ ឈ្មោះសុព្រហ្មថា

រូបគ្រុឌបីរយ រូបហង្សបួនរយ រូបខ្លែងប្រាំរយ (នេះជាសម្បត្តិ ក្នុងវិមាន)របស់ខ្ញុំ ជាអ្នកមានឈាន នៃព្រហ្មវិមាននោះ ភ្លឺស្វាង រុងរឿង ក្នុងទិសខាងជើង ។

[៦៩] កិញ្ចាបិ តេ តំ ជលតី វិមានំ
ឱភាសយំ ឧត្តរស្សំ ទិសាយំ
រូបេ រណំ ទិស្វា សទា បវេទិតំ
តស្មា ន រូបេ រមតី សុមេធោតិ ។

[៧០] អថខោ សុព្រហ្មា ច បច្ចេកព្រហ្មា សុទ្ធាវាសោ ច បច្ចេកព្រហ្មា តំ ព្រហ្មានំ សំវេជេត្វា តត្ថេវន្តរធាយឹសុ ។ អគមាសិ ច សោ ព្រហ្មា អបរេន សមយេន ភគវតោ ឧបដ្ឋានំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

## សត្តមំ បឋមកោកាលិកសុត្តំ

[៧១] សាវត្ថិយំ... តេន ខោ បន សមយេន ភគវា ទិវាវិហារគតោ ហោតិ បដិសល្លីនោ ។ អថខោ សុព្រហ្មា ច បច្ចេកព្រហ្មា សុទ្ធាវាសោ ច បច្ចេកព្រហ្មា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា បច្ចេកំ ទ្វារពាហំ និស្សាយ អដ្ឋំសុ ។

[៦៩] សុព្រហ្មតបថា វិមានរបស់អ្នកនោះ ភ្លឺស្វាងរុងរឿង ក្នុងទិសខាងជើង ក៏មែនហើយ ប៉ុន្តែ អ្នកប្រាជ្ញ មានប្រាជ្ញាល្អ តែងឃើញទោសក្នុងរូបផង ឃើញរូបដែលញាប់ញ័រសព្វកាលផង ហេតុនោះ បានជាលោក មិនត្រេកអរក្នុងរូប ។

[៧០] លំដាប់នោះឯង ព្រហ្មមួយអង្គ ឈ្មោះសុព្រហ្ម និងព្រហ្មមួយអង្គ ឈ្មោះសុទ្ធាវាស ញុាំងព្រហ្មនោះ ឲ្យសង្វេគហើយ ក៏បាត់អំពីទីនោះទៅ ។ លុះចំណេរតមក ព្រហ្មនោះ ក៏បានទៅកាន់ទីបម្រើព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ។

## បឋមកោកាលិកសូត្រ ទី ៧

[៧១] ទៀបក្រុងសាវត្ថី... សម័យនោះឯង ព្រះមានព្រះភាគទ្រង់គង់សម្រាកក្នុងវេលាថ្ងៃ សម្ងំនៅក្នុងឈានសមាបត្តិ ។ លំដាប់នោះ មានព្រហ្មមួយអង្គ ឈ្មោះសុព្រហ្មនិងព្រហ្មមួយអង្គ ឈ្មោះសុទ្ធាវាស ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរអែបនឹងសន្ទឹកទ្វារម្ខាងម្នាក់ ។

[៧២] អថខោ សុព្រហ្មា បច្ចេកព្រហ្មា កោកាលិកំ ភិក្ខុំ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

អប្បមេយ្យំ បមិនន្តោ
កោធ វិទ្វា វិកប្បយេ
អប្បមេយ្យំ បមាយិនំ
និវុតន្តំ(១) មញ្ញេ បុថុជ្ជនន្តិ ។

## អដ្ឋមំ តិស្សកសុត្តំ

[៧៣] សាវត្ថិយំ... តេន ខោ បន សមយេន ភគវា ទិវាវិហារគតោ ហោតិ បដិសល្លីនោ ។ អថខោ សុព្រហ្មា ច បច្ចេកព្រហ្មា សុទ្ធាវាសោ ច បច្ចេកព្រហ្មា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា បច្ចេកំ ទ្វារពាហំ និស្សាយ អដ្ឋំសុ ។

១ ឱ. ម. និវុតំ ។

[៧២] លំដាប់នោះឯង ព្រហ្មមួយអង្គឈ្មោះសុព្រហ្ម ប្រារព្ធនឹងកោកាលិកភិក្ខុ ហើយពោលនូវគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

តើអ្នកប្រាជ្ញណា ក្នុងលោកនេះ កំណត់រាប់នូវគុណព្រះខីណាស្រព ដែលជាគុណរាប់មិនអស់បាន[១] ខ្ញុំសម្គាល់នូវបុថុជ្ជន ដែលថាអាចរាប់នូវគុណព្រះខីណាស្រព ជាគុណរាប់មិនអស់បាន (នោះ) ថាជាបុថុជ្ជនល្ងង់ខ្លៅ[២] ។

[៧៣] ទៀបក្រុងសាវត្ថី... សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់សម្រាកក្នុងវេលាថ្ងៃ សម្ងំនៅក្នុងឈានសមាបត្តិ ។ លំដាប់នោះឯង ព្រហ្មមួយអង្គ ឈ្មោះសុព្រហ្មនិងព្រហ្មមួយអង្គ ឈ្មោះសុទ្ធាវាស បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរអែបនឹងសន្ទឹកទ្វារម្ខាងម្នាក់ ។

---

១ គុណព្រះខីណាស្រពគ្មានអ្នកណារាប់អស់ឡើយ ។ ២ បុថុជ្ជនណា អួតថារាប់គុណព្រះខីណាស្រពអស់ បុថុជ្ជននោះ ចាត់ថាជាអ្នកល្ងង់ខ្លៅ ។ អដ្ឋកថា ។

[៧៤] អថខោ សុព្រហ្មា បច្ចេកព្រហ្មា ក-តមោរកតិស្សកំ ភិក្ខុំ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

អប្បមេយ្យំ បមិនន្តោ
កោធ វិទ្វា វិកប្បយេ
អប្បមេយ្យំ បមាយិនំ
និវុតន្តំ មញ្ញេ អកិស្សវន្តិ ។

## នវមំ តុទុព្រហ្មសុត្តំ

[៧៥] សាវត្ថិយំ... តេន ខោ បន សមយេន កោ-កាលិកោ ភិក្ខុ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហ-គិលានោ ។ អថខោ តុទុ[១] បច្ចេកព្រហ្មា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភា-សេត្វា យេន កោកាលិកោ ភិក្ខុ តេនុបសង្កមិ

១ ម. តុរុ ។

[៧៤] គ្រានោះ ព្រហ្មមួយអង្គឈ្មោះសុទ្ធាវាស ប្រារព្ធនឹងភិក្ខុឈ្មោះកតមោរកតិស្សកៈ ហើយពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា

តើអ្នកប្រាជ្ញណា ក្នុងលោកនេះ កំណត់រាប់នូវគុណព្រះខីណាស្រព ដែលជាគុណរាប់មិនអស់បាន ខ្ញុំសម្គាល់នូវបុគ្គលឥតប្រាជ្ញា ដែលថាអាចរាប់គុណព្រះខីណាស្រព ជាគុណរាប់មិនអស់បាន (នោះ) ថាជាបុគ្គលល្ងង់ខ្លៅ ។

# តុទុព្រហ្មសូត្រ ទី ៩

[៧៥] ទៀបក្រុងសាវត្ថី... សម័យនោះឯង កោកាលិកភិក្ខុមានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ ។ លំដាប់នោះឯង កាលវេលារាត្រីបឋមយាមកន្លងទៅហើយ ព្រហ្មមួយអង្គឈ្មោះតុទុ មានរស្មីភ្លឺរុងរឿង ញុំាំងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ចូលទៅរកកោកាលិកភិក្ខុ

ឧបសង្កមិត្វា ភគវន្តំ ឯតទវោច បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។ កោសិ ត្វំ អាវុសោតិ ។ អហំ តុទុបច្ចេកព្រហ្មាតិ ។ កិន្នុ[១] ត្វំ អាវុសោ ភគវតា អនាគាមី ព្យាកតោ កថញ្ចរហិ[២] ឥធាគតោតិ ។ បស្ស យាវញ្ច តេ ឥទំ អបរទ្ធន្តិ ។

[៧៦] បុរិសស្ស ហិ ជាតស្ស
កុធារី ជាយតេ មុខេ
យាយ ឆិន្ទតិ អត្តានំ
ពាលោ ទុព្ភាសិតំ ភណំ
យោ និន្ទិយំ បសំសតិ
តំ វា និន្ទតិ យោ បសំសិយោ
វិចិនាតិ មុខេន សោ កលឹ

១ ឱ. ម. នន្ទ ត្វំ ។ ២ អថ កិញ្ចរហិ ។

លុះចូលទៅដល់ហើយ ក៏ឋិតនៅឰដ៏អាកាស បាននិយាយនឹងកោ-កាលិកភិក្ខុយ៉ាងនេះថា នែកោកាលិក លោកចូរញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះសារីបុត្តនិងព្រះមោគ្គល្លានចុះ ព្រោះព្រះសារីបុត្តនិងព្រះមោគ្គល្លានមានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុសួរថា ម្នាលអាវុសោ អ្នកជាអ្វី ។ តុទុព្រហ្មតបថា ខ្លួនខ្ញុំជាព្រហ្មម្នាក់ឈ្មោះតុទុ ។ កោកាលិក-ភិក្ខុ សួរថា ម្នាលអាវុសោ អ្នកឯងព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាអនាគាមិបុគ្គលហើយ ហេតុអ្វីក៏ឥឡូវនេះ អ្នកមកក្នុងទីនេះ ។ តុទុ-ព្រហ្មតបថា លោកចូរឃើញកំហុសរបស់លោកនេះចុះ ។

[៧៦] បុគ្គលពាល ពោលទុព្ភាសិត កាត់បង់ខ្លួនដោយ
វាចាណា វាចានោះដូចជាផ្ទៃដឹង កើតក្នុងមាត់បុរសដែល
កើតហើយ អ្នកណាសរសើរបុគ្គលដែលគួរនិន្ទា ឬនិន្ទាបុគ្គល
ដែលគួរសរសើរ អ្នកនោះឈ្មោះថា សន្សំទោសដោយមាត់

៤៩



កលិនា តេន សុខំ ន វិន្ទតិ
អប្បមត្តោ អយំ កលិ
យោ អក្ខេសុ ធនបរាជយោ
សព្វស្សាបិ សហាបិ អត្តនា
អយមេវ មហន្តតរោ កលិ
យោ សុគតេសុ មនំ បទោសយេ ។
សតំ សហស្សានំ និរព្វុទានំ
ឆត្តឹសតិ បញ្ច ច អព្វុទានិ
យមរិយេ គរហី និរយំ ឧបេតិ
វាចំ មនញ្ច បណិធាយ បាបកន្តិ ។

## ទសមំ ទុតិយកោកាលិកសុត្តំ

[៧៧] សាវត្ថិយំ... អថខោ កោកាលិកោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច បាបិច្ឆា ភន្តេ សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំ គតាតិ ។

រមែងមិនបានសុខព្រោះទោសនោះ ការចាញ់ធន ព្រមទាំងទ្រព្យគ្រប់ចំពូក ព្រមទាំងខ្លួន ទៅលើល្បែងភ្នាល់ទាំង-ឡាយ ទោសនេះ ជាទោសមានប្រមាណតិចទេ បុគ្គលដែលញុំាងចិត្តឲ្យប្រទូស្ត ក្នុងបុគ្គលទាំងឡាយ ដែលមានគតិល្អ ទោសនេះឯង ទើបជាទោសធំជាង ។ បុគ្គលតម្កល់វាចានិងចិត្តអាក្រក់ ជាអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ទៅកើតក្នុងនរកណា នរកនោះ មានអាយុចំនួនមួយសែន និងសាមសិបប្រាំមួយនិរព្វុទៈ និងប្រាំអព្វុទៈ ។

# ទុតិយកោកាលិកសូត្រ ទី ១០

[៧៧] ទៀបក្រុងសាវត្ថី... លំដាប់នោះឯង កោកាលិកភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះកោកាលិកភិក្ខុអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សារីបុត្តនិងមោគ្គល្លាន ជាអ្នកប្រាថ្នាលាមក ប្រព្រឹត្តទៅតាមអំណាចសេចក្តីប្រាថ្នាលាមក ។

[៧៨] ឯវំ វុត្តេ ភគវា កោកាលិកំ ភិក្ខុំ ឯតទវោច មា ហេវំ កោកាលិក អវច មា ហេវំ កោកាលិក អវច បសាទេហិ កោកាលិក សារី-បុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានា-តិ ។ ទុតិយម្បិ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច កិញ្ចាបិ មេ ភន្តេ សទ្ធាយិកោ បច្ចយិកោ អថខោ បាបិច្ឆាវ សារីបុត្តមោគ្គល្លានា បាបកានំ ឥច្ឆានំ វសំ គតាតិ ។ ទុតិយម្បិ ខោ ភគវា កោ-កាលិកំ ភិក្ខុំ ឯតទវោច មា ហេវំ កោកាលិក អវច មា ហេវំ កោកាលិក អវច បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គ-ល្លានាតិ ។ តតិយម្បិ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច ។ បេ ។ ឥច្ឆានំ វសំ គតាតិ ។ តតិយម្បិ ខោ ភគវា កោកាលិកំ ភិក្ខុំ ឯតទវោច ។ បេ ។ បេសលា សារីបុត្តមោគ្គល្លានាតិ ។

[៧៨] កាលបើកោកាលិកភិក្ខុ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងកោកាលិកភិក្ខុ យ៉ាងនេះថា ម្នាលកោ-កាលិក អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលកោកាលិក អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលកោកាលិក អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លា ក្នុងសា-រីបុត្តនិងមោគ្គល្លានចុះ ព្រោះសារីបុត្តនិងមោគ្គល្លាន មានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ក្រាបទូលព្រះមានព្រះភាគ ជាគម្រប់ពីរដង យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលគួរជឿ គួរប្រតិបត្តិតាមរបស់ខ្ញុំមានស្រាប់ហើយ សារីបុត្តនិងមោគ្គល្លាន ជាអ្នកប្រាថ្នាលាមកពិត ៗ ប្រព្រឹត្តទៅតាមអំណាចនៃសេចក្តីប្រាថ្នាដ៏លាមក ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងកោកាលិកភិក្ខុជាគម្រប់ពីរដង យ៉ាងនេះថា ម្នាលកោកាលិក អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលកោកាលិក អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលកោកាលិក អ្នកចូរញុំាងចិត្តឲ្យជ្រះថ្លា ក្នុងសារីបុត្តនិងមោគ្គល្លានទៅចុះ ព្រោះសារីបុត្តនិងមោគ្គល្លាន មានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ក្រាបទូលព្រះមានព្រះភាគ ជាគម្រប់បីដង យ៉ាងនេះថា ។ បេ ។ ប្រព្រឹត្តទៅតាមអំណាចសេចក្តីប្រាថ្នា ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងកោកាលិកភិក្ខុ ជាគម្រប់បីដងយ៉ាងនេះថា ។បេ។ ព្រោះសារីបុត្តនិងមោគ្គល្លាន មានសីលជាទីស្រឡាញ់ ។

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ កោកាលិកស្ស កាលកិរិយា

[៧៩] អថខោ កោកាលិកោ ភិក្ខុ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អចិរប្បក្កន្តស្ស ច កោកាលិកស្ស ភិក្ខុនោ សាសបមត្តីហិ បិឡកាហិ សព្វោ កាយោ ផុដ្ឋោ អហោសិ សាសបមត្តិយោ ហុត្វា មុគ្គមត្តិយោ អហោសុំ មុគ្គមត្តិយោ ហុត្វា កឡាយមត្តិយោ អហោសុំ កឡាយមត្តិយោ ហុត្វា កោលដ្ឋិមត្តិយោ អហោសុំ កោលដ្ឋិមត្តិយោ ហុត្វា កោលមត្តិយោ អហោសុំ កោលមត្តិយោ ហុត្វា អាមលកមត្តិយោ អហោសុំ អាមលកមត្តិយោ ហុត្វា វេលុវសលាដុកមត្តិយោ អហោសុំ វេលុវសលាដុកមត្តិយោ ហុត្វា ពិល្វមត្តិយោ អហោសុំ ពិល្វមត្តិយោ ហុត្វា បភិជ្ជឹសុ បុព្វញ្ច លោហិតញ្ច បគ្ឃរឹសុ ។ អថខោ កោកាលិកោ ភិក្ខុ តេនេវ អាពាធេន កាលមកាសិ ។ កាលកតោ ច កោកាលិកោ ភិក្ខុ បទុមនិរយំ ឧបបជ្ជិ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វា ។

ព្រហ្មសំយុត្ត អាយាចនវគ្គ កាលកិរិយានៃកោកាលិកភិក្ខុ

[៧៩] លំដាប់នោះឯង កោកាលិកភិក្ខុ ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។ កោកា-លិកភិក្ខុចេញទៅ មិនយូរប៉ុន្មាន កាយទាំងមូលក៏ចេញជាអុត[១] ប៉ុន ៗ គ្រាប់ស្ពៃ អុតដែលប៉ុនគ្រាប់ស្ពៃ ក្លាយឡើងប៉ុន ៗ គ្រាប់សណ្តែកបាយ អុតដែលប៉ុនគ្រាប់សណ្តែកបាយ ក្លាយឡើងប៉ុន ៗ គ្រាប់សណ្តែកកង់ អុតដែលប៉ុនគ្រាប់សណ្តែកកង់ ក្លាយឡើងប៉ុន ៗ គ្រាប់ពុទ្រា អុតដែលប៉ុនគ្រាប់ពុទ្រា ក្លាយឡើងប៉ុន ៗ ផ្លែពុទ្រា អុតដែលប៉ុនផ្លែពុទ្រា ក្លាយឡើងប៉ុន ៗ ផ្លែកន្ទួតព្រៃ អុតដែលប៉ុនផ្លែកន្ទួតព្រៃ ក្លាយឡើងប៉ុន ៗ ក្តិបត្នោត អុតដែលប៉ុនក្តិបត្នោត ក្លាយឡើងប៉ុន ៗ ផ្លែត្នោត អុតដែលប៉ុនផ្លែត្នោត ក៏បែកធ្លាយហូរខ្ទុះនិងឈាម ។ គ្រានោះ កោកាលិកភិក្ខុ ក៏ធ្វើមរណកាលដោយជំងឺនោះទៅ ។ លុះកោកាលិកភិក្ខុធ្វើមរណកាលហើយ ទៅកើតក្នុងបទុមនរក ព្រោះតែចងចិត្តអាឃាត ក្នុងព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។

១ អាចារ្យខ្លះប្រែថា បូស ខ្លះថា បូសរលកកែវ ខ្លះថា កមរលាយ ។

[៨០] អថខោ ព្រហ្មា សហម្បតិ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ព្រហ្មា សហម្បតិ ភគវន្តំ ឯតទវោច កោកាលិកោ ភន្តេ ភិក្ខុ កាលកតោ[១] កាលកតោ ច ភន្តេ កោកាលិកោ ភិក្ខុ បទុមនិរយំ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ។ ឥទមវោច ព្រហ្មា សហម្បតិ ឥទំ វត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

---

១ ឱ. កាលមកាសីតិ បាឋោ ។

[៨០] លំដាប់នោះ លុះវេលារាត្រីបឋមយាម កន្លងទៅហើយ សហម្បតិព្រហ្មមានរស្មីល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។ លុះសហម្បតិព្រហ្មឈរនៅក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុធ្វើមរណកាលហើយ បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុ លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងបទុមនរក ព្រោះតែចងចិត្តអាឃាត ក្នុងព្រះសារីបុត្តនិងព្រះមោគ្គល្លាន ។ សហម្បតិព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចបាត់អំពីទីនោះ ។

៦៣

ព្រហ្មសំយុត្តស្ស អាយាចនវគ្គេ បទុមនិរយេ អាយុប្បមាណបុច្ឆា

[៨១] អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ ព្រហ្មា សហម្បតិ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតោ ខោ ភិក្ខវេ ព្រហ្មា សហម្បតិ មំ ឯតទវោច កោកាលិកោ ភន្តេ ភិក្ខុ កាលកតោ កាលកតោ ច ភន្តេ កោកាលិកោ ភិក្ខុ បទុមនិរយំ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ឥទមវោច ភិក្ខវេ ព្រហ្មា សហម្បតិ ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

[៨២] ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច ទីឃំ នុ ខោ ភន្តេ បទុមនិរយេ អាយុប្បមាណន្តិ ។ ទីឃំ ខោ ភិក្ខុ បទុមនិរយេ អាយុប្បមាណំ តំ

[៨១] *លុះកន្លងរាត្រីនោះទៅ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ កាលវេលារាត្រីបឋមយាមកន្លងទៅហើយ ក្នុងរាត្រីនេះ សហម្បតិព្រហ្មមានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ចូលមករកតថាគត លុះចូលមកដល់ ថ្វាយបង្គំតថាគត ហើយឈរនៅក្នុងទីដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ លុះសហម្បតិព្រហ្មឈរនៅក្នុងទីដ៏សមគួរហើយ ទើបនិយាយពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុ ធ្វើមរណកាលហើយ បពិត្រព្រះអង្គដ៏ចម្រើន កោកាលិកភិក្ខុលុះធ្វើមរណកាលហើយក៏ទៅកើតក្នុងបទុមនរក ព្រោះតែចងចិត្តអាឃាត ក្នុងព្រះសារីបុត្តនិងព្រះមោគ្គល្លាន ម្នាលភិក្ខុទាំងឡាយ សហម្បតិព្រហ្មបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ រួចក៏បាត់អំពីទីនោះទៅ ។*

[៨២] *កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ប្រមាណអាយុក្នុងបទុមនរក តើយូរប៉ុន្មាន ។ ម្នាលភិក្ខុប្រមាណអាយុក្នុងបទុមនរក យូរពន់ពេក ប្រមាណអាយុ ក្នុងបទុមនរកនោះ*

ន សុករំ សង្ខាតុំ ឯត្តកានិ វស្សានិ ឥតិ វា ឯត្តកានិ វស្សសតានិ ឥតិ វា ឯត្តកានិ វស្សសហស្សានិ ឥតិ វា ឯត្តកានិ វស្សសតសហស្សានិ ឥតិ វាតិ ។ សក្កា បន ភន្តេ ឧបមា កាតុន្តិ ។

[៨៣] សក្កា ភិក្ខូតិ ភគវា អវោច សេយ្យថាបិ ភិក្ខុ វីសតិខារិកោ កោសលកោ តិលវាហោ តតោ បុរិសោ វស្សសតស្ស វស្សសតស្ស អច្ចយេន ឯកមេកំ តិលំ ឧទ្ធរេយ្យ ខិប្បតរំ ខោ សោ ភិក្ខុ វីសតិខារិកោ កោសលកោ តិលវាហោ ឥមិនា ឧបក្កមេន បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ន ត្វេវ ឯកោ អព្ពុទោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អព្ពុទា និរយា ឯវមេកោ និរព្ពុទោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ និរព្ពុទា និរយា ឯវមេកោ អពពោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អពពា និរយា ឯវមេកោ អដដោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អដដា និរយា ឯវមេកោ អហហោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អហហា និរយា ឯវមេកោ កុមុទោ និរយោ

មិនអាចរាប់បានដោយងាយថា ប៉ុណ្ណោះឆ្នាំ ប៉ុណ្ណោះរយឆ្នាំ ប៉ុណ្ណោះពាន់ឆ្នាំ ឬប៉ុណ្ណោះសែនឆ្នាំបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះអាចធ្វើឧបមាបានឬទេ ។

[៨៣] ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុ តថាគត អាចធ្វើបាន ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុ ដូចជារទេះផ្ទុកគ្រាប់ល្ងរបស់អ្នកដែនកោសល ដែលមានចំណុះ ២០ ខារិ[១] លុះដល់កន្លងទៅមួយរយឆ្នាំ ៗ បុរសចាប់យកគ្រាប់ល្ងមួយគ្រាប់ ៗ អំពីរទេះនោះ ម្នាលភិក្ខុ រទេះល្ងរបស់អ្នកដែនកោសល ដែលមានចំណុះ ២០ ខារិនោះ អស់រលីងឥតសេសសល់ ដោយលំដាប់ នេះឆាប់ជាង នៅមិនទាន់ដល់នរកឈ្មោះ អព្វុទៈមួយទេ ម្នាលភិក្ខុ ២០ អព្វុទនរក ស្មើនឹងនិរព្វុទ-នរកមួយ ម្នាលភិក្ខុ ២០ និរព្វុទនរក ស្មើនឹងអពពនរកមួយ ម្នាលភិក្ខុ ២០ អពពនរក ស្មើនឹងអដដនរកមួយ ម្នាលភិក្ខុ ២០ អដដនរក ស្មើនឹងអហហនរកមួយ ម្នាលភិក្ខុ ២០ អហហនរក ស្មើនឹងកុមុទនរកមួយ

---

១ អដ្ឋកថា ថា ៤ បត្ថៈ (នាលិ) នៃអ្នកដែនមគធៈជា ១ បត្ថៈរបស់អ្នកដែនកោសល, ៤ បត្ថៈនោះ ជា ១ អាឡ្ហកៈ, ៤ អាឡ្ហកៈជា ១ ទោណៈ , ៤ ទោណៈ ជា ១ មានិកា, ៤ មានិកា ទើបត្រូវជា ១ ខារិ គឺ ១ អំរែក ។

សេយ្យថាបិ ភិក្ខុ វីសតិ កុមុទា និរយា ឯវមេកោ សោគន្ធិកោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ សោគន្ធិកា និរយា ឯវមេកោ ឧប្បលកោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ ឧប្បលកា និរយា ឯវមេកោ បុណ្ឌរីកោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ បុណ្ឌរីកា និរយា ឯវមេកោ បទុមោ និរយោ បទុមំ ខោ បន ភិក្ខុ និរយំ កោកាលិកោ ភិក្ខុ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ។

[៨៤] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

បុរិសស្ស ហិ ជាតស្ស
កុឋារី ជាយតេ មុខេ
យាយ ឆិន្ទតិ អត្តានំ
ពាលោ ទុព្ភាសិតំ ភណំ
យោ និន្ទិយំ បសំសតិ
តំ វា និន្ទតិ យោ បសំសិយោ
វិចិនាតិ មុខេន សោ កលឹ

ម្នាលភិក្ខុ ២០ កុមុទនរក ស្មើនឹងសោគន្ធិកនរកមួយ ម្នាលភិក្ខុ ២០ សោគន្ធិកនរក ស្មើនឹងឧប្បលកនរកមួយ ម្នាលភិក្ខុ ២០ ឧប្បលកនរក ស្មើនឹងបុណ្ឌរីកនរកមួយ ម្នាលភិក្ខុ ២០ បុណ្ឌរីកនរក ទើបស្មើនឹងបទុម-នរកមួយ ម្នាលភិក្ខុ ចំណែកកោកាលិកភិក្ខុ ទៅកើតក្នុងនរកឈ្មោះបទុមៈ ព្រោះតែងចងចិត្តអាឃាត ក្នុងសារីបុត្តនិងមោគ្គល្លាន ។

[៨២] ព្រះមានព្រះភាគ បានត្រាស់សូត្រនេះហើយ លុះព្រះសុគតជាសាស្ដា ទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបត្រាស់ពាក្យនេះតទៅទៀតថា

បុគ្គលពាល ពោលទុព្ភាសិត កាត់បង់ខ្លួន ដោយវាចា
ណា វាចានោះ ដូចជាផ្ទៃដឹង កើតក្នុងមាត់បុរសដែលកើត
ហើយ អ្នកណាសរសើរបុគ្គលដែលគួរនិន្ទា ឬនិន្ទាបុគ្គល
ដែលគួរសរសើរ អ្នកនោះឈ្មោះថា សន្សំទោសដោយមាត់

កាលិជា តេន សុខំ ន វិន្ទតិ
អប្បមត្តោ អយំ កលិ
យោ អក្ខេសុ ធនបរាជយោ
សព្វស្សាបិ សហាបិ អត្តនា
អយមេវ មហន្តតរោ កលិ
យោ សុគតេសុ មនំ បទោសយេ ។
សតំ សហស្សានំ និរព្ពុទានំ
ឆត្តឹសតិ បញ្ច ច អព្ពុទានិ
យមរិយេ គរហី និរយំ ឧបេតិ
វាចំ មនញ្ច បណិធាយ ចាបកន្តិ ។

អាយាចនវគ្គោ ។

## តស្សុទ្ទានំ

អាយាចនំ គារវោ ព្រហ្មទេវោ
ពកោ ច ព្រហ្មា អបរា ច ទិដ្ឋិ
បមាទកោកាលិកតិស្សកោ ច
តុទុ ច ព្រហ្មា អបរោ កោកាលិកោតិ ។

រមែងមិនបានសុខ ព្រោះទោសនោះ ការចាញ់ធនព្រមទាំងទ្រព្យគ្រប់ចំពូក ព្រមទាំងខ្លួន ទៅលើល្បែងភ្នាល់ទាំងឡាយ ទោសនេះ ជាទោសមានប្រមាណតិចទេ បុគ្គលដែលញុំាងចិត្តឲ្យប្រទូស្ត ក្នុងបុគ្គលទាំងឡាយ ដែលមានគតិល្អ ទោសនេះឯង ទើបជាទោសធំជាង ។ បុគ្គលតម្កល់វាចានិងចិត្តអាក្រក់ ជាអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ទៅកើតក្នុងនរកណា នរកនោះមានអាយុចំនួនមួយសែន និងសាមសិបប្រាំមួយនិរព្វុទៈនិងប្រាំអព្វុទៈ ។

ចប់ អាយាចនវគ្គ ។

## ឧទ្ទាននៃអាយាចនវគ្គនោះ គឺ

អាយាចនសូត្រ ១ គារវសូត្រ ១ ព្រហ្មទេវសូត្រ ១ ពកព្រហ្មសូត្រ ១ អបរាទិដ្ឋិសូត្រ ១ បមាទសូត្រ ១ បឋមកោកាលិកសូត្រ ១ តិស្សកសូត្រ ១ តុទុព្រហ្មសូត្រ ១ ទុតិយកោកាលិកសូត្រដទៃទៀត ១ ។

# ព្រហ្មបញ្ចកំ[១]

## បឋមំ សនង្កុមារសុត្តំ

[៨៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ សប្បិនីតីរេ ។ អថខោ ព្រហ្មា សនង្កុមារោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ សប្បិនីតីរំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[៨៦] ឯកមន្តំ ឋិតោ ខោ ព្រហ្មា សនង្កុមារោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេ ។

---

១ ឱ. ទុតិយោ វគ្គោតិបិ បញ្ចកន្តិបិ បាឋោ ។

# ព្រហ្មបញ្ចកៈ

---

## សនង្កុមារសូត្រ ទី ១

[៨៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរស្ទឹងឈ្មោះសប្បិនី ទៀបក្រុងរាជគ្រឹះ ។ លំដាប់នោះឯង កាលវេលារាត្រីបឋមយាមកន្លងទៅហើយ ព្រហ្មឈ្មោះសនង្កុមារ មានរស្មីដ៏ល្អ ញុំាងឆ្នេរស្ទឹងសប្បិនីទាំងមូលឲ្យភ្លឺស្វាង រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

[៨៦] លុះសនង្កុមារព្រហ្ម ឈរនៅក្នុងទីដ៏សមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា

ពួកជនដែលអាស្រ័យនូវគោត្រ មានតែក្សត្រិយ៍ប្រសើរបំផុតក្នុងប្រជុំជន ចំណែកខីណាសវព្រាហ្មណ៍ អ្នកបរិបូណ៌ដោយវិជ្ជានិងចរណៈ ប្រសើរបំផុតក្នុងពួកទេវតានិងមនុស្ស ។

[៨៧] ឥធមហោច ព្រហ្មា សនង្កុមារោ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ ព្រហ្មា សនង្កុមារោ សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

## ទុតិយំ ទេវទត្តសុត្តំ

[៨៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ អចិរប្បក្កន្តេ ទេវ-ទត្តេ ។ អថខោ ព្រហ្មា សហម្បតិ អភិក្កន្តាយ រត្តិ-យា អភិក្កន្តវណ្ណោ កេវលកប្បំ គិជ្ឈកូដំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[៨៩] ឯកមន្តំ ឋិតោ ខោ ព្រហ្មា សហម្បតិ ទេវទត្តំ អារព្ភ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

[៨៧] លុះសនង្កុមារព្រហ្ម បានពោលគាថានេះហើយ ព្រះសាស្តា ទ្រង់ពេញព្រះហឫទ័យ ។ លំដាប់នោះឯង សនង្កុមារព្រហ្ម ដឹងថា ព្រះសាស្តារបស់អាត្មាអញ ទ្រង់ពេញព្រះហឫទ័យ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយក៏បាត់អំពីទីនោះទៅ ។

## ទេវទត្តសូត្រ ទី ២

[៨៨] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ កាលដែលទេវទត្ត ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ លំដាប់នោះឯង កាលវេលារាត្រីបឋមយាមកន្លងទៅហើយ សហម្បតិព្រហ្ម មានរស្មីដ៏ល្អ ញុំាងភ្នំគិជ្ឈ-កូដទាំងមូលឲ្យភ្លឺស្វាង ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។

[៨៩] លុះសហម្បតិព្រហ្ម ឈរក្នុងទីដ៏សមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគ ប្រារព្ធនឹងទេវទត្តថា

៦៩

ព្រហ្មសំយុត្តស្ស ព្រហ្មបញ្ចកេ សហម្បតិស្ស ភាសិតំ

ផលំ វេ កទលឹ ហន្តិ
ផលំ វេឡុំ ផលំ នឡំ
សក្ការោ កាបុរិសំ ហន្តិ
គព្ភោ អស្សតរឹ យថាតិ ។

## តតិយំ អន្ធកវិន្ទសុត្តំ

[៩០] ឯកំ សមយំ ភគវា មគធេសុ វិហរតិ អន្ធកវិន្ទេ ។ តេន ខោ បន សមយេន ភគវា រត្តន្ធការតិមិសាយំ អព្ភោកាសេ និសិន្នោ ហោតិ ។ ទេវោ ច ឯកមេកំ ផុសាយតិ ។ អថខោ ព្រហ្មា សហម្បតិ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ អន្ធកវិន្ទំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[៩១] ឯកមន្តំ ឋិតោ ខោ ព្រហ្មា សហម្បតិ ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

ផ្លែចេក សម្លាប់ដើមចេក ផ្លែឫស្សី សម្លាប់ដើមឫស្សី ផ្លែបបុស សម្លាប់ដើមបបុស គ្រឿងសក្ការៈសម្លាប់បុរសខូច ដូចជាគភ៌ សម្លាប់មេសេះអស្សតរ ។

# អន្ធកវិន្ទសូត្រ ទី ៣

[៩០] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងស្រុកអន្ធកវិន្ទៈ ក្នុងដែនមគធៈ ។ សម័យនោះឯង ព្រះមានព្រះភាគគង់ក្នុងទីវាល ក្នុងវេលារាត្រីងងឹតអ័ព្ទ ។ ភ្លៀងក៏ធ្លាក់ស្រិប ៗ ។ គ្រានោះ លុះវេលារាត្រីបឋមកន្លងទៅហើយ សហម្បតិព្រហ្មមានរស្មីដ៏ល្អ ញុំាងស្រុកអន្ធកវិន្ទៈទាំងមូលឲ្យភ្លឺស្វាង រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយឈរក្នុងទីដ៏សមគួរ ។

[៩១] លុះសហម្បតិព្រហ្ម ឈរក្នុងទីដ៏សមគួរហើយ ក៏បានពោលគាថាទាំងឡាយនេះ ក្នុងសំណាក់ព្រះមានព្រះភាគថា

សេវេថ បន្តានិ សយនាសនានិ
ចរេយ្យ សញ្ញោជនវិប្បមោក្ខា
សចេ រតឹ នាធិគច្ឆេយ្យ តត្ថ
សង្ឃេ វសេ រក្ខិតត្តោ សតីមា
កុលា កុលំ បិណ្ឌិកាយ ចរន្តោ
ឥន្ទ្រិយគុត្តោ និបកោ សតីមា
សេវេថ បន្តានិ សយនាសនានិ
ភយា បមុត្តោ អភយេ វិមុត្តោ
យត្ថ ភេរវា សិរីសបា
វិជ្ជុ សញ្ចរតិ ថនេតិ ទេវោ
អន្ធការតិមិសាយ រត្តិយា
និសីទិ តត្ថ ភិក្ខុ វិគតលោមហំសោ
ឥទញ្ហិ ជាតុ មេ ទិដ្ឋំ
នយិទំ ឥតិហីតិហំ
ឯកស្មឹ ព្រហ្មចរិយស្មឹ
សហស្សំ មច្ចុហាយិនំ
ភីយោ បញ្ចសតា សេក្ខា

ភិក្ខុគួរសេពសេនាសនៈស្ងាត់ គួរប្រព្រឹត្តឲ្យរួចស្រឡះចាក សំយោជនៈ បើមិនបានសេចក្តីត្រេកអរ ក្នុងសេនាសនៈនោះទេ ក៏គួរនៅក្នុងពួកចុះ តែថាត្រូវរក្សាខ្លួន ត្រូវមានស្មារតី ភិក្ខុកាលត្រាច់ទៅបិណ្ឌបាត អំពីត្រកូលមួយ ទៅត្រកូលមួយ ត្រូវរក្សាឥន្ទ្រិយ ត្រូវមានប្រាជ្ញា មានស្មារតី ហើយគួរសេពសេនាសនៈស្ងាត់ ក្នុងទីណាមានពួកពស់តូច ពស់ធំ ជាសត្វទីឃជាតិដែលគួរខ្លាច ផ្ទេកបន្ទោរកំពុងតែឆ្វៀលឆ្វាត់ មេឃកំពុងតែគ្រហឹម ក្នុងរាត្រីដែលងងឹតអ័ព្ទ ភិក្ខុអ្នករួចស្រឡះចាកភ័យ ចុះបិត្តស៊ប់ក្នុងព្រះនិព្វានដែលឥតភ័យ ក៏អស់ព្រឺព្រួចរោមហើយ អង្គុយក្នុងទីទាំងនោះបាន មួយទៀត ហេតុនេះ ខ្ញុំឃើញច្បាស់ហើយ ខ្ញុំមិនមែននិយាយផ្តេសផ្តាសទេ ក្នុងព្រហ្មចរិយៈ គឺធម្មទេសនាម្តង បានពួកលោកដែលលះបង់នូវមច្ចុបានមួយពាន់ បានពួកលោកជាសេក្ខៈជាងប្រាំរយ

ឧសា ច ឧសជា ឧស[១]

សព្វេ សោតំ សមាបន្នា

អតិវច្ឆានគាមិនោ

អថាយំ ឥតរា បជា

បុញ្ញភាគាតិ មេ មនោ

សង្ខាតុំ នោបិ សក្កោមិ

មុសាវាទស្ស ឱត្តប្បន្តិ[២] ។

# ចតុត្ថំ អរុណវតីសុត្តំ

[៩២] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ។ បេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៩៣] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ រាជា អហោសិ អរុណវា នាម ។ រញ្ញោ ខោ បន ភិក្ខវេ អរុណវតោ អរុណវតី នាម រាជធានី អហោសិ ។

១ ឱ. សតំ ។ ២ ឱ. ឱតប្បតិ ។ ម. ឱតប្បេតីតិ ។

ក៏មាន វេយដប់ក៏មាន លោកទាំងអស់នោះ បានដល់នូវ ខ្សែអរិយមគ្គហើយ មិនទៅកើតជាសត្វតិរច្ឆានទេ មួយទៀត ចិត្តខ្ញុំគិតថា ពួកសត្វក្រៅពីសេក្ខៈនេះ សុទ្ធតែជាអ្នក បានចំណែកបុណ្យ តែខ្ញុំមិនអាចនឹងរាប់បាន ព្រោះខ្លាច មុសាវាទ ។

# អរុណវតីសូត្រ ទី ៤

[៩២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុង សាវត្ថី ។ បេ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះ ពុទ្ធដីកាព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ។

[៩៣] ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំង- ឡាយ កាលពីព្រេងនាយមក មានព្រះរាជាឈ្មោះអរុណវន្ត ។ ម្នាល ភិក្ខុទាំងឡាយ ក៏ព្រះរាជាអរុណវន្ត មានរាជធានីឈ្មោះអរុណវតី ។

អរុណវតី ខោ បន ភិក្ខវេ រាជធានី សិខី ភគវា អរហំ សម្មាសម្ពុទ្ធោ ឧបនិស្សាយ វិហាសិ ។ សិខិស្ស ខោ បន ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អភិភូសម្ភវំ នាម សាវកយុគំ អហោសិ អគ្គយុគំ ភទ្ទយុគំ ។

[៩៤] អថខោ ភិក្ខវេ សិខី ភគវា អរហំ សម្មាសម្ពុទ្ធោ អភិភុំ ភិក្ខុំ អាមន្តេសិ អាយាម ព្រាហ្មណ យេន អញ្ញតរោ ព្រហ្មលោកោ តេនុបសង្កមិស្សាម យាវ ភត្តស្ស កាលោ ភវិស្សតីតិ ។ ឯវំ ភន្តេតិ ខោ ភិក្ខវេ អភិភូ ភិក្ខុ សិខិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បច្ចស្សោសិ ។ អថខោ ភិក្ខវេ សិខី ច ភគវា អរហំ សម្មាសម្ពុទ្ធោ អភិភូ ច ភិក្ខុ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ អរុណវតិយា រាជធានិយា អន្តរហិតោ តស្មឹ ព្រហ្មលោកេ ចាតុរហេសុំ ។ អថខោ ភិក្ខវេ សិខី ភគវា អរហំ សម្មាសម្ពុទ្ធោ អភិភុំ ភិក្ខុំ អាមន្តេសិ

ម្នាលភិក្ខុទាំងឡាយ កាលនោះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមសិខី បានគង់អាស្រ័យនូវអរុណវតីរាជធានី ។ ម្នាលភិក្ខុទាំងឡាយ សាវ័កមួយគូ ឈ្មោះអភិភូនិងសម្ភវៈ ជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន របស់ព្រះសិខី មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។

[៩៤] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ បានត្រាស់ហៅភិក្ខុឈ្មោះអភិភូថា ម្នាលព្រាហ្មណ៍ មក យើងនឹងចូលទៅកាន់ព្រហ្មលោកណាមួយ ទំរាំដល់ពេលភត្ត ។ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុ ទទួលព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ និងអភិភូភិក្ខុ ក៏បាត់អំពីអរុណវតីរាជធានី ទៅប្រាកដក្នុងព្រហ្មលោកនោះ ដូចជាបុរសមានកម្លាំងលាចេញនូវដៃ ដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលំដាប់នោះ ព្រះសិខី មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់នឹងអភិភូភិក្ខុថា

បដិភាតុ ព្រាហ្មណា ព្រហ្មុនោ ច ព្រហ្មបរិសាយ ច ព្រហ្មបារិសជ្ជានញ្ច ធម្មី កថាតិ ។ ឯវំ ភន្តេតិ ខោ ភិក្ខវេ អភិភូ ភិក្ខុ សិខិស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស បដិស្សុត្វា ព្រហ្មានញ្ច ព្រហ្មបរិសញ្ច ព្រហ្មបារិសជ្ជេ ច ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។

[៩៤] តត្រ សុទំ ភិក្ខវេ ព្រហ្មា ច ព្រហ្មបរិសា ច ព្រហ្មបារិសជ្ជា ច ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ កថញ្ហិ នាម សត្ថរិ សម្មុខីភូតេ សាវកោ ធម្មំ ទេសេស្សតីតិ ។ អថខោ ភិក្ខវេ សិខី ភគវា អរហំ សម្មាសម្ពុទ្ធោ អភិភុំ ភិក្ខុំ អាមន្តេសិ ឧជ្ឈាយន្តិ ខោ តេ ព្រាហ្មណា ព្រហ្មា ច ព្រហ្មបរិសា ច ព្រហ្មបារិសជ្ជា ច អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ កថញ្ហិ នាម សត្ថរិ សម្មុខីភូតេ សាវកោ ធម្មំ ទេសេស្សតីតិ តេនហិ ត្វំ ព្រាហ្មណា

ម្នាលព្រាហ្មណ៍ អ្នកចូរសំដែងនូវធម្មីកថា ដល់ព្រហ្មផង ដល់បរិស័ទរបស់ព្រហ្មផង ដល់អ្នកបម្រើរបស់ព្រហ្មផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះអភិភូ ទទួលព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធថា ព្រះករុណាព្រះអង្គ ហើយញុំាងព្រហ្មផង ញុំាងបរិស័ទរបស់ព្រហ្មផង ញុំាងអ្នកបម្រើរបស់ព្រហ្មផង ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។

[៩៥] ម្នាលភិក្ខុទាំងឡាយ បានឮមក ក្នុងរឿងនោះថា ព្រហ្ម និងបរិស័ទរបស់ព្រហ្ម និងអ្នកបម្រើរបស់ព្រហ្ម ពោលទោស តិះដៀល និន្ទាថា អស្ចារ្យណាស់ហ្ន៎ ចំឡែកណាស់ហ្ន៎ ព្រះសាស្តា គង់នៅក្នុងទីចំពោះមុខ មិនសមបីបើសាវ័កហ៊ានសំដែងធម៌សោះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់នឹងអភិភូភិក្ខុថា ម្នាលព្រាហ្មណ៍ ព្រហ្ម និងបរិស័ទរបស់ព្រហ្ម និងអ្នកបម្រើរបស់ព្រហ្មទាំងនោះ ពោលទោសថា អស្ចារ្យណាស់ហ្ន៎ ចំឡែកណាស់ហ្ន៎ ព្រះសាស្តាគង់នៅក្នុងទីចំពោះមុខ មិនសមបីបើសាវ័កហ៊ានសំដែងធម៌សោះ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរ

ភិយ្យោសោ មត្តាយ ព្រហ្មានញ្ច ព្រហ្មបរិសញ្ច ព្រហ្ម-
ចារិសជ្ជេ ច សំវេជេហីតិ ។ ឯវំ ភន្តេតិ ខោ ភិក្ខវេ
អភិភូ ភិក្ខុ សិខិស្ស ភគវតោ អរហតោ សម្មា-
សម្ពុទ្ធស្ស បដិស្សុត្វា ទិស្សមានេនបិ កាយេន ធម្មំ
ទេសេសិ អទិស្សមានេនបិ កាយេន ធម្មំ ទេសេសិ
ទិស្សមានេនបិ ហេដ្ឋិមេន ឧបឌ្ឍកាយេន អទិស្ស-
មានេនបិ ឧបរិមេន ឧបឌ្ឍកាយេន ធម្មំ ទេសេសិ
ទិស្សមានេនបិ ឧបរិមេន ឧបឌ្ឍកាយេន អទិស្សមា-
នេនបិ ហេដ្ឋិមេន ឧបឌ្ឍកាយេន ធម្មំ ទេសេសិ ។

[៩៦] តត្រ សុទំ ភិក្ខវេ ព្រហ្មា ច ព្រហ្ម-
បរិសា ច ព្រហ្មចារិសជ្ជា ច អច្ឆរិយព្ភុតចិត្តជាតា អ-
ហេសុំ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សមណស្ស
មហិទ្ធិកតា មហានុភាវតាតិ ។ អថខោ ភិក្ខវេ

ញ៉ាំងព្រហ្ម និងបរិស័ទរបស់ព្រហ្ម និងអ្នកបម្រើរបស់ព្រហ្ម ឲ្យសង្វេគ ក្រៃលែងជាងប្រមាណចុះ ។ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុ ទទួល ព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធថា ព្រះករុណា ព្រះអង្គ ហើយមានកាយប្រាកដ សំដែងធម៌ខ្លះ មានកាយមិនប្រាកដ សំដែងធម៌ខ្លះ មានកាយពាក់កណ្តាលខាងក្រោមប្រាកដ តែកាយពាក់ កណ្តាលខាងលើមិនប្រាកដ សំដែងធម៌ខ្លះ មានកាយពាក់កណ្តាល ខាងលើប្រាកដ តែកាយពាក់កណ្តាលខាងក្រោមមិនប្រាកដ សំដែង ធម៌ខ្លះ ។

[៩៦] ម្នាលភិក្ខុទាំងឡាយ បានឮមក ក្នុងរឿងនោះថា ព្រហ្ម និងបរិស័ទរបស់ព្រហ្ម និងអ្នកបម្រើរបស់ព្រហ្ម មានសេចក្តីអស្ចារ្យចំឡែក កើតឡើងក្នុងចិត្តថា អស្ចារ្យណាស់ហ្ន៎ ចំឡែកណាស់ហ្ន៎ សមណៈ មានឫទ្ធិច្រើន មានអានុភាពច្រើន ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ

ព្រហ្មសំយុត្តស្ស ព្រហ្មបញ្ចកេ អភិភុស្ស គាថាភាសនំ

អភិភូ ភិក្ខុ សិខី ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច អភិជានាមិ ខ្វាហំ ភន្តេ ភិក្ខុសង្ឃស្ស មជ្ឈេ ឯវរូបឹ វាចំ ភាសិតា បហោមិ ខ្វាហំ អាវុសោ ព្រហ្មលោកេ ឋិតោ សហស្សីលោកធាតុំ សរេន វិញ្ញាបេតុន្តិ ។ ឯតស្ស ព្រាហ្មណ កាលោ ឯតស្ស ព្រាហ្មណ កាលោ យំ ត្វំ ព្រាហ្មណ ព្រហ្មលោកេ ឋិតោ សហស្សីលោកធាតុំ សរេន វិញ្ញាបេយ្យាសីតិ ។ ឯវំ ភន្តេតិ ខោ ភិក្ខវេ អភិភូ ភិក្ខុ សិខិស្ស ភ-គវតោ អរហតោ សម្មាសម្ពុទ្ធស្ស បដិស្សុត្វា ព្រហ្ម-លោកេ ឋិតោ ឥមា គាថាយោ អភាសិ

ព្រហ្មសំយុត្ត ព្រហ្មបញ្ចកៈ អភិភូភិក្ខុពោលគាថា

អភិភូភិក្ខុ បានក្រាបទូលព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់ពោលវាចា មានសភាពយ៉ាងនេះ ក្នុងកណ្ដាលភិក្ខុសង្ឃថា ម្នាលអាវុសោទាំងឡាយ ខ្ញុំឋិតនៅក្នុងព្រហ្មលោក អាចញុំាងលោកធាតុទាំងមួយពាន់ឲ្យដឹងច្បាស់ ដោយសំឡេងបាន ។ ម្នាលព្រាហ្មណ៍ កាលនេះគួរហើយ ម្នាលព្រាហ្មណ៍ កាលនេះគួរហើយ ម្នាលព្រាហ្មណ៍ អ្នកឋិតនៅក្នុងព្រហ្មលោកហើយ គប្បីញុំាងលោកធាតុទាំងមួយពាន់ ឲ្យដឹងច្បាស់ដោយសំឡេងចុះ ។ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុ ទទួលព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធថា ព្រះករុណា ព្រះអង្គ ហើយឋិតនៅក្នុងព្រហ្មលោក បានពោលគាថាទាំងនេះថា

អារព្ភថ និក្កមថ
យុញ្ជថ ពុទ្ធសាសនេ
ធុនាថ មច្ចុនោ សេនំ
នឡាគារំវ កុញ្ជរោ
យោ ឥមស្មឹ ធម្មវិនយេ
អប្បមត្តោ វិហេស្សតិ
បហាយ ជាតិសំសារំ
ទុក្ខស្សន្តំ ករិស្សតីតិ ។

[៩៧] អថខោ ភិក្ខវេ សិខី ច ភគវា អរហំ សម្មាសម្ពុទ្ធោ អភិភូ ច ភិក្ខុ ព្រហ្មានញ្ច ព្រហ្មបរិសញ្ច ព្រហ្មបារិសជ្ជេ ច សំវេជេត្វា សេយ្យថាបិ នាម ។ បេ ។ តស្មឹ ព្រហ្មលោកេ អន្តរហិតា អរុណវតិយា រាជធានិយា បាតុរហេសុំ ។ អថខោ ភិក្ខវេ សិខី ភគវា អរហំ សម្មាសម្ពុទ្ធោ ភិក្ខូ អាមន្តេសិ អស្សុត្ថ នោ តុម្ហេ ភិក្ខវេ អភិភុស្ស ភិក្ខុនោ ព្រហ្មលោកេ ឋិតស្ស គាថាយោ ភាសមានស្សាតិ ។ អស្សុម្ហា ខោ មយំ ភន្តេ អភិភុស្ស ភិក្ខុនោ

អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាម ក្នុងពុទ្ធសាសនា ចូរកម្ចាត់បង់សេនានៃមច្ចុ ដូចជាកុញ្ជរញាំញីផ្ទះបបុស អ្នកណាមិនប្រហែស ក្នុងធម្មវិន័យនេះ អ្នកនោះនឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវទីបំផុតទុក្ខបាន ។

[៩៧] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនិងអភិភូភិក្ខុ ញុំាងព្រហ្ម និងបរិស័ទរបស់ព្រហ្ម និងអ្នកបម្រើរបស់ព្រហ្ម ឲ្យសង្វេគហើយ បាត់អំពីព្រហ្មលោកនោះ មកប្រាកដក្នុងអរុណវតីរាជធានីវិញ ដោយឆាប់រហ័ស ប្រៀបដូចជា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ កាលដែលអភិភូភិក្ខុ ឋិតនៅក្នុងព្រហ្មលោក ពោលនូវគាថាទាំងឡាយ អ្នកទាំងឡាយបានឮដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលអភិភូភិក្ខុ

៧៧

ព្រហ្មសំយុត្តស្ស ព្រហ្មបញ្ចកេ ភិក្ខូនំ អភិភុស្ស គាថាសវនំ

ព្រហ្មលោកេ ឋិតស្ស គាថាយោ ភាសមានស្សាតិ ។ យថាកថំ បន តុម្ហេ ភិក្ខវេ អស្សុត្ថ អភិភុស្ស ភិក្ខុនោ ព្រហ្មលោកេ ឋិតស្ស គាថាយោ ភាសមា-នស្សាតិ ។ ឯវំ ខោ មយំ ភន្តេ អស្សុម្ហា អភិភុស្ស ភិក្ខុនោ ព្រហ្មលោកេ ឋិតស្ស គាថាយោ ភាស-មានស្ស

អារព្ភថ និក្កមថ
យុញ្ជថ ពុទ្ធសាសនេ
ធុនាថ មច្ចុនោ សេនំ
នឡាគារំវ កុញ្ជរោ
យោ ឥមស្មឹ ធម្មវិនយេ
អប្បមត្តោ វិហេស្សតិ
បហាយ ជាតិសំសារំ
ទុក្ខស្សន្តំ ករិស្សតីតិ

ឯវំ ខោ មយំ ភន្តេ អស្សុម្ហា អភិភុស្ស ភិក្ខុនោ ព្រ-ហ្មលោកេ ឋិតស្ស គាថាយោ ភាសមានស្សាតិ ។

ឋិតនៅក្នុងព្រហ្មលោក ពោលគាថាទាំងឡាយ ពួកយើងខ្ញុំព្រះអង្គបានឮដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលអភិភូភិក្ខុឋិតនៅក្នុងព្រហ្មលោក ពោលនូវគាថាទាំងឡាយ អ្នកទាំងឡាយបានឮពាក្យថាដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលអភិភូភិក្ខុឋិតនៅក្នុងព្រហ្មលោក ពោលគាថាទាំងឡាយ ពួកយើងខ្ញុំព្រះអង្គបានឮយ៉ាងនេះថា

អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាម
ក្នុងពុទ្ធសាសនា ចូរកម្ចាត់បង់សេនានៃមច្ចុ ដូចជាកុញ្ជរ
ញាំញីផ្ទះបបុស អ្នកណាមិនប្រហែសក្នុងធម្មវិន័យនេះ អ្នក
នោះនឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវទីបំផុតទុក្ខបាន

បពិត្រព្រះអង្គដ៏ចម្រើន កាលដែលអភិភូភិក្ខុឋិតនៅ ក្នុងព្រហ្មលោក ពោលគាថាទាំងឡាយ ពួកយើងខ្ញុំព្រះអង្គ បានឮយ៉ាងនេះឯង ។

[៩៨] សាធុ សាធុ ភិក្ខវេ សាធុ ខោ តុម្ហេ ភិក្ខវេ អស្សុត្ថ អភិភុស្ស ភិក្ខុនោ ព្រហ្មលោកេ ឋិតស្ស គាថាយោ ភាសមានស្សាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

## បញ្ចមំ បរិនិព្វានសុត្តំ

[៩៩] ឯកំ សមយំ ភគវា កុសិនារាយំ វិហរតិ ឧបវត្តនេ មល្លានំ សាលវនេ អន្តរេន យមកសាលានំ បរិនិព្វានសមយេ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ។ អយំ តថាគតស្ស បច្ឆិមា វាចាតិ ។

[៩៨] ម្នាលភិក្ខុទាំងឡាយ ល្អហើយ ល្អហើយ ម្នាលភិក្ខុទាំងឡាយ ពិតជាប្រពៃហើយ កាលដែលអភិភូភិក្ខុ ឋិតនៅក្នុងព្រហ្មលោក ពោលគាថាទាំងឡាយ អ្នកទាំងឡាយបានឮ ។ ព្រះមានព្រះភាគត្រាស់ព្រះពុទ្ធដីកានេះហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអររីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

# បរិនិព្វានសូត្រ ទី ៥

[៩៩] សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងសាលវ័នរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីបត់ចូលទៅក្នុងក្រុងកុសិនារា ក្នុងសម័យជាទីបរិនិព្វាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក៏ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយថា សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួង ឲ្យសម្រេចដោយសេចក្តីមិនប្រហែសចុះ ។ នេះជាបច្ឆិមវាចា របស់ព្រះតថាគត ។

ព្រហ្មសំយុត្តស្ស ព្រហ្មបញ្ចកេ បឋមជ្ឈានាទិសមាបជ្ជនំ

[១០០] អថខោ ភគវា បឋមជ្ឈានំ សមាបជ្ជិ បឋមជ្ឈានា វុដ្ឋហិត្វា ទុតិយជ្ឈានំ សមាបជ្ជិ ទុតិយជ្ឈានា វុដ្ឋហិត្វា តតិយជ្ឈានំ សមាបជ្ជិ តតិយជ្ឈានា វុដ្ឋហិត្វា ចតុត្ថជ្ឈានំ សមាបជ្ជិ ចតុត្ថជ្ឈានា វុដ្ឋហិត្វា អាកាសានញ្ចាយតនំ សមាបជ្ជិ អាកាសានញ្ចាយតនា វុដ្ឋហិត្វា វិញ្ញាណញ្ចាយតនំ សមាបជ្ជិ វិញ្ញាណញ្ចាយតនា វុដ្ឋហិត្វា អាកិញ្ចញ្ញាយតនំ សមាបជ្ជិ អាកិញ្ចញ្ញាយតនា វុដ្ឋហិត្វា នេវសញ្ញានាសញ្ញាយតនំ សមាបជ្ជិ នេវសញ្ញានាសញ្ញាយតនា វុដ្ឋហិត្វា សញ្ញាវេទយិតនិរោធំ សមាបជ្ជិ សញ្ញាវេទយិតនិរោធា វុដ្ឋហិត្វា នេវសញ្ញានាសញ្ញាយតនំ សមាបជ្ជិ នេវសញ្ញានាសញ្ញាយតនា វុដ្ឋហិត្វា អាកិញ្ចញ្ញាយតនំ សមាបជ្ជិ អាកិញ្ចញ្ញាយតនា វុដ្ឋហិត្វា វិញ្ញាណញ្ចាយតនំ សមាបជ្ជិ វិញ្ញាណញ្ចាយតនា វុដ្ឋហិត្វា អាកាសានញ្ចាយតនំ សមាបជ្ជិ អាកាសានញ្ចាយតនា វុដ្ឋហិត្វា ចតុត្ថជ្ឈានំ សមាបជ្ជិ ចតុត្ថជ្ឈានា វុដ្ឋហិត្វា

[១០០] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចូលបឋមជ្ឈាន ចេញអំពីបឋមជ្ឈាន ចូលទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈាន ចូលតតិយជ្ឈាន ចេញអំពីតតិយជ្ឈាន ចូលចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈាន ចូលអាកាសានញ្ចាយតនជ្ឈាន ចេញអំពីអាកាសានញ្ចាយតនជ្ឈាន ចូលវិញ្ញាណញ្ចាយតនជ្ឈាន ចេញអំពីវិញ្ញាណញ្ចាយតនជ្ឈាន ចូលអាកិញ្ចញ្ញាយតនជ្ឈាន ចេញអំពីអាកិញ្ចញ្ញាយតនជ្ឈាន ចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ចេញអំពីនេវសញ្ញានាសញ្ញាយតនជ្ឈាន ចូលសញ្ញាវេទយិតនិរោធ ចេញអំពីសញ្ញាវេទយិតនិរោធ ត្រឡប់ចូលនេវសញ្ញានាសញ្ញាយតនជ្ឈានវិញ ចេញអំពីនេវសញ្ញានាសញ្ញាយតនជ្ឈាន ចូលអាកិញ្ចញ្ញាយតន-ជ្ឈាន ចេញអំពីអាកិញ្ចញ្ញាយតនជ្ឈាន ចូលវិញ្ញាណញ្ចាយតនជ្ឈាន ចេញអំពីវិញ្ញាណញ្ចាយតនជ្ឈាន ចូលអាកាសានញ្ចាយតនជ្ឈាន ចេញអំពីអាកាសានញ្ចាយតនជ្ឈាន ចូលចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈាន

តតិយជ្ឈានំ សមាបជ្ជិ តតិយជ្ឈានា វុដ្ឋហិត្វា ទុតិយជ្ឈានំ សមាបជ្ជិ ទុតិយជ្ឈានា វុដ្ឋហិត្វា បឋមជ្ឈានំ សមាបជ្ជិ បឋមជ្ឈានា វុដ្ឋហិត្វា ទុតិយជ្ឈានំ សមាបជ្ជិ ទុតិយជ្ឈានា វុដ្ឋហិត្វា តតិយជ្ឈានំ សមាបជ្ជិ តតិយជ្ឈានា វុដ្ឋហិត្វា ចតុត្ថជ្ឈានំ សមាបជ្ជិ ចតុត្ថជ្ឈានា វុដ្ឋហិត្វា សមនន្តរំ ភគវា បរិនិព្វាយិ ។

[១០១] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា ព្រហ្មា សហម្បតិ ឥមំ គាថំ អភាសិ

សព្វេវ និក្ខិបិស្សន្តិ
ភូតា លោកេ សមុស្សយំ
យត្ថ ឯតាទិសោ សត្ថា
លោកេ អប្បដិបុគ្គលោ
តថាគតោ ពលប្បត្តោ
សម្ពុទ្ធោ បរិនិព្វុតោតិ ។

[១០២] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា សក្កោ ទេវានមិន្ទោ ឥមំ គាថំ អភាសិ

ចូលតតិយជ្ឈាន ចេញអំពីតតិយជ្ឈាន ចូលទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈាន ចូលបឋមជ្ឈាន ចេញអំពីបឋមជ្ឈាន ចូលទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈាន ចូលតតិយជ្ឈាន ចេញអំពីតតិយជ្ឈាន ចូលចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈាន ព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងបន្ទោះ ។

[១០១] កាលព្រះមានព្រះភាគ បរិនិព្វានហើយ សហម្បតិ-ព្រហ្ម ពោលគាថានេះ ដំណាលគ្នានឹងការបរិនិព្វានថា

ព្រះតថាគត ជាសាស្តា មានគុណប្រាកដដូច្នេះ មិន
មានបុគ្គលប្រៀបផ្ទឹមបានក្នុងលោក ទ្រង់ដល់នូវកម្លាំងនៃ
ញាណ ត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់បរិនិព្វានហើយ
ក្នុងលោកណា ពួកសត្វទាំងអស់ នឹងដាក់ចុះនូវរាងកាយ
ក្នុងលោក (នោះ) មិនខានឡើយ ។

[១០២] កាលព្រះមានព្រះភាគ បរិនិព្វានហើយ សក្កៈជាធំជាងទេវតាទាំងឡាយ ពោលគាថានេះ ដំណាលគ្នានឹងការបរិនិព្វានថា

៨១

ព្រហ្មសំយុត្តស្ស ព្រហ្មបញ្ចកេ អនុរុទ្ធភាសិតំ

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោតិ ។

[១០៣] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា អាយស្មា អានន្ទោ ឥមំ គាថំ អភាសិ

តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេតិ ។

[១០៤] បរិនិព្វុតេ ភគវតិ សហ បរិនិព្វានា អាយស្មា អនុរុទ្ធោ ឥមា គាថាយោ អភាសិ

នាហុ អស្សាសបស្សាសោ
ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ
ចក្ខុមា បរិនិព្វុតោ
អសល្លីនេន ចិត្តេន
វេទនំ អជ្ឈវាសយិ
បជ្ជោតស្សេវ និព្វានំ
វិមោក្ខោ ចេតសោ អហូតិ ។

ព្រហ្មបញ្ចកំ ។

សង្ខារទាំងឡាយ មិនទៀងទេហ្ន៎ មានការកើតឡើងនិងការ
សូន្យទៅវិញជាធម្មតា លុះកើតឡើងហើយក៏រលត់ទៅវិញ
ការរម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្ដីសុខ ។

[១០៣] កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអានន្ទមានអាយុ ពោលគាថានេះ ដំណាលគ្នានឹងការបរិនិព្វានថា

កាលដែលព្រះសម្ពុទ្ធ ប្រកបដោយហេតុដ៏ប្រសើរគ្រប់យ៉ាង
ទ្រង់បរិនិព្វានហើយ សេចក្ដីខ្លាចនោះ សេចក្ដីព្រឺពោមនោះ
ក៏តែងកើតមានប្រាកដ ។

[១០៤] កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអនុរុទ្ធមានអាយុ ក៏ពោលគាថាទាំងនេះ ដំណាលគ្នានឹងការបរិនិព្វានថា

ខ្យល់អស្សាសៈនិងបស្សាសៈ របស់ព្រះសម្ពុទ្ធ ដែលមាន
ព្រះហឫទ័យខ្ជាប់ខ្ជួននឹងធឹង មិនមានទេ ព្រះសម្ពុទ្ធ ទ្រង់
មិនញាប់ញ័រដោយតណ្ហាទេ ទ្រង់ប្រារព្ធសេចក្ដីស្ងប់ គឺអនុ-
បាទិសេសនិព្វាន ទ្រង់មានបញ្ញាចក្ខុ បរិនិព្វានហើយ ទ្រង់
អត់សង្កត់នូវវេទនា ដោយព្រះហឫទ័យមិនបានរួញរា មាន
ព្រះហឫទ័យរួចស្រឡះ ដូចជាប្រទីបរលត់ហើយ ។

ចប់ ព្រហ្មបញ្ចក: ។

## តស្សុទ្ទានំ

ព្រហ្មាសនំ ទេវទត្តោ
អន្ធកវិន្ទោ អរុណវតី
បរិនិព្វានេន ច ទេសិតំ
ឥទំ ព្រហ្មបញ្ចកំ ។

## តត្រ ឧទ្ទានំ

ព្រហ្មាយាចនំ គារវញ្ច
ព្រហ្មទេវោ ពកោ ព្រហ្មា
អញ្ញតរោ ច ព្រហ្មា ច
ព្រហ្មលោកោ កោកាលិកញ្ច
អាទ្យវិកញ្ច តុទុ ច
ព្រហ្មា កោកាលិកភិក្ខុ
សនង្កុមារេ ទេវទត្តំ
អន្ធកវិន្ទំ អរុណវតី
បរិនិព្វានេន បណ្ណរសាតិ
ញានិសា ចាបក្កមា និស្សន្តិ ។

ព្រហ្មសំយុត្តំ សមត្តំ ។

## ឧទ្ទាននៃព្រហ្មបញ្ចកៈនោះ គឺ

*ព្រហ្មាសនសូត្រ ១ ទេវទត្តសូត្រ ១ អន្ធកវិន្ទសូត្រ ១ អរុណវតីសូត្រ ១ និងបរិនិព្វានសូត្រ ១ នេះឈ្មោះថា ព្រហ្មបញ្ចកៈ ដែលព្រះមានព្រះភាគ សំដែងហើយ ។*

## ឧទ្ទានក្នុងព្រហ្មសំយុត្តនោះ គឺ

*ព្រហ្មាយាចនសូត្រ ១ គារវសូត្រ ១ ព្រហ្មទេវសូត្រ ១ ពកព្រហ្មសូត្រ ១ ព្រហ្មដទៃទៀត ក្នុងអបរាទិដ្ឋិសូត្រ ១ រឿងព្រហ្មលោកក្នុងបមាទសូត្រ ១ បឋមកោកាលិកសូត្រ ១ អាទ្បវិកៈ (តិស្សកៈ) សូត្រ ១ តុទុព្រហ្មសូត្រ ១ កោកាលិកភិក្ខុសូត្រ ១ សនង្កុមារសូត្រ ១ ទេវទត្តសូត្រ ១ អន្ធកវិន្ទសូត្រ ១ អរុណវតីសូត្រ ១ បរិនិព្វានសូត្រ ១ ត្រូវជា ១៥ លំដាប់បាលី ដែលមានមក ប្រាកដដូច្នេះឯង ។*

ចប់ ព្រហ្មសំយុត្ត ។

---

១- តាមបាលី ឧទ្ទាន ។

# ព្រាហ្មណសំយុត្តំ

## បឋមោ អរហន្តវគ្គោ

---

## បឋមំ ធនញ្ជានីសុត្តំ

[១០៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស ធនញ្ជានី នាម ព្រាហ្មណី អភិប្បសន្នា ហោតិ ពុទ្ធេ ច ធម្មេ ច សង្ឃេ ច ។

[១០៦] អថខោ ធនញ្ជានី ព្រាហ្មណី ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស ភត្តំ ឧបសំហរន្តី ឧបក្ខលិត្វា[១] តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... នមោ

---

១ ម. ឧបក្ខលិត្វា ។

# ព្រាហ្មណសំយុត្ត

## អរហន្តវគ្គ ទី ១

---

## ធនញ្ជានីសូត្រ ទី ១

[១០៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង នាងព្រាហ្មណីឈ្មោះធនញ្ជានី (ជាភរិយា) នៃព្រាហ្មណ៍ម្នាក់ ជាភារទ្វាជគោត្រ នាងជ្រះថ្លាក្រៃពេក ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

[១០៦] លំដាប់នោះឯង នាងធនញ្ជានីព្រាហ្មណី កំពុងចាត់ចែងភត្ត ដើម្បីព្រាហ្មណ៍ភារទ្វាជគោត្រ ក៏ភ្ញាត់បន្ទឺនូវឧទានបីដងថា សូមថ្វាយបង្គំព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមថ្វាយបង្គំ

តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។ ឯវំ វុត្តេ ភារទ្វាជគោត្តោ ព្រាហ្មណោ ធនញ្ជានឹ ព្រាហ្មណឹ ឯតទវោច ឯវមេវំ បនាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស សមណស្ស វណ្ណំ ភាសតិ ឥទានិ ត្យាហំ វសលិ តស្ស សត្ថុនោ វាទំ អារោបេស្សាមីតិ ។ ន ខ្វាហន្តំ ព្រាហ្មណ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ តស្ស ភគវតោ វាទំ អារោបេយ្យ អរហតោ សម្មាសម្ពុទ្ធស្ស អបិច ត្វំ ព្រាហ្មណ គច្ឆ គន្ត្វាបិ ជានិស្សសីតិ ។

[១០៧] អថខោ ភារទ្វាជគោត្តោ ព្រាហ្មណោ កុបិតោ អនត្តមនោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភារទ្វាជគោត្តោ ព្រាហ្មណោ ភគវន្តំ គាថាយ អជ្ឈភាសិ

ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។ កាលបើនាង ព្រាហ្មណី ពោលយ៉ាងនេះហើយ ព្រាហ្មណ៍ភារទ្វាជគោត្រ និយាយនឹងនាងធនញ្ជានីព្រាហ្មណីយ៉ាងនេះថា មេចង្រៃនេះ ធ្លាប់តែអ៊ីចឹង ៗ ហ៊ាន ពោលសរសើរសមណៈត្រងោល ក្នុងទីផ្តេសផ្តាស នៃមេចង្រៃ អញ នឹងលើកនូវវាទៈ[១] ចំពោះគ្រូរបស់ឯងនោះ ក្នុងកាលឥឡូវនេះ ។ ម្នាលព្រាហ្មណ៍ ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក មនុស្សលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ខ្ញុំមិនដែលឃើញអ្នកណា អាចលើកនូវវាទៈចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះបានទេ ម្នាល ព្រាហ្មណ៍ តែថាអ្នកចូរទៅចុះ លុះទៅហើយ គង់តែនឹងដឹងទេ ។

[១០៧] គ្រានោះឯង ព្រាហ្មណ៍ភារទ្វាជគោត្រ ខឹងអន់ចិត្ត ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យ ដែលគួរឭកហើយ ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ ភារទ្វាជគោត្រ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា

---

អញនឹងលើកនូវវាទៈ បានសេចក្តីថា អញនឹងសួរដេញដោល ។

កឹសុ ឆេត្វា សុខំ សេតិ
កឹសុ ឆេត្វា ន សោចតិ
កិស្សស្ស ឯកធម្មស្ស
វធំ រោចេសិ គោតមាតិ ។

[១០៨] កោធំ ឆេត្វា សុខំ សេតិ
កោធំ ឆេត្វា ន សោចតិ
កោធស្ស វិសមូលស្ស
មធុរគ្គស្ស ព្រាហ្មណ
វធំ អរិយា បសំសន្តិ
តញ្ហិ ឆេត្វា ន សោចតីតិ ។

[១០៩] ឯវំ វុត្តេ ភារទ្វាជគោត្តោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិ-ច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ

បុគ្គលកាត់បង់នូវអ្វី ទើបដេកជាសុខ បុគ្គលកាត់បង់នូវអ្វី ទើបមិនសោកសៅ បពិត្រព្រះគោតម ព្រះអង្គពេញព្រះហឫទ័យនឹងសម្លាប់ធម៌ណា ដែលជាធម៌ឯក ។

[១០៨] ព្រះមានព្រះភាគត្រាស់ថា បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបដេកជាសុខ បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបមិនសោកសៅ ម្នាលព្រាហ្មណ៍ ពួកព្រះអរិយៈ តែងសរសើរនូវការសម្លាប់សេចក្តីក្រោធ ដែលមានឫសជាពិស មានចុងដ៏ផ្អែម ព្រោះថា បុគ្គលកាត់បង់នូវសេចក្តីក្រោធនោះបានហើយ ទើបមិនសោកសៅ ។

[១០៩] កាលដែលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍ភារទ្វាជគោត្រ បានទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាបុគ្គលផ្ងារ នូវរបស់ដែលផ្កាប់ បើកបង្ហាញ នូវរបស់ដែលកំបាំង ឬចង្អុលបង្ហាញផ្លូវដល់មនុស្សវង្វេង

វា តេលប្បជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ ភារទ្វាជគោត្តោ ព្រាហ្មណោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា ភារទ្វាជោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

ឬក៏ទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុ នឹងឃើញរូបទាំងឡាយបាន ធម៌ដែលព្រះគោតមដ៏ចម្រើនប្រកាសហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទា ក្នុងសំណាក់ព្រះគោតមដ៏ចម្រើន ។ ព្រាហ្មណ៍ភារទ្វាជគោត្រ ក៏បានបព្វជ្ជា និងឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ។ លុះភារទ្វាជៈមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា (ព្រះភារទ្វាជៈនោះ) ក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ហើយដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុក៏ជាព្រះអរហន្តមួយអង្គដែរ ។

៨៧



# ទុតិយំ  អក្កោសកសុត្តំ

[១១០] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អស្សោសិ ខោ អក្កោសកភារទ្វាជោ ព្រាហ្មណោ ភារទ្វាជគោត្តោ កិរ ព្រាហ្មណោ សមណស្ស គោតមស្ស សន្តិកេ អាគារស្មា អនគារិយំ បព្វជិតោតិ កុបិតោ អនត្តមនោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសតិ បរិភាសតិ ។

[១១១] ឯវំ វុត្តេ ភគវា អក្កោសកភារទ្វាជំ ព្រាហ្មណំ ឯតទវោច តំ កិំ មញ្ញសិ ព្រាហ្មណ អបិ នុ តេ អាគច្ឆន្តិ មិត្តាមច្ចា ញាតិសាលោហិតា អតិថិយោតិ ។ អប្បេកទា មេ ភោ គោតម អាគច្ឆន្តិ មិត្តាមច្ចា ញាតិសាលោហិតា អតិថិយោតិ ។ តំ កិំ មញ្ញសិ ព្រាហ្មណ អបិ នុ តេសំ អនុប្បទេសិ ខាទនីយំ វា ភោជនីយំ វា សាយនីយំ វាតិ ។ អប្បេកទា នេសាហំ ភោ គោតម អនុប្បទេមិ ខាទនីយំ វា ភោជនីយំ វា សាយនីយំ វាតិ ។

# អក្កោសកសូត្រ ទី ២

[១១០] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្ត វេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ព្រាហ្មណ៍ឈ្មោះ អក្កោសកភារទ្វាជៈ បានឮដំណឹងថា ព្រាហ្មណ៍ភារទ្វាជគោត្រ ចេញ ចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងសំណាក់ព្រះសមណគោតម ក៏ខឹង អន់ចិត្ត ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ជេរគម្រាមព្រះ មានព្រះភាគ ដោយវាចាជាអសប្បុរស អាក្រក់ ។*

[១១១] *កាលបើអក្កោសកភារទ្វាជៈ ពោលយ៉ាងនេះហើយ ព្រះ មានព្រះភាគ បានត្រាស់នឹងអក្កោសកភារទ្វាជព្រាហ្មណ៍ យ៉ាងនេះថា ម្នាលព្រាហ្មណ៍ អ្នកសម្គាល់ហេតុនោះដូចម្ដេច ពួកមិត្រអាមាត្យញាតិ សាលោហិត ជាភ្ញៀវ ធ្លាប់មករកអ្នកដែរឬ ។ បពិត្រព្រះគោតម ដ៏ចម្រើន ចួនកាលពួកមិត្តអាមាត្យ ញាតិសាលោហិត ជាភ្ញៀវ ធ្លាប់មក រកខ្ញុំម្ដង ៗ ដែរ ។ ម្នាលព្រាហ្មណ៍ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អ្នកបានរៀបខាទនីយភោជនីយាហារនិងសាយនីយាហារ ទទួលពួកភ្ញៀវ ទាំងនោះ ដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ចួនកាលខ្ញុំបានរៀបខាទ-នីយភោជនីយាហារនិងសាយនីយាហារ ទទួលពួកភ្ញៀវទាំងនោះដែរ ។*

សចេ បន តេ ព្រាហ្មណ នប្បដិគ្គណ្ហន្តិ កស្ស តំ ហោតីតិ ។ សចេ តេ ភោ គោតម នប្បដិគ្គណ្ហន្តិ អម្ហាកមេវ តំ ហោតីតិ ។ ឯវមេវ ខោ ព្រាហ្មណ យំ ត្វំ អម្ហេ អនក្កោសន្តេ អក្កោសសិ អរោសេន្តេ រោសេសិ អភណ្ឌន្តេ ភណ្ឌសិ តំ តេ មយំ នប្បដិគ្គណ្ហាម តវេវេតំ ព្រាហ្មណ ហោតិ តវេវេតំ ព្រាហ្មណ ហោតីតិ ។ យោ ខោ ព្រាហ្មណ អក្កោសន្តំ បច្ចក្កោសតិ រោសេន្តំ បដិរោសេតិ ភណ្ឌន្តំ បដិភណ្ឌតិ អយំ វុច្ចតិ ព្រាហ្មណ សម្ភុញ្ជតិ វីតិហរតិ[១] តេ មយំ តយា នេវ សម្ភុញ្ជាម ន វីតិហរាម តវេវេតំ ព្រាហ្មណ ហោតិ តវេវេតំ ព្រាហ្មណ ហោតីតិ ។ ភវន្តំ ខោ គោតមំ សរាជិកា បរិសា ឯវំ ជានាតិ អរហំ សមណោ គោតមោតិ អថ ច បន ភវំ គោតមោ កុជ្ឈតីតិ ។

---

១ ម. វីតិហរតីតិ ។

ម្នាលព្រាហ្មណ៍ ប្រសិនបើពួកភ្ញៀវទាំងនោះ មិនទទួលយកទេ តើវត្ថុនោះបានទៅអ្នកណាវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើពួកភ្ញៀវទាំងនោះ មិនទទួលយកទេ វត្ថុនោះត្រូវបានមកខ្ញុំវិញ ។ ម្នាលព្រាហ្មណ៍ ការជេរនុ៎ះ ក៏យ៉ាងនោះដែរ អ្នកឯងជេរតថាគត ដែលជាអ្នកមិនជេរ ខឹងនឹងតថាគត ដែលជាអ្នកមិនខឹង ប្រកួតប្រកាន់នឹងតថាគត ដែលជាអ្នកមិនប្រកួតប្រកាន់ តថាគត មិនទទួលការប្រទូស្តរបស់អ្នកនោះទេ ម្នាលព្រាហ្មណ៍ ការជេរនុ៎ះ ត្រូវបានទៅអ្នកវិញ ម្នាលព្រាហ្មណ៍ ការជេរនុ៎ះ ត្រូវបានទៅអ្នកវិញ ។ ម្នាលព្រាហ្មណ៍ អ្នកណាជេរតបបុគ្គលដែលជេរ ខឹងតបបុគ្គលដែលខឹង ប្រកួតប្រកាន់តបបុគ្គលដែលប្រកួតប្រកាន់ ម្នាលព្រាហ្មណ៍ បុគ្គលនេះ តថាគតឲ្យឈ្មោះថា ស៊ីជាមួយគ្នា ធ្វើតបបុគ្គលដែលធ្វើហើយ តថាគតនោះ មិនបរិភោគជាមួយនឹងអ្នកទេ មិនធ្វើតបអ្នកវិញទេ ម្នាលព្រាហ្មណ៍ ការជេរនុ៎ះ ត្រូវបានទៅអ្នកវិញ ម្នាលព្រាហ្មណ៍ ការជេរនុ៎ះ ត្រូវបានទៅអ្នកវិញ ។ ព្រាហ្មណ៍ពោលថា បរិស័ទព្រមទាំងស្តេច ស្គាល់ព្រះគោតមដ៏ចម្រើនយ៉ាងនេះថា ព្រះសមណគោតម ជាព្រះអរហន្តមែន តែព្រះគោតមដ៏ចម្រើននៅតែខឹង ។

៨៩

ព្រាហ្មណសំយុត្តស្ស អរហន្តវគ្គេ ភគវតោ ភាសិតំ

[១១២] អក្កោធស្ស កុតោ កោធោ
ទន្តស្ស សមជីវិនោ
សម្មទញ្ញា វិមុត្តស្ស
ឧបសន្តស្ស តាទិនោ
តស្សេវ តេន បាបិយោ
យោ កុទ្ធំ បដិកុជ្ឈតិ
កុទ្ធំ អប្បដិកុជ្ឈន្តោ
សង្គាមំ ជេតិ ទុជ្ជយំ
ឧភិន្នមត្ថំ ចរតិ
អត្តនោ ច បរស្ស ច
បរំ សង្កុបិតំ ញត្វា
យោ សតោ ឧបសម្មតិ
ឧភិន្នំ តិកិច្ឆន្តានំ
អត្តនោ ច បរស្ស ច
ជនា មញ្ញន្តិ ពាលោតិ
យេ ធម្មស្ស អកោវិទាតិ ។

[១១២] ព្រះមានព្រះភាគត្រាស់ថា បុគ្គលមិនក្រោធ មានខ្លួនទូន្មានហើយ រស់នៅសមរម្យ មានចិត្តរួចស្រឡះ ព្រោះយល់ត្រូវ អ្នកស្ងប់រម្ងាប់កិលេស មិនញាប់ញ័រដោយលោកធម៌ តើមានក្រោធពីណាមក ព្រោះថាអ្នកណាក្រោធតបបុគ្គលដែលក្រោធហើយ អ្នកនោះឯង នឹងមានសេចក្តីអាក្រក់ ព្រោះសេចក្តីក្រោធនោះឯង ឯបុគ្គលមិនក្រោធតបនឹងអ្នកដែលក្រោធ រមែងឈ្នះសង្គ្រាមដែលគេឈ្នះបានដោយក្រ អ្នកណាដឹងថា អ្នកដទៃក្រោធនឹងខ្លួន ជាអ្នកមានស្មារតីរម្ងាប់សេចក្តីក្រោធបាន អ្នកនោះឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍ដល់ជនទាំងពីរនាក់ គឺខ្លួននិងអ្នកដទៃ បណ្តាជនទាំង ២ នាក់ គឺខ្លួននិងអ្នកដទៃ ដែលជាអ្នករក្សាសេចក្តីសុខ ជនទាំងឡាយណាមិនឈ្លាសក្នុងធម៌ ជនទាំងឡាយនោះ រមែងសម្គាល់អ្នកនោះ ថាជាមនុស្សពាល ។

[១១៣] ឯវំ វុត្តេ អក្កោសកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ អក្កោសកភារទ្វាជោ ព្រាហ្មណោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា អក្កោសកភារទ្វាជោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

[១១៣] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អក្កោសកភារទ្វាជព្រាហ្មណ៍ បានទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។ បេ ។ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់ព្រះគោតមដ៏ចម្រើន ។ អក្កោសក-ភារទ្វាជព្រាហ្មណ៍ បានបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគហើយ ។ លុះអក្កោសកភារទ្វាជៈមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា លោកក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេច ដោយប្រាជ្ញាដ៏ឧត្តមនៃខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ហើយដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើហើយ មគ្គភាវនាកិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

# តតិយំ អសុរិន្ទកសុត្តំ

[១១៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អស្សោសិ ខោ អសុរិន្ទកភារទ្វាជោ ព្រាហ្មណោ ភារទ្វាជគោត្តោ កិរ ព្រាហ្មណោ សមណស្ស គោតមស្ស សន្តិកេ អគារស្មា អនគារិយំ បព្វជិតោតិ កុបិតោ អនត្តមនោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសតិ បរិភាសតិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ អថខោ អសុរិន្ទកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច ជិតោសិ សមណ ជិតោសិ សមណាតិ ។

# អសុរិន្ទកសូត្រ ទី ៣

[១១៤] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត វេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ អសុរិន្ទកភារទ្វាជ-ព្រាហ្មណ៍ បានឮដំណឹងថា ព្រាហ្មណ៍ភារទ្វាជគោត្រ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ក្នុងសំណាក់ព្រះសមណគោតមហើយ ក៏ក្រោធខឹង អន់ចិត្ត ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ជេរ គម្រាមព្រះមានព្រះភាគ ដោយវាចាជាអសប្បុរសដ៏អាក្រក់ ។ កាល បើអសុរិន្ទកព្រាហ្មណ៍ជេរ យ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏នៅតែ ស្ងៀម ។ លំដាប់នោះឯង អសុរិន្ទកភារទ្វាជព្រាហ្មណ៍ បានពោល នឹងព្រះមានព្រះភាគ យ៉ាងនេះថា នែសមណៈ យើងឈ្នះអ្នកឯង ហើយ នែសមណៈ យើងឈ្នះអ្នកឯងហើយ ។*

[១១៨] ជយំ វេ មញ្ញតិ ពាលោ
វាចាយ ផរុសំ ភណំ
ជយញ្ចេវស្ស តំ ហោតិ
យា តីតិក្ខា វិជានតោ
តស្សេវ តេន បាបិយោ
យោ កុទ្ធំ បដិកុជ្ឈតិ
កុទ្ធំ អប្បដិកុជ្ឈន្តោ
សង្គាមំ ជេតិ ទុជ្ជយំ
ឧភិន្នមត្ថំ ចរតិ
អត្តនោ ច បរស្ស ច
បរំ សង្កុបិតំ ញត្វា
យោ សតោ ឧបសម្មតិ
ឧភិន្នំ តិកិច្ឆន្តានំ
អត្តនោ ច បរស្ស ច
ជនា មញ្ញន្តិ ពាលោតិ
យេ ធម្មស្ស អកោវិទាតិ ។

[១១៥] ព្រះមានព្រះភាគត្រាស់ថា បុគ្គលពាលពោលនូវផរុសវាចា តែងសម្គាល់ថាជ័យជំនះ តែថាសេចក្តីអត់ធន់ជាជ័យជំនះ របស់អ្នកប្រាជ្ញនោះ អ្នកណាក្រោធតបនឹងបុគ្គលអ្នកក្រោធ អ្នកនោះឯង រមែងមានសេចក្តីអាក្រក់ ព្រោះសេចក្តីក្រោធនោះ បុគ្គលមិនក្រោធតបនឹងបុគ្គលអ្នកក្រោធឈ្មោះថា ឈ្នះសង្គ្រាម ដែលគេឈ្នះបានដោយកម្រ អ្នកណាដឹងថា អ្នកដទៃក្រោធនឹងខ្លួន ហើយមានស្មារតីរម្ងាប់សេចក្តីក្រោធបាន អ្នកនោះឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍ដល់ជនទាំង ២ នាក់ គឺខ្លួននិងអ្នកដទៃ បណ្តាជនទាំង ២ នាក់ គឺខ្លួននិងអ្នកដទៃ ដែលជាអ្នករក្សាសេចក្តីសុខ ជនទាំងឡាយ ដែលមិនឈ្លាសក្នុងធម៌ រមែងសម្គាល់អ្នកដែលអត់ធន់នោះ ថាជាមនុស្សពាល ។

[១១៦] ឯវំ វុត្តេ អសុរិន្ទកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

## ចតុត្ថំ ពិលង្គិកសុត្តំ

[១១៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អស្សោសិ ខោ ពិលង្គិកភារទ្វាជោ ព្រាហ្មណោ ភារទ្វាជគោត្តោ កិរ ព្រាហ្មណោ សមណស្ស គោតមស្ស សន្តិកេ អគារស្មា អនគារិយំ បព្វជិតោតិ កុបិតោ អនត្តមនោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា តុណ្ហីភូតោ ឯកមន្តំ អដ្ឋាសិ ។

[១១៨] អថខោ ភគវា ពិលង្គិកភារទ្វាជស្ស ព្រាហ្មណស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ ពិលង្គិកភារទ្វាជំ ព្រាហ្មណំ គាថាយ អជ្ឈភាសិ

[១១៦] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អសុរិន្ទកភារទ្វាជព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។ បេ ។ បានដឹងច្បាស់ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

# ពិលង្គិកសូត្រ ទី ៤

[១១៧] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ពិលង្គិកភារទ្វាជ-ព្រាហ្មណ៍ បានឮដំណឹងថា ព្រាហ្មណ៍ភារទ្វាជគោត្រ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងសំណាក់ព្រះសមណគោតម ក៏ក្រោធខឹង អន់ចិត្តចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរស្ងៀមក្នុងទីដ៏សមគួរ ។

[១១៨] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះ ក្នុងចិត្តនៃពិលង្គិកភារទ្វាជព្រាហ្មណ៍ ដោយព្រះហឫទ័យហើយ ទ្រង់ត្រាស់នឹងពិលង្គិកភារទ្វាជព្រាហ្មណ៍ ដោយគាថា ថា

យោ  អប្បទុដ្ឋស្ស  នរស្ស  ទុស្សតិ
សុទ្ធស្ស  បោសស្ស  អនង្គណស្ស
តមេវ  ពាលំ  បច្ចេតិ  បាបំ
សុខុមោ  រជោ  បដិវាតំវ  ខិត្តោតិ  ។

[១១៩] ឯវំ វុត្តេ ពិលង្គិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ ។ បេ ។ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

បុគ្គលពាលណា ប្រទូស្ត ចំពោះជន ដែលមិនបានប្រទូស្ត
ជាសត្វដ៏ស្អាត មិនមានទីទួលគឺកិលេស បាបរមែងត្រឡប់
មកត្រូវបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិត ដែលគេ
បាចប្រាសខ្យល់ ។

[១១៩] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ពិលង្គិកភារទ្វាជព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។ បេ ។ ខ្ញុំព្រះអង្គនេះ សូមដល់ព្រះគោតមដ៏ចម្រើន ផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ខ្ញុំព្រះអង្គសូមបាន នូវបព្វជ្ជា ក្នុងសំណាក់ព្រះគោតមដ៏ចម្រើន ។ បេ ។ បានធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយប្រាជ្ញាដ៏ឧត្តមនៃខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ហើយដឹងច្បាស់ថា ជាតិអស់ហើយ មគ្គ-ព្រហ្មចរិយៈបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើហើយ មគ្គ-ភាវនាកិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះ អរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

# បញ្ចមំ អហឹសកសុត្តំ

[១៦០] សាវត្ថីនិទានំ ។ អថខោ អហឹសកភារទ្វាជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អហឹសកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អហឹសកាហំ ភោ គោតម អហឹសកាហំ ភោ គោតមាតិ ។

[១៦១] យថា នាមំ តថា ចស្ស
សិយា ខោ ត្វំ អហឹសកោ
យោ ច កាយេន វាចាយ
មនសា ច ន ហឹសតិ
សចេ អហឹសកោ ហោតិ
យោ បរំ ន វិហឹសតីតិ ។

# អហឹសកសូត្រ ទី ៥

[១២០] *សាវត្ថីនិទាន ។ លំដាប់នោះឯង អហឹសកភារទ្វាជព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះអហឹសកភារទ្វាជព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បាន ពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះអហឹសកៈ បពិត្រគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះ អហឹសកៈ ។*

[១២១] *ព្រះអង្គត្រាស់ថា ប្រសិនបើឈ្មោះអ្នកឯង ពិត*
*ដូច្នោះមែន អ្នកឯងគួរជាអ្នកមិនបៀតបៀន ព្រោះថាបុគ្គល*
*ណា មិនបៀតបៀនដោយកាយវាចាចិត្ត បុគ្គលនោះទើប*
*ឈ្មោះថាអហឹសកៈ មួយទៀត បើបុគ្គលណា មិនសម្លាប់*
*សត្វដទៃ បុគ្គលនោះ ឈ្មោះថា អហឹសកៈ ។*

[១៦២] ឯវំ វុត្តេ អហឹសកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

## ឆដ្ឋំ ជដាសុត្តំ

[១៦៣] សាវត្ថីនិទានំ ។ អថខោ ជដាភារទ្វាជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណី-យំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[១៦៤] ឯកមន្តំ និសិន្នោ ខោ ជដាភារទ្វាជោ ព្រាហ្មណោ ភគវន្តំ គាថាយ អជ្ឈភាសិ

អន្តោ ជដា ពហិ ជដា
ជដាយ ជដិតា បជា
តំ តំ គោតម បុច្ឆាមិ
កោ ឥមំ វិជដយេ ជដន្តិ ។

[១២២] *កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អហឹសកភារទ្វាជព្រាហ្មណ៍ បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។ បេ ។ បានដឹងច្បាស់ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។*

# ជដាសូត្រ ទី ៦

[១២៣] *សាវត្ថីនិទាន ។ គ្រានោះឯង ជដាភារទ្វាជព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។*

[១២៤] *លុះជដាភារទ្វាជព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា*

*បណ្តាញខាងក្នុងក៏មាន បណ្តាញខាងក្រៅក៏មាន ពួកសត្វ*
*តែងជំពាក់ ដោយបណ្តាញ បពិត្រព្រះគោតម ព្រោះ*
*ហេតុនោះ ខ្ញុំព្រះអង្គសូមសួរនូវសេចក្តីនោះ តើអ្នកណា*
*អាចកាប់ឆ្ការនូវបណ្តាញនេះបាន ។*

[១២៥] សីលេ បតិដ្ឋាយ នរោ សបញ្ញោ
ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ
សោ ឥមំ វិជដយេ ជដំ
យេសំ រាគោ ច ទោសោ ច
អវិជ្ជា ច វិរាជិតា
ខីណាសវា អរហន្តោ
តេសំ វិជដិតា ជដា
យត្ថ នាមញ្ច រូបញ្ច
អសេសំ ឧបរុជ្ឈតិ
បដិឃំ រូបសញ្ញា ច
ឯត្ថេសា ឆិជ្ជតេ ជដាតិ ។

[១២៦] ឯវំ វុត្តេ ជដាភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

ព្រាហ្មណសំយុត្ត អរហន្តវគ្គ សេចក្ដីសរសើរព្រះមានព្រះភាគ

[១២៥] ព្រះអង្គត្រាស់ថា នរជនឃើញភ័យ ក្នុងសង្សារវដ្ត ប្រកបដោយបញ្ញា មានព្យាយាម មានបញ្ញាជាគ្រឿងរក្សាខ្លួន តាំងនៅក្នុងសីល ហើយចម្រើននូវចិត្តនិងបញ្ញា នរជននោះ ទើបគួរកាប់ឆ្ការនូវបណ្ដាញនេះបាន រាគៈក្ដី ទោសៈក្ដី អវិជ្ជាក្ដី ដែលជនទាំងឡាយណា ឲ្យសាបរលាបទៅហើយ ជនទាំងនោះ មានអាសវៈអស់ហើយ ជាព្រះអរហន្ត ជនទាំងនោះ ឈ្មោះថាបានកាប់ឆ្ការនូវបណ្ដាញបាន នាមក្ដី រូបក្ដី បដិឃសញ្ញានិងរូបសញ្ញាក្ដី រលត់មិនសល់ក្នុងទីណា បណ្ដាញនុ៎ះ ក៏ដាច់សូន្យក្នុងទីនោះ ។

[១២៦] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ជដាភារទ្វាជព្រាហ្មណ៍ បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។ បេ ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

# សត្តមំ សុទ្ធិកសុត្តំ

[១២៧] សាវត្ថីនិទានំ ។ អថខោ សុទ្ធិកភារទ្វាជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[១២៨] ឯកមន្តំ និសិន្នោ ខោ សុទ្ធិកភារទ្វាជោ ព្រាហ្មណោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ន ព្រាហ្មណោ សុជ្ឈតិ កោចិ លោកោ
សីលវាបិ តបោ ករំ
វិជ្ជាចរណសម្បន្នោ សោ សុជ្ឈតិ
ន អញ្ញា ឥតរា បជាតិ ។

[១២៩] ពហុម្បិ បលបំ ជប្បំ
ន ជច្ចា ហោតិ ព្រាហ្មណោ
អន្តោ កសម្ពុសង្កិលិដ្ឋោ
កុហនា ឧបនិស្សិតោ

# សុទ្ធិកសូត្រ ទី ៧

[១២៧] សាវត្ថីនិទាន ។ គ្រានោះឯង សុទ្ធិកភារទ្វាជព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[១២៨] លុះសុទ្ធិកភារទ្វាជព្រាហ្មណ៍ អង្គុយទីដ៏សមគួរហើយ បានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា

បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ពុំទាន់បរិសុទ្ធនៅឡើយទេ លុះតែបុគ្គលណាមួយ ក្នុងលោក ដែលមានសីល ធ្វើនូវតបៈ ប្រកបដោយវិជ្ជានិងចរណៈ បុគ្គលនោះ ទើបឈ្មោះថា បរិសុទ្ធ ពួកសត្វឯទៀត ក្រៅពីនេះ រមែងមិនបរិសុទ្ធឡើយ ។

[១២៩] ព្រះអង្គត្រាស់ថា បុគ្គលកាលពោលនូវពាក្យច្រើន តែជាអ្នកជ្រោកជ្រាកសៅហ្មង ខាងក្នុង អាស្រ័យដោយការកុហក ក៏មិនឈ្មោះថា ព្រាហ្មណ៍ ព្រោះជាតិឡើយ

ខត្តិយោ ព្រាហ្មណោ វេស្សោ
សុទ្ទោ ចណ្ឌាលបុក្កុសោ
អារទ្ធវីរិយោ បហិតត្តោ
និច្ចំ ទឡ្ហបរក្កមោ
បប្បោតិ បរមំ សុទ្ធឹ
ឯវំ ជានាហិ ព្រាហ្មណាតិ ។

[១៣០] ឯវំ វុត្តេ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

# អដ្ឋមំ អគ្គិកសុត្តំ

[១៣១] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អគ្គិកភារទ្វាជស្ស ព្រាហ្មណស្ស សប្បិនា បាយាសោ សន្និហិតោ ហោតិ អគ្គឹ ជុហិស្សាមិ អគ្គិហុត្តំ បរិច-រិស្សាមីតិ ។

ក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាល អ្នកចោលសំរាម ដែលមានព្យាយាម ប្រារព្ធហើយ មានចិត្តបញ្ជូនទៅ កាន់ព្រះនិព្វាន មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច រមែងដល់នូវសេចក្តីបរិសុទ្ធដ៏ក្រៃលែងបាន ម្នាលព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ។

[១៣០] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សុទ្ធិកភារទ្វាជព្រាហ្មណ៍ បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

## អគ្គិកសូត្រ ទី ៨

[១៣១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង អគ្គិកភារទ្វាជព្រាហ្មណ៍ លាយនូវបាយាសដោយសប្បិ ដោយបំណងថា អាត្មាអញនឹងបូជាភ្លើង នឹងបម្រើនូវការបូជាភ្លើង ។

[១៣២] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ ចាវិសិ រាជគហេ សបទានំ បិណ្ឌាយ ចរមានោ យេន អគ្គិកភារទ្វាជស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។

[១៣៣] អទ្ទសា ខោ អគ្គិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ បិណ្ឌាយ ឋិតំ[1] ទិស្វាន ភគវន្តំ គាថាយ អជ្ឈភាសិ

តីហិ វិជ្ជាហិ សម្បន្នោ
ជាតិមា សុតវា ពហូ
វិជ្ជាចរណសម្បន្នោ
សោមំ កុញ្ជេយ្យ ចាយសន្តិ[2] ។

[១៣៤] ពហុម្បិ បលបំ ជប្បំ
ន ជច្ចា ហោតិ ព្រាហ្មណោ
អន្តោ កសម្ពុសង្ក្លិដ្ឋោ
កុហនា បរិវារិតោ

---

១ ឱ. ម. បិណ្ឌាយ ចរន្តំ ។ ២ ឱ. ម. បាយាសន្តិ ។

[១៣២] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ កាលត្រាច់បិណ្ឌបាតតាមលំដាប់ផ្ទះ ក្នុងក្រុងរាជគ្រឹះហើយ ក៏ចូលទៅកាន់ផ្ទះរបស់អគ្គិកភារទ្វាជព្រាហ្មណ៍ លុះចូលទៅដល់ហើយ ទ្រង់ឈរនៅក្នុងទីដ៏សមគួរ ។

[១៣៣] អគ្គិកភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគកំពុងទ្រង់ឈរ ដើម្បីបិណ្ឌបាត លុះឃើញហើយ បានពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា

អ្នកណាបរិបូណ៌ដោយវិជ្ជា ៣ មានជាតិ (ដ៏បរិសុទ្ធ) ជាអ្នកចេះចាំគម្ពីរច្រើន ជាអ្នកបរិបូណ៌ដោយវិជ្ជាចរណៈ អ្នកនោះទើបគួរបរិភោគ នូវបាយាសនេះបាន ។

[១៣៤] ព្រះអង្គត្រាស់ថា បុគ្គលកាលពោលនូវពាក្យច្រើន តែជាអ្នកជ្រោកជ្រាកសៅហ្មង ខាងក្នុង ត្រូវសេចក្តីកុហករួបរឹតហើយ មិនឈ្មោះថាព្រាហ្មណ៍ ព្រោះជាតិឡើយ

១០១



បុព្វេនិវាសំ យោ វេទិ
សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ
អភិញ្ញា វោសិតោ មុនិ
ឯតាហិ តីហិ វិជ្ជាហិ
តេវិជ្ជោ ហោតិ ព្រាហ្មណោ
វិជ្ជាចរណសម្បន្នោ
សោហំ កុញ្ជេយ្យ ចាយសន្តិ ។

កុញ្ចតុ ភវំ គោតមោ ព្រាហ្មណោ ភវន្តិ ។

[១៣៥] គាថាភិគីតំ មេ អភោជនេយ្យំ
សម្បស្សតំ ព្រាហ្មណ នេស ធម្មោ
គាថាភិគីតំ បនុទន្តិ ពុទ្ធា
ធម្មេ សតិ ព្រាហ្មណ វុត្តិ រេសា
អញ្ញេន ច កេវលិនំ មហេសឹ
ខីណាសវំ កុក្កុច្ចវូបសន្តំ
អន្នេន បានេន ឧបដ្ឋហស្សុ
ខេត្តញ្ហិ តំ បុញ្ញបេក្ខស្ស ហោតីតិ ។

អ្នកណាដឹងនូវខន្ធសន្តាន ដែលសត្វធ្លាប់អាស្រ័យនៅពីមុន ឃើញនូវសួគ៌និងអបាយ មួយទៀត ជាអ្នកដល់នូវការអស់ទៅនៃជាតិ ជាអ្នកប្រាជ្ញ ដល់នូវការសម្រេចព្រោះត្រាស់ដឹង បានឈ្មោះថា តេវិជ្ជបុគ្គល ព្រោះវិជ្ជាទាំងបីនុ៎ះ ទាំងបរិបូណ៌ ដោយវិជ្ជាចរណៈ ទើបឈ្មោះថា ព្រាហ្មណ៍ ព្រាហ្មណ៍នោះ គួរបរិភោគបាយាសនេះបាន ។

ព្រាហ្មណ៍ ក្រាបទូលថា សូមព្រះគោតមដ៏ចម្រើន ជាព្រាហ្មណ៍ដ៏ចម្រើន បរិភោគចុះ ។

[១៣៥] ព្រះអង្គត្រាស់ថា តថាគត មិនគួរបរិភោគភោជនដែលបានអំពីការពោលគាថា ដូចជាចម្រៀងទេ ម្នាលព្រាហ្មណ៍ ធម៌នេះ មិនមែនជាធម៌របស់ពួកបុគ្គលអ្នកឃើញធម៌អាច៌ទេ ព្រះពុទ្ធទាំងឡាយ តែងបន្ទោបង់នូវការពោលគាថា ដូចជាចម្រៀង ម្នាលព្រាហ្មណ៍ កាលបើធម៌មានហើយ នេះឯងជាការចិញ្ចឹមជីវិត ចូរអ្នកទំនុកបម្រុងព្រះខីណាស្រព ដែលមានគុណបរិបូណ៌ អ្នកស្វែងរកនូវគុណដ៏ធំ ជាអ្នករម្ងាប់នូវសេចក្តីរពឹស ដោយបាយនិងទឹកដទៃចុះ ព្រោះថា នោះជាខេត្តរបស់បុគ្គលអ្នកប្រាថ្នានូវបុណ្យ ។

[១៣៦] ឯវំ វុត្តេ អគ្គិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

## នវមំ សុន្ទរិកសុត្តំ

[១៣៧] ឯកំ សមយំ ភគវា កោសលេសុ វិហរតិ សុន្ទរិកាយ នទិយា តីរេ ។ តេន ខោ បន សមយេន សុន្ទរិកភារទ្វាជោ ព្រាហ្មណោ សុន្ទរិកាយ នទិយា តីរេ អគ្គឹ ជុហតិ អគ្គិហុត្តំ បរិចរតិ ។ អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ អគ្គឹ ជុហិត្វា អគ្គិហុត្តំ បរិចរិត្វា ឧដ្ឋាយាសនា សមន្តា ចតុទ្ទិសា អនុវិលោ-កេសិ កោ នុ ខោ ឥមំ ហព្យសេសំ ភុញ្ជេយ្យាតិ ។

[១៣៦] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អគ្គិកភារទ្វាជព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ អគ្គិកភារទ្វាជៈមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

# សុន្ទរិកសូត្រ ទី ៩

[១៣៧] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបឆ្នេរស្ទឹងសុន្ទរិកា ក្នុងដែនកោសល ។ សម័យនោះឯង សុន្ទរិកភារទ្វាជ-ព្រាហ្មណ៍ តែងបូជាភ្លើង បម្រើនូវការបូជាភ្លើង ទៀបឆ្នេរស្ទឹងសុន្ទរិកា ។ លុះសុន្ទរិកភារទ្វាជព្រាហ្មណ៍ បូជាភ្លើង បម្រើនូវការបូជាភ្លើងហើយ ក៏ក្រោកអំពីអាសនៈ ងាកមើលជុំទិសទាំងបួន គិតថា អ្នកណាហ្ន៎ គួរបរិភោគនូវបាយាស ដែលសល់ពីបូជានេះ ។

ព្រាហ្មណសំយុត្តស្ស អរហន្តវគ្គេ ភគវន្តូបសង្កមនំ

[១៣៨] អទ្ទសា ខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ សសីសំ បារុតំ និសិន្នំ ទិស្វាន វាមេន ហត្ថេន ហព្យសេសំ គហេត្វា ទក្ខិណេន ហត្ថេន កមណ្ឌលុំ គហេត្វា យេន ភគវា តេនុបសង្កមិ ។ អថខោ ភគវា សុន្ទរិកភារទ្វាជស្ស ព្រាហ្មណស្ស បទសទ្ទេន សីសំ វិវរិ ។ អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ មុណ្ឌោ អយំ ភវំ មុណ្ឌកោ អយំ ភវន្តិ តតោ វ បុន និវត្តិកាមោ អហោសិ ។ អថខោ សុន្ទរិកភាទ្វាជស្ស ព្រាហ្មណស្ស ឯតទហោសិ មុណ្ឌាបិ ហិ ឥធេកច្ចេ ព្រាហ្មណា ភវន្តិ យន្នូនាហំ តំ ឧបសង្កមិត្វា ជាតឹ បុច្ឆេយ្យន្តិ ។ អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច កឹជច្ចោ ភវន្តិ ។

[១៣៨] សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគ ទ្រង់គង់ទទូរព្រះសិរ ក្រោមម្លប់ឈើមួយ លុះឃើញហើយ ក៏កាន់នូវបាយាស ដែលសល់អំពីការបូជា ដោយដៃឆ្វេង ហើយកាន់នូវកុណ្ឌីទឹកដោយដៃស្តាំ ចូលទៅរកព្រះមានព្រះភាគ ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់បើកព្រះសិរ ដោយឮសូរជើង នៃសុន្ទរិក-ភារទ្វាជព្រាហ្មណ៍ ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍ ក៏ពោលថា លោកដ៏ចម្រើននេះ ក្បាលត្រងោល លោកដ៏ចម្រើននេះ ក្បាលត្រងោល ដូច្នេះហើយ ចង់ត្រឡប់អំពីទីនោះមកវិញ ។ ទើបសុន្ទរិកភារទ្វាជព្រាហ្មណ៍ មានសេចក្តីត្រិះរិះដូច្នេះថា ព្រាហ្មណ៍ទាំងឡាយពួកមួយ ក្នុងលោកនេះ មានក្បាលត្រងោលដែរ បើដូច្នោះ មានតែអាត្មាអញត្រូវចូលទៅរកលោកដ៏ចម្រើននោះ ហើយសួរនូវជាតិវិញ ។ លំដាប់នោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះ នឹងព្រះមានព្រះភាគថា លោកដ៏ចម្រើនជាជាតិអ្វី ។

[១៣៩] មា ជាតឹ បុច្ឆ ចរណញ្ច បុច្ឆ
កដ្ឋា ហវេ ជាយតិ ជាតវេទោ
នីចាកុលីនោបិ មុនី ធិតិមា
អាជានីយោ ហោតិ ហិរីនិសេធោ
សច្ចេន ទន្តោ ទមសា ឧបេតោ
វេទន្តគូ វុសិតព្រហ្មចរិយោ
យញ្ញូបនីតោ តមុបវ្ហយេថ
កាលេន សោ ជុហាតិ ទក្ខិណេយ្យេតិ ។

[១៤០] អទ្ធា សុយិដ្ឋំ សុហុតំ មមយិទំ
យំ តាទិសំ វេទគុមទ្ទសាមិ
តុម្ហាទិសានំ ហិ អទស្សនេន
អញ្ញោ ជនោ ភុញ្ជតិ ហព្យសេសន្តិ ។
ភុញ្ជតុ ភវំ គោតមោ ព្រាហ្មណោ ភវន្តិ ។

[១៣៩] ព្រះអង្គត្រាស់ថា ចូរអ្នកកុំសួររកជាតិឡើយ ចូរសួរតែការប្រព្រឹត្តវិញ ភ្លើងតែងកើតអំពីឈើ ឯអ្នកប្រាជ្ញទោះបីកើតក្នុងត្រកូលទាប ក៏គង់មានសេចក្តីព្យាយាម ជាបុរសអាជានេយ្យ ជាអ្នកហាមឃាត់ នូវបាបដោយហិរិ ទូន្មានដោយបរមត្ថសច្ចៈ ប្រកបដោយការទូន្មាននូវឥន្ទ្រិយ ដល់នូវទីបំផុតនៃចតុវេទ គឺមគ្គ ៤ មានព្រហ្មចរិយៈនៅរួចហើយ បុគ្គលណាតាក់តែងនូវយ័ញ្ញ ជនគប្បីហៅបុគ្គលនោះ (ថាជាព្រាហ្មណ៍ដ៏ឧត្តម) បុគ្គលនោះ រមែងបូជានូវទក្ខិណេយ្យបុគ្គលទាំងឡាយ តាមកាល ។

[១៤០] សុន្ទរិកភារទ្វាជព្រាហ្មណ៍ពោលថា វត្ថុនេះ ខ្ញុំបូជាហើយដោយប្រពៃ វត្ថុនេះ ខ្ញុំគំនាប់ហើយដោយប្រពៃដោយពិត ខ្ញុំមិនបានឃើញបុគ្គលណា ដែលដល់នូវវេទដូចជាព្រះអង្គសោះ ព្រោះថាជនឯទៀត លុះតែមិនឃើញពួកបុគ្គលដូចជាព្រះអង្គ ទើបបរិភោគបាយាស ដែលសល់អំពីការបូជា ។

សូមព្រះគោតមដ៏ចម្រើន ជាព្រាហ្មណ៍ដ៏ចម្រើន បរិភោគចុះ ។

[១៨១] គាថាភិគីតំ មេ អភោជនេយ្យំ

សម្បស្សតំ ព្រាហ្មណ នេស ធម្មោ

គាថាភិគីតំ បនុទន្តិ ពុទ្ធា

ធម្មេ សតិ ព្រាហ្មណ វុត្តិរេសា

អញ្ញេន ច កេវលិនំ មហេសឹ

ខីណាសវំ កុក្កុច្ចវូបសន្តំ

អន្នេន បានេន ឧបដ្ឋហស្សុ

ខេត្តញ្ហិ តំ បុញ្ញបេក្ខស្ស ហោតីតិ ។

[១៨២] អថ កស្ស ចាហំ ភោ គោតម ឥមំ ហព្យសេសំ ទម្មីតិ ន ខ្វាហន្តំ ព្រាហ្មណ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សម-ណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យស្ស-សោ ហព្យសេសោ ភុត្តោ សម្មាបរិណាមំ គច្ឆេយ្យ

[១៨១] ព្រះអង្គត្រាស់ថា តថាគតមិនគួរបរិភោគភោជន ដែលបានអំពីការពោលគាថា ដូចជាចម្រៀងទេ ម្នាលព្រាហ្មណ៍ ធម៌នេះ មិនមែនជាធម៌របស់ពួកបុគ្គលអ្នកឃើញធម៌អាថ៌ទេ ព្រះពុទ្ធទាំងឡាយ តែងបន្ទោបង់នូវការពោលគាថា ដូចជាចម្រៀង ម្នាលព្រាហ្មណ៍ កាលបើធម៌មានហើយ នេះឯង ជាការចិញ្ចឹមជីវិត ចូរអ្នកទំនុកបម្រុងព្រះខីណាស្រព ដែលមានគុណបរិបូណ៌ អ្នកស្វែងរកនូវគុណដ៏ធំ អ្នករម្ងាប់នូវសេចក្តីរពឹស ដោយបាយនិងទឹកដទៃចុះ ព្រោះថា នោះជាខេត្តរបស់បុគ្គលអ្នកប្រាថ្នានូវបុណ្យ ។

[១៨២] បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ ខ្ញុំព្រះអង្គនឹងឲ្យនូវបាយាស ដែលសល់អំពីការបូជានេះដល់អ្នកណា ។ ម្នាលព្រាហ្មណ៍ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគត មិនឃើញមានបុគ្គលណា ដែលបរិភោគបាយាស សល់អំពីការបូជា ហើយគប្បីដល់ នូវការទ្រុឌទ្រោមទៅដោយស្រួល

អញ្ញត្រ តថាគតស្ស វា តថាគតសាវកស្ស វា តេនហិ ត្វំ ព្រាហ្មណ តំ ហព្យសេសំ អបហរិតេ វា ឆឌ្ឌេហិ អប្បាណកេ វា ឧទកេ ឱបិលាបេសីតិ ។

[១៤៣] អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ តំ ហព្យសេសំ អប្បាណកេ ឧទកេ ឱបិលាបេសិ ។ អថខោ សោ ហព្យសេសោ ឧទកេ បក្ខិត្តោ វិចិដាយតិ[១] វិដិចិដាយតិ សន្ធូបាយតិ សម្បធូបាយតិ ។ សេយ្យថាបិ នាម ផាលោ[២] ទិវសសន្តត្តោ ឧទកេ បក្ខិត្តោ វិចិដាយតិ វិដិចិដាយតិ សន្ធូបាយតិ សម្បធូបាយតិ ឯវមេវ សោ ហព្យសេសោ ឧទកេ បក្ខិត្តោ វិចិដាយតិ វិដិចិដាយតិ សន្ធូបាយតិ សម្បធូបាយតិ ។ អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ សំវិគ្គោ លោមហដ្ឋជាតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។

---

១ ឱ. ចិច្ចិដាយតិ ចិដិចិដាយតិ ។ ២ ម. លោហោ ។

ក្រៅពីតថាគត ឬក្រៅពីសាវ័កតថាគតនេះឡើយ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរចាក់ចោលនូវបាយាស ដែលសល់អំពីការបូជានោះ ក្នុងទីគ្មានស្មៅស្រស់ ឬបាចទៅក្នុងទឹកដែលគ្មានសត្វចុះ ។

[១៤៣] លំដាប់នោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ ក៏បាចបាយាស ដែលសល់អំពីការបូជានោះ ទៅក្នុងទឹកដែលគ្មានសត្វ ។ បាយាស ដែលសល់អំពីការបូជានោះ លុះព្រាហ្មណ៍បានបាចទៅក្នុងទឹកហើយ ក៏ធ្វើសំឡេងឮវិចិដ វិដិចិដ ហុយផ្សែងឡើង ហុយផ្សែងថ្គោល ។ ដូចជាផាលគេហាលអស់មួយថ្ងៃ ហើយដាក់ទៅក្នុងទឹក ធ្វើនូវសំឡេងឮវិចិដ វិដិចិដ ហុយផ្សែងឡើង ហុយផ្សែងថ្គោល យ៉ាងណាមិញ បាយាស ដែលសល់អំពីការបូជានោះ ព្រាហ្មណ៍បានបាចទៅក្នុងទឹក ហើយធ្វើនូវសំឡេងឮវិចិដ វិដិចិដ ហុយផ្សែងឡើង ហុយផ្សែងថ្គោល យ៉ាងនោះឯង ។ លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ មានសេចក្តីសង្វេគ កើតសេចក្តីព្រឺរោម ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ ។

១០៧

ព្រាហ្មណសំយុត្តស្ស អរហន្តវគ្គេ វិរិធូបមា

[១៤៤] ឯកមន្តំ ឋិតំ ខោ សុន្ទរិកភារទ្វាជំ ព្រាហ្មណំ ភគវា គាថាហិ អជ្ឈភាសិ

មា ព្រាហ្មណ ទារុសមាទហានោ
សុទ្ធឹ អមញ្ញិ ពហិទ្ធា ហិ ឯតំ
ន ហិ តេន សុទ្ធឹ កុសលា វទន្តិ
យោ ពាហិរេន បរិសុទ្ធិមិច្ឆេ
ហិត្វា អហំ ព្រាហ្មណ ទារុទាហំ
អជ្ឈត្តមេវ ជលយាមិ ជោតឹ
និច្ចគ្គិនី និច្ចសមាហិតត្តោ
អរហំ អហំ ព្រហ្មចរិយំ ចរាមិ
មានោ ហិ តេ ព្រាហ្មណ ខារិភារោ
កោធោ ធូមោ ភស្មនិ មោសវជ្ជំ

[១៤៤] លុះសុន្ទរិកភារទ្វាជព្រាហ្មណ៍ ឋិតក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ បានត្រាស់ដោយព្រះគាថាទាំងឡាយថា ម្នាលព្រាហ្មណ៍ អ្នកកុំដុតឧស សម្គាល់ថាបរិសុទ្ធិឡើយ ព្រោះថាការដុតនុ៎ះ ជាខាងក្រៅទេ បុគ្គលណា ប្រាថ្នានូវសេចក្តីបរិសុទ្ធិខាងក្រៅ អ្នកប្រាជ្ញទាំងឡាយ មិនហៅនូវបុគ្គលនោះ ថាមានសេចក្តីបរិសុទ្ធ ព្រោះហេតុនោះឡើយ ម្នាលព្រាហ្មណ៍ តថាគតលះបង់ នូវការដុតឧសហើយ ដុតតែភ្លើងខាងក្នុងទេ តថាគតមានភ្លើងរុងរឿងជានិច្ច មានចិត្តតាំងមាំជានិច្ច ជាអរហន្ត ប្រព្រឹត្តនូវព្រហ្មចរិយៈ ម្នាលព្រាហ្មណ៍ មានះរបស់អ្នក ដូចជាអម្រែកដ៏ធ្ងន់ សេចក្តីក្រោធដូចជាផ្សែង ពាក្យកុហកដូចជាផេះ

ជិវ្ហា សុជា ហទយំ ជោតិហានំ
អត្តា សុទន្តោ បុរិសស្ស ជោតិ
ធម្មោ រហទោ ព្រាហ្មណ សីលតិត្ថោ
អនាវិលោ សព្ភិ សតំ បសត្ថោ
យត្ថ ហវេ វេទគុនោ សិនាតា
អនល្លគត្តាវ[១] តរន្តិ ចារំ
សច្ចំ ធម្មោ សំយមោ ព្រហ្មចរិយំ
មជ្ឈេសិតា ព្រាហ្មណ ព្រហ្មបត្តិ
សតុជ្ជុភូតេសុ នមោ ករោហិ
តមហំ នរំ ធម្មសារីតិ ព្រូមីតិ ។

[១៤៩] ឯវំ វុត្តេ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

---

១ ឱ. ម. អនល្លីនគត្តាវ ។

អណ្ដាតដូចជាវែក ហទយវត្ថុដូចជាកន្ទែងភ្លើង ចិត្តដែលបុគ្គលទូន្មានល្អហើយ ដូចជាភ្លើងរបស់បុរស ពួកបុគ្គលដល់នូវវេទ ងូតក្នុងអន្លង់ណា មិនទទឹកខ្លួនសោះ តែងឆ្លងដល់ត្រើយគឺព្រះនិព្វាន ម្នាលព្រាហ្មណ៍ អន្លង់នោះ គឺធម៌ មានសីលជាកំពង់ មិនល្អក់ ដែលសប្បុរសទាំងឡាយសរសើរហើយ ថាជារបស់សប្បុរសទាំងឡាយ ម្នាលព្រាហ្មណ៍ សច្ចៈក្តី ធម្មៈក្តី[១] សំយមៈក្តី[២] ព្រហ្មចរិយៈក្តី ជាធម្មជាតតាំងនៅជាកណ្តាល ជាចំណែកដ៏ប្រសើរ ចូរអ្នកធ្វើនូវការនមស្ការ ចំពោះព្រះខីណាស្រព ដែលមានចិត្តស្លូតត្រង់ទាំងឡាយចុះ តថាគតហៅជននោះ ថាជាអ្នកវៀកនូវធម៌ ដូច្នេះឯង ។

[១៨៩] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ភារទ្វាជៈមានអាយុ ក៏ជាអរហន្តមួយរូបដែរ ។

---

១ ធម្មៈ បានដល់ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

២ ការសង្រួម បានដល់ សម្មាកម្មន្តៈ សម្មាអាជីវៈ ។

# ទសមំ ពហុធិតិសុត្តំ

[១៤៦] ឯកំ សមយំ ភគវា កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស ចតុទ្ទស ពលិពទ្ទា នដ្ឋា ហោន្តិ ។

[១៤៧] អថខោ ភារទ្វាជគោត្តោ ព្រាហ្មណោ តេ ពលិពទ្ទេ គវេសន្តោ យេន សោ វនសណ្ឌោ តេនុប-សង្កមិ ឧបសង្កមិត្វា អទ្ទស ភគវន្តំ តស្មឹ វនសណ្ឌេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ទិស្វាន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ សន្តិកេ ឥមា គាថាយោ អភាសិ

# ពហុធិតិសូត្រ ទី ១០

[១៨៦] *សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះឯង ព្រាហ្មណ៍ម្នាក់ ជាភារទ្វាជ-គោត្រ មានគោចំនួន ១៤ បាត់រកមិនទាន់ឃើញ ។*

[១៨៧] *គ្រានោះ ភារទ្វាជគោត្តព្រាហ្មណ៍ ដើររកគោទាំងនោះ ក៏ចូលទៅកាន់ដងព្រៃនោះ លុះចូលទៅដល់ហើយ បានឃើញព្រះមានព្រះភាគ គង់ផ្គត់ព្រះភ្នែន តាំងព្រះកាយត្រង់ តម្កល់ព្រះស្មារតីឆ្ពោះទៅរកព្រះកម្មដ្ឋាន ក្នុងដងព្រៃនោះ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានពោលនូវគាថាទាំងឡាយនេះ ក្នុងសំណាក់ព្រះមានព្រះភាគថា*

នហ[១] នូនិមស្ស សមណស្ស
ពលិពទ្ទា ចតុទ្ទស
អជ្ជ សដ្ឋី ន ទិស្សន្តិ
តេនាយំ សមណោ សុខី
នហ នូនិមស្ស សមណស្ស
តិលា ខេត្តស្មិំ បាបិកា
ឯកបណ្ណា ទុបណ្ណា ច
តេនាយំ សមណោ សុខី
នហ នូនិមស្ស សមណស្ស
តុច្ឆកោដ្ឋស្មិំ មូសិកា
ឧស្សោឡ្ហិកាយ នច្ចន្តិ
តេនាយំ សមណោ សុខី
នហ នូនិមស្ស សមណស្ស
សន្ថារោ សត្តមាសិកោ
ឧប្បាទកេហិ សញ្ឆន្នោ
តេនាយំ សមណោ សុខី

១ ឱ. ម. នហិ ។

គោទាំង ១៤ ដែលរកមិនឃើញអស់ ៦ ថ្ងៃនឹងថ្ងៃនេះហើយ របស់សមណៈនេះ ប្រហែលមិនមានទេ ព្រោះហេតុនោះ បានជាសមណៈនេះ នៅជាសុខ លូសូម្បីមានតែស្ទឹកមួយ ឬមានស្ទឹកពីរដែលខូចក្នុងចម្ការ របស់សមណៈនេះ ប្រ-ហែលមិនមានទេ ព្រោះហេតុនោះ បានជាសមណៈនេះ នៅជាសុខ កណ្តុរទាំងឡាយ រាំរែកដោយការលោតលេង ក្នុងជង្រុកទទេ របស់សមណៈនេះ ប្រហែលមិនមានទេ ព្រោះហេតុនោះ បានជាសមណៈនេះ នៅជាសុខ កម្រាល ដែលក្រាលចោលប្រាំពីរខែ សឹងដេរដាសដោយបាណក-ជាតិទាំងឡាយ របស់សមណៈនេះ ប្រហែលមិនមាន ទេ ព្រោះហេតុនោះ បានជាសមណៈនេះ នៅជាសុខ

១១១

## ព្រាហ្មណសំយុត្តស្ស អរហន្តវគ្គេ ភគវន្តស្ស បដិវចនំ

នហ នូនិមស្ស សមណស្ស
វិធវា បុត្តជីតកោ
ឯកបុត្តា ទ្វិបុត្តា ច
តេនាយំ សមណោ សុខី
នហ នូនិមស្ស សមណស្ស
បិង្គលា តិលកាហតា
សោត្ថំ ចានេន ចោទេតិ
តេនាយំ សមណោ សុខី
នហ នូនិមស្ស សមណស្ស
បច្ចូសម្ហិ ឥណាយិកា
ទេថ ទេថាតិ ចោទេន្តិ
តេនាយំ សមណោ សុខីតិ ។
[១៤៨] នហ មយ្ហំ ព្រាហ្មណា
ពលិពទ្ធា ចតុទ្ទស
អជ្ជ សដ្ឋី ន ទិស្សន្តិ
តេនាហំ ព្រាហ្មណា សុខី
នហ មយ្ហំ ព្រាហ្មណា

កូនប្រុស កូនស្រី ដែលពោះម៉ាយ ឬមេម៉ាយ មានកូនមួយឬមានកូនពីរ របស់សមណៈនេះ ប្រហែលមិនមានទេ ព្រោះហេតុនោះ បានជាសមណៈនេះនៅជាសុខ ស្រមោចដែលមានខ្លួនសៅហ្មង ដោយប្រជ្រុយ[១] យកជើងបៀតបៀនទូវសេចក្ដីលក់ របស់សមណៈនេះ ប្រហែលមិនមានទេ ព្រោះហេតុនោះ បានជាសមណៈនេះ នៅជាសុខ ម្ចាស់បំណុលរបស់សមណៈនេះ មកទារថា អ្នកចូរឲ្យមក ចូរឲ្យមក ដូច្នេះ ក្នុងបច្ចូសសម័យ ប្រហែលមិនមានទេ ព្រោះហេតុនោះ បានជាសមណៈនេះ នៅជាសុខ ។

[១៤៨] ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ គោ ១៤ ដែលរកមិនឃើញ អស់ ៦ ថ្ងៃ នឹងថ្ងៃនេះហើយ របស់តថាគត មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគត នៅជាសុខ ម្នាលព្រាហ្មណ៍ ល្ងសូម្បី

១ សត្វបាណកជាតិដែលមានខ្លួនរអុជ ៗ រទុះ ៗ ។

តិលា ខេត្តស្មិំ ចាបិកា

ឯកបណ្ណា ទុបណ្ណា ច

តេជាហំ ព្រាហ្មណា សុខី

ឆហា មយ្ហំ ព្រាហ្មណា

តុច្ឆកោដ្ឋស្មិំ មូសិកា

ឧស្សោឡ្ហិកាយ នច្ចន្តិ

តេជាហំ ព្រាហ្មណា សុខី

ឆហា មយ្ហំ ព្រាហ្មណា

សត្តាហេ សត្តមាសិកោ

ឧប្បាដកេហិ សញ្ជគ្ឃោ

តេជាហំ មយ្ហំ ព្រាហ្មណា

វិធវា បុត្តជីវកោ

ឯកបុត្តា ទ្វិបុត្តា ច

តេជាហំ ព្រាហ្មណា សុខី

ឆហា មយ្ហំ ព្រាហ្មណា

បិង្គលា តិលកាហាតា

មានតែស្ទឹកមួយ ឬមានស្ទឹកពីរ ដែលខូចក្នុងចម្ការ របស់តថាគត មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគតនៅជាសុខ ម្នាលព្រាហ្មណ៍ កណ្តុរទាំងឡាយ រាំរែកដោយការលោតលេង ក្នុងជង្រុកទទេ របស់តថាគត មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគតនៅជាសុខ ម្នាលព្រាហ្មណ៍ កម្រាលដែលក្រាលចោល ៧ ខែ សឹងដេរដាសដោយបាណកជាតិទាំងឡាយរបស់តថាគត មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគតនៅជាសុខ ម្នាលព្រាហ្មណ៍ កូនប្រុស កូនស្រី ដែលពោះម៉ាយឬមេម៉ាយ មានកូនមួយ ឬមានកូនពីរ របស់តថាគត មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគត នៅជាសុខ ម្នាលព្រាហ្មណ៍ ស្រមោចដែលមានខ្លួនសៅហ្មង ដោយប្រជ្រុយ

សោត្តំ ចារេន ចោទេតិ
តេនាហំ ព្រាហ្មណ សុខី
នហ មយ្ហំ ព្រាហ្មណ
បច្ចូសម្ហិ ឥណាយិកា
ទេថ ទេថាតិ ចោទេន្តិ
តេនាហំ ព្រាហ្មណ សុខីតិ ។

[១៤៩] ឯវំ វុត្តេ ភារទ្វាជគោត្តោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភគវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ ភារទ្វាជគោត្តោ

យកជើងបៀតបៀននូវសេចក្តីលក់ របស់តថាគត មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគតនៅជាសុខ ម្នាលព្រាហ្មណ៍ ម្ចាស់បំណុលរបស់តថាគតមកទារថា អ្នកចូរឲ្យមក ចូរឲ្យមក ដូច្នេះ ក្នុងបច្ចូសសម័យក៏មិនមានឡើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគតនៅជាសុខ ។

[១៤៩] កាលព្រះមានព្រះភាគ ទ្រង់បានត្រាស់យ៉ាងនេះហើយ ភារទ្វាជគោត្តព្រាហ្មណ៍ ក៏បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់ប្រកាសដោយអនេកបរិយាយ ដូចជាបុគ្គលធ្វើរបស់ដែលផ្កាប់ឲ្យផ្ងារឡើង ឬដូចជាបើកបង្ហាញរបស់ដែលបិទបាំង ឬដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបក្នុងទីងងឹតដោយគិតថា ពួកមនុស្សដែលមានភ្នែក នឹងមើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទា ក្នុងសំណាក់ព្រះគោតមដ៏ចម្រើន ។ ភារទ្វាជ-

ព្រាហ្មណោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ច បនាយស្មា ភារទ្វាជោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

អរហន្តវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ធនញ្ជានី ច អក្កោសំ
អសុរិន្ទំ ពិលង្គិកំ
អហឹសកំ ជដា ចេវ
សុទ្ធិកញ្ចេវ អគ្គិកា
សុន្ទរិកា ពហុធិតិ
យេន ច តេ ទសាតិ ។

*គោត្តព្រាហ្មណ៍ ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។ លុះភារទ្វាជៈមានអាយុ បានឧបសម្បទា មិនយូរប៉ុន្មាន ក៏គេចចេញទៅតែម្នាក់ឯង មិនមានសេចក្តីប្រមាទ មានតែព្យាយាម ជាគ្រឿងដុតនូវកិលេស មានខ្លួនបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា ភារទ្វាជៈ មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ហើយដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញ បាននៅរួចហើយ កិច្ចដែលគួរធ្វើ អាត្មាអញ ក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមានឡើយ បណ្តាព្រះអរហន្តទាំងឡាយ ភារទ្វាជៈមានអាយុ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។*

ចប់ អរហន្តវគ្គ ទី ១ ។

# បញ្ជីរឿងនៃអរហន្តវគ្គនោះ គឺ

*ធនញ្ជានីសូត្រ ១ អក្កោសសូត្រ ១ អសុរិន្ទសូត្រ ១ ពិលង្គិកសូត្រ ១ អហឹសកសូត្រ ១ ជដាសូត្រ ១ សុទ្ធិកសូត្រ ១ អគ្គិកសូត្រ ១ សុន្ទរិកសូត្រ ១ ពហុធិតិសូត្រ ១ ត្រូវជា ១០ សូត្រ ។*

# ទុតិយោ ឧបាសកវគ្គោ

## បឋមំ កសិសុត្តំ

[១៥០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មគធេសុ វិហរតិ ទក្ខិណាគិរិស្មឹ ឯកនាលាយំ ព្រាហ្មណគាមេ ។ តេន ខោ បន សមយេន កសិ-ភារទ្វាជស្ស ព្រាហ្មណស្ស បញ្ចមត្តានិ នង្គលសតានិ បយុត្តានិ ហោន្តិ វប្បកាលេ ។

[១៥១] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន កសិភារទ្វាជស្ស ព្រាហ្មណស្ស កម្មន្តោ តេនុបសង្កមិ ។ តេន ខោ បន សមយេន កសិភារទ្វាជស្ស ព្រាហ្មណស្ស បរិវេសនា វត្តតិ ។ អថខោ ភគវា យេន បរិវេសនា តេនុបសង្កមិ ឧប-សង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ អទ្ទសា ខោ កសិ-ភារទ្វាជោ ព្រាហ្មណោ ភគវន្តំ បិណ្ឌាយ ឋិតំ ទិស្វាន ភគវន្តំ ឯតទវោច អហំ ខោ សមណ កសាមិ ច

# ឧបាសកវគ្គ ទី ២

## កសិសូត្រ ទី ១

[១៥០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងព្រាហ្មណគ្រាម ឈ្មោះឯកនាលា ក្នុងទក្ខិណាគិរិជនបទ នាដែនមគធៈ ។ សម័យនោះឯង កសិភារទ្វាជព្រាហ្មណ៍ បានតាក់តែងនង្គ័លប្រមាណ ៥០០ ក្នុងវេលាដែលព្រោះស្រូវ ។

[១៥១] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ការងាររបស់កសិភារទ្វាជព្រាហ្មណ៍ ។ សម័យនោះឯង ការអង្គាស (លៀងភ្ញៀវ) របស់កសិភារទ្វាជព្រាហ្មណ៍ កំពុងប្រព្រឹត្តទៅ ។ លំដាប់នោះ ព្រះមានព្រះភាគស្តេចចូលទៅកាន់ការអង្គាស លុះចូលទៅដល់ហើយ ក៏ប្រថាប់នៅក្នុងទីដ៏សមគួរ ។ កសិភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគ ដែលទ្រង់ឈរបិណ្ឌបាត លុះឃើញហើយ ក៏បានពោលនូវពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះសមណៈ ខ្ញុំព្រះអង្គភ្ជួរផង

វចាមិ ច កសិត្វា ច វបិត្វា ច ភុញ្ជាមិ ត្វម្បិ សមណ កស ច វបស្សុ ច កសិត្វា ច វបិត្វា ច ភុញ្ជស្សូតិ ។ អហម្បិ ខោ ព្រាហ្មណ កសាមិ ច វចាមិ ច កសិត្វា ច វបិត្វា ច ភុញ្ជាមីតិ ។ ន ខោ បន មយំ បស្សាម ភោតោ គោតមស្ស យុគំ វា នង្គលំ វា ផាលំ វា ចាចនំ វា ពលិពទ្ទេ វា អថ ច បន ភវំ គោតមោ ឯវមាហ អហម្បិ ខោ ព្រាហ្មណ កសាមិ ច វចាមិ ច កសិត្វា ច វបិត្វា ច ភុញ្ជាមីតិ ។

[១៩២] អថខោ កសិភារទ្វាជោ ព្រាហ្មណោ ភគវន្តំ គាថាយ អជ្ឈភាសិ

កស្សកោ បដិជានាសិ
ន ច បស្សាមិ តេ កសឹ
កស្សកោ បុច្ឆិតោ ព្រូហិ
កថំ ជានេមុ តំ កសិន្តិ ។

[១៩៣] សទ្ធា ពីជំ តបោ វុដ្ឋិ
បញ្ញា មេ យុគនង្គលំ
ហិរិ ឦសា មនោ យោត្តំ

ព្រោះផង លុះខ្ញុំព្រះអង្គភ្ជួរហើយ ព្រោះហើយ ទើបបរិភោគ បពិត្រព្រះសមណៈ ចំណែកព្រះអង្គចូរភ្ជួរផង ព្រោះផង លុះភ្ជួរហើយ ព្រោះហើយ ចូរបរិភោគចុះ ។ ម្នាលព្រាហ្មណ៍ តថាគតភ្ជួរផង ព្រោះផង លុះតថាគតភ្ជួរហើយ ព្រោះហើយ ទើបបរិភោគដែរ ។ យើងខ្ញុំ មិនឃើញនឹម ឬនង្គ័ល ផាល ឬជន្លួញ ឬគោទាំងឡាយ របស់ព្រះគោតមដ៏ចម្រើនទេ តែថាព្រះគោតមដ៏ចម្រើន ពោលយ៉ាងនេះថា ម្នាលព្រាហ្មណ៍ តថាគតភ្ជួរផង ព្រោះផង លុះតថាគត ភ្ជួរហើយ ព្រោះហើយ ទើបបរិភោគដែរ ។

[១៩២] លំដាប់នោះ កសិភារទ្វាជព្រាហ្មណ៍ បានពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា

ព្រះអង្គប្តេជ្ញាថាជាអ្នកភ្ជួរ តែថា ខ្ញុំព្រះអង្គមិនដែលឃើញនូវ
ការភ្ជួររបស់ព្រះអង្គសោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គជាអ្នកភ្ជួរ
សូមប្រាប់មក ធ្វើដូចម្តេច នឹងឲ្យយើងខ្ញុំដឹង នូវការភ្ជួរ
នោះបាន ។

[១៩៣] ព្រះអង្គត្រាស់ថា សទ្ធាជាពូជ តបៈជាភ្លៀង
បញ្ញារបស់តថាគតជានឹមនិងនង្គ័ល ហិរិជាយាមនង្គ័ល ចិត្ត

១១៧

ព្រាហ្មណសំយុត្តស្ស ឧបាសកវគ្គេ គាថាភិគីតបនូទនំ

សតិ មេ ផាលចាចនំ
កាយគុត្តោ វចីគុត្តោ
អាហារេ ឧទរេ យតោ
សច្ចំ ករោមិ និទ្ទានំ
សោរច្ចំ មេ បមោចនំ
វិរិយំ មេ ធុរធោរយ្ហំ
យោគក្ខេមាធិវាហនំ
គច្ឆតិ អនិវត្តន្តំ
យត្ថ គន្ត្វា ន សោចតិ
ឯវមេសា កសី កដ្ឋា
សា ហោតិ អមតប្ផលា
ឯតំ កសឹ កសិត្វាន
សព្វទុក្ខា បមុច្ចតីតិ ។

ភុញ្ជតុ ភវំ គោតមោ កស្សកោ ភវំ យញ្ហិ ភវំ គោតមោ អមតប្ផលំបិ កសតីតិ ។

[១៨៤] គាថាភិគីតំ មេ អភោជនេយ្យំ
សម្បស្សតំ ព្រាហ្មណ ឯស ធម្មោ

ជាខ្សែ សតិរបស់តថាគត ជាផាលនិងជន្លួញ តថាគត គ្រប់គ្រងកាយ គ្រប់គ្រងវាចា សង្រួមអាហារ សង្រួមផ្ទៃ តថាគត ធ្វើនូវការជម្រះស្មៅដោយសច្ចៈ សេចក្ដីត្រេកអរក្នុងព្រះនិព្វាន ទុកជាការឈប់សម្រាក របស់តថាគត សេចក្ដីព្យាយាម របស់តថាគត ដូចជាគោអូសនឹម ជាធម្មជាតនាំមកនូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ បុគ្គលទៅក្នុងទីណា មិនសោកសៅ សេចក្ដីព្យាយាម រមែងទៅកាន់ទីនោះ ដែលជាទីមិនត្រឡប់មកវិញ ស្រែនុ៎ះតថាគតបានភ្ជួរយ៉ាងនេះ ស្រែនុ៎ះមានព្រះនិព្វានជាផល បុគ្គលភ្ជួរស្រែនុ៎ះហើយ រមែងរួចចាកទុក្ខទាំងពួងបាន ។

កសិភារទ្វាជព្រាហ្មណ៍ ក្រាបទូលថា ព្រះគោតមដ៏ចម្រើន ជាអ្នកភ្ជួរដ៏ល្អ ចូរបរិភោគចុះ ព្រោះថា ព្រះគោតមដ៏ចម្រើន ភ្ជួរនូវស្រែ ដែលមានព្រះនិព្វានជាផល ។

[១៩៤] ព្រះអង្គត្រាស់ថា តថាគត មិនគួរបរិភោគភោជន ដែលបានអំពីការពោលគាថា ដូចជាចម្រៀងទេ ម្នាលព្រាហ្មណ៍ នេះជាធម្មតារបស់ពួកបុគ្គល អ្នកឃើញធម៌អាចំ

គាថាភិគីតំ បនុទន្តិ ពុទ្ធា
ធម្មេ សតិ ព្រាហ្មណ វុត្តិ រេសា
អញ្ញេន ច កេវលិនំ មហេសឹ
ខីណាសវំ កុក្កុច្ចវូបសន្តំ
អន្នេន បានេន ឧបដ្ឋហស្សុ
ខេត្តញ្ហិ តំ បុញ្ញបេក្ខស្ស ហោតីតិ ។

[១៩៥] ឯវំ វុត្តេ កសិភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

## ទុតិយំ ឧទយសុត្តំ

[១៩៦] សាវត្ថីនិទានំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឧទយស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ។ អថខោ ឧទយោ ព្រាហ្មណោ ភគវតោ បត្តំ ឱទនេន បូរេសិ ។

ព្រះពុទ្ធទាំងឡាយ តែងបន្ទោបង់នូវការពោលគាថា ដូចជាចម្រៀង ម្នាលព្រាហ្មណ៍ កាលបើធម៌មានហើយ នេះឯងការចិញ្ចឹមជីវិត ចូរអ្នកទំនុកបម្រុងព្រះខីណាស្រព ដែលមានគុណបរិបូណ៌ ជាអ្នកស្វែងរកនូវគុណដ៏ធំ ជាអ្នករម្ងាប់នូវសេចក្តីរពឹស ដោយបាយនិងទឹកទៀតចុះ ព្រោះថានោះជាខេត្តរបស់បុគ្គលអ្នកប្រាថ្នានូវបុណ្យ ។

[១៥៥] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ កសិភារទ្វាជព្រាហ្មណ៍ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ ខ្ញុំព្រះអង្គ សូមដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីរថ្ងៃនេះជាដើមរៀងទៅ ។

# ឧទយសូត្រ ទី ២

[១៥៦] សាវត្ថីនិទាន ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់ឧទយព្រាហ្មណ៍ ។ លំដាប់នោះឯង ឧទយព្រាហ្មណ៍ យកបាយ ដាក់ពេញបាត្រព្រះមានព្រះភាគ ។

១១៩

ព្រាហ្មណសំយុត្តស្ស ឧបាសកវគ្គេ ឧទយស្ស និវេសនូបសង្កមនំ

[១៩៧] ទុតិយម្បិ ខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឧទយស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ។ ទុតិយម្បិ ខោ ឧទយោ ព្រាហ្មណោ ភគវតោ បត្តំ ឱទនេន បូរេសិ ។

[១៩៨] តតិយម្បិ ខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឧទយស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ។ តតិយម្បិ ខោ ឧទយោ ព្រាហ្មណោ ភគវតោ បត្តំ ឱទនេន បូរេត្វា ភគវន្តំ ឯតទវោច បកដ្ឋក្វាយំ សមណោ គោតមោ បុនប្បុនំ អាគច្ឆតីតិ ។

[១៩៩] បុនប្បុនំ ចេវ វបន្តិ ពីជំ
បុនប្បុនំ វស្សតិ ទេវរាជា
បុនប្បុនំ ខេត្តំ កសន្តិ កស្សកា

[១៩៧] ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅ របស់ឧទយព្រាហ្មណ៍ អស់វារៈពីរផង ។ ឧទយព្រាហ្មណ៍ ក៏យកបាយ ដាក់ពេញបាត្រព្រះមានព្រះភាគ ជាគម្រប់ពីរដង ។

[១៩៨] ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅ របស់ឧទយព្រាហ្មណ៍ ជាគម្រប់បីដង ។ ឧទយព្រាហ្មណ៍ ក៏យកបាយ ដាក់ពេញបាត្រព្រះមានព្រះភាគ ជាគម្រប់បីដង ហើយពោលពាក្យនេះ នឹងព្រះមានព្រះភាគថា ព្រះសមណគោតមនេះ ជាអ្នកជាប់ចិត្តក្នុងរស ទើបនិមន្តមករឿយ ៗ ។

[១៩៩] ភ្លៀងបង្អុរចុះរឿយ ៗ ជនទាំងឡាយ ក៏ព្រោះ
ពូជរឿយ ៗ អ្នកភ្ជួររាស់ទាំងឡាយ ភ្ជួររាស់ស្រែរឿយ ៗ

បុនប្បុនំ ចញ្ញមុបេន្តិ វដ្ឋំ
បុនប្បុនំ យាចកា យាចយន្តិ
បុនប្បុនំ ទានបតី ទទន្តិ
បុនប្បុនំ ទានបតី ទទិត្វា
បុនប្បុនំ សគ្គមុបេន្តិ ឋានំ
បុនប្បុនំ ខីរណិកា ទុហន្តិ
បុនប្បុនំ វច្ឆោ ឧបេតិ មាតរំ
បុនប្បុនំ កិលមតិ ផន្ទតិ ច
បុនប្បុនំ គព្ភមុបេតិ មន្ទោ
បុនប្បុនំ ជាយតិ មិយ្យតិ ច
បុនប្បុនំ សីវថិកំ ហរន្តិ
មគ្គញ្ច លទ្ធា អបុនព្ភវាយ
បុនប្បុនំ[១] ជាយតិ ភូរិបញ្ញោតិ ។

[១៦០] ឯវំ វុត្តេ ឧទយោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ។

១ ឱ. ន បុនប្បុនំ ។ អតិរេកបទំ មញ្ញេ ។

តែងនាំស្រូវទៅកាន់ជង្រុកក៏រឿយៗ ស្ទូមទាំងឡាយ សូមរឿយ ៗ ម្ចាស់ទានទាំងឡាយក៏ឲ្យរឿយៗ លុះម្ចាស់ទានទាំងឡាយ ឲ្យរឿយៗ ហើយ រមែងទៅកាន់ឋានសួគ៌ក៏រឿយៗ អ្នករូតទឹកដោះគោទាំងឡាយ រូតរឿយៗ កូនគោក៏ចូលទៅរកមេគោរឿយៗ អ្នកលូង់ខ្លៅលំបាកផង ញាប់ញ័រផងរឿយៗ តែងចូលទៅកាន់គភ៌ក៏រឿយៗ ទាំងកើតទាំងស្លាប់ ក៏រឿយៗ គេនាំទៅកាន់ទីស្មសានក៏រឿយៗ ចំណែកអ្នកមានបញ្ញា ដូចជាផែនដី លុះបាននូវមគ្គហើយ មិនកើតក្នុងភពថ្មីទៀត រឿយៗ ឡើយ ។

[១៦០] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ឧទយព្រាហ្មណ៍ បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

# តតិយំ ទេវហិតសុត្តំ

[១៦១] សាវត្ថិយំ វិហរតិ ជេតវនេ... តេន ខោ បន សមយេន ភគវា វាតេហាពាធិកោ ហោតិ ។ អាយស្មា ច ឧបវាណោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ ភគវា អាយស្មន្តំ ឧបវាណំ អាមន្តេសិ ឥង្ឃ មេ ត្វំ ឧបវាណ ឧណ្ហោទកំ ជានាហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា ឧបវាណោ ភគវតោ បដិស្សុត្វា និវាសេត្វា បត្តចីវរមាទាយ យេន ទេវហិតស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា តុណ្ហីភូតោ ឯកមន្តំ អដ្ឋាសិ ។

[១៦២] អទ្ទសា ខោ ទេវហិតោ ព្រាហ្មណោ អាយស្មន្តំ ឧបវាណំ តុណ្ហីភូតំ ឯកមន្តំ ឋិតំ ទិស្វាន អាយស្មន្តំ ឧបវាណំ គាថាយ អជ្ឈភាសិ

# ទេវហិតសូត្រ ទី ៣

[១៦១] ព្រះសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី... សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់មានព្រះអាពាធដោយខ្យល់ក្នុងព្រះឧទរ ។ ព្រះឧបវាណៈមានអាយុ ជាអ្នកបម្រើព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះឧបវាណៈមានអាយុមកថា ម្នាលឧបវាណៈ អ្នកចូរដឹងនូវទឹកក្តៅដល់តថាគតចុះ ។ ព្រះឧបវាណៈមានអាយុ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅកាន់លំនៅរបស់ទេវហិតព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏ឈរស្ងៀមក្នុងទីដ៏សមគួរ ។

[១៦២] ទេវហិតព្រាហ្មណ៍ បានឃើញព្រះឧបវាណៈ មានអាយុ ឈរស្ងៀមក្នុងទីដ៏សមគួរ លុះឃើញហើយ បានពោលនឹងព្រះឧបវាណៈមានអាយុ ដោយគាថា ថា

តុណ្ហីភូតោ ភវំ តិដ្ឋ
មុណ្ឌោ សង្ឃាដិបារុតោ
កឹ បត្ថយានោ កឹ ឯសំ
កឹ នុ យាចិតុមាគតោតិ ។

[១៦៣] អរហំ សុគតោ លោកេ
វាតេហាពាធិកោ មុនិ
សចេ ឧណ្ហោទកំ អត្ថិ
មុនិនោ ទេហិ ព្រាហ្មណ
បូជិតោ បូជនេយ្យានំ
សក្ករេយ្យាន សក្កតោ
អបចិតោ អបចិនេយ្យានំ[១]
តស្ស ឥច្ឆាមិ ហាតវេតិ ។

[១៦៤] អថខោ ទេវហិតោ ព្រាហ្មណោ ឧណ្ហោទកស្ស កាជំ បុរិសេន គាហាបេត្វា ផាណិតស្ស ច បុដំ អាយស្មតោ ឧបវាណស្ស បាទាសិ ។ អថខោ អាយស្មា ឧបវាណោ យេន ភគវា តេនុបសង្កមិ

១ ឱ. អបចេយ្យានំ ។

អ្នកត្រងោលដ៏ចម្រើន ឈ្មុំសង្ឃាដី ឈរនៅស្ងៀម ប្រាថ្នាអ្វី ស្វែងរកអ្វី មកដើម្បីសូមនូវអ្វីហ្ន៎ ។

[១៦៣] ព្រះឧបវាណៈតបថា ព្រះសុគតជាអរហន្ត ជាអ្នកប្រាជ្ញក្នុងលោក ទ្រង់មានអាពាធដោយខ្យល់ក្នុងព្រះឧទរ ម្នាលព្រាហ្មណ៍ បើអ្នកមានទឹកក្តៅ អ្នកចូរថ្វាយដល់ព្រះពុទ្ធជាអ្នកប្រាជ្ញ (ព្រោះថា) ព្រះមានព្រះភាគ គឺបូជនេយ្យ-បុគ្គល[១] ទាំងឡាយ បានបូជាហើយ សក្ការេយ្យបុគ្គល[២] ទាំងឡាយ បានធ្វើសក្ការៈហើយ អបចិនេយ្យបុគ្គល[៣] ទាំងឡាយ បានកោតក្រែងហើយ អាត្មាប្រាថ្នាដើម្បីនាំទឹកទៅថ្វាយព្រះអង្គ ។

[១៦៤] លំដាប់នោះ ទេវហិតព្រាហ្មណ៍ ឲ្យបុរសរែកអម្រែកទឹកក្តៅនិងដុំស្ករអំពៅ ទៅប្រគេនព្រះឧបវាណៈមានអាយុ ។ លំដាប់នោះឯង ព្រះឧបវាណៈមានអាយុ ក៏ចូលទៅគាល់ព្រះមានព្រះភាគ

១ បុគ្គលដែលគួរដល់ការបូជាមានអសីតិមហាថេរជាដើម ។ ២ បុគ្គលដែលគួរដល់សក្ការៈ។ ៣ បុគ្គលដែលគួរដល់ការកោតក្រែង ។

១២៣



ឧបសង្កមិត្វា ភគវន្តំ ឧណ្ហោទកេន នហាបេត្វា ឧណ្ហោទកេន ផាណិតំ អាលោឡេត្វា ភគវតោ បាទាសិ ។ អថខោ ភគវតោ សោ អាពាធោ បដិប្បស្សម្ភិ ។

[១៦៤] អថខោ ទេវហិតោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទេវហិតោ ព្រាហ្មណោ ភគវន្តំ គាថាយ អជ្ឈភាសិ

កត្ថ ទជ្ជា ទេយ្យធម្មំ
កត្ថ ទិន្នំ មហប្ផលំ
កថំ ហិ យជមានស្ស
កត្ថ ឥជ្ឈតិ ទក្ខិណាតិ ។

[១៦៦] បុព្វេនិវាសំ យោ វេទិ
សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ
អភិញ្ញា វោសិតោ មុនិ

លុះចូលទៅដល់ហើយ ក៏បានស្រង់ព្រះមានព្រះភាគ ដោយទឹកក្ដៅ ហើយលាយស្ករអំពៅដោយទឹកក្ដៅ ថ្វាយព្រះមានព្រះភាគ ។ លំដាប់នោះ អាពាធព្រះមានព្រះភាគនោះ ក៏សះស្បើយទៅ ។

[១៦៥] គ្រានោះ ទេវហិតព្រាហ្មណ៍ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួរឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះទេវហិតព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបទូលព្រះមានព្រះភាគ ដោយគាថា ថា

បុគ្គលគួរឲ្យទេយ្យធម៌ ចំពោះបុគ្គលណា ទានដែលបុគ្គល
ឲ្យចំពោះបុគ្គលណា ទើបមានផលច្រើន កាលបុគ្គលបូជា
ដូចម្ដេច ទក្ខិណាទានសម្រេច[១] ដូចម្ដេច ។

[១៦៦] ព្រះអង្គត្រាស់ថា បុគ្គលណា ដឹងនូវបុព្វេនិវាស
ផង ឃើញនូវសួគ៌និងអបាយផង មួយទៀត ដល់នូវការ
អស់ទៅនៃជាតិ ជាអ្នកប្រាជ្ញ សម្រេចហើយព្រោះត្រាស់ដឹង

---

១ ទក្ខិណាទានសម្រេច បានសេចក្ដីថា ទក្ខិណាទាន មានផលច្រើន ។ អដ្ឋកថា ។

ឯត្ថ ជដ្ឋា នេយ្យជម្មំ
ឯត្ថ ជិន្នំ មហាប្ផលំ
ឯវំ ហិ យជមានស្ស
ឯវំ ឥជ្ឈតិ ទក្ខិណាតិ ។

[១៦៧] ឯវំ វុត្តេ ទេវហិតោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

# ចតុត្ថំ មហាសាលសុត្តំ

[១៦៨] សាវត្ថីនិទានំ ។ អថខោ អញ្ញតរោ ព្រាហ្មណមហាសាលោ លូខោ លូខបាបុរណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ព្រាហ្មណមហាសាលំ ភគវា ឯតទវោច

បុគ្គលគួរឲ្យទេយ្យធម៌ចំពោះបុគ្គលនោះ ទានដែលបុគ្គលឲ្យចំពោះបុគ្គលនុ៎ះ ទើបមានផលច្រើន កាលបុគ្គលបូជាយ៉ាងនេះ ទក្ខិណាទាន តែងសម្រេច គឺមានផលច្រើន យ៉ាងនេះ ។

[១៦៧] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ទេវ-ហិតព្រាហ្មណ៍ ក៏បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

# មហាសាលសូត្រ ទី ៩

[១៦៨] សាវត្ថីនិទាន ។ គ្រានោះ ព្រាហ្មណមហាសាលម្នាក់ មានខ្លួនសៅហ្មង មានសំពត់ដណ្តប់ក៏សៅហ្មង ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណមហាសាលនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា

កិន្នុ ត្វំ ព្រាហ្មណ លូខោ លូខចាបុរណោតិ ។ ឥធ មេ ភោ គោតម ចត្តារោ បុត្តា តេ មំ ទារេហិ សំបុច្ឆ ឃរា និក្ខាមេន្តីតិ ។

[១៦៩] តេនហិ ត្វំ ព្រាហ្មណ ឥមា គាថាយោ បរិយាបុណិត្វា សភាយំ មហាជនកាយេ សន្និបតិតេ បុត្តេសុ ច សន្និសិន្នេសុ ភាសស្សុ

យេហិ ជាតេហិ នន្ទិស្សំ
យេសញ្ច ភវមិច្ឆិសំ
តេ មំ ទារេហិ សំបុច្ឆ
សាវ ភាទេន្តិ(១) សូករំ
អសន្តា កិរ មំ ជម្មា
តាត តាតាតិ ភាសរេ
រក្ខសា បុត្តរូបេន
តេ ជហន្តិ វយោគតំ

---

១ ឱ. ម. ភាវេន្តិ ។

ម្នាលព្រាហ្មណ៍ អ្នកឯងមានខ្លួនសៅហ្មង មានសំពត់ដណ្ដប់ក៏សៅហ្មង តើព្រោះហេតុអ្វី ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមានកូន ៤ នាក់ ក្នុងទីនេះ កូនទាំងនោះ សមគំនិតគ្នានឹងប្រពន្ធទាំងឡាយ ហើយបណ្ដេញខ្ញុំព្រះអង្គចេញពីផ្ទះ ។

[១៦៩] ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូររៀននូវគាថាទាំងឡាយនេះ ហើយសូត្រក្នុងរោងជាទីប្រជុំ នៅវេលាដែលពួកមហាជនប្រជុំគ្នាផង នៅវេលាដែលកូនទាំងឡាយ របស់អ្នកអង្គុយហើយផងថា

ខ្ញុំត្រេកអរ ដោយកូនទាំងឡាយណា ដែលកើតហើយផង ប្រាថ្នានូវសេចក្ដីចម្រើន ដល់កូនទាំងឡាយផង កូនទាំង-នោះ ក៏សមគំនិតគ្នាជាមួយនឹងប្រពន្ធទាំងឡាយ ហើយបណ្ដេញខ្ញុំ ដូចជាឆ្កែដេញជ្រូក ក៏កូនទាំងឡាយ ជាអសប្បុរសលាមក គ្រាន់តែហៅខ្ញុំថា បិតា បិតាប៉ុណ្ណោះទេ ប៉ុន្តែកូនទាំងនោះ ដូចអារក្សទឹកដែលមកដោយរូបជាកូន លះបង់នូវខ្ញុំដែលមានអាយុ ចូលដល់បច្ឆិមវ័យហើយ

អស្សោវ ជិណ្ណោ និព្ភោគោ
ខាទនា អបនីយតិ
ពាលកានំ បិតា ថេរោ
បរាគារេសុ ភិក្ខតិ
ទណ្ឌោវ កិរ មេ សេយ្យោ
យញ្ចេ បុត្តា អនស្សវា
ចណ្ឌម្បិ គោណំ វារេតិ
អថោ ចណ្ឌម្បិ កុក្កុរំ
អន្ធការេ បុរេ ហោតិ
គម្ភីរេ គាធមេធតិ
ទណ្ឌស្ស អានុភាវេន
ខលិត្វា បតិតិដ្ឋតីតិ ។

[១៧០] អថខោ សោ ព្រាហ្មណមហាសាលោ ភគវតោ សន្តិកេ ឥមា គាថាយោ បរិយាបុណិត្វា សភាយំ មហាជនកាយេ សន្និបតិតេ បុត្តេសុ ច សន្និសិន្នេសុ អភាសិ

បិតាចាស់របស់បុគ្គលពាលទាំងឡាយ តែងសូមទានប្របផ្ទះនៃជនដទៃ ដូចជាសេះចាស់ប្រើប្រាស់មិនបាន គេនាំចេញចាកចំណី ឈើច្រត់របស់ខ្ញុំប្រសើរ កូនទាំងឡាយ ដែលមិនស្តាប់បង្គាប់ មិនប្រសើរដូចឈើច្រត់ឡើយ ព្រោះឈើច្រត់ រមែងការពារគោកាចក៏បាន ការពារឆ្កែកាចក៏បាន ច្រត់ក្នុងខាងមុខ ក្នុងទីងងឹតក៏បាន ស្ទង់ក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់រអិល គង់ទប់វិញបាន ដោយអានុភាពនៃឈើច្រត់ ។

[១៧០] លំដាប់នោះ ព្រាហ្មណមហាសាលនោះ បានរៀននូវគាថាទាំងឡាយនេះ ក្នុងសំណាក់ព្រះមានព្រះភាគ ហើយពោលក្នុងរោងជាទីប្រជុំ នៅវេលាដែលពួកមហាជនប្រជុំគ្នាផង នៅវេលាដែលកូនទាំងឡាយ អង្គុយហើយផងថា

១២៧



យេហិ ជាតេហិ នន្ទិស្សំ
យេសញ្ច ភវមិច្ឆិសំ
តេ មំ ទារេហិ សំបុច្ឆ
សាវ វារេន្តិ សូករំ
អសន្តា កិរ មំ ជម្មា
តាត តាតាតិ ភាសរេ
រក្ខសា បុត្តរូបេន
តេ ជហន្តិ វយោគតំ
អស្សោវ ជិណ្ណោ និព្ភោគោ
ខាទនា អបនីយតិ
ពាលកានំ បិតា ថេរោ
បរាគារេសុ ភិក្ខតិ
ទណ្ឌោវ កិរ មេ សេយ្យោ
យញ្ចេ បុត្តា អនស្សវា
ចណ្ឌម្បិ គោណំ វារេតិ
អថោ ចណ្ឌម្បិ កុក្កុរំ

ព្រាហ្មណសំយុត្ត ឧបាសកវគ្គ ព្រាហ្មណ៍ពោលគាថា

ខ្ញុំត្រេកអរ ដោយកូនទាំងឡាយណា ដែលកើតហើយផង ប្រាថ្នានូវសេចក្តីចម្រើន ដល់កូនទាំងឡាយណាផង កូនទាំងនោះ ក៏សមគំនិតគ្នាជាមួយនឹងប្រពន្ធទាំងឡាយ ហើយបណ្តេញខ្ញុំ ដូចជាឆ្កែដេញជ្រូក ក៏កូនទាំងឡាយជាអសប្បុរសលាមក គ្រាន់តែហៅខ្ញុំថា បិតា បិតាប៉ុណ្ណោះទេ ប៉ុន្តែកូនទាំងនោះ ដូចអារក្សទឹកដែលមកដោយរូបជាកូន លះបង់នូវខ្ញុំដែលមានអាយុ ចូលដល់បច្ឆិមវ័យហើយ បិតាចាស់របស់បុគ្គលពាលទាំងឡាយ តែងសូមទានប្របផ្ទះនៃជនដទៃ ដូចជាសេះចាស់ប្រើប្រាស់មិនបាន គេនាំចេញចាកចំណី ឈើច្រត់របស់ខ្ញុំប្រសើរ កូនទាំងឡាយដែលមិនស្តាប់បង្គាប់ មិនប្រសើរដូចឈើច្រត់ឡើយ ព្រោះឈើច្រត់រមែងការពារគោកាចក៏បាន ការពារឆ្កែកាចក៏បាន ច្រត់

អង្គការេ ឋុរេ ហោតិ
គម្ភីរេ គាធមេធតិ
ធណ្ណាស្ស អាធុភាវេធ
ខលិត្វា បដិតិដ្ឋតីតិ ។

[១៧១] អថខោ ធំ ព្រាហ្មណមហាសាលំ ឋុត្តា យរំ ធេត្វា ធហាបេត្វា បច្ចុកំ ធុស្សយុគេធ អច្ឆាធេសុំ ។ អថខោ សោ ព្រាហ្មណមហាសាលោ ឯកំ ធុស្សយុគំ អាធាយ យេធ ភគវា តេធុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោធិ សម្មោធនីយំ កាថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីធិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណមហាសាលោ ភគវន្តំ ឯតធវោច មយំ ភោ គោតម ព្រាហ្មណា ធាម អាចរិយស្ស អាចរិយធនំ បរិយេសាម បដិគ្គណ្ហាតុ មេ ភវំ គោតមោ អាចរិយោ អាចរិយភាគន្តិ ។ បដិគ្គហេសិ ភគវា អនុកម្បំ ឧចាធាយ ។

[១៧២] អថខោ សោ ព្រាហ្មណមហាសាលោ ភគវន្តំ ឯតធវោច អភិក្កន្តំ ភោ គោតម ។ បេ ។

*ក្នុងខាងមុខ ក្នុងទីងងឹតក៏បាន ស្ទង់ក្នុងទឹកជ្រៅក៏បាន បុគ្គល ភ្ញាក់រអិល គង់ទប់វិញបាន ដោយអានុភាពនៃឈើច្រត់ ។*

[១៧១] *លំដាប់នោះ កូនទាំងឡាយ នាំព្រាហ្មណមហាសាល នោះទៅកាន់ផ្ទះ ហើយឲ្យងូតទឹក ឲ្យស្លៀកដណ្តប់ ដោយគូសំពត់ មួយគូ ម្នាក់ ៗ ។ ទើបព្រាហ្មណមហាសាលនោះ យកសំពត់មួយគូ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីក-រាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ-មហាសាលនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំព្រះអង្គជា ព្រាហ្មណ៍ ស្វែងរកនូវទ្រព្យសម្រាប់អាចារ្យ* (មកប្រគេន) *ដល់អាចារ្យ សូមព្រះគោតមដ៏ចម្រើនជាអាចារ្យ ទទួលយកនូវចំណែកអាចារ្យរបស់ ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ទទួលយក ដោយសេចក្តី អនុគ្រោះ ។*

[១៧២] *លំដាប់នោះ ព្រាហ្មណមហាសាលនោះ ក្រាបទូលព្រះមាន ព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺណាស់ ។ បេ ។*

១២៩

ព្រាហ្មណសំយុត្តស្ស ឧបាសកវគ្គេ មានត្ថទ្ធស្ស បរិវិតក្កនំ

ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

## បញ្ចមំ មានត្ថទ្ធសុត្តំ

[១៧៣] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន មានត្ថទ្ធោ នាម ព្រាហ្មណោ សាវត្ថិយំ បដិវសតិ ។ សោ នេវ មាតរំ អភិវាទេតិ ន បិតរំ អភិវាទេតិ ន អាចរិយំ អភិវាទេតិ ន ជេដ្ឋភាតរំ អភិវាទេតិ ។

[១៧៤] តេន ខោ បន សមយេន ភគវា មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេតិ ។ អថខោ មានត្ថទ្ធស្ស ព្រាហ្មណស្ស ឯតទហោសិ អយំ ខោ សមណោ គោតមោ មហតិយា បរិយាយ បរិវុតោ ធម្មំ ទេសេតិ យន្នូនាហំ យេន សមណោ គោតមោ តេនុបសង្កមេយ្យំ សចេ មំ សមណោ គោតមោ អាលបិស្សតិ អហម្បិ តំ អាលបិស្សាមិ នោ ចេ មំ សមណោ គោតមោ អាលបិស្សតិ អហម្បិ តំ នាលបិស្សាមីតិ ។

*សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។*

# មានត្ថទ្ធសូត្រ ទី ៥

[១៧៣] *សាវត្ថីនិទាន ។ សម័យនោះឯង ព្រាហ្មណ៍ឈ្មោះមានត្ថទ្ធៈ (អ្នកមានមានះរឹងរូស) អាស្រ័យនៅ ក្នុងក្រុងសាវត្ថី ។ ព្រាហ្មណ៍នោះ មិនសំពះមាតា មិនសំពះបិតា មិនសំពះអាចារ្យ មិនសំពះបងឡើយ ។*

[១៧៤] *សម័យនោះឯង ព្រះមានព្រះភាគ កំពុងមានបរិស័ទច្រើនចោមរោម ទ្រង់សំដែងធម៌ ។ គ្រានោះ មានត្ថទ្ធព្រាហ្មណ៍មានសេចក្តីត្រិះរិះ យ៉ាងនេះថា ព្រះសមណគោតមនេះឯង មានបរិស័ទច្រើនចោមរោម ទ្រង់សំដែងធម៌ បើដូច្នោះ មានតែអាត្មាអញចូលទៅរកព្រះសមណគោតម ប្រសិនបើព្រះសមណគោតម និយាយនិងអាត្មាអញ អាត្មាអញ ក៏និយាយនឹងលោកវិញ បើព្រះសមណគោតម មិននិយាយនឹងអាត្មាអញទេ អាត្មាអញ ក៏មិននិយាយនឹងលោកវិញដែរ ។*

អថខោ មានត្ថទ្ធោ ព្រាហ្មណោ យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា[១] ឯកមន្តំ អដ្ឋាសិ ។ អថខោ ភគវា[២] នាលបតិ ។ អថខោ មានត្ថទ្ធោ ព្រាហ្មណោ នាយំ សមណោ គោតមោ កិញ្ចិ ជានាតីតិ តតោ វ បុន និវត្តិតុកាមោ អហោសិ ។

[១៧៥] អថខោ ភគវា មានត្ថទ្ធស្ស ព្រាហ្មណស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ មានត្ថទ្ធំ ព្រាហ្មណំ គាថាយ អជ្ឈភាសិ

ន មានំ ព្រាហ្មណ សាធុ
អត្ថិ កស្សីធ ព្រាហ្មណ
យេន អត្ថេន អាគញ្ឆិ
តមេវមនុព្រូហយេតិ ។

[១៧៦] អថខោ មានត្ថទ្ធោ ព្រាហ្មណោ ចិត្តំ មេ សមណោ គោតមោ ជានាតីតិ តត្ថេវ ភគវតោ បាទេសុ សិរសា និបតិត្វា ភគវតោ បាទានិ មុខេ-ន បរិចុម្ពតិ បាណីហិ ច បរិសម្ពាហតិ នាមំ ច

១ ឱ. ម. ឯត្ថន្តរេ តុណ្ហីភូតោតិ ទិស្សតិ ។ ២ ឱ. ម. ឯត្ថន្តរេ តន្តិ ទិស្សតិ ។

លំដាប់នោះ មានត្ថទ្ធព្រាហ្មណ៍ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះមានព្រះភាគ មិនទ្រង់មានព្រះបន្ទូលរក ។ ទើបមានត្ថទ្ធព្រាហ្មណ៍ចង់ត្រឡប់អំពីទីនោះវិញ ដោយគិតថា ព្រះសមណគោតមនេះ មិនដឹងអ្វីសោះ ។

[១៧៥] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបរិវិតក្កៈក្នុងចិត្តរបស់មានត្ថទ្ធព្រាហ្មណ៍ ដោយព្រះហឫទ័យរបស់ព្រះអង្គ ហើយបានត្រាស់នឹងមានត្ថទ្ធព្រាហ្មណ៍ ដោយគាថា ថា

ម្នាលព្រាហ្មណ៍ មានះរបស់បុគ្គលណា ក្នុងលោកនេះ
ម្នាលព្រាហ្មណ៍ មានះនោះ មិនប្រពៃទេ បុគ្គលមកហើយ
ដោយប្រយោជន៍ណា បុគ្គលត្រូវចម្រើន នូវប្រយោជន៍
នោះឯង ។

[១៧៦] លំដាប់នោះ មានត្ថទ្ធព្រាហ្មណ៍ដឹងថា ព្រះសមណ-គោតមស្គាល់ចិត្តរបស់អាត្មាអញ ហើយក៏ឱនក្បាលចុះ ទៀបព្រះបាទយុគ្គលនៃព្រះមានព្រះភាគ ក្នុងទីនោះឯង ហើយជប់ព្រះបាទទាំងគូរបស់ព្រះមានព្រះភាគ ដោយមាត់ផង ច្របាច់ដោយដៃទាំងពីរផង

សាវេតិ មានត្ថទ្ធាហំ ភោ គោតម មានត្ថទ្ធាហំ ភោ គោតមាតិ ។ អថខោ សា បរិសា អព្ភុតចិត្តជាតា អហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ អយញ្ហិ មានត្ថទ្ធោ ព្រាហ្មណោ នេវ មាតរំ អភិវាទេតិ ន បិតរំ អភិវាទេតិ ន អាចរិយំ អភិវាទេតិ ន ជេដ្ឋភាតរំ អភិវាទេតិ អថ ច បន សមណេ គោតមេ ឯវរូបំ បរមនិបច្ចការំ ករោតីតិ ។ អថខោ ភគវា មានត្ថទ្ធំ ព្រាហ្មណំ ឯតទវោច អលំ ព្រាហ្មណ ឧដ្ឋេហិ សកេ អាសនេ និសីទ យតោ តេ មយិ ចិត្តំ បសន្នន្តិ ។

[១៧៧] អថខោ មានត្ថទ្ធោ ព្រាហ្មណោ សកេ អាសនេ និសីទិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

កេសុ ន មានំ កយិរាថ
កថំ ស្វស្ស សគារវោ
ក្យស្ស អបចិតា អស្សុ
ក្យស្ស សាធុ សុបូជិតាតិ ។

ប្រកាសនាមខ្លួនឯងថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គ ឈ្មោះមានត្ថទ្ធៈ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គ ឈ្មោះមានត្ថទ្ធៈ ។ គ្រានោះ បរិស័ទនោះ ក៏កើតសេចក្តីអស្ចារ្យក្នុងចិត្តថា យីអើ អស្ចារ្យណាស់ យីអើ ចំឡែកណាស់ ដ្បិតមានត្ថទ្ធព្រាហ្មណ៍នេះ មិនសំពះមាតា មិនសំពះបិតា មិនសំពះអាចារ្យ មិនសំពះបងឡើយ ទើបតែព្រះសមណគោតម ធ្វើនូវមនុស្សបែបនេះ ឲ្យធ្វើនូវការគោរពដ៏ក្រៃលែងបាន ។ គ្រានោះ ព្រះមានព្រះភាគ បានត្រាស់នូវពាក្យនេះនឹងមានត្ថទ្ធព្រាហ្មណ៍ ថា ម្នាលព្រាហ្មណ៍ ណ្ហើយ អ្នកចូរក្រោកឡើង ចូរអង្គុយលើអាសនៈរបស់ខ្លួនចុះ ព្រោះថា ចិត្តរបស់អ្នកជ្រះថ្លាក្នុងតថាគតហើយ ។

[១៧៧] គ្រានោះ មានត្ថទ្ធព្រាហ្មណ៍ អង្គុយលើអាសនៈរបស់ខ្លួនហើយ បានក្រាបទូលព្រះមានព្រះភាគ ដោយគាថា ថា

បុគ្គលមិនគួរធ្វើមានះ ក្នុងពួកបុគ្គលណា បុគ្គលគួរប្រកប
ដោយសេចក្តីគោរព ក្នុងបុគ្គលណា ពួកបុគ្គលណា ដែល
បុគ្គលគប្បីលំអុតលំអោន ពួកបុគ្គលណា ដែលបុគ្គល
បូជាល្អហើយ ញុំាងប្រយោជន៍ឲ្យសម្រេច ។

[១៧៨] មាតរី បិតរិ វាបិ

អថោ ជេដ្ឋម្ហិ ភាតរិ

អាចរិយេ ចតុត្ថម្ហិ

តេសុ អស្ស សគារវោ[(១)]

ត្យស្សុ អបចិតា អស្សុ

តេ ចស្សុ សាធុ បូជិតា

អរហន្តេ សីតិភូតេ

កតកិច្ចេ អនាសវេ

និហច្ច មានំ អត្ថទ្ធោ

តេន អនុសយេន អនុត្តរេតិ ។

[១៧៩] ឯវំ វុត្តេ មានត្ថទ្ធោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

១ ឱ. ម. តេសុ ន មានំ កយិរាថ ។

[១៧៨] ព្រះអង្គត្រាស់ថា បុគ្គលមិនគួរធ្វើមានះចំពោះ មាតា បិតា បង និងអាចារ្យ ជាគម្រប់ ៤ គួរប្រកបដោយ សេចក្តីគោរព ចំពោះបុគ្គលទាំង ៤ នោះ បុគ្គលទាំង ៤ នោះ បុគ្គលគួរលំអុតលំអោន មួយទៀត បុគ្គលទាំង ៤ នោះ ដែលគេបូជាល្អហើយ ញុំាងប្រយោជន៍ឲ្យសម្រេច បុគ្គលគួរកម្ចាត់មានះ មិនគួររឹងត្អឹងដោយអនុស័យ គឺមានះ នោះ ចំពោះព្រះអរហន្ត ដែលមានសេចក្តីត្រជាក់ មាន សោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ជាអ្នកប្រសើរ ។

[១៧៩] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មានត្ថទ្ធព្រាហ្មណ៍ បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃ នេះជាដើមរៀងទៅ ។

១៣៣

ព្រាហ្មណសំយុត្តស្ស ឧបាសកវគ្គេ ភគវន្តូបសង្កមនំ

# ឆដ្ឋំ បច្ចនិកសុត្តំ

[១៨០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន បច្ចនិកសាតោ[១] នាម ព្រាហ្មណោ សាវត្ថិយំ បដិវសតិ ។ អថខោ បច្ចនិកសាតស្ស ព្រាហ្មណស្ស ឯតទហោសិ យន្នូនាហំ យេន សមណោ គោតមោ តេនុបសង្កមេយ្យំ យំ យទេវ សមណោ គោតមោ ភាសិស្សតិ តំ តទេវស្សាហំ បច្ចនិកាស្សន្តិ ។

[១៨១] តេន ខោ បន សមយេន ភគវា អព្ភោកាសេ ចង្កមតិ ។ អថខោ បច្ចនិកសាតោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ចង្កមន្តំ អនុចង្កមមានោ ភគវន្តំ ឯតទវោច ភណ សមណ ធម្មន្តិ ។

---

១ បច្ចនីកំ ឥតិបិ បាឋោ ឯវំ សព្វត្ថ ។

# បច្ចនិកសូត្រ ទី ៦

[១៨០] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រាហ្មណ៍ ឈ្មោះបច្ចនិកសាតៈ (អ្នកមានសេចក្តីសុខជាសត្រូវ) អាស្រ័យនៅ ក្នុងក្រុងសាវត្ថី ។ គ្រានោះ បច្ចនិកសាត-ព្រាហ្មណ៍ មានសេចក្តីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ មានតែអាត្មាអញចូលទៅរកព្រះសមណគោតម បើព្រះសមណគោតម នឹងពោលនូវពាក្យណា ៗ អាត្មាអញគប្បីពោលទាស់នឹងពាក្យនោះ ៗ របស់លោក ។*

[១៨១] *សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ចង្រ្កមក្នុងទីវាល ។ គ្រានោះ បច្ចនិកសាតព្រាហ្មណ៍ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ដើរតាមព្រះមានព្រះភាគ ដែលកំពុងចង្រ្កម ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះសមណៈ សូមព្រះអង្គសំដែងធម៌ ។*

[១៨២] ន បច្ចនិកសាតេន
សុវិជានំ សុភាសិតំ
ឧបក្កិលិដ្ឋចិត្តេន
សារម្ភពហុតេន ច
យោ ច វិនេយ្យ សារម្ភំ
អប្បសាទញ្ច ចេតសោ
អាឃាតំ បដិនិស្សជ្ជ
សវេ[១] ជញ្ញា សុភាសិតន្តិ ។

[១៨៣] ឯវំ វុត្តេ បច្ចនិកសាតោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

១ ឱ. សវេ ។

[១៨២] ព្រះអង្គត្រាស់ថា បច្ចនិកសាតព្រាហ្មណ៍ មានចិត្តសៅហ្មង ច្រើនដោយការប្រណាំងប្រជែង មិនងាយនឹងដឹងសុភាសិតទេ លុះតែបុគ្គលណា នាំចេញនូវការប្រណាំងប្រជែងផង នូវសេចក្ដីមិនជ្រះថ្លានៃចិត្តផង លះបង់នូវគំនុំផង បុគ្គលនោះ ទើបដឹងនូវសុភាសិតបាន ។

[១៨៣] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ បច្ចនិកសាតព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក ដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

១៣៥

ព្រាហ្មណសំយុត្តស្ស ឧបាសកវគ្គេ ភគវន្តូបសង្កមនំ

# សត្តមំ នវកម្មិកសុត្តំ

[១៨៤] ឯកំ សមយំ ភគវា កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន នវកម្មិកភារទ្វាជោ ព្រាហ្មណោ តស្មឹ វនសណ្ឌេ កម្មន្តំ ការាបេតិ ។ អទ្ទសា ខោ នវកម្មិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ អញ្ញតរស្មឹ សាលរុក្ខមូលេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ ទិស្វានស្ស ឯតទហោសិ អហំ ខោ ឥមស្មឹ វនសណ្ឌេ កម្មន្តំ ការាបេន្តោ រមាមិ អយំ សមណោបិ កឹ ការាបេន្តោ រមតីតិ ។

[១៨៥] អថខោ នវកម្មិកភារទ្វាជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

កេ នុ កម្មន្តា កយិរន្តិ
ភិក្ខុ សាលវនេ តវ
យទេកកោ អរញ្ញស្មឹ
រតឹ វិន្ទតិ គោតមោតិ ។

# នវកម្មិកសូត្រ ទី ៧

[១៨៤] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ សម័យនោះឯង នវកម្មិកភារទ្វាជ-ព្រាហ្មណ៍ ឲ្យគេធ្វើការងារ ក្នុងដងព្រៃនោះ ។ នវកម្មិកភារទ្វាជ-ព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគ គង់ក្រោមម្លប់សាលព្រឹកមួយ ផ្គត់ព្រះភ្នែន តាំងព្រះកាយត្រង់ តម្កល់ស្មារតី ឆ្ពោះត្រង់ទៅរកព្រះកម្មដ្ឋាន ។ លុះឃើញហើយ ទើបនវកម្មិកព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញឲ្យគេធ្វើការងារ ក្នុងដងព្រៃនេះ កំពុងសប្បាយចុះព្រះសមណៈនេះ ឲ្យគេធ្វើការងារអ្វី សប្បាយដែរ ។

[១៨៥] ទើបនវកម្មិកភារទ្វាជព្រាហ្មណ៍ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏បានពោលនឹងព្រះមានព្រះភាគដោយគាថា ថា

នែភិក្ខុ លោកធ្វើការងារដូចម្តេច បានជាលោកមកនៅក្នុង
ព្រៃសាលព្រឹក្ស ព្រះគោតមតែមួយអង្គទេ ចុះបានសេចក្តី
ត្រេកអរណា ក្នុងព្រៃកើត ។

[១៨៦] ន ច មេ វនស្មឹ ករណីយមត្ថិ
ឧច្ឆិន្នមូលំ មេ វនំ វិសូកំ
ស្វាហំ វនេ និព្វនថោ វិសល្លោ
ឯកោ រមេ អរតឹ វិប្បហាយាតិ ។

[១៨៧] ឯវំ វុត្តេ នវកម្មិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

## អដ្ឋមំ កដ្ឋហារសុត្តំ

[១៨៨] ឯកំ សមយំ ភគវា កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស សម្ពហុលា អន្តេវាសិកា កដ្ឋហារកា មាណវកា យេន សោ វនសណ្ឌោ តេនុបសង្កមឹសុ ឧបសង្កមិត្វា

[១៨៦] ព្រះអង្គត្រាស់ថា តថាគត មិនមានកិច្ចដែលត្រូវធ្វើក្នុងព្រៃទេ ព្រៃគឺកិលេសជាសត្រូវ តថាគត បានដកឫសគល់អស់ហើយ តថាគតនោះ ជាបុគ្គលម្នាក់ឯង មិនមានព្រៃគឺកិលេសទេ ទាំងសរគឺកិលេស វិនាសអស់ហើយ តថាគតលះបង់នូវសេចក្តីអផ្សុកហើយ ទើបត្រេកអរ ក្នុងព្រៃបាន ។

[១៨៧] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ នវកម្មិកភារទ្វាជព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

# កដ្ឋហារសូត្រ ទី ៨

[១៨៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ សម័យនោះឯង មានពួកមាណពជាច្រើន ជាអ្នកនាំឧស ជាអន្តេវាសិក របស់ព្រាហ្មណ៍ភារទ្វាជ-គោត្តម្នាក់ នាំគ្នាចូលទៅកាន់ដងព្រៃនោះ លុះចូលទៅដល់ហើយ

អទ្ទសំសុ ភគវន្តំ តស្មឹ វនសណ្ឌេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ទិស្វាន យេន ភារទ្វាជគោត្តោ ព្រាហ្មណោ តេនុបសង្កមឹសុ ឧបសង្កមិត្វា ភារទ្វាជគោត្តំ ព្រាហ្មណំ ឯតទវោចុំ យគ្ឃេ ភវំ ជានេយ្យ អសុកស្មឹ វនសណ្ឌេ សមណោ គោតមោ និសិន្នោ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វាតិ ។

[១៨៩] អថខោ ភារទ្វាជគោត្តោ ព្រាហ្មណោ តេហិ មាណវកេហិ សទ្ធឹ យេន សោ វនសណ្ឌោ តេនុប-សង្កមិ ឧបសង្កមិត្វា អទ្ទស ភគវន្តំ តស្មឹ វនសណ្ឌេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ទិស្វាន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

ក៏បានឃើញព្រះមានព្រះភាគ ទ្រង់គង់ក្នុងដងព្រៃនោះ ផ្គត់ព្រះភ្នែន តាំងព្រះកាយត្រង់ តម្កល់ព្រះស្មារតី ឆ្ពោះត្រង់ទៅរកកម្មដ្ឋាន លុះឃើញហើយ ក៏ចូលទៅរកភារទ្វាជគោត្តព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏បានពោលនូវពាក្យនេះ នឹងភារទ្វាជគោត្តព្រាហ្មណ៍ថា សូមជំរាបលោក សូមលោកដ៏ចម្រើន គប្បីជ្រាប ដ្បិតព្រះសមណគោតម គង់ក្នុងដងព្រៃឯណោះ ផ្គត់ព្រះភ្នែន តាំងព្រះកាយត្រង់ តម្កល់ព្រះស្មារតី ឆ្ពោះត្រង់ទៅរកកម្មដ្ឋាន ។

[១៨៩] គ្រានោះ ភារទ្វាជគោត្តព្រាហ្មណ៍ ចូលទៅកាន់ដងព្រៃនោះ ជាមួយនឹងមាណពទាំងអម្បាលនោះ លុះចូលទៅដល់ហើយ បានឃើញព្រះមានព្រះភាគ ទ្រង់គង់ក្នុងដងព្រៃនោះ ផ្គត់ព្រះភ្នែន តាំងព្រះកាយត្រង់ តម្កល់ព្រះស្មារតី ឆ្ពោះត្រង់ទៅរកកម្មដ្ឋាន លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានពោលនឹងព្រះមានព្រះភាគ ដោយគាថា ថា

គម្ភីររូបេ ពហុភេរវេ វនេ
សុញ្ញំ អរញ្ញំ វិជនំ វិគាហិយ
អនិញ្ជមានេន ឋិតេន វគ្គុនា
សុចារុរូបំ វត ភិក្ខុ ឈាយសិ
ន យត្ថ គីតំ នបិ យត្ថ វាទិតំ
ឯកោ អរញ្ញេ វនវស្សិតោ មុនិ
អច្ឆេររូបំ បដិភាតិ មំ ឥទំ
យទេកកោ បីតិមនោ វនេ វសេ
មញ្ញមហំ(១) លោកាធិបតិសហព្យតំ
អាកង្ខមានោ តិទិវំ អនុត្តរំ
កស្មា ភវំ វិជនមរញ្ញមស្សិតោ
តបោ ឥធ កុព្វតិ ព្រហ្មបត្តិយាតិ ។

[១៩០] យា កាចិ កង្ខា អភិនន្ទនា វា
អនេកធាតូសុ បុថូ សទា សិតា
អញ្ញាណមូលប្បភវា បជប្បិតា

១ ឱ. បញ្ញេហំ ។

បពិត្រភិក្ខុ អ្នកចូលមករកព្រៃស្ងាត់ ឥតមានមនុស្ស ជាព្រៃដ៏ជ្រៅគួរឲ្យខ្លាចច្រើន លោកមានកាយដ៏ល្អ ប្រកបដោយប្រយោជន៍ មិនបានញាប់ញ័រ ទើបចម្រើនឈានដ៏ល្អក្រៃពេកបាន ក្នុងព្រៃណាគ្មានចំរៀង ឬក្នុងព្រៃណាគ្មានល្បែងប្រគំ ព្រះមុនីក៏អាស្រ័យនៅ ក្នុងព្រៃនោះតែម្នាក់ឯង ព្រះមុនីមានចិត្តត្រេកអរ នៅក្នុងព្រៃម្នាក់ឯង ដោយហេតុណាហេតុនេះ ជាការអស្ចារ្យប្រាកដដល់ខ្ញុំ ខ្ញុំកំពុងប្រាថ្នានូវត្រីទិព្វ គឺព្រហ្មលោកដ៏ប្រសើរ សម្គាល់លោកថាជាអ្នកទៅកើតជាមួយនឹងមហាព្រហ្មជាធំក្នុងលោកដែរ ព្រោះហេតុអ្វីលោកដ៏ចម្រើនអាស្រ័យនៅ ក្នុងព្រៃដែលឥតមនុស្ស លោកធ្វើនូវតបៈក្នុងទីនេះ ដើម្បីដល់នូវព្រហ្មលោកឬ ។

[១៩០] ព្រះអង្គត្រាស់ថា ធម្មជាតិណាមួយ គឺសេចក្ដីប្រាថ្នាក្ដី សេចក្ដីត្រេកអរក្ដី មានប្រការផ្សេង ៗ អាស្រ័យនៅក្នុងធាតុទាំងឡាយ គឺអារម្មណ៍មានសភាព មិនតែមួយសព្វ ៗ កាល មានការមិនដឹងជាមូល ប្រកពជាគ្រឿង

សញ្ញា មយា ព្យន្តិកតា សម្ពុលិកា
ស្វាហំ អកាង្ខោ អសិតោ អនូបយោ
សព្វេសុ ធម្មេសុ វិសុទ្ធចក្ខុ
បប្បុយ្យ សម្ពោធិមនុត្តរំ សិវំ
ឈាយាមហំ ព្រហ្មរហោ វិសារទោតិ ។

[១៩១] ឯវំ វុត្តេ ភារទ្វាជគោត្តោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ អជ្ជតគ្គេ បាណុបេតំ សរ-ណាគតន្តិ ។

ញុំាំងជនឲ្យជាប់ចំពាក់ ធម្មជាតិទាំងអស់នោះ តថាគត បានធ្វើឲ្យវិនាស ព្រមទាំងឫសគល់អស់ហើយ តថាគតនោះ មិនប្រាថ្នា មិនអាស្រ័យនូវតណ្ហា មិនចូលទៅរកតណ្ហា (និងអវិជ្ជាឡើយ) មានសេចក្តីឃើញដ៏បរិសុទ្ធ ក្នុងធម៌ទាំងពួង ហើយដល់ នូវសម្ពោធិញ្ញាណដ៏ប្រសើរក្រៃលែង តថាគត គួរដល់ព្រហ្មលោក ជាអ្នកក្សៀវក្លា តែងដុតបំផ្លាញនូវកិលេស (ដោយឈានទាំងពីរ) ។

[១៩១] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភារទ្វាជគោត្តព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

# នវមំ មាតុបោសកសុត្តំ

[១៩២] សាវត្ថីនិទានំ ។ អថខោ មាតុបោសកោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មាតុបោសកោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អហញ្ហិ ភោ គោតម ធម្មេន ភិក្ខំ បរិយេសាមិ ធម្មេន ភិក្ខំ បរិយេសិត្វា មាតាបិតរោ បោសេមិ កច្ចាហំ ភោ គោតម ឯវំការី កិច្ចការី ហោមីតិ ។ តគ្ឃ ត្វំ ព្រាហ្មណ ឯវំការី កិច្ចការី អហោសិ យោ ខោ ព្រាហ្មណ ធម្មេន ភិក្ខំ បរិយេសតិ ធម្មេន ភិក្ខំ បរិយេសិត្វា មាតាបិតរោ បោសេតិ ពហុំ សោ បុញ្ញំ បសវតីតិ ។

# មាតុបោសកសូត្រ ទី ៩

[១៩២] *សាវត្ថីនិទាន ។ គ្រានោះ ព្រាហ្មណ៍ឈ្មោះមាតុ-បោសកៈ (អ្នកចិញ្ចឹមមាតា) ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះមាតុបោសកព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គស្វែងរកនូវភិក្ខាដោយធម៌ លុះស្វែងរកនូវភិក្ខាដោយធម៌ហើយ តែងចិញ្ចឹមនូវមាតាបិតា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គធ្វើយ៉ាងនេះ ឈ្មោះថាជាអ្នកធ្វើ នូវកិច្ច (តបគុណ) បានដែរឬ ។ ព្រះអង្គត្រាស់ថា អើព្រាហ្មណ៍ អ្នកធ្វើយ៉ាងនេះ ឈ្មោះថាជាអ្នកធ្វើនូវកិច្ច (តបគុណ) បានហើយ ម្នាលព្រាហ្មណ៍ បុគ្គលណាស្វែងរក នូវភិក្ខាដោយធម៌ លុះស្វែងរកនូវភិក្ខាដោយធម៌ហើយ ចិញ្ចឹមមាតាបិតា បុគ្គលនោះ តែងបានបុណ្យដ៏ច្រើន ។*

ព្រាហ្មណសំយុត្តស្ស ឧបាសកវគ្គេ សរណគមនំ

[១៩៣] ឥធមវោច ។ បេ ។

យោ មាតរំ បិតរំ វា

មច្ចោ ធម្មេន ពោសតិ

តាយ នំ បារិចរិយាយ

មាតាបិតូសុ បណ្ឌិតា

ឥធេវ នំ បសំសន្តិ

បេច្ច សគ្គេ បមោទតីតិ ។

[១៩៤] ឯវំ វុត្តេ មាតុពោសកោ ព្រាហ្មណោ

ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ

ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ

ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណាគ្គតន្តិ ។

[១៩៣] ព្រះមានព្រះភាគ បានត្រាស់នូវពាក្យនេះ ។ បេ ។

បុគ្គលណា ចិញ្ចឹមមាតាឬបិតាដោយធម៌ បណ្ឌិតទាំងឡាយ
រមែងសរសើរបុគ្គលនោះ ក្នុងលោកនេះ ព្រោះការបម្រើ
មាតាបិតាទាំងឡាយនោះ លុះបុគ្គលនោះ ទៅកាន់បរលោក
ហើយ រមែងរីករាយ ក្នុងឋានសួគ៌ ។

[១៩៤] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មាតុបោសកព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃ នេះជាដើមរៀងទៅ ។

# ទសមំ ភិក្ខកសុត្តំ

[១៩៥] សាវត្ថីនិទានំ ។ អថខោ ភិក្ខកោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភិក្ខកោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អហម្បិ[១] ភោ គោតម ភិក្ខកោ ភវម្បិ ភិក្ខកោ ឥធ នោ កឹ នានាករណន្តិ ។

[១៩៦] ន តេន ភិក្ខកោ ហោតិ
យាវតា ភិក្ខតេ បរេ
វិសំ ធម្មំ សមាទាយ
ភិក្ខុ ហោតិ ន តាវតា
យោធ បុញ្ញញ្ច បាបញ្ច
បាហេត្វា ព្រហ្មចរិយំ
សង្ខាយ លោកេ ចរតិ
ស វេ ភិក្ខូតិ វុច្ចតីតិ ។

១ ឱ. ម. អហម្បិ ។

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ

# ភិក្ខកសូត្រ ទី ១០

[១៩៥] សាវត្ថីនិទាន ។ គ្រានោះឯង ភិក្ខកព្រាហ្មណ៍ (ព្រាហ្មណ៍អ្នកសូម) បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខកព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គ ជាអ្នកសូមគេ ឯព្រះអង្គ ក៏ជាអ្នកសូមគេដែរ យើងទាំងពីរនាក់ផ្សេងគ្នាដូចម្តេច ក្នុងពាក្យថា អ្នកសូមនេះ ។

[១៩៦] ព្រះអង្គត្រាស់ថា បុគ្គលណា សូមពួកជនដទៃ
ដោយហេតុណា បុគ្គលនោះ មិនឈ្មោះថាភិក្ខុ (អ្នកសូម)
ដោយហេតុនោះឡើយ បុគ្គលណាកាន់ធម៌មានពិស គឺ
អកុសលធម៌ បុគ្គលនោះ ក៏មិនឈ្មោះថាភិក្ខុដែរ ក្នុង
លោកនេះ លុះតែបុគ្គលណា បានបណ្តោតបង់នូវបុណ្យនិង
បាបចេញ ហើយប្រព្រឹត្តមគ្គព្រហ្មចរិយៈ ក្នុងខន្ធាទិលោក ។
ដោយបញ្ញា បុគ្គលនោះ ទើបតថាគតហៅថា ភិក្ខុពិត ។

[១៩៧] ឯវំ វុត្តេ ភិក្ខកោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

# ឯកាទសមំ សង្គារវសុត្តំ

[១៩៨] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន សង្គារវោ នាម ព្រាហ្មណោ សាវត្ថិយំ បដិវសតិ ឧទកសុទ្ធិកោ ឧទកេន សុទ្ធឹ បច្ចេតិ សាយបាតំ ឧទកោរោហណានុយោគមនុយុត្តោ វិហរតិ ។ អថ-ខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិយំ បិណ្ឌាយ បាវិសិ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១៩៧] *កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខកព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹង ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។*

# សង្គារវសូត្រ ទី ១១

[១៩៨] *សាវត្ថីនិទាន ។ សម័យនោះឯង សង្គារវព្រាហ្មណ៍ អាស្រ័យនៅក្នុងក្រុងសាវត្ថី មានសេចក្តីសម្គាល់ថា ទឹកជារបស់បរិសុទ្ធ រមែងប្រាថ្នាការបរិសុទ្ធដោយទឹក ប្រកបការព្យាយាមចុះទឹករឿយ ៗ ក្នុងវេលាល្ងាចព្រឹក ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាព្រឹក ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីរួចហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ទើបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។*

[១៩៩] ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធ ភន្តេ សង្គារវោ នាម ព្រាហ្មណោ សាវត្ថិយំ បដិវសតិ ឧទកសុទ្ធិកោ ឧទកេន សុទ្ធឹ បច្ចេតិ សាយចាតំ ឧទកោរោហណានុយោគមនុយុត្តោ វិហរតិ សាធុ ភន្តេ ភគវា យេន សង្គារវស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន សង្គារវស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។

[២០០] អថខោ សង្គារវោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សង្គារវំ ព្រាហ្មណំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ ព្រាហ្មណ ឧទកសុទ្ធិកោ

[១៩៩] លុះព្រះអានន្ទ មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សង្គារវ-ព្រាហ្មណ៍ អាស្រ័យនៅក្នុងក្រុងសាវត្ថីនេះ មានសេចក្តីសម្គាល់ថា ទឹកជារបស់បរិសុទ្ធ តែងប្រាថ្នាការបរិសុទ្ធដោយទឹក ប្រកបសេចក្តីព្យាយាមចុះទឹករឿយ ៗ ក្នុងវេលាល្ងាចព្រឹក បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យសេចក្តីអនុគ្រោះ ស្តេចចូលទៅកាន់លំ-នៅរបស់សង្គារវព្រាហ្មណ៍ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយភាពស្ងៀម ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរក្នុងវេលាព្រឹក ហើយស្តេចចូលទៅកាន់លំនៅ របស់សង្គារវព្រាហ្មណ៍ ។ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលព្រាហ្មណ៍ក្រាលថ្វាយ ។

[២០០] លំដាប់នោះឯង សង្គារវព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះសង្គារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលព្រាហ្មណ៍ បានឮថា អ្នកមានសេចក្តីសម្គាល់ថា ទឹកជារបស់បរិសុទ្ធ

ឧទកេន សុទ្ធឹ បច្ចេសិ សាយបាតំ ឧទកោរោហណានុយោគមនុយុត្តោ វិហរសីតិ ។ ឯវំ ភោ គោតមាតិ ។ កឹ បន ត្វំ ព្រាហ្មណ អត្ថវសំ សម្បស្សមានោ ឧទកសុទ្ធិកោ ឧទកេន សុទ្ធឹ បច្ចេសិ សាយបាតំ ឧទកោរោហណានុយោគមនុយុត្តោ វិហរសីតិ ។ ឥធ មេ ភោ គោតម យំ ទិវា បាបកម្មំ កតំ ហោតិ តំ សាយំ នហានេន បវាហេមិ យំ រត្តឹ បាបកម្មំ កតំ ហោតិ តំ បាតំ នហានេន បវាហេមិ ឥមំ ច ខ្វាហំ ភោ គោតម អត្ថវសំ សម្បស្សមានោ ឧទកសុទ្ធិកោ ឧទកេន សុទ្ធឹ បច្ចេមិ សាយបាតំ ឧទកោរោហណានុយោគមនុយុត្តោ វិហរាមីតិ ។

[២០១] ធម្មោ រហទោ ព្រាហ្មណ សីលតិត្ថោ
អនាវិលោ សព្ភិ សតំ បសត្ថោ
យត្ថ ហវេ វេទគុនោ សិនាតា
អនល្លគត្តា វ តរន្តិ បារន្តិ ។

តែងប្រាថ្នាការបរិសុទ្ធដោយទឹក ប្រកបសេចក្ដីព្យាយាម ចុះទឹករឿយ ៗ ក្នុងវេលាល្ងាចព្រឹកមែនឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មែនហើយ ។ ម្នាលព្រាហ្មណ៍ ចុះអ្នកឯងយល់ឃើញអំណាចប្រយោជន៍ដូចម្ដេច បានជាសម្គាល់ថា ទឹកជារបស់បរិសុទ្ធ ប្រាថ្នាការបរិសុទ្ធដោយទឹក ប្រកបសេចក្ដីព្យាយាម ចុះទឹករឿយ ៗ ក្នុងវេលាល្ងាចព្រឹក ។ បពិត្រព្រះគោតមដ៏ចម្រើន ក្នុងទីនេះ បាបកម្មណា ដែលខ្ញុំព្រះអង្គបានធ្វើហើយ ក្នុងវេលាថ្ងៃ ខ្ញុំព្រះអង្គ បន្សាត់បង់នូវបាបកម្មនោះ ដោយការងូតទឹកក្នុងវេលាល្ងាច បាបកម្មណា ដែលខ្ញុំព្រះអង្គបានធ្វើហើយ ក្នុងវេលាយប់ ខ្ញុំព្រះអង្គ ក៏បន្សាត់បង់នូវបាបកម្មនោះ ដោយការងូតទឹក ក្នុងវេលាព្រឹក បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឃើញច្បាស់ នូវអំណាចប្រយោជន៍នេះឯង បានជាសម្គាល់ថា ទឹកជារបស់បរិសុទ្ធ ប្រាថ្នាការបរិសុទ្ធដោយទឹក ប្រកបសេចក្ដីព្យាយាម ចុះទឹករឿយ ៗ ក្នុងវេលាល្ងាចព្រឹក ។

[២០១] ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកបុគ្គលអ្នកដល់នូវវេទ បានងូតទឹកក្នុងអន្លង់ទឹកណា មិនបានទទឹកខ្លួនសោះ ហើយស្រាប់តែឆ្លងដល់ត្រើយម្ខាង អន្លង់ទឹកនោះ ក៏គឺធម៌ មានសីលជាកំពង់ មិនល្អក់ ដែលសប្បុរសទាំងឡាយ សរសើថាជារបស់សប្បុរសទាំងឡាយ ។

[២០២] ឯវំ វុត្តេ សង្គារវោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

## ទ្វាទសមំ ខោមទុស្សសុត្តំ

[២០៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ ខោមទុស្សន្នាម សក្យានំ និគមោ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ខោមទុស្សំ បិណ្ឌាយ បាវិសិ ។ តេន ខោ បន សមយេន ខោមទុស្សកា ព្រាហ្មណគហបតិកា សភាយំ សន្និបតិតា ហោន្តិ កេនចិទេវ ករណីយេន ។ ទេវោ ច ឯកមេកំ ផុសាយតិ ។ អថខោ ភគវា យេន សា សភា តេនុបសង្កមិ ។ អទ្ទសំសុ ខោ ខោមទុស្សកា ព្រាហ្មណគហបតិកា ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន

[២០២] *កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សង្គារវព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះតទៅ ។*

# ខោមទុស្សសូត្រ ទី ១២

[២០៣] *ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគមឈ្មោះខោមទុស្សៈ របស់ពួកសក្យៈ ក្នុងដែនសក្កៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរក្នុងវេលាព្រឹក ហើយចូលទៅកាន់ខោមទុស្សនិគម ដើម្បីបិណ្ឌ-បាត ។ សម័យនោះឯង ពួកព្រាហ្មណ៍និងគហបតី អ្នកខោមទុស្សនិគម បានប្រជុំគ្នាក្នុងរោង ដោយកិច្ចនីមួយ ។ ចួនជាភ្លៀង ក៏ស្រក់ចុះមកមួយដំណក់ ៗ ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់យាងទៅជ្រកក្នុងរោងនោះ ។ ពួកព្រាហ្មណ៍និងគហបតី អ្នកខោមទុស្សនិគម បានឃើញព្រះមានព្រះភាគ យាងមកអំពីចម្ងាយ លុះឃើញហើយ*

ឯតទវោចុំ កេ ច មុណ្ឌកា សមណកា កេ ច សភាធម្មំ ជានិស្សន្តីតិ ។

[២០៤] អថខោ ភគវា ខោមទុស្សកេ ព្រាហ្ម-ណគហបតិកេ គាថាយ អជ្ឈភាសិ

នេសា សភា យត្ថ ន សន្តិ សន្តោ
សន្តោ ន តេ យេ ន វទន្តិ ធម្មំ
រាគញ្ច ទោសញ្ច បហាយ មោហំ
ធម្មំ វទន្តា ច ភវន្តិ សន្តោតិ ។

[២០៥] ឯវំ វុត្តេ ខោមទុស្សកា ព្រាហ្មណគហ-បតិកា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម

ក៏ទូលសួរយ៉ាងនេះថា ពួកជនត្រង់លបែបណា ឈ្មោះថា អ្នកស្ងប់រម្ងាប់ ពួកជនបែបណា នឹងដឹងនូវសភាធម៌[១] ។

[២០៤] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ចំពោះពួកព្រាហ្មណ៍និងគហបតី អ្នកខោមទុស្សនិគម ដោយគាថា ថា

ពួកសប្បុរសមិនមាន ក្នុងទីណា ទីនោះ មិនឈ្មោះថាទីប្រជុំឡើយ ជនទាំងឡាយណា មិនពោលធម៌ ជនទាំងនោះមិនឈ្មោះថា សប្បុរស (អ្នកស្ងប់រម្ងាប់) ទេ លុះតែពួកជនលះបង់រាគៈ ទោសៈ មោហៈ ទាំងពោលនូវធម៌ផង ទើបឈ្មោះថា សប្បុរស (ពួកជនបែបនេះ នឹងដឹងនូវសភាធម៌) ។

[២០៥] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណ៍និងគហបតី អ្នកខោមទុស្សនិគម បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់

១ ធម៌ដែលត្រូវប្រតិបត្តិក្នុងទីប្រជុំ ។

អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតា ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណង្គតេតិ ។

ឧបាសកវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

កសី ឧទយោ ទេវហិតោ
អញ្ញតរមហាសាលំ
មានត្ថទ្ធញ្ច បច្ចនិកញ្ច
នវកម្មំ កដ្ឋហារំ
មាតុបោសកំ ភិក្ខកោ សង្គារវោ
ខោមទុស្សេន ទ្វាទសាតិ ។

ព្រាហ្មណសំយុត្តំ សមត្តំ ។

បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់សំដែងដោយអនេកបរិយាយ ដូចជាមនុស្សផ្ងារវត្ថុដែលផ្កាប់ ឬបើកបង្ហាញវត្ថុដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាមនុស្សកាន់ប្រទីបប្រេងទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា ឲ្យពួកមនុស្សដែលមានភ្នែកភ្លឺ មើលឃើញរូបទាំងឡាយបាន យើងខ្ញុំទាំងឡាយនេះ សូមដល់ព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង សូមព្រះគោតមដ៏ចម្រើនជ្រាបនូវយើងខ្ញុំទាំងឡាយ ថាជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ។

ចប់ ឧបាសកវគ្គ ទី ២ ។

## ឧទ្ទាននៃឧបាសកវគ្គនោះ គឺ

កសីសូត្រ ១ ឧទយសូត្រ ១ ទេវហិតសូត្រ ១ មហាសាលសូត្រ ១ មានត្ថទ្ធសូត្រ ១ បច្ចនិកសូត្រ ១ នវកម្មិកសូត្រ ១ កដ្ឋហារសូត្រ ១ មាតុបោសកសូត្រ ១ ភិក្ខកសូត្រ ១ សង្គារវសូត្រ ១ ខោមទុស្សសូត្រ ១ ត្រូវជា ១២ ។

ចប់ ព្រាហ្មណសំយុត្ត ។

---

# វង្គីសសំយុត្តំ

## បឋមំ និក្ខន្តសុត្តំ

[២០៦] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា វង្គីសោ អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ អាយស្មតា និគ្រោធកប្បេន ឧបជ្ឈាយេន សទ្ធឹ ។ តេន ខោ បន សមយេន អាយស្មា វង្គីសោ នវោ ហោតិ អចិរបព្វជិតោ ឱហិយ្យកោ វិហារបាលោ ។

[២០៧] អថខោ សម្ពហុលា ឥត្ថិយោ សមលង្ករិត្វា យេនារាមោ[១] តេនុបសង្កមឹសុ វិហារបេក្ខិកាយោ ។ អថខោ អាយស្មតោ វង្គីសស្ស តា ឥត្ថិយោ ទិស្វា អនភិរតិ ឧប្បជ្ជតិ រាគោ ចិត្តំ អនុទ្ធំសេតិ ។ អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ

១ ម. យេន អគ្គាឡវកោ អារាមោ ។

# វង្គីសសំយុត្ត

## និក្ខន្តសូត្រ ទី ១

[២០៦] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះវង្គីសៈមានអាយុ នៅក្នុងអគ្គាឡវចេតិយ ទៀបក្រុងអាឡវី ជាមួយនឹងឧបជ្ឈាយ៍ឈ្មោះនិគ្រោធកប្បៈ មានអាយុ ។ ក៏សម័យនោះឯង ព្រះវង្គីសៈមានអាយុ ជាភិក្ខុថ្មី បួសមិនយូរប៉ុន្មាន នៅជាភិក្ខុតូចទាបជាអ្នករក្សាវិហារ ។

[២០៧] គ្រានោះឯង ពួកស្រីច្រើននាក់តាក់តែងខ្លួន ចូលទៅកាន់អារាម មៀងមើលវិហារ ។ គ្រានោះ ព្រះវង្គីសៈមានអាយុបានឃើញ នូវស្រីទាំងនោះហើយ ក៏កើតសេចក្តីអផ្សុក រាគៈក៏ញាំងកុសលចិត្តឲ្យវិនាស ។ ទើបព្រះវង្គីសៈមានអាយុ មានសេចក្តីត្រិះរិះថា អើហ្ន៎ អាត្មាអញ ពេញជាមិនមានលាភ អើហ្ន៎ លាភមិនមានដល់អាត្មាអញឡើយ អើហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញ បានដោយអាក្រក់

ន វត មេ សុលទ្ធំ យស្ស មេ អនភិរតិ ឧប្បន្នា រាគោ ចិត្តំ អនុទ្ធំសេតិ តំ កុតេត្ថ លព្ភា យំ មេ បរោ អនភិរតឹ វិនោទេត្វា អភិរតឹ ឧប្បាទេយ្យ យន្នូនាហំ អត្តនា វ អត្តនោ អនភិរតឹ វិនោទេត្វា អភិរតឹ ឧប្បាទេយ្យន្តិ ។

[២០៨] អថខោ អាយស្មា វង្គីសោ អត្តនា វ អត្តនោ អនភិរតឹ វិនោទេត្វា អភិរតឹ ឧប្បាទេត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

និក្ខន្តំ វត មំ សន្តំ

អគារស្មានគារិយំ

វិតក្កា ឧបធាវន្តិ

បគព្ភា កណ្ហតោ ឥមេ

អើហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញ មិនបានដោយល្អទេ ព្រោះសេចក្តីអផ្សុក កើតឡើងដល់អាត្មាអញ រាគៈក៏ញាំងកុសលចិត្តឲ្យវិនាស ជនទាំងឡាយដទៃ គប្បីបន្ទោបង់សេចក្តីអផ្សុក របស់អាត្មាអញ ហើយធ្វើសេចក្តីត្រេកអរឲ្យកើតឡើង ដោយហេតុណា ហេតុនោះ អាត្មាអញគប្បីបានជនទាំងនោះអំពីទីណា បើដូច្នោះ មានតែអាត្មាអញ បន្ទោបង់នូវសេចក្តីអផ្សុករបស់ខ្លួន ដោយខ្លួនឯងចុះ ហើយធ្វើសេចក្តីត្រេកអរឲ្យកើតឡើង ។

[២០៨] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ ក៏បន្ទោបង់សេចក្តីអផ្សុក របស់ខ្លួនដោយខ្លួនឯង ហើយធ្វើសេចក្តីត្រេកអរ ឲ្យកើតឡើង រួចពោលគាថាទាំងឡាយនេះ ក្នុងពេលនោះថា

វិតក្កៈទាំងឡាយនេះ ជាសភាវៈឃ្នើសឃ្នង តែងស្ទុះមកអំពីមារ

គ្របសង្កត់អាត្មាអញ ដែលចេញអំពីផ្ទះ ចូលមកកាន់ផ្នួស

វង្គីសសំយុត្តស្ស និក្ខន្តសុត្តេ វង្គីសស្សុទានំ

ឧគ្គបុត្តា មហិស្សាសា
សិក្ខិតា ទឡ្ហធម្មិនោ
សមន្តា បរិកិរេយ្យុំ
សហស្សំ អបលាយិនំ
សចេបិ ឯត្តកា ភិយ្យោ
អាគមិស្សន្តិ ឥត្ថិយោ
នេវ មំ ព្យាធយិស្សន្តិ
ធម្មេ សម្ហិ បតិដ្ឋិតំ
សក្ខី ហិ មេ សុតំ ឯតំ
ពុទ្ធស្សាទិច្ចពន្ធុនោ
និព្វានគមនំ មគ្គំ
តត្ថ មេ និរតោ មនោ
ឯវញ្ចេ មំ វិហរន្តំ
បាបិមា ឧបគច្ឆសិ
តថា មច្ចុ ករិស្សាមិ
ន មេ មគ្គម្បិ ទក្ខសីតិ ។

ពួកខ្មាន់ធ្នូជាបុត្តនៃជនអ្នកខ្ពង់ខ្ពស់ បានសិក្សាហើយ មានធ្នូដ៏មាំ គប្បីបាញ់បាចសាចដោយជុំវិញ ចំពោះសត្វទាំងពាន់ កុំឲ្យរត់ទៅរួច ទោះបីពួកស្ត្រីមកច្រើន ជាងសត្វទាំងនុ៎ះ ក៏នឹងមិនអាចធ្វើអាត្មាអញ ដែលឋិតនៅក្នុងធម៌របស់ខ្លួនឲ្យញាប់ញ័របានឡើយ ព្រោះថាពាក្យនុ៎ះអាត្មាអញបានស្តាប់អំពីទីចំពោះព្រះភក្ត្រនៃព្រះពុទ្ធ ជាផៅពង្សនៃព្រះអាទិត្យហើយ ចិត្តរបស់អាត្មាអញត្រេកអរ ក្នុងផ្លូវជាទីទៅកាន់ព្រះនិព្វាននោះហើយ ម្នាលមារគឺកិលេស បើអ្នកចូលមករកអាត្មាអញ ដែលកំពុងនៅយ៉ាងនេះ ម្នាលមច្ចុ អ្នកឯងមិនឃើញផ្លូវរបស់យើង យ៉ាងណា យើងនឹងធ្វើ យ៉ាងនោះ ។

# ទុតិយំ អរតិសុត្តំ

[២០៩] ឯកំ សមយំ អាយស្មា វង្គីសោ អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ អាយស្មតា និគ្រោធកប្បេន ឧបជ្ឈាយេន សទ្ធឹ ។ តេន ខោ បន សមយេន អាយស្មា និគ្រោធកប្បោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វិហារំ បវិសតិ សាយំ វា និក្ខមតិ អបរជ្ជុ វា កាលេ ។

[២១០] តេន ខោ បន សមយេន អាយស្មតោ វង្គីសស្ស អនភិរតិ ឧប្បន្នា ហោតិ រាគោ ចិត្តំ អនុទ្ធំសេតិ ។ អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យស្ស មេ អនភិរតិ ឧប្បន្នា រាគោ ចិត្តំ អនុទ្ធំសេតិ តំ កុតេត្ថ លព្ភា យំ មេ បរ អនភិរតឹ វិនោទេត្វា អភិរតឹ ឧប្បាទេយ្យុំ យន្នូនាហំ

# អរតិសូត្រ ទី ២

[២០៩] *សម័យមួយ ព្រះវង្គីសៈមានអាយុ គង់នៅក្នុងអគ្គាឡវចេតិយ ទៀបក្រុងអាឡវី ជាមួយនឹងឧបជ្ឈាយ៍ ឈ្មោះនិគ្រោធកប្បៈមានអាយុ ។ សម័យនោះឯង ព្រះនិគ្រោធកប្បៈ មានអាយុ ត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ក៏ចូលទៅកាន់វិហារ ចេញ (អំពីវិហារទៅវិញ) ក្នុងវេលាល្ងាច ឬក្នុងកាលថ្ងៃស្អែកឡើង ។*

[២១០] *សម័យនោះឯង សេចក្តីអផ្សុក កើតមានដល់ព្រះវង្គីសៈ មានអាយុ ទាំងរាគៈ ក៏ញុំាងកុសលចិត្ត ឲ្យវិនាស ។ ព្រះវង្គីសៈមានអាយុ មានសេចក្តីត្រិះរិះ យ៉ាងនេះថា អើហ្ន៎ អាត្មាអញ ពេញជាមិនមានលាភ អើហ្ន៎ លាភមិនមានដល់អាត្មាអញឡើយ អើហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញ បានដោយអាក្រក់ អើហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញ មិនបានដោយល្អទេ ព្រោះថា សេចក្តីអផ្សុក កើតឡើងដល់អាត្មាអញ រាគៈក៏ញុំាងកុសលចិត្តឲ្យវិនាស ពួកជនដទៃ គប្បីបន្ទោបង់សេចក្តីអផ្សុករបស់អាត្មាអញ ហើយធ្វើសេចក្តីត្រេកអរ ឲ្យកើតឡើងដោយហេតុណា ហេតុនោះ អាត្មាអញគប្បីបានជនទាំងនោះអំពីទីណា ក្នុងរាគៈនេះ*

១៨៣



អត្តនា វ អត្តនោ អនភិរតឹ វិនោទេត្វា អភិរតឹ ឧប្បា-
ទេយ្យន្តិ ។

[២១១] អថខោ អាយស្មា វង្គីសោ អត្តនា វ អត្តនោ អនភិរតឹ វិនោទេត្វា អភិរតឹ ឧប្បាទេត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

អរតិញ្ច រតិញ្ច បហាយ
សព្វសោ គេហសិតញ្ច វិតក្កំ
វនថំ ន ករេយ្យ កុហិញ្ចិ
និព្វនថោ អនតោ[១] ស ហិ ភិក្ខុ
យមិធ បថវិញ្ច វេហាសំ
រូបគតញ្ច ជគតោគធំ
កិញ្ចិ បរិជិយ្យតិ សព្វមនិច្ចំ
ឯវំ សមេច្ច ចរន្តិ មុតត្តា
ឧបធីសុ ជនា គធិតាសេ

---

១ ម. អរតោ ស ភិក្ខុ ។

បើដូច្នោះ មានតែអាត្មាអញបន្ទោបង់ នូវសេចក្តីអផ្សុករបស់ខ្លួន ដោយខ្លួនឯង ហើយធ្វើសេចក្តីត្រេកអរ ឲ្យកើតឡើង ។

[២១១] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ ក៏បន្ទោបង់សេចក្តីអផ្សុករបស់ខ្លួន ដោយខ្លួនឯង ហើយធ្វើសេចក្តីត្រេកអរ ឲ្យកើតឡើង រួចពោលគាថាទាំងឡាយនេះ ក្នុងវេលានោះថា

ភិក្ខុណាលះបង់ នូវសេចក្តីមិនត្រេកអរផង នូវសេចក្តីត្រេកអរផង នូវវិតក្កៈដែលអាស្រ័យ នូវផ្ទះគឺកាមគុណផង ដោយប្រការទាំងពួង ហើយមិនធ្វើនូវព្រៃធំ គឺកិលេស ក្នុងអារម្មណ៍ណាមួយឡើយ ភិក្ខុនោះឈ្មោះថា មិនមានព្រៃធំគឺកិលេស ជាអ្នកប្រាសចាកតណ្ហា របស់អ្វីមួយ ក្នុងលោកនេះ ដែលមានរូបឋិតលើផែនដីក្តី ដែលឋិតលើអាកាសក្តី ដែលឋិតនៅក្នុងរូងផែនដីក្តី[១] របស់ទាំងអស់នោះ មិនទៀងរមែងគ្រាំគ្រាទៅ ពួកជនដែលស្គាល់ច្បាស់ នូវអត្តភាពតែងមកប្រជុំយ៉ាងនេះ តែងជាប់ចំពាក់ ក្នុងឧបធិទាំងឡាយ

១ សំដៅយកពិភពនាគ ។

ទិដ្ឋសុតេ បដិឃេ ច មុតេ ច

ឯត្ថ វិនោទយ[១] ឆន្ទមនេជោ

យោ ឯត្ថ[២] ន លិម្បតិ តំ មុនិមាហុ

អថ សដ្ឋិសិតា សវិតក្កា

បុថុជ្ជនតាយ អធម្មនិវិដ្ឋា

ន ច វគ្គគតស្ស[៣] កុហិញ្ចិ

នោ បន ទុដ្ឋុល្លភាណី ស ភិក្ខុ

ទព្វោ ចិររត្តសមាហិតោ

អកុហកោ និបកោ អបិហាលុ

សន្តំ បទំ អជ្ឈគមា មុនិ បដិច្ច

បរិនិព្វុតោ កង្ខតិ កាលន្តិ ។

---

១ ឱ. មនោទិយ ។ ២ ឱ. តត្ថ ។ ៣ ឱ. ន ច វគ្គគតស្ស ។ ម. វគ្គគតោ ចស្ស ។

អ្នកឯងជាបុគ្គល មិនមានតណ្ហាជាគ្រឿងញាប់ញ័រ ចូរបន្ទោ-បង់នូវចំណង់ ក្នុងរូបដែលឃើញហើយ ក្នុងសំឡេងដែលឮហើយ ក្នុងក្លិននិងរសដែលប៉ះពាល់ហើយ ក្នុងផោដ្ឋព្វា-រម្មណ៍ ដែលពាល់ត្រូវហើយ អ្នកណាមិនជាប់នៅ ក្នុងបញ្ចកាមគុណនេះ ពួកជនហៅអ្នកនោះ ថាជាអ្នកប្រាជ្ញមួយទៀត វិតក្កៈទាំងឡាយ ដែលមិនប្រកបដោយធម៌អាស្រ័យនូវអារម្មណ៍ ៦ តាំងនៅក្នុងពួកបុថុជ្ជន បុគ្គលណា មិនទៅកាន់កិលេសវដ្ដៈ ក្នុងទីណាមួយ ទាំងមិនពោលពាក្យអាក្រក់ បុគ្គលនោះ ឈ្មោះថាភិក្ខុ ជាអ្នកប្រាជ្ញមានចិត្តតាំងមាំ អស់កាលជាយូរអង្វែង ជាអ្នកមិនកុហកមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ទាំងមិនមានសេចក្ដីស្រឡាញ់ឈ្មោះថាជាអ្នកប្រាជ្ញ បានត្រាស់ដឹងនូវព្រះនិព្វាន មួយទៀត បុគ្គលនោះបរិនិព្វានហើយ ព្រោះអាស្រ័យព្រះនិព្វានតែងទន្ទឹងនូវបរិនិព្វានកាល ។

# តតិយំ បេសលាតិមញ្ញនាសុត្តំ

[២១២] ឯកំ សមយំ អាយស្មា វង្គីសោ អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ អាយស្មតា និគ្រោធកប្បេន ឧបជ្ឈាយេន សទ្ធឹ ។ តេន ខោ បន សមយេន អាយស្មា វង្គីសោ អត្តនោ បដិភាណេន អញ្ញេ បេសលេ ភិក្ខូ អតិមញ្ញតិ ។ អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យ្វាហំ អត្តនោ បដិភាណេន អញ្ញេ បេសលេ ភិក្ខូ អតិមញ្ញតីតិ ។

[២១៣] អថខោ អាយស្មា វង្គីសោ អត្តនា វ អត្តនោ វិប្បដិសារំ ឧប្បាទេត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

# បេសលាតិមញ្ញនាសូត្រ ទី ៣

[២១២] *សម័យមួយ ព្រះវង្គីសៈមានអាយុ នៅក្នុងអគ្គាឡវចេតិយ ទៀបក្រុងអាឡវី ជាមួយនឹងឧបជ្ឈាយ៍ ឈ្មោះនិគ្រោធកប្បៈដ៏មានអាយុ ។ ក៏សម័យនោះឯង ព្រះវង្គីសៈមានអាយុ មើលងាយនូវពួកភិក្ខុដទៃ ដែលមានសីលជាទីស្រឡាញ់ ដោយសេចក្តីឈ្លាសវៃរបស់ខ្លួន ។ លំដាប់នោះ ព្រះវង្គីសៈមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ អាត្មាអញ ពេញជាមិនមានលាភ អើហ្ន៎ លាភមិនមាន ដល់អាត្មាអញឡើយ អើហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញបានដោយអាក្រក់ អើហ្ន៎ អត្តភាពជាមនុស្ស អាត្មាអញ មិនបានដោយល្អទេ ព្រោះអាត្មាអញ មើលងាយពួកភិក្ខុដទៃ ដែលមានសីលជាទីស្រឡាញ់ ដោយសេចក្តីឈ្លាសវៃរបស់ខ្លួន ។*

[២១៣] *លំដាប់នោះ ព្រះវង្គីសៈមានអាយុ ក៏ធ្វើសេចក្តីក្តៅក្រហាយរបស់ខ្លួន ឲ្យកើតឡើងដោយខ្លួនឯង ហើយពោលនូវគាថាទាំងឡាយនេះ ក្នុងវេលានោះថា*

មានសំ ជហាស្សុ គោតម
មានបថមិធ[១] ជហាស្សុ
អសេសំ មានបថមិធ[២] មុញ្ចិតោ
វិប្បជិសារីហុវា ចិររត្តំ
មក្ខេន មក្ខិតា បជា
មានហតា[៣] និរយំ បបតន្តិ
សោចន្តិ ជនា ចិររត្តំ
មានហតា និរយំ ឧបបន្នា
ន ហិ សោចតិ ភិក្ខុ កទាចិ
មគ្គជិនោ សម្មាបដិបន្នោ
កិត្តិញ្ច សុខញ្ច អនុភោតិ
ធម្មទសោតិ[៤] តមាហុ តថត្តំ[៥]
តស្មា អខិលោធ បធានវា
នីវរណានិ បហាយ វិសុទ្ធោ
មានញ្ច បហាយ អសេសំ
វិជ្ជាយន្តករោ សមិតាវីតិ ។

១ ឱ. ម. មានបហាញ្ច ជហាស្សុ ។ ២ ឱ. ម. មានបថស្មឹ សមុច្ឆិតោ ។ ៣ ឱ. មាន-គតា ។ ៤ ឱ. ធម្មរតោតិ ។ ម. ធម្មរស្សោតិ ។ ៥ ម. បហិតត្តំ ។

ម្នាលអ្នកជាសាវ័កព្រះគោតម អ្នកចូរលះបង់ នូវចិត្តមានះចេញ ចូរលះបង់នូវគន្លងនៃមានះ ក្នុងកាយនេះចេញ បុគ្គលដែលមានសេចក្តីក្តៅក្រហាយ អស់កាលជាយូរអង្វែង គួរតែលះបង់នូវគន្លងនៃមានះ ក្នុងកាយនេះ កុំឲ្យសេសសល់ ពពួកសត្វដែលប្រឡាក់ ដោយសេចក្តីលុបគុណ ដែលត្រូវមានះបៀតបៀនហើយ រមែងធ្លាក់ទៅក្នុងនរក ពួកជន ដែលត្រូវមានះបៀតបៀនហើយ តែងទៅកើតក្នុងនរក សោកសៅ អស់រាត្រីជាយូរអង្វែង ភិក្ខុដែលឈ្នះកិលេសដោយមគ្គ ប្រតិបត្តិដោយប្រពៃ រមែងមិនសោកសៅ ក្នុងកាលណាម្តងឡើយ រមែងបាននូវសេចក្តីសរសើរ និងសេចក្តីសុខ អ្នកប្រាជ្ញទាំងឡាយហៅភិក្ខុនោះ ដែលមានសភាពដូច្នោះថា ជាអ្នកឃើញធម៌ ហេតុដូច្នោះ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនរឹងត្អឹង មានព្យាយាម លះបង់នូវនីវរណៈទាំងឡាយ ជាអ្នកបរិសុទ្ធ លះបង់មានះមិនឲ្យសេសសល់ ហើយធ្វើនូវទីបំផុត នៃកិលេសដោយវិជ្ជា ជាអ្នកស្ងប់រម្ងាប់ ។

# ចតុត្ថំ អានន្ទសុត្តំ

[២១៤] ឯកំ សមយំ អាយស្មា អានន្ទោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរ-មាទាយ សាវត្ថិយំ បិណ្ឌាយ ចារិ អាយស្មតា វង្គីសេន បច្ឆាសមណេន ។ តេន ខោ បន សមយេន អាយស្មតោ វង្គីសស្ស អនភិរតិ ឧប្បន្នា ហោតិ រាគោ ចិត្តំ អនុទ្ធំសេតិ ។

[២១៥] អថខោ អាយស្មា វង្គីសោ អាយស្មន្តំ អានន្ទំ គាថាយ អជ្ឈភាសិ

កាមរាគេន ឌយ្ហាមិ

ចិត្តំ មេ បរិឌយ្ហតិ

សាធុ និព្វាបនំ ព្រូហិ

អនុកម្បាយ គោតមាតិ ។

# អានន្ទសូត្រ ទី ៤

[២១៤] សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាព្រឹក ព្រហាម ចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី មានព្រះវង្គីសៈមានអាយុ ជាបច្ឆាសមណៈ ។ សម័យនោះ សេចក្តីអផ្សុកក៏កើតឡើង ដល់ព្រះ វង្គីសៈមានអាយុ ទាំងរាគៈក៏ធ្វើកុសលចិត្តឲ្យវិនាស ។

[២១៥] ទើបព្រះវង្គីសៈមានអាយុ បានពោលនឹងព្រះអានន្ទ មានអាយុ ដោយគាថា ថា

បពិត្រលោក ជាគោតមគោត្រ ខ្ញុំក្តៅដោយកាមរាគៈ ចិត្ត
របស់ខ្ញុំក្តៅក្រហាយណាស់ សូមលោកមេត្តា សំដែងធម៌
ជាគ្រឿងរំលត់រាគៈ ដោយសេចក្តីអនុគ្រោះឲ្យទាន ។

[២១៦] សញ្ញាយ វិបរិយេសា
ចិត្តន្តេ បរិឌយ្ហតិ
និមិត្តំ បរិវជ្ជេហិ
សុភំ រាគូបសញ្ហិតំ
សង្ខារេ បរតោបស្ស
ទុក្ខតោ មា ច អត្តតោ
និព្វាបេហិ មហារាគំ
មា ឌយ្ហិត្ថោ បុនប្បុនំ
អសុភាយ ចិត្តំ ភាវេហិ
ឯកគ្គំ សុសមាហិតំ
សតិ កាយគតា ត្យត្ថុ
និព្វិទាពហុលោ ភវ
អនិមិត្តញ្ច ភាវេហិ
មានានុសយមុជ្ជហ
តតោ មានាភិសមយា
ឧបសន្តោ ចរិស្សសីតិ ។

[២១៦] ព្រះអានន្ទ ពោលថា ចិត្តរបស់លោកក្តៅក្រហាយ ព្រោះសេចក្តីប្រែប្រួលនៃសញ្ញា លោកចូរវៀរនូវនិមិត្តល្អដែលប្រកបដោយរាគៈចេញ ហើយពិចារណាសង្ខារទាំងឡាយ ថាជារបស់ដទៃ ថាជាទុក្ខ កុំពិចារណាថាជារបស់ខ្លួនឡើយ ចូរធ្វើរាគៈដ៏ធំឲ្យរលត់បាត់ទៅ កុំមានសេចក្តីក្តៅក្រហាយរឿយ ៗ ឡើយ លោកចូរចម្រើននូវចិត្តឲ្យមានអារម្មណ៍តែមួយ ឲ្យតាំងនៅដោយប្រពៃ ដោយអសុភារម្មណ៍ កាយគតាសតិ ចូរមានដល់លោក លោកចូរជាអ្នកមានសេចក្តីនឿយណាច្រើន ចូរចម្រើននូវអនិមិត្តគឺវិបស្សនា ដកនូវមានានុស័យចេញ ហើយជាអ្នកមានចិត្តស្ងប់រម្ងាប់ប្រព្រឹត្តនៅ ដោយការយល់ច្បាស់នូវមានៈនោះ ។

# បញ្ចមំ សុភាសិតសុត្តំ

[២១៧] សាវត្ថីនិទានំ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ នោ ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា ច វិញ្ញូនំ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ សុភាសិតំយេវ ភាសតិ នោ ទុព្ភាសិតំ ធម្មំយេវ ភាសតិ នោ អធម្មំ បិយំយេវ ភាសតិ នោ អប្បិយំ សច្ចំយេវ ភាសតិ នោ អលិកំ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ នោ ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា ច វិញ្ញូនន្តិ ។

# សុភាសិតសូត្រ ទី ៥

[២១៧] សាវត្ថីនិទាន ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ឈ្មោះថា សុភាសិត មិនមែនទុព្ភាសិតទេ ជាវាចាមិនមានទោសផង ដែលអ្នកប្រាជ្ញមិនតិះដៀលផង ។ វាចាដែលប្រកបដោយអង្គ ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងពោលពាក្យសុភាសិត មិនពោលពាក្យទុព្ភាសិត ១ ពោលពាក្យជាធម៌ មិនពោលពាក្យមិនជាធម៌ ១ ពោលពាក្យជាទីស្រឡាញ់ មិនពោលពាក្យមិនជាទីស្រឡាញ់ ១ ពោលពាក្យពិត មិនពោលពាក្យកុហក ១ ។ ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ នេះឯង ឈ្មោះថា សុភាសិត មិនមែនទុព្ភាសិតទេ ជាវាចាមិនមានទោសផង ដែលអ្នកប្រាជ្ញមិនតិះដៀលផង ។

[២១៨] ឥធមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

សុភាសិតំ ឧត្តមមាហុ សន្តោ
ធម្មំ ភណេ នាធម្មន្តំ ទុតិយំ
បិយំ ភណេ នាប្បិយន្តំ តតិយំ
សច្ចំ ភណេ នាលិកន្តំ ចតុត្ថន្តិ ។

អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ វង្គីសាតិ ភគវា អវោច ។

[២១៩] អថខោ អាយស្មា វង្គីសោ ភគវន្តំ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវិ

[២១៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះហើយ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់ភាសិតនេះហើយ ក៏ទ្រង់ត្រាស់គាថានេះតទៅទៀតថា

ពួកសប្បុរស ពោលសុភាសិត ជាពាក្យខ្ពង់ខ្ពស់ (ទី ១)
ពោលពាក្យជាធម៌ មិនពោលពាក្យមិនជាធម៌ នោះជាទី ២
ពោលពាក្យជាទីស្រឡាញ់ មិនពោលពាក្យមិនជាទីស្រ-
ឡាញ់ នោះជាទី ៣ ពោលពាក្យពិត មិនពោលពាក្យ
កុហក នោះជាទី ៤ ។

លំដាប់នោះឯង ព្រះវង្គីសៈ មានអាយុ ក្រោកចាកអាសនៈហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ហើយពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមសំដែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ សូមសំដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ អ្នកចូរសំដែងធម៌ចុះ ។

[២១៩] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ បានពោលសរសើរព្រះមានព្រះភាគ ដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះព្រះភក្រ្តថា

១៦១

វង្គីសសំយុត្តស្ស សុភាសិតសុត្តេ ភគវន្តាភិថុតិ

តមេវ វាចំ ភាសេយ្យ
យាយត្តានំ ន តាបយេ
បរេ ច ន វិហឹសេយ្យ
សា វេ វាចា សុភាសិតា
បិយវាចមេវ ភាសេយ្យ
យា វាចា បដិនន្ទិតា
យំ អនាទាយ បាបានិ
បរេសំ ភាសតេ បិយំ
សច្ចំ វេ អមតា វាចា
ឯស ធម្មោ សនន្តនោ
សច្ចេ អត្ថេ ច ធម្មេ ច
អាហុ សន្តោ បតិដ្ឋិតា
យំ ពុទ្ធោ ភាសតិ វាចំ
ខេមំ និព្វានបត្តិយា
ទុក្ខស្សន្តកិរិយាយ
សា វេ វាចានមុត្តមាតិ ។

វង្គីសសំយុត្ត សុភាសិតសូត្រ សេចក្តីសរសើរព្រះមានព្រះភាគ

បុគ្គលមិនធ្វើខ្លួនឲ្យក្តៅ ដោយវាចាណា គប្បីពោលវាចា នោះឯង មួយទៀត បុគ្គលមិនគប្បីបៀតបៀនពួកជនដទៃ (ដោយវាចាណា) វាចានោះឯង ឈ្មោះថាសុភាសិត វាចា ណា ដែលគេត្រេកអរ បុគ្គលគប្បីពោល នូវវាចានោះ ជាវាចាជាទីស្រឡាញ់ បុគ្គលពោល នូវវាចាណា មិនកាន់ យកវាចាដ៏អាក្រក់ ពោលនូវវាចាជាទីស្រឡាញ់ ដល់ជន ទាំងឡាយដទៃ (បុគ្គលគប្បីពោលនូវវាចានោះ) ពាក្យពិត ឈ្មោះថាជាពាក្យមិនស្លាប់ ធម៌នេះជាប្រពៃណី ពួកសប្បុ-រស តាំងនៅហើយក្នុងសច្ចៈ ដែលជាអត្ថផង ជាធម៌ផង ព្រះពុទ្ធទ្រង់ពោលវាចាណា ដ៏ក្សេមក្សាន្ត ដើម្បីដល់នូវ ព្រះនិព្វាន នឹងធ្វើនូវទីបំផុតទុក្ខបាន វាចានោះឯង ជា វាចាដ៏ខ្ពង់ខ្ពស់ជាងវាចាទាំងឡាយ ។

# ឆដ្ឋំ សារីបុត្តសុត្តំ

[២២០] ឯកំ សមយំ អាយស្មា សារីបុត្តោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ចោរិយា វាចាយ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។

[២២១] អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អយំ ខោ អាយស្មា សារីបុត្តោ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ ។ បេ ។ អត្ថស្ស វិញ្ញាបនិយា តេ ច ភិក្ខូ អដ្ឋិកត្វា ។ បេ ។ ធម្មំ សុណន្តិ យន្នូនាហំ អាយស្មន្តំ សារីបុត្តំ សម្មុខា សារូប្បាហិ គាថាហិ អភិត្ថវេយ្យន្តិ ។ អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា

# សារីបុត្តសូត្រ ទី ៦

[២២០] *សម័យមួយ ព្រះសារីបុត្តមានអាយុ នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះ ព្រះសារីបុត្តមានអាយុ បានពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ជាវាចាបរិបូណ៌ដោយអក្ខរៈនិងបទច្បាស់លាស់ ជាវាចាឥតទោស អាចញុំាងបុគ្គល ឲ្យដឹងច្បាស់នូវសេចក្តីបាន ។ ភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលនូវចិត្តទាំងអស់ ផ្ទៀងត្រចៀកស្តាប់ធម៌ ។*

[២២១] *លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះសារីបុត្តមានអាយុនេះឯង បានពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ដោយធម្មីកថា ។ បេ ។ ជាវាចាអាចញុំាងបុគ្គលឲ្យដឹងច្បាស់នូវសេចក្តីបាន ចំណែកភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ។ បេ ។ ស្តាប់ធម៌ បើដូច្នោះ មានតែអាត្មាអញ ពោលសរសើរព្រះសារីបុត្តមានអាយុ ដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះមុខ ។ ទើបព្រះវង្គីសៈមានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង*

យេនាយស្មា សារីបុត្តោ តេនញ្ជលិម្បណាមេត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច បដិភាតិ មំ អាវុសោ សារីបុត្ត បដិភាតិ មំ អាវុសោ សារីបុត្តាតិ ។ បដិភាតុ តំ អាវុសោ វង្គីសាតិ ។

[២២២] អថខោ អាយស្មា វង្គីសោ អាយស្មន្តំ សារីបុត្តំ សម្មុខា សរូបាហិ គាថាហិ អភិត្ថវិ

គម្ភីរបញ្ញោ មេធាវី
មគ្គាមគ្គស្ស កោវិទោ
សារីបុត្តោ មហាបញ្ញោ
ធម្មំ ទេសេតិ ភិក្ខុនំ
សង្ខិត្តេនបិ ទេសេតិ
វិត្ថារេនបិ ភាសតិ
សាលិកា វិយ និគ្ឃោសោ

ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះសារីបុត្តមានអាយុ ហើយពោលពាក្យនេះ នឹងព្រះសារីបុត្តមានអាយុថា បពិត្រព្រះសារីបុត្តមានអាយុ ខ្ញុំសូមសំដែងធម៌ បពិត្រព្រះសារីបុត្តមានអាយុ ខ្ញុំសូមសំដែងធម៌ ។ ព្រះសារីបុត្តតបថា អើអាវុសោវង្គីសៈ ចូរលោកសំដែងធម៌ចុះ ។

[២២២] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ ពោលសរសើរព្រះសារីបុត្តមានអាយុ ដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីបំពោះមុខថា

ព្រះសារីបុត្តជាអ្នកប្រាជ្ញ មានបញ្ញាជ្រាលជ្រៅ ជាអ្នក
ឈ្លាសក្នុងមគ្គនិងមិនមែនមគ្គ មានបញ្ញាច្រើន តែងសំដែង
ធម៌ដល់ភិក្ខុទាំងឡាយ សំដែងដោយសង្ខេបខ្លះ សំដែង
ដោយពិស្ដារខ្លះ មានសំឡេងគឹកកង ដូចជាសត្វសាលិកា

បដិភាណំ មុទីរយិ
តស្ស តំ ទេសយន្តស្ស
សុណន្តិ មធុរំ គិរំ
សរេន រជនីយេន
សវនីយេន វគ្គុនា
ឧទគ្គចិត្តា មុទិតា
សោតំ ឱទេន្តិ ភិក្ខវោតិ ។

## សត្តមំ បវារណាសុត្តំ

[២២៣] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បាសាទេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ បវារណាយ ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។ អថខោ ភគវា តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ បវារយាមិ[១] វោ ន ច មេ កិញ្ចិ គរហថ កាយិកំ វា វាចសិកំ វាតិ ។

១ ម. បវារេមិ ។

បញ្ចេញនូវប្រាជ្ញាដ៏វិសេស ពួកភិក្ខុនាំគ្នាស្តាប់នូវវាចាដ៏ពីរោះ របស់លោក ដែលកំពុងសំដែងធម៌នោះ ភិក្ខុទាំងឡាយ មានចិត្តអណ្តែតឡើង មានចិត្តរីករាយដោយសំឡេង ដែលគួរត្រេកអរ គួរស្តាប់ ជាសំឡេងដ៏ពីរោះ ហើយផ្ទៀងត្រចៀកស្តាប់ ។

# បវារណាសូត្រ ទី ៧

[២២៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទនៃមិគារមាតា ឈ្មោះបុព្វារាម ទៀបក្រុងសាវត្ថី ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូប សុទ្ធតែជាព្រះអរហន្ត ។ ក៏ក្នុងសម័យនោះឯង ព្រះមានព្រះភាគ មានព្រះភិក្ខុសង្ឃ គាល់ទ្រៀបត្រា គង់ក្នុងទីវាល ក្នុងថ្ងៃបណ្ណរសីបវារណា ជាថ្ងៃឧបោសថនោះ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ឆ្មៀងព្រះនេត្រទតឃើញភិក្ខុសង្ឃដែលនៅស្ងៀមហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតបវារណា ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ មិនតិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ របស់តថាគតទេឬ ។

វង្គីសសំយុត្តស្ស បវារណាសុត្តេ សារីបុត្តាភិថុតិ

[២២៤] ឯវំ វុត្តេ អាយស្មា សារីបុត្តោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច ន ខោ មយំ ភន្តេ ភគវតោ កិញ្ចិ គរហាម កាយិកំ វា វាចសិកំ វា ភគវា ហិ ភន្តេ អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ មគ្គានុគា ច ភន្តេ ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតា អហញ្ច ខោ ភន្តេ ភគវន្តំ បវារេមិ ន ច មេ ភគវា កិញ្ចិ គរហតិ កាយិកំ វា វាចសិកំ វាតិ ។ ន ខ្វាហំ តេ សារីបុត្ត កិញ្ចិ គរហាមិ កាយិកំ វា វាចសិកំ វា បណ្ឌិតោ ត្វំ សារីបុត្ត មហាបញ្ញោ ត្វំ សារីបុត្ត បុថុប្បញ្ញោ ត្វំ សារីបុត្ត ហាសប្បញ្ញោ

[២២៤] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណាម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានតិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ របស់ព្រះមានព្រះភាគទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើត ឲ្យស្គាល់ផ្លូវដែលមិនទាន់ស្គាល់ ប្រាប់ផ្លូវដែលមិនទាន់ប្រាប់ ទ្រង់ដឹងនូវផ្លូវ ជ្រាបច្បាស់នូវផ្លូវ ឈ្លាសវៃក្នុងផ្លូវ បពិត្រព្រះអង្គដ៏ចម្រើន ពួកសាវ័កក្នុងកាលឥឡូវនេះ តែងដើរទៅតាមផ្លូវ ដើរតាមក្រោយ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខ្ញុំព្រះអង្គ សូមបវារណាចំពោះព្រះមានព្រះភាគ ព្រះមានព្រះភាគ មិនទ្រង់តិះដៀល នូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ របស់ខ្ញុំព្រះអង្គទេឬ ។ ម្នាលសារីបុត្ត តថាគត មិនបានតិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ របស់អ្នកទេ ម្នាលសារីបុត្ត អ្នកជាបណ្ឌិត ម្នាលសារីបុត្ត អ្នកមានប្រាជ្ញាច្រើន ម្នាលសារីបុត្ត អ្នកមានប្រាជ្ញាក្រាស់ ម្នាលសារីបុត្ត អ្នកមានប្រាជ្ញា ជាហេតុឲ្យកើតសេចក្តីរីករាយ

ត្វំ សារីបុត្ត ជវនប្បញ្ញោ ត្វំ សារីបុត្ត តិក្ខប្បញ្ញោ ត្វំ សារីបុត្ត និព្វេធិកប្បញ្ញោ ត្វំ សារីបុត្ត សេយ្យថាបិ សារីបុត្ត រញ្ញោ ចក្កវត្តិស្ស ជេដ្ឋបុត្តោ បិតរា បវត្តិតំ ចក្កំ សម្មទេវ អនុបវត្តេហិ ឯវមេវ ខោ ត្វំ សារីបុត្ត មយា អនុត្តរំ ធម្មចក្កំ បវត្តិតំ សម្មទេវ អនុបវត្តេសីតិ ។ នោ ចេ កិរ មេ ភន្តេ ភគវា កិញ្ចិ គរហតិ កាយិកំ វា វាចសិកំ វា ឥមេសំ បន ភន្តេ ភគវា បញ្ចន្នំ ភិក្ខុសតានំ ន កិញ្ចិ គរហតិ កាយិកំ វា វាចសិកំ វាតិ ។ ឥមេសំបិ ខ្វាហំ សារីបុត្ត បញ្ចន្នំ ភិក្ខុសតានំ ន កិញ្ចិ គរហាមិ កាយិកំ វា វាចសិកំ វា ឥមេសំ ហិ សារីបុត្ត បញ្ចន្នំ ភិក្ខុសតានំ សដ្ឋី ភិក្ខូ តេវិជ្ជា សដ្ឋី ភិក្ខូ ឆឡភិញ្ញា សដ្ឋី ភិក្ខូ ឧភតោភាគវិមុត្តា

ម្នាលសារីបុត្ត អ្នកមានប្រាជ្ញារហ័ស ម្នាលសារីបុត្ត អ្នកមានប្រាជ្ញាមុត ម្នាលសារីបុត្ត អ្នកមានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ម្នាលសារីបុត្ត ប្រៀបដូចបុត្តច្បងរបស់ស្តេចចក្រពត្តិ រមែងញុំាងចក្រដែលបិតាឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅបានដោយល្អ យ៉ាងណា ម្នាលសារីបុត្ត អ្នកក៏ញុំាងអនុត្តរធម្មចក្រ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅបានដោយល្អ យ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគ មិនទ្រង់តិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ របស់ខ្ញុំព្រះអង្គទេ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះមានព្រះភាគ មិនតិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ របស់ពួកភិក្ខុ ៥០០ នេះដែរឬ ។ ម្នាលសារីបុត្ត តថាគតមិនតិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារ របស់ពួកភិក្ខុ ៥០០ នេះទេ ម្នាលសារីបុត្ត ព្រោះថា បណ្តាភិក្ខុទាំង ៥០០ នេះ ភិក្ខុ ៦០ រូប ជាតេវិជ្ជបុគ្គល (បុគ្គលបានវិជ្ជា ៣) ភិក្ខុ ៦០ រូប ជាឆឡភិញ្ញាបុគ្គល (បុគ្គលបានអភិញ្ញា ៦) ភិក្ខុ ៦០ រូបជាឧភតោភាគវិមុត្តបុគ្គល

១៦៧

វង្គីសសំយុត្តស្ស បវារណាសុត្តេ ភគវន្តាភិថុតិ

អថ ឥតរេ បញ្ញាវិមុត្តាតិ ។ អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ វង្គីសាតិ ភគវា អវោច ។

[២២៨] អថខោ អាយស្មា វង្គីសោ ភគវន្តំ សម្មុខា សរុប្បាហិ គាថាហិ អភិត្ថវិ

អជ្ជ បណ្ណរសេ វិសុទ្ធិយា
ភិក្ខុបញ្ចសតា សមាគតា
សញ្ញោជនពន្ធនច្ឆិទា
អនីឃា ខីណបុនព្ភវា ឥសី

(បុគ្គលរួចចាកកិលេស ដោយធម៌ ២ គឺ រូបសមាបត្តិ និងអរូបសមាបត្តិ) ឯភិក្ខុទាំងឡាយក្រៅពីនេះ ជាបញ្ញាវិមុត្តបុគ្គល (បុគ្គលរួចចាកកិលេសដោយប្រាជ្ញា) ។ ទើបព្រះវង្គីសៈមានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសំដែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គសូមសំដែងធម៌ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវង្គីសៈ អ្នកចូរសំដែងធម៌ចុះ ។

[២២៥] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ ពោលសរសើរ ព្រះមានព្រះភាគ ដោយគាថាទាំងឡាយ ដ៏សមគួរក្នុងទីចំពោះព្រះភក្ត្រថា

ថ្ងៃនេះជាថ្ងៃ ១៥ ភិក្ខុទាំងឡាយ ៥០០ រូបជាអ្នកកាត់បង់នូវ
កិលេសគឺសញ្ញោជនៈនិងពន្ធនៈ ជាអ្នកមិនមានទុក្ខ មានភព
ថ្មីអស់ហើយ ជាអ្នកស្វែងរកនូវគុណ មានសីលគុណជាដើម

ចក្កវត្តិ យថា រាជា
អមច្ចបរិវារិតោ
សមន្តា អនុបរិយេតិ
សាគរន្តំ មហឹ ឥមំ
ឯវំ វិជិតសង្គាមំ
សត្ថវាហំ អនុត្តរំ
សាវកា បយិរុបាសន្តិ
តេវិជ្ជា មច្ចុហាយិនោ
សព្វេ ភគវតោ បុត្តា
បលាបេត្ថ ន វិជ្ជតិ
តណ្ហាសល្លស្ស ហន្តារំ
វន្ទេ អាទិច្ចពន្ធុនន្តិ ។

មកប្រជុំគ្នា ដើម្បីធ្វើខ្លួនឲ្យបរិសុទ្ធិ ប្រៀបដូចស្តេចចក្រពត្តិ ដែលពួកអាមាត្យចោមរោម ទ្រង់ស្តេចត្រួតត្រាជុំវិញផែនដីនេះ ដែលមានសាគរជាទីបំផុត យ៉ាងណា ពួកសាវ័កដែលបានត្រៃវិជ្ជាញុំាងមច្ចុឲ្យវិនាស ចូលទៅអង្គុយជិតព្រះទសពល ទ្រង់ឈ្នះសង្គ្រាមគឺកិលេស ទ្រង់ដឹកនាំពួកសត្វ រកបុគ្គលជាង់គ្មាន យ៉ាងនោះដែរ សាវ័កទាំងអស់ ជាបុត្តរបស់ព្រះមានព្រះភាគ បុគ្គលជ្រោកជ្រាក មិនមានក្នុងពួកសាវ័កនេះឡើយ ខ្ញុំព្រះអង្គសូមថ្វាយបង្គំព្រះទសពល ជាផៅពង្សនៃព្រះអាទិត្យ ជាអ្នកដកនូវសរគឺតណ្ហាបាន ។

១៦៩

វង្គីសសំយុត្តស្ស បរោសហស្សសុត្តេ វង្គីសស្ស បរិវិតក្កនំ

# អដ្ឋមំ បរោសហស្សសុត្តំ

[២២៦] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។ តេន ខោ បន សមយេន ភគវា ភិក្ខូ និព្វានប្បដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។

[២២៧] អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អយំ ខោ ភគវា ភិក្ខូ និព្វានប្បដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ យន្នូនាហំ ភគវន្តំ សម្មុខា សរុប្បាហិ គាថាហិ អភិត្ថវេយ្យន្តិ ។ អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា

# បរោសហស្សសូត្រ ទី ៨

[២២៦] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ជាមួយនឹង ភិក្ខុសង្ឃច្រើន គឺភិក្ខុចំនួន ១២៥០ រូប ។ ក៏ក្នុងសម័យនោះឯង ព្រះ មានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដែលជាប់ទាក់ទងដោយព្រះ និព្វាន ។ ភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូល មកនូវចិត្តទាំងអស់ ផ្ទៀងត្រចៀកស្តាប់ធម៌ ។*

[២២៧] *លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ មានសេចក្តី ត្រិះរិះ យ៉ាងនេះថា ព្រះមានព្រះភាគនេះ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញ ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ដែល ជាប់ទាក់ទងដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវចិត្តទាំងអស់ ផ្ទៀងត្រចៀកស្តាប់ធម៌ បើដូច្នោះ មានតែអាត្មាអញ ពោលសរសើរព្រះមានព្រះភាគ ដោយ គាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រ ។ លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង*

យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ វង្គីសោតិ ភគវា អវោច ។

[២២៨] អថខោ អាយស្មា វង្គីសោ ភគវន្តំ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវិ

បរោសហស្សំ ភិក្ខូនំ
សុគតំ បយិរុបាសតិ
ទេសេន្តំ វិរជំ ធម្មំ
និព្វានំ អកុតោភយំ
សុណន្តិ ធម្មំ វិមលំ
សម្មាសម្ពុទ្ធទេសិតំ
សោភតិ វត សម្ពុទ្ធោ
ភិក្ខុសង្ឃបុរក្ខតោ
នាគនាមោសិ ភគវា
ឥសីនំ ឥសិសត្តមោ
មហាមេឃោវ ហុត្វាន

ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមសំដែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ សូមសំដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ ចូរអ្នកសំដែងធម៌ចុះ ។

[២២៨] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ បានពោលសរសើរព្រះមានព្រះភាគ ដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រថា

ភិក្ខុច្រើនជាងពាន់ ចូលទៅគាល់ព្រះសុគត កំពុងសំដែងធម៌ដែលជាប់ទាក់ទងដោយព្រះនិព្វាន ជាធម៌ប្រាសចាកធូលីគឺកិលេស ឥតមានភ័យអំពីទីណាមួយឡើយ ពួកភិក្ខុទាំងនោះស្តាប់ធម៌ដែលប្រាសចាកមន្ទិល ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងហើយ ព្រះសម្ពុទ្ធ ដែលភិក្ខុសង្ឃគាល់ត្រៀបត្រាល្អណាស់ហ្ន៎ បណ្តាឥសីទាំងឡាយ ព្រះមានព្រះភាគទ្រង់ព្រះនាមថា នាគ ជាទី ៧ នៃពួកឥសី (រាប់តាំងអំពីព្រះពុទ្ធវិបស្សីមក) តែងបង្អុរភ្លៀង ចំពោះសាវ័កទាំងឡាយ

សាវកោ អភិវស្សតិ

ទិវាវិហារា និក្ខម្ម

សត្ថុទស្សនកាមតា

សាវកោ តេ មហាវីរ

ចាទេ វន្ទតិ វង្គីសោតិ ។

កឹ នុ តេ វង្គីស ឥមា គាថាយោ បុព្វេ បរិវិតក្កិតា ឧទាហុ ឋានសោ វ តំ បដិភន្តីតិ ។ ន ខោ មេ ភន្តេ ឥមា គាថាយោ បុព្វេ បរិវិតក្កិតា អថខោ ឋានសោ វ មំ បដិភន្តីតិ ។ តេនហិ តំ វង្គីស ភិយ្យោសោ មត្តាយ បុព្វេ អបរិវិតក្កិតា គាថាយោ បដិភន្តុតិ ។

[២២៩] ឯវំ ភន្តេតិ ខោ អាយស្មា វង្គីសោ ភគវតោ បដិស្សុត្វា ភិយ្យោសោ មត្តាយ ភគវន្តំ បុព្វេ អបរិវិតក្កិតាហិ គាថាហិ អភិត្ថវិ

បីដូចភ្លៀងធំធ្លាក់ចុះ បពិត្រព្រះអង្គមានព្យាយាមធំ វង្គីសៈ ជាសាវ័ករបស់ព្រះអង្គ ចេញមកអំពីទីសម្រាក ក្នុងវេលាថ្ងៃ ព្រោះចង់ឃើញព្រះសាស្តា សូមថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ ។

ព្រះអង្គត្រាស់ថា ម្នាលវង្គីសៈ គាថាទាំងឡាយនេះ អ្នកធ្លាប់បានត្រិះរិះពីកាលមុនឬ ឬទើបនឹងប្រាកដដល់អ្នក មួយរំពេចនេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន គាថាទាំងនេះ ខ្ញុំព្រះអង្គមិនដែលបានត្រិះរិះ ពីកាលមុនមកទេ ស្រាប់តែប្រាកដដល់ខ្ញុំព្រះអង្គ មួយរំពេចនេះឯង ។ ម្នាលវង្គីសៈ បើដូច្នោះ គាថាទាំងឡាយ ដែលអ្នកមិនធ្លាប់បានត្រិះរិះក្នុងកាលមុនមកនោះ ចូរអ្នកសំដែងឲ្យក្រៃលែងតទៅទៀត ។

[២២៩] ព្រះវង្គីសៈមានអាយុ ទទួលព្រះបន្ទូល នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយពោលសរសើរ ព្រះមានព្រះភាគ ដោយគាថាទាំងឡាយ ដែលមិនធ្លាប់ត្រិះរិះក្នុងកាលមុន ឲ្យក្រៃលែងតទៅថា

ឧម្មគ្គសតំ[១] មារស្ស អភិភុយ្យ
ចរសិ បភិជ្ជ ខីលានិ
តំ បស្សថ ពន្ធបមុញ្ចករំ
អសិតំ ភាគសោ បវិភជ្ជំ
ឱឃស្ស ហិ និត្ថរណត្ថំ
អនេកវិហិតំ មគ្គំ អក្ខាសិ
តស្មឹ ចេ អមតេ អក្ខាតេ
ធម្មទ្ទសា ឋិតា អសំហិរា
បជ្ជោតករោ អតិវិជ្ឈ ធម្មំ
សព្វទិដ្ឋីនំ អតិក្កមមទ្ទស
ញត្វា ច សច្ឆិកត្វា ច
អគ្គំ សោ ទេសយិ ទសទ្ធានំ[២]
ឯវំ សុទេសិតេ ធម្មេ
កោ បមាទោ វិជានតំ[៣]

---

១ ឱ. ឧម្មគ្គបថំ ។ ២ ម. សទ្ធានំ ។ ៣ ឱ. ម. វិជានតំ ធម្មំ ។

ព្រះមានព្រះភាគ ទ្រង់គ្របសង្កត់នូវផ្លូវខុសជាច្រើន របស់មារ ទ្រង់ត្រាច់ទៅបំបាក់គោលគឺកិលេសបាន លោកទាំង-ឡាយ ចូរមើលព្រះអង្គកំពុងស្រាយ នូវចំណងដែលមិនអាស្រ័យកិលេស ទ្រង់ចែកធម៌ជាចំណែក ៗ ព្រះអង្គសំដែងប្រាប់ផ្លូវច្រើនបែប ដើម្បីពីខ្លួនចាកអន្លង់ (ទាំង ៤) កាលបើព្រះអង្គសំដែងប្រាប់ នូវព្រះនិព្វាននោះហើយ ពួកជនដែលជាអ្នកឃើញធម៌ ក៏តាំងនៅឥតមានរសេមរសាម ព្រះអង្គជាអ្នកធ្វើនូវពន្លឺ ត្រាស់ដឹងនូវធម៌ បានឃើញច្បាស់ នូវព្រះនិព្វាន ជាទីកន្លងបង់នូវហេតុ នៃទិដ្ឋិទាំងអស់ លុះព្រះអង្គត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ហើយ សំដែងនូវធម៌ដ៏ឧត្តម ដល់ជនទាំងឡាយដែលមានសទ្ធា កាលបើធម៌ដែលព្រះអង្គសំដែង ដោយល្អយ៉ាងនេះហើយ ជនទាំង-ឡាយអ្នកដឹងច្បាស់ នឹងមានសេចក្តីប្រមាទ ដូចម្តេចបាន

តស្មា ហិ តស្ស ភគវតោ សាសនេ
អប្បមត្តោ សទា នមស្សមនុសិក្ខេតិ ។

## នវមំ កោណ្ឌញ្ញសុត្តំ

[២៣០] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អាយស្មា អញ្ញា-កោណ្ឌញ្ញោ(១) សុចិរស្សេវ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវតោ បាទានិ មុខេន ច បរិចុម្ពតិ បាណីហិ ច បរិសម្ពាហតិ នាមញ្ច សាវេតិ កោណ្ឌញ្ញោហំ ភគវា កោណ្ឌញ្ញោហំ សុគតាតិ ។

[២៣១] អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អយំ ខោ អាយស្មា អញ្ញាកោណ្ឌញ្ញោ សុចិរស្សេវ

១ ឱ. ម. អញ្ញាសិកោណ្ឌញ្ញោ ។

ព្រោះហេតុនោះឯង បុគ្គលក្នុងសាសនា របស់ព្រះមានព្រះភាគនោះ គប្បីជាអ្នកមិនប្រមាទ គប្បីសិក្សារឿយ ៗ នូវការថ្វាយបង្គំគ្រប់កាលចុះ ។

# កោណ្ឌញ្ញសូត្រ ទី ៩

[២៣០] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះអញ្ញាកោណ្ឌញ្ញៈមានអាយុ យូរណាស់ហើយ ទើបនឹងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឱនសិរ្សៈទៀបព្រះបាទានៃព្រះមានព្រះភាគ ជញ្ជក់បាទាព្រះមានព្រះភាគដោយមាត់ ច្របាច់ដោយបាតដៃ ហើយប្រកាសនាមថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ឈ្មោះកោណ្ឌញ្ញៈ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ ឈ្មោះកោណ្ឌញ្ញៈ ។

[២៣១] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះកោណ្ឌញ្ញៈមានអាយុនេះ យូរណាស់ហើយ

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវតោ បាទានិ មុខេន ច បរិចុម្ពតិ បាណីហិ ច បរិសម្ពាហតិ នាមញ្ច សាវេតិ កោណ្ឌញ្ញោហំ ភគវា កោណ្ឌញ្ញោហំ សុគតាតិ ។ អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ វង្គីសាតិ ភគវា អវោច ។

[២៣២] អថខោ អាយស្មា វង្គីសោ អាយស្មន្តំ អញ្ញាកោណ្ឌញ្ញំ ភគវតោ សម្មុខា សកាហិ គាថាហិ អភិត្ថវិ

ទើបតែនឹងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឱនសិរ្សៈទៀបបាទា នៃព្រះមានព្រះភាគ ជញ្ជក់បាទានៃព្រះមានព្រះភាគ ដោយមាត់ ច្របាច់ដោយបាតដៃ ហើយប្រកាសនាមថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ឈ្មោះកោណ្ឌញ្ញៈ បពិត្រព្រះសុគត ខ្ញុំព្រះអង្គឈ្មោះកោណ្ឌញ្ញៈដូច្នេះ បើដូច្នោះ មានតែអាត្មាអញ ពោលសរសើរព្រះអញ្ញាកោណ្ឌញ្ញៈមានអាយុ ដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ។ ទើបព្រះវង្គីសៈមានអាយុក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយប្រណម្យអញ្ជលីឆ្ពោះទៅរកព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមសំដែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ សូមសំដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ ចូរអ្នកសំដែងធម៌ចុះ ។

[២៣២] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ បានពោលសរសើរព្រះអញ្ញាកោណ្ឌញ្ញៈមានអាយុ ដោយគាថាទាំងឡាយ ដ៏សមគួរក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា

១៧៤

វង្គីសសំយុត្តស្ស កោណ្ឌញ្ញសុត្តេ អញ្ញាកោណ្ឌញ្ញាភិថុតិ

ពុទ្ធានុពុទ្ធោ សោ ថេរោ
កោណ្ឌញ្ញោ តិព្វនិក្កមោ
លាភី សុខវិហារានំ
វិវេកានំ អភិណ្ហសោ
យំ សាវកេន បត្តព្វំ
សត្ថុសាសនការិនា
សព្វស្ស តំ អនុប្បត្តំ
អប្បមត្តស្ស សិក្ខតោ
មហានុភាវោ តេវិជ្ជោ
ចេតោបរិយាយកោវិទោ
កោណ្ឌញ្ញោ ពុទ្ធទាយាទោ[១]
បាទេ វន្ទតិ សត្ថុនោតិ ។

១ ឱ. ពុទ្ធស្សាវកោ ។

វគ្គីសសំយុត្ត កោណ្ឌញ្ញសូត្រ សេចក្តីសរសើរព្រះអញ្ញាកោណ្ឌញ្ញ

ព្រះថេរៈឈ្មោះកោណ្ឌញ្ញៈនោះ ជាពុទ្ធានុពុទ្ធ គឺជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធ មានព្យាយាមដ៏ក្លៀវក្លា បាននូវសុខវិហារៈធម៌និងវិវេកធម៌រឿយៗ កិច្ចណា ដែលសាវ័កជាអ្នកធ្វើតាមនូវពាក្យប្រដៅរបស់ព្រះសាស្តា លោកក៏សម្រេចកិច្ចទាំងអស់នោះ ព្រះកោណ្ឌញ្ញៈនោះជាអ្នកមិនប្រមាទ សិក្សាក្នុងត្រៃសិក្ខា បានសម្រេចហើយ ព្រះកោណ្ឌញ្ញៈ(នេះ) មានអានុភាពច្រើន បាននូវវិជ្ជា ៣ ឈ្លាសវៃក្នុងការកំណត់ដឹងចិត្តរបស់សត្វដទៃ ជាពុទ្ធទាយាទ (អ្នកទទួលមត៌ករបស់ព្រះពុទ្ធ) តែងថ្វាយបង្គំព្រះបាទា របស់ព្រះសាស្តា ។

# ទសមំ មោគ្គល្លានសុត្តំ

[២៣៣] ឯកំ សមយំ ភគវា រាជគហេ វិហរតិ ឥសិគិលិបស្សេ កាឡសិលាយំ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ ។ តេសំ សុទំ អាយស្មា មហាមោគ្គល្លានោ ចេតសា ចិត្តំ សមន្នេសតិ វិប្បមុត្តំ និរុបធឹ ។

[២៣៤] អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អយំ ខោ ភគវា រាជគហេ វិហរតិ ឥសិគិលិបស្សេ កាឡសិលាយំ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ តេសំ សុទំ អាយស្មា មហាមោគ្គល្លានោ ចេតសា ចិត្តំ សមន្នេសតិ វិប្បមុត្តំ និរុបធឹ យន្នូនាហំ អាយស្មន្តំ មហាមោគ្គល្លានំ ភគវតោ សម្មុខា សារូប្បាហិ គាថាហិ អភិត្ថវេយ្យន្តិ ។ អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា

# មោគ្គល្លានសូត្រ ទី ១០

[២៣៣] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងកាឡ-សិលា ខាងភ្នំឥសិគិលិ ទៀបនគររាជគ្រឹះ ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូប សុទ្ធតែជាព្រះអរហន្ត ។ បានឮថា ព្រះមហាមោគ្គល្លានមានអាយុ ពិចារណាមើលចិត្ត ដែលរួចស្រឡះ មិនមានឧបធិក្កិលេស របស់ភិក្ខុទាំងនោះ ដោយចិត្តរបស់ខ្លួន ។*

[២៣៤] *លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ មានសេចក្តីត្រិះរិះ ដូច្នេះថា ព្រះមានព្រះភាគអង្គនេះ ទ្រង់គង់ ក្នុងកាឡសិលា ខាងភ្នំឥសិគិលិ ទៀបក្រុងរាជគ្រឹះ ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូប សុទ្ធតែជាព្រះអរហន្ត បានឮថា ព្រះមហា-មោគ្គល្លានមានអាយុ ពិចារណាមើលចិត្ត ដែលផុតស្រឡះ មិនមានឧបធិក្កិលេស របស់ភិក្ខុទាំងនោះ ដោយចិត្តរបស់ខ្លួន បើដូច្នោះ គួរតែអាត្មាអញ ពោលសរសើរព្រះមហាមោគ្គល្លានមានអាយុ ដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។ ទើបព្រះវង្គីសៈមានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះត្រង់ទៅរកព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសំដែងធម៌*

បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ វង្គីសាតិ ភគវា អវោច ។

[២៣៨] អថខោ អាយស្មា វង្គីសោ អាយស្មន្តំ មហាមោគ្គល្លានំ ភគវតោ សម្មុខា សរូបាហិ គាថាហិ អភិត្ថវិ

នគស្ស បស្សេ អាសីនំ
មុនឹ ទុក្ខស្ស បារគុំ
សាវកា បយិរុបាសន្តិ
តេវិជ្ជា មច្ចុហាយិនោ
តេ ចេតសា អនុបរិយេសតិ
មោគ្គល្លានោ មហិទ្ធិកោ
ចិត្តំ នេសំ សមន្វេសំ
វិប្បមុត្តំ និរូបធឹ
ឯវំ សព្វង្គសម្បន្នំ
មុនឹ ទុក្ខស្ស បារគុំ
អនេកាការសម្បន្នំ
បយិរុបាសន្តិ គោតមន្តិ ។

បពិត្រព្រះសុគត ខ្ញុំព្រះអង្គ សូមសំដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ ចូរអ្នកសំដែងធម៌ចុះ ។

[២៣៥] លំដាប់នោះ ព្រះវង្គីសៈ មានអាយុ បានពោលសរសើរ ព្រះមហាមោគ្គល្លានមានអាយុ ដោយគាថាទាំងឡាយដ៏សមគួរក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា

ពួកសាវ័កជាអ្នកមានត្រៃវិជ្ជា លះបង់នូវមច្ចុ នាំគ្នាចូលទៅ
អង្គុយជិតព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ដល់នូវត្រើយនៃសេចក្តី
ទុក្ខ ទ្រង់គង់នៅក្បែរខាងភ្នំ ព្រះមោគ្គល្លានជាអ្នកមានឫទ្ធិ
ច្រើន កំពុងពិចារណាមើលចិត្ត របស់សាវ័កទាំងនោះ
ដែលជាចិត្តផុតស្រឡះ មិនមានឧបធិក្កិលេស ក៏កំណត់
ដឹងនូវសាវ័កទាំងនោះ ដោយចិត្តរបស់ខ្លួន សាវ័កទាំងឡាយ
តែងចូលទៅអង្គុយជិតព្រះគោតមជាអ្នកប្រាជ្ញ ដែលប្រកប
ដោយគុណទាំងអស់យ៉ាងនេះ ទ្រង់ដល់នូវត្រើយនៃសេចក្តី
ទុក្ខ ទាំងប្រកបដោយគុណច្រើនប្រការ ។

# ឯកាទសមំ គគ្គរាសុត្តំ

[២៣៦] ឯកំ សមយំ ភគវា ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សត្តហិ ច ឧបាសកសតេហិ អនេកេហិ ច ទេវតាសហស្សេហិ ។ត្យាស្សុទំ ភគវា អតិរោចតិ វណ្ណេន ចេវ យសសា ច ។

[២៣៧] អថខោ អាយស្មតោ វង្គីសស្ស ឯតទហោសិ អយំ ខោ ភគវា ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សត្តហិ ច ឧបាសកសតេហិ អនេកេហិ ច ទេវតាសហស្សេហិ ត្យាស្សុទំ ភគវា អតិរោចតិ វណ្ណេន ចេវ យសសា ច យន្នូនាហំ

# គគ្គរាសូត្រ ទី ១១

[២៣៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ជិតឆ្នេរស្រះបោក្ខរណីឈ្មោះ គគ្គរា ទៀបនគរចម្បា ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូបផង ឧបាសក ៧០០ នាក់ផង ទេវតាជាច្រើនពាន់ផង ។ បានឮថា ព្រះមានព្រះភាគ រុងរឿងលើសជនទាំង-នោះ ដោយសម្បុរព្រះសរីរៈផង ដោយយសបរិវារផង ។

[២៣៧] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនេះ គង់នៅជិតឆ្នេរស្រះបោក្ខរណីឈ្មោះ គគ្គរា ទៀបនគរចម្បា ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូបផង ឧបាសក ៧០០ នាក់ផង ទេវតាជាច្រើនពាន់ផង បានឮថា ព្រះមានព្រះភាគ រុងរឿងលើសជនទាំងនោះ ដោយសម្បុរព្រះសរីរៈផង ដោយយសបរិវារផង បើដូច្នោះ គួរតែអាត្មាអញ

ភគវន្តំ សម្មុខា សរូបាយ គាថាយ អភិត្ថវេយ្យន្តិ ។ អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ វង្គីសាតិ ភគវា អវោច ។

[២៣៨] អថខោ អាយស្មា វង្គីសោ ភគវន្តំ[១] សម្មុខា សរូបាយ គាថាយ អភិត្ថវិ

ចន្ទោ យថា វីតវលាហកេ នភេ
វិរោចតិ វីតមលោវ ភាណុមា
ឯវម្បិ អង្គីរស ត្វំ មហាមុនិ
អតិរោចសិ យសសា សព្វលោកន្តិ ។

១ ឱ. ម. ភគវតោ សម្មុខា ។

ពោលសរសើរព្រះមានព្រះភាគ ដោយគាថាដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រ ។ ទើបព្រះវង្គីសៈមានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមសំដែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ សូមសំដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ ចូរអ្នកសំដែងធម៌ចុះ ។

[២៣៨] លំដាប់នោះឯង ព្រះវង្គីសៈមានអាយុ បានពោលសរសើរព្រះមានព្រះភាគ ដោយគាថាដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រថា

ព្រះចន្ទ្ររុងរឿងឰដ៏អាកាស ដែលឥតភ្លៀង យ៉ាងណា ព្រះអាទិត្យដែលប្រាសចាកមន្ទិល រមែងរុងរឿង យ៉ាងណា បពិត្រព្រះអង្គជាអង្គីរស (ទ្រង់មានរស្មីផ្សាយចេញពីព្រះអង្គ) ព្រះអង្គជាអ្នកប្រាជ្ញធំ តែងរុងរឿង (ដោយសម្បុរព្រះសរីរៈ) និងយសបរិវារ គ្រប់សត្វលោកទាំងអស់ យ៉ាងនោះៗដែរ ។

# ទ្វាទសមំ វង្គីសសុត្តំ

[២៣៩] ឯកំ សមយំ អាយស្មា វង្គីសោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា វង្គីសោ អចិរអរហត្តប្បត្តោ ហោតិ[១] វិមុត្តិសុខំ បដិសំវេទី តាយំ វេលាយំ ឥមា គាថាយោ អភាសិ

កាវេយ្យមត្តា វិចរិម្ហ បុព្វេ
គាមា គាមំ បុរា បុរំ
អថទ្ទសាម សម្ពុទ្ធំ
សទ្ធា នោ ឧបបជ្ជថ
សោ មេ ធម្មមទេសេសិ
ខន្ធេ អាយតនានិ ធាតុយោ
តស្សាហំ ធម្មំ សុត្វាន

---

១ ឱ. ម. ហុត្វា ។

# វង្គីសសូត្រ ទី ១២

[២៣៩] សម័យមួយ ព្រះវង្គីសៈ មានអាយុ នៅក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យ នោះឯង ព្រះវង្គីសៈមានអាយុ ទើបតែនឹងបានសម្រេចព្រះអរហន្តថ្មី ៗ សោយវិមុត្តិសុខ ហើយពោលគាថាទាំងនេះ ក្នុងពេលនោះថា

ក្នុងកាលមុន យើងជាអ្នកស្រវឹងដោយកាព្យឃ្លោង ចេញពី
ស្រុកមួយត្រាច់ទៅស្រុកមួយ ចេញពីបុរីមួយត្រាច់ទៅបុរី
មួយ ក៏ស្រាប់តែយើងបានឃើញព្រះសម្ពុទ្ធ សទ្ធារបស់
យើងក៏កើតឡើង ព្រះអង្គទ្រង់សំដែងធម៌ គឺខន្ធ អាយតនៈ
និងធាតុដល់យើង យើងបានស្តាប់ធម៌របស់ព្រះអង្គហើយ

១៨១

វង្គីសសំយុត្តស្ស វង្គីសសុត្តេ វង្គីសវចនំ

បព្វជឹ អនគារិយំ

ពហុន្នំ វត អត្ថាយ

ពោធិមជ្ឈគមា មុនិ

ភិក្ខូនំ ភិក្ខុនីនញ្ច

យេ និយាមគតទ្ទសា

ស្វាគតំ វត មេ អាសិ

មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា

កតំ ពុទ្ធស្ស សាសនំ

បុព្វេនិវាសំ ជានាមិ

ទិព្វចក្ខុំ វិសោធិតំ

តេវិជ្ជោ ឥទ្ធិប្បត្តោម្ហិ

ចេតោបរិយាយកោវិទោតិ ។

វង្គីសសំយុត្តំ សមត្តំ ។

ក៏ចូលមកកាន់ផ្នួស អើហ្ន៎ ព្រះមុនីបានដល់នូវការត្រាស់ដឹង ដើម្បីប្រយោជន៍ដល់ភិក្ខុនិងភិក្ខុនីជាច្រើន ដែលដល់នូវផ្លូវទាំងឃើញផ្លូវគឺអរិយមគ្គ ដំណើរដែលអាត្មាអញបានមកកាន់សំណាក់ព្រះពុទ្ធនេះ ជាដំណើរល្អ វិជ្ជា ៣ អាត្មាអញបានដល់ហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ អាត្មាអញដឹងនូវបុព្វេនិវាស ចក្ខុជាទិព្វអាត្មាអញបានជម្រះស្អាតហើយ អាត្មាអញបានវិជ្ជា ៣ សម្រេចនូវឥទ្ធិវិធញ្ញាណ ឈ្លាសវៃក្នុងការកំណត់ចិត្ត (នៃជនដទៃដោយចិត្តរបស់ខ្លួន) បាន ។

ចប់ វង្គីសសំយុត្ត ។

## តស្ស  ឧទ្ទានំ

និក្ខន្តអរតិ  ចេវ
បេសលាអតិមញ្ញនា
អានន្ទេន  សុភាសិតា
សារីបុត្តបវារណា
បរោសហស្សំ  កោណ្ឌញ្ញោ
មោគ្គល្លានេន  គគ្គរា
វង្គីសេន  ទ្វាទសាតិ  ។

# ឧទ្ទាននៃវង្គីសសំយុត្តនោះគឺ

*និក្ខន្តសូត្រ ១ អរតិសូត្រ ១ បេសលាតិមញ្ញនាសូត្រ ១ អានន្ទសូត្រ ១ សុភាសិតសូត្រ ១ សារីបុត្រ ១ បវារណាសូត្រ ១ បរោសហស្សសូត្រ ១ កោណ្ឌញ្ញសូត្រ ១ មោគ្គល្លានសូត្រ ១ គគ្គរាសូត្រ ១ វង្គីសសូត្រ ១ ត្រូវជា ១២ ។*

---

# វនសំយុត្តំ

## បឋមំ វិវេកសុត្តំ

[២៤០] ឯវម្មេ សុតំ ។ ឯកំ សមយំ អញ្ញតរោ ភិក្ខុ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន សោ ភិក្ខុ ទិវាវិហារគតោ បាបកេ អកុសលេ វិតក្កេ វិតក្កេតិ គេហនិស្សិតេ ។

[២៤១] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តស្ស ភិក្ខុនោ អនុកម្បិកា អត្ថកាមា តំ ភិក្ខុំ សំវេជេតុកាមា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ គាថាហិ អជ្ឈភាសិ

វិវេកកាមោសិ វនំ បវិដ្ឋោ
អថ តេ មនោ និច្ឆរតិ ពហិទ្ធា
ត្វំ ជនោ ជនស្មឹ វិនយស្សុ ឆន្ទំ
តតោ សុខី ហោហិសិ វីតរាគោ
អរតឹ បជហាសិ[១] សតោ

---

១ ឱ. បជហាសិ សោ ។

# វនសំយុត្ត

## វិវេកសូត្រ ទី ១

[២៤០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏ក្នុងសម័យនោះ ភិក្ខុនោះ ទៅកាន់ទីសម្រាក ក្នុងវេលាថ្ងៃ ហើយត្រិះរិះនូវអកុសលវិតក្កៈទាំង-ឡាយដ៏លាមក ដែលអាស្រ័យនឹងបញ្ចកាមគុណ ។

[២៤១] ក្នុងកាលនោះ មានទេវតាដែលអាស្រ័យនៅក្នុងដងព្រៃនោះ ជាអ្នកមានសេចក្តីអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុនោះ ប្រាថ្នា ដើម្បីធ្វើភិក្ខុនោះឲ្យសង្វេគ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុនោះ ដោយគាថាទាំងឡាយថា

លោកប្រាថ្នាសេចក្តីស្ងាត់ បានជាចូលមកកាន់ព្រៃ តែចិត្ត
របស់លោកនៅតែត្រាច់ទៅក្នុងអារម្មណ៍ខាងក្រៅ លោកចូរ
ជាជននាំចេញនូវឆន្ទរាគក្នុងជន (ដទៃ) តអំពីនោះ លោក
នឹងបានសេចក្តីសុខ ប្រាសចាករាគៈមិនខាន លោកចូរ
លះបង់សេចក្តីមិនត្រេកអរចេញ លោកចូរជាអ្នកមានស្មារតី

ភវាសិ សតំ តំ សារយាមសេ
ចាតាលរជោ ហិ ទុត្តរោ[១]
មា តំ កាមរជោ អវាហរិ
សកុណោ យថា បំសុកុណ្ឋិតោ
វិធុនំ ចាតយតិ សិតំ រជំ
ឯវំ ភិក្ខុ បធានវា សតីមា[២]
ចាតយតិ សិតំ រជន្តិ ។

អថខោ សោ ភិក្ខុ តាយ ទេវតាយ សំវេជិតោ សំវេគមាបាទីតិ ។

# ទុតិយំ ឧបដ្ឋានសុត្តំ

[២៤២] ឯកំ សមយំ អញ្ញតរោ ភិក្ខុ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន សោ ភិក្ខុ ទិវាវិហារគតោ សុបតិ ។

១ ទុរុត្តមោ ។ ម. ទុក្ករោ ។ ២ ឱ. ម. វិធូនំ បាតយតិ ។

ខ្ញុំសូមរំឭកលោក ដែលជាអ្នកមានស្មារតី ព្រោះថាធូលីគឺកិលេស ដែលបណ្ឌិតហៅថា បាតាល[១](នេះ) លំបាកនឹងឆ្លងណាស់ ធូលីគឺកាមកុំនាំលោកទៅឡើយ ដូចសត្វស្វាប ដែលប្រឡាក់ខ្លួនដោយអាចម៍ដី ប្រឹងទទះជម្រុះធូលី ដែលប្រឡាក់ខ្លួនឲ្យធ្លាក់ចេញ យ៉ាងណា ភិក្ខុអ្នកមានព្យាយាម មានស្មារតី តែងធ្វើធូលីគឺកិលេសដែលប្រឡាក់ខ្លួន ឲ្យធ្លាក់ចេញ យ៉ាងនោះឯង ។

ក្នុងកាលនោះ ភិក្ខុនោះ ក៏បានដល់នូវសេចក្ដីសង្វេគ ដោយសារទេវតានោះធ្វើឲ្យសង្វេគ ។

# ឧបដ្ឋានសូត្រ ទី ២

[២៤២] សម័យមួយ មានភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ នាដែនកោសល ។ ក៏ក្នុងកាលនោះ ភិក្ខុនោះ ចូលទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ហើយដេកលក់ ។

---

១ ប្រែថា ពិភពនាគ ក៏បាន ថា សមុទ្រ ក៏បាន ថា ភ្លើងក្នុងទន្លេ ក៏បាន ខ្មែរយើងពីដើមធ្លាប់នាំគ្នានិយាយថា បាដាល (បាលីលិបិក្រម) ។

[២៤៣] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តស្ស ភិក្ខុនោ អនុកម្បិកា អត្ថកាមា តំ ភិក្ខុំ សំវេជេតុកាមា យេន សោ ភិក្ខុ តេនុប-សង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ គាថាហិ អជ្ឈភាសិ

ឧដ្ឋេហិ ភិក្ខុ កឹ សោបិ[១]
កោ អត្ថោ សុបិតេន តេ
អាតុរស្ស ហិ តេ និទ្ទា
សល្លវិទ្ធស្ស រុប្បតោ
យាយ សទ្ធាយ បព្វជិតោ
អគារស្មានគារិយំ
តមេវ សទ្ធំ ព្រូហេហិ
មា និទ្ទាយ វសំ គមីតិ ។

[២៤៤] អនិច្ចា អធុវា កាមា
យេសុ មន្ទោ វ មុច្ឆិតោ
ពទ្ធេសុ មុត្តំ អសិតំ
កស្មា បព្វជិតំ តបេ

១ ឱ. ម. កឹ សេសិ ។

វនសំយុត្ត ឧបដ្ឋានសូត្រ ពាក្យភិក្ខុពោលតបទេវតា

[២៤៣] គ្រានោះ ទេវតាដែលអាស្រ័យនៅ ក្នុងដងព្រៃនោះ ជាអ្នកមានសេចក្តីអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុនោះ ចង់ធ្វើភិក្ខុនោះឲ្យសង្វេគ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុនោះ ដោយគាថាទាំងឡាយថា

បពិត្រភិក្ខុ លោកចូរក្រោកឡើង លោកសិងធ្វើអ្វី លោកមាន
ប្រយោជន៍អ្វី ដោយការសិង ព្រោះថាការលក់របស់លោក
ដែលមានកិលេសក្តៅពោលពល មុតដោយសរគឺតណ្ហា មាន
សេចក្តីលំបាក លោកចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួស
ក្នុងពុទ្ធសាសនា ដោយសទ្ធាណា លោកចូរចម្រើននូវសទ្ធា
នោះចុះ ចូរកុំលុះក្នុងអំណាចនៃការលក់នេះឡើយ ។

[២៤៤] ភិក្ខុនោះតបថា បុគ្គលមានប្រាជ្ញាទន់ ជ្រប់ចុះ
ក្នុងកាមទាំងឡាយណា កាមទាំងឡាយនោះ មិនទៀង
មិនឋិតថេរឡើយ (ការដេកលក់ក្នុងវេលាថ្ងៃ) ដូចម្តេច
នឹងដុតកម្តៅអ្នកបួស ដែលផុតចាកចំណងទាំងឡាយ មិន
អាស្រ័យតណ្ហានិងទិដ្ឋិបាន (ការដេកលក់ក្នុងវេលាថ្ងៃ)

ឆន្ទរាគស្ស វិនយា
អវិជ្ជាសមតិក្កមា
តំ ញាណំ បរមោធាតំ[១]
កស្មា បព្វជិតំ តបេ
ភេត្វា អវិជ្ជំ វិជ្ជាយ
អាសវានំ បរិក្ខយា
អសោកំ អនុបាយាសំ
កស្មា បព្វជិតំ តបេ
អារទ្ធវីរិយំ បហិតត្តំ
និច្ចំ ទឡ្ហបរក្កមំ
និព្វានំ អភិកង្ខន្តំ
កស្មា បព្វជិតំ តបេតិ ។

១ ឱ. បរិយោទាតំ ។ ម. បរមោ ទានំ ។

ដូចម្តេចនឹងដុតកម្តៅអ្នកបួស ដែលប្រកបដោយប្រាជ្ញាដ៏បរិសុទ្ធក្រៃលែងនោះបាន ព្រោះលោកនាំបង់នូវឆន្ទរាគ ទាំងប្រព្រឹត្តកន្លងផុតអវិជ្ជាហើយ (ការដេកលក់ក្នុងវេលាថ្ងៃ) ដូចម្តេចនឹងដុតកម្តៅអ្នកបួស ដែលមិនមានសេចក្តីសោក មិនមានសេចក្តីចង្អៀតចង្អល់បាន ព្រោះលោកទម្លាយអវិជ្ជាដោយវិជ្ជាហើយ ទាំងអាសវៈក៏អស់ហើយ (ការដេកលក់ក្នុងវេលាថ្ងៃ) ដូចម្តេចនឹងដុតកម្តៅ អ្នកបួសដែលប្រារព្ធព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទាំងមានសេចក្តីប្រឹងប្រែងដ៏មាំអស់កាលជានិច្ច ដែលជាអ្នកប្រាថ្នានូវព្រះនិព្វាន ។

# តតិយំ  កស្សបគោត្តសុត្តំ

[២៤៥]  ឯកំ  សមយំ  អាយស្មា  កស្សបគោត្តោ  កោសលេសុ  វិហរតិ  អញ្ញតរស្មឹ  វនសណ្ឌេ  ។  តេន  ខោ  បន  សមយេន  អាយស្មា  កស្សបគោត្តោ  ទិវាវិ-ហារគតោ  អញ្ញតរំ  ឆេតំ  ឱវទតិ  ។

[២៤៦]  អថខោ  យា  តស្មឹ  វនសណ្ឌេ  អធិវត្ថា  ទេវតា  អាយស្មតោ  កស្សបគោត្តស្ស  អនុកម្បិកា  អត្ថកាមា  អាយស្មន្តំ  កស្សបគោត្តំ  សំវេជេតុកាមា  យេនាយស្មា  កស្សបគោត្តោ  តេនុបសង្កមិ  ឧបសង្ក-មិត្វា  អាយស្មន្តំ  កស្សបគោត្តំ  គាថាយ  អជ្ឈភាសិ

គិរិទុគ្គចរំ  ឆេតំ
អប្បបញ្ញំ  អចេតសំ
អកាលេ  ឱវទំ  ភិក្ខុ
មន្ទោវ  បដិភាតិ  មំ

# កស្សបគោត្តសូត្រ ទី ៣

[២៤៥] *សម័យមួយ ព្រះកស្សបគោត្រមានអាយុ នៅក្នុងដងព្រៃមួយ នាដែនកោសល ។ ក៏ក្នុងសម័យនោះ ព្រះកស្សបគោត្រមានអាយុ ចូលទៅកាន់ទីសម្រាក ក្នុងវេលាថ្ងៃ ហើយប្រដៅព្រានម្រឹគម្នាក់ ។*

[២៤៦] *លំដាប់នោះឯង មានទេវតាដែលនៅអាស្រ័យ ក្នុងដងព្រៃនោះ ជាអ្នកមានសេចក្តីអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ដល់ព្រះកស្សបគោត្រមានអាយុ ចង់ឲ្យព្រះកស្សបគោត្រ មានអាយុនោះសង្វេគ ក៏ចូលទៅរកព្រះកស្សបគោត្រ មានអាយុ លុះចូលទៅដល់ហើយ បានពោល នឹងព្រះកស្សបគោត្រ មានអាយុ ដោយគាថាទាំងឡាយថា*

*បពិត្រភិក្ខុ លោកបំភ្លឺនូវឱវាទចំពោះព្រានម្រឹគ ដែលអាប់ប្រាជ្ញា ឥតចិត្ត ជាអ្នកត្រាច់ទៅក្នុងទីភ្នំដែលលំបាកដើរ ក្នុងកាលខុស* (នេះ) *ហាក់ដូចជាជនល្ងង់បំភ្លឺនូវឱវាទចំពោះខ្ញុំដែរ*

សុណាតិ ន វិជានាតិ
អាលោកេតិ ន បស្សតិ
ធម្មស្មឹ ភញ្ញមានស្មឹ
អត្ថំ ពាលោ ន ពុជ្ឈតិ
សចេបិ ទស បជ្ជោតេ
ធារយិស្សសិ កស្សប
នេវ ទក្ខតិ រូបានិ
ចក្ខុំ ហិស្ស ន វិជ្ជតីតិ ។

អថខោ អាយស្មា កស្សបគោត្តោ តាយ ទេវ-តាយ សំវេជិតោ សំវេគមាបាទីតិ ។

## ចតុត្ថំ សម្ពហុលសុត្តំ

[២៤៧] ឯកំ សមយំ សម្ពហុលា ភិក្ខូ កោ-សលេសុ វិហរន្តិ អញ្ញតរស្មឹ វនសណ្ឌេ ។ អថខោ តេ ភិក្ខូ វស្សំ វុត្ថា តេមាសច្ចយេន ចារិកំ បក្កមឹសុ ។

បុគ្គលពាល បើស្តាប់ (ធម៌) ក៏មិនដឹងសេចក្តី បើពិនិត្យមើល ក៏មិនឃើញ ទាំងមិនភ្ញាក់ខ្លួននឹងសេចក្តីក្នុងធម៌ ដែលលោកម្ចាស់សំដែងប្រាប់ បពិត្រព្រះកស្សបៈ ទោះបីលោកនឹងទ្រោលបំភ្លឺប្រទីប គ្រប់ម្រាមដៃទាំង ១០ បុគ្គលពាល ក៏មិនឃើញរូបទាំងឡាយបានទេ ព្រោះថាបញ្ញាចក្ខុរបស់បុគ្គលពាលនោះគ្មានឡើយ ។

គ្រានោះឯង ព្រះកស្សបគោត្រ មានអាយុ ក៏ដល់សេចក្តីសង្វេគ ដោយសារទេវតានោះធ្វើឲ្យសង្វេគ ។

# សម្ពហុលសូត្រ ទី ៤

[២៤៧] សម័យមួយ ពួកភិក្ខុច្រើនរូប នៅក្នុងដងព្រៃមួយក្នុងដែនកោសល ។ កាលដែលភិក្ខុទាំងនោះ នៅចាំវស្សារួចហើយលុះកន្លងទៅ ៣ ខែ ក៏នាំគ្នាចៀសចេញទៅកាន់ចារិក ។

[១៤៨] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តេ ភិក្ខូ អបស្សន្តី បរិទេវមានា តាយំ វេ-
លាយំ ឥមំ គាថំ អភាសិ

អរតិ វិយ មេជ្ជំ ខាយតិ
ពហុកេ ទិស្វាន វិវិត្តេ អាសនេ
តេ ចិត្តកថា ពហុស្សុតា
កោមេ គោតមសាវកា គតាតិ ។

[១៤៩] ឯវំ វុត្តេ អញ្ញតរា ទេវតា តំ ទេវតំ គា-
ថាយ អជ្ឈភាសិ

មគធំ គតា កោសលំ គតា
ឯកច្ចិយា បន វជ្ជិភូមិយា
មក្កដា(១) វិយ សង្ឃចារិណោ
អនិកេតា វិហរន្តិ ភិក្ខវោតិ ។

---

១ ឱ. ម. មគ្គា វិយ អសង្គបារិនោ ។

វនសំយុត្ត សម្ពហុលសូត្រ ទេវតាពោលប្រាប់ទេវតា

[២៤៨] គ្រានោះឯង ទេវតាដែលអាស្រ័យនៅ ក្នុងដងព្រៃនោះ កាលបើមិនឃើញភិក្ខុទាំងនោះ ក៏យំសោកពោលគាថា ក្នុងវេលានោះថា

ទីដែលគួរត្រេកអរប្រាកដ ហាក់ដូចជាទីមិនគួរត្រេកអរទៅ
វិញ ពួកភិក្ខុជាសាវ័ករបស់ព្រះគោតមទាំងនោះ លោកមាន
សំដីដ៏វិចិត្ត ជាពហូសូត បានឃើញអាសនៈស្វាត់ដ៏ច្រើន
ហើយ នាំគ្នាចេញទៅទីណាវិញអស់ ។

[២៤៩] កាលទេវតានោះ ពោលយ៉ាងនេះហើយ មានទេវតាមួយអង្គទៀត បានប្រាប់ទេវតានោះ ដោយគាថា ថា

ភិក្ខុទាំងឡាយខ្វះ ទៅកាន់ដែនមគធៈ ខ្វះទៅកាន់ដែន
កោសល ខ្វះឆ្ពោះមុខទៅកាន់ដែនវជ្ជី ត្រាច់ទៅជាពួក
មិនកំណត់ទីលំនៅ បីដូចជាពានរ ។

# បញ្ចមំ អានន្ទសុត្តំ

[២៤០] ឯកំ សមយំ អាយស្មា អានន្ទោ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន អាយស្មា អានន្ទោ អតិវេលំ គិហិសញ្ញត្តិពហុលោ វិហរតិ ។

[២៤១] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា អាយស្មតោ អានន្ទស្ស អនុកម្បិកា អត្ថកាមា អាយស្មន្តំ អានន្ទំ សំវេជេតុកាមា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ គាថាយ អជ្ឈភាសិ

រុក្ខមូលគហនំ បសក្កិយ
និព្វានំ ហទយស្មឹ ឱបិយ
ឈាយ គោតម មា បមាទោ
កឹ តេ ពីឡិពីឡិកា ករិស្សតីតិ ។

អថខោ អាយស្មា អានន្ទោ តាយ ទេវតាយ សំវេជិតោ សំវេគមាបាទីតិ ។

# អានន្ទសូត្រ ទី ៥

[២៥០] សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះឯង ព្រះអានន្ទមានអាយុ ច្រើននិយាយពន្យល់ពួកគ្រហស្ថហួសវេលា ។

[២៥១] គ្រានោះឯង ទេវតាដែលអាស្រ័យនៅ ក្នុងដងព្រៃនោះ មានសេចក្តីអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ដល់ព្រះអានន្ទមានអាយុ ប្រាថ្នានឹងធ្វើព្រះអានន្ទមានអាយុ ឲ្យសង្វេគ ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ទើបពោលគាថា នឹងព្រះអានន្ទមានអាយុថា

បពិត្រលោកជាសាវ័ក របស់ព្រះគោតម ចូរលោកចូលទៅ
កាន់ម្លប់ឈើនិងព្រៃស្បាត ដាក់ព្រះនិព្វាន ក្នុងហឫទ័យ
ហើយចម្រើនឈានចុះ កុំមានសេចក្តីប្រមាទឡើយ ពាក្យ
ប៉ប៉ាច់ប៉ប៉ូវ (ជាមួយនឹងគ្រហស្ថ) នឹងធ្វើអ្វីដល់លោកបាន ។

គ្រានោះឯង ព្រះអានន្ទមានអាយុ ក៏បានដល់នូវសេចក្តីសង្វេគ ដោយសារទេវតានោះ ធ្វើឲ្យសង្វេគ ។

# ឆដ្ឋំ អនុរុទ្ធសុត្តំ

[២៨២] ឯកំ សមយំ អាយស្មា អនុរុទ្ធោ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។

[២៨៣] អថខោ អញ្ញតរា តាវត្តឹសកាយិកា ទេវតា ជាលិនី នាម អាយស្មតោ អនុរុទ្ធស្ស បុរាណទុតិយិកា យេនាយស្មា អនុរុទ្ធោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អនុរុទ្ធំ គាថាយ អជ្ឈភាសិ

តត្ថ ចិត្តំ បណិធេហិ
យត្ថ តេ វុសិតំ បុរេ
តាវត្តឹសេសុ ទេវេសុ
សព្វកាមសមិទ្ធិសុ
បុរក្ខតោ បរិវុតោ
ទេវគណេហិ[១] សោភសីតិ ។

[២៨៤] ទុគ្គតា ទេវកញ្ញាយោ
សក្កាយស្មឹ បតិដ្ឋិតា
តេ ចាបិ ទុគ្គតា សត្តា
ទេវកញ្ញាហិ បត្ថិតាតិ[២] ។

---

១ ឱ. ម. ទេវកញ្ញាហិ ។ ២ បត្តិកាតិ ។

# អនុរុទ្ធសូត្រ ទី ៦

[២៥២] *សម័យមួយ ព្រះអនុរុទ្ធ មានអាយុ គង់នៅនាដងព្រៃមួយ ក្នុងដែនកោសល ។*

[២៥៣] *គ្រានោះឯង ទេវតាមួយអង្គ ឈ្មោះជាលិនី ជាពួកទេវតានៅឋានតាវត្តិង្ស ជាប្រពន្ធពីដើម របស់ព្រះអនុរុទ្ធមានអាយុ បានចូលទៅរកព្រះអនុរុទ្ធមានអាយុ លុះចូលទៅដល់ហើយ ទើបពោលគាថានឹងព្រះអនុរុទ្ធមានអាយុថា*

*កាលពីដើម លោកប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងទីណា ចូរលោកតាំងចិត្តឲ្យនឹងក្នុងទីនោះ លោកមានពួកទេវតាចោមរោមជាបរិវារ តែងល្អក្នុងឋានទេវតាឈ្មោះតាវត្តិង្ស ជាទីសម្រេចនៃសេចក្តីប្រាថ្នាគ្រប់យ៉ាង ។*

[២៥៤] *ព្រះអនុរុទ្ធតបថា ទេវកញ្ញាដែលទុគ៌ត តាំងនៅក្នុងសក្កាយទិដ្ឋិ ទោះបីពួកសត្វជាទុគ៌តនោះ ក៏ពួកទេវកញ្ញាប្រាថ្នាដែរ ។*

[២៨៨] ន តេ សុខំ បជានន្តិ
យេ ន បស្សន្តិ នន្ទនំ
អាវាសំ នរទេវានំ
តិទសានំ យសស្សិនន្តិ ។

[២៨៦] ន ត្វំ ពាលេ វិជានាសិ
យថា អរហតំ វចោ
អនិច្ចា សព្វេ សង្ខារា
ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ
តេសំ វូបសមោ សុខោ
នត្ថិ ទានិ បុនាវាសោ
ទេវកាយស្មិ ជាលិនី
វិក្ខីណោ ជាតិសំសារោ
នត្ថិ ទានិ បុនព្ភវោតិ ។

[២៥៥] ទេវតាតបថា ពួកជនណាមិនឃើញឱទ្យាន ឈ្មោះនន្ទនៈ ជាអាវាសរបស់ពួកទេវតា មានប្រមាណ ៣[១] ដ៏មានយស ពួកជននោះ ឈ្មោះថាមិនស្គាល់សេចក្តីសុខសប្បាយ ។

[២៥៦] ព្រះអនុរុទ្ធតបថា ម្នាលទេវតាពាលនាងឯង មិនដឹងពាក្យរបស់ព្រះអរហន្តទាំងឡាយថា សង្ខារទាំងពួងមិនទៀង មានការកើតឡើង និងការវិនាសទៅវិញជាធម្មតា លុះកើតឡើងហើយរលត់ទៅវិញ លុះតែរម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ ម្នាលនាងជាលិនី ការនៅរបស់យើងក្នុងពួកទេវតាទៀត ក្នុងកាលឥឡូវនេះ មិនមានទេ ជាតិសង្សារអស់ហើយ ឥឡូវកពថ្មីមិនមានទេ ។

---

១ មានប្រមាណ ៣ គឺ ជាតិ ១ សត្ត ១ អវិនាស ១ ។

វនសំយុត្តស្ស នាគទត្តសុត្តេ ទេវតាភាសនំ

# សត្តមំ នាគទត្តសុត្តំ

[២៨៧] ឯកំ សមយំ អាយស្មា នាគទត្តោ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន អាយស្មា នាគទត្តោ អតិកាលេន គាមំ បវិសតិ អតិទិវា បដិក្កមតិ ។

[២៨៨] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា អាយស្មតោ នាគទត្តស្ស អនុកម្បិកា អត្ថ-កាមា អាយស្មន្តំ នាគទត្តំ សំវេជេតុកាមា យេនាយ-ស្មា នាគទត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ នាគទត្តំ គាថាហិ អជ្ឈភាសិ

កាលេ បវិស្ស នាគទត្ត
ទិវា ច អាគន្ត្វា អតិវេល-
ចារី សំសដ្ឋោ គហដ្ឋេហិ
សមានសុខទុក្ខោ

# នាគទត្តសូត្រ ទី ៧

[២៥៧] សម័យមួយ ព្រះនាគទត្តមានអាយុ នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះឯង ព្រះនាគទត្តមានអាយុ ចូលទៅកាន់ស្រុកក្នុងវេលាព្រឹកពេក ត្រឡប់មកវិញ ក្នុងវេលាថ្ងៃពេក ។

[២៥៨] គ្រានោះឯង ទេវតា ដែលអាស្រ័យនៅក្នុងដងព្រៃនោះ ជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ដល់ព្រះនាគទត្តមានអាយុ ចង់ធ្វើព្រះនាគទត្តមានអាយុឲ្យសង្វេគ ក៏ចូលទៅរកព្រះនាគទត្តមានអាយុ លុះចូលទៅដល់ហើយ ទើបពោលគាថា នឹងព្រះនាគទត្តមានអាយុថា

បពិត្រព្រះនាគទត្ត លោកចូលទៅ (កាន់ស្រុក) ក្នុងវេលា
ព្រឹក ត្រឡប់មកវិញក្នុងវេលាថ្ងៃ ត្រាច់ទៅហួសវេលា នៅ
ច្រឡូកច្រឡំដោយពួកគ្រហស្ថ រួមសុខរួមទុក្ខជាមួយគ្នា

ភាយាមិ ជាតរូបំ សុបតន្តំ

កុលេសុ វិជិពន្ធំ

មា ហេវ មច្ចុរញ្ញោ ពលវតោ

អន្តកស្ស វសមេសីតិ(១) ។

អថខោ អាយស្មា ជាតរូបោ តាយ ទេវតាយ សំវេជិតោ សំវេគមាបាទីតិ ។

## អដ្ឋមំ កុលឃរណីសុត្តំ

[២៤៩] ឯកំ សមយំ អញ្ញតរោ ភិក្ខុ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន សោ ភិក្ខុ អញ្ញតរស្មឹ កុលេ អតិវេលំ អជ្ឈោគាឡ្ហប្បត្តោ វិហរតិ ។

១ ឱ. វសមេយ្យាតិ ។ ម. វសំ ឧបេសីតិ ។

ខ្ញុំខ្លាចព្រះនាគទត្ត ប្រែទៅជាអ្នកឃ្មើសឃ្មង៍ក្រៃពេក ជាប់ចំពាក់ក្នុងត្រកូលទាំងឡាយ លោកកុំលុះអំណាចនៃស្តេចមច្ចុ ដែលឈ្មោះថាអន្តកៈ ដ៏មានកម្លាំងឡើយ ។

លំដាប់នោះឯង ព្រះនាគទត្តមានអាយុ លុះទេវតានោះ ធ្វើឲ្យសង្វេគហើយ ក៏ដល់នូវសេចក្តីសង្វេគ ។

# កុលឃរណីសូត្រ ទី ៨

[២៥៩] សម័យមួយ ភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះឯង ភិក្ខុនោះ ចូលទៅក្នុងត្រកូលមួយ ហួសវេលា ។

១៩៤

វនសំយុត្តស្ស កុលឃរណីសុត្តេ អញ្ញតរភិក្ខុភាសនំ

[២៦០] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តស្ស ភិក្ខុនោ អនុកម្បិកា អត្ថកាមា តំ ភិក្ខុំ សំវេជេតុកាមា យា តស្មឹ កុលេ កុលឃ-រណី តស្សា វណ្ណំ អភិនិម្មិនិត្វា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ គាថាយ អជ្ឈភាសិ

នទីតីរេសុ សណ្ឋានេ
សភាសុ រថិយាសុ ច
ជនា សង្គម្ម មន្តេន្តិ
មញ្ច តញ្ច កិមន្តរន្តិ ។

[២៦១] ពហូ ហិ សទ្ទា បច្ចូហា
ខមិតព្វា តបស្សិនា
ន តេន មង្កុហោតព្វំ
ន ហិ តេន កិលិស្សតិ
យោ ច សទ្ទបរិត្តាសី
វនេ វាតមិគោ យថា

[២៦០] គ្រានោះឯង ទេវតាដែលនៅក្នុងដងព្រៃនោះ ជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុនោះ ចង់ធ្វើឲ្យភិក្ខុនោះសង្វេគ ក៏និម្មិតជាភេទស្រីមេផ្ទះ ក្នុងត្រកូលនោះ ហើយចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទើបពោលគាថានឹងភិក្ខុនោះថា

ជនទាំងឡាយ មកប្រជុំនិយាយគ្នា ទៀបឆ្នេរស្ទឹងទាំងឡាយ
ផង ក្នុងរោងសម្រាប់សម្រាកផង ក្នុងរោងសម្រាប់ប្រជុំគ្នា
និយាយផង នាផ្លូវបែ្រកផង ហើយនិយាយចំពោះខ្ញុំផង
ចំពោះលោកផង តើព្រោះហេតុអ្វី ។

[២៦១] ភិក្ខុតបថា ព្រោះថា ជនទាំងឡាយ មានសទ្ទា
ជាបដិលោម ក្នុងលោកនេះ ច្រើនគ្នា អ្នកដែលមានតបៈ
នោះ គួរតែអត់ទ្រាំ មិនគួរអៀនខ្មាសឡើយ ដ្បិតសត្វមិន
មែនសៅហ្មង ដោយពាក្យដែលពួកជនដទៃ និយាយនោះទេ
បុគ្គលណា តក់ស្លុតនឹងសំឡេង ដូចជាសត្វឈ្លូសក្នុងព្រៃ

លហុចិត្តោតិ តំ អាហុ
ជាស្ស សម្បជ្ជតេ វតន្តិ ។

## នវមំ វជ្ជីបុត្តសុត្តំ

[២៦២] ឯកំ សមយំ អញ្ញតរោ វជ្ជីបុត្តកោ ភិក្ខុ វេសាលិយំ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន វេសាលិយំ សព្វរត្តិវារោ[១] ហោតិ ។

[២៦៣] អថខោ សោ ភិក្ខុ វេសាលិយំ តុរិយតាឡិតវាទិតនិគ្ឃោសសទ្ទំ សុត្វា បរិទេវមានោ តាយំ វេលាយំ ឥមំ គាថំ អភាសិ

ឯកកា មយំ អរញ្ញេ វិហរាម
អបវិទ្ធំវ វនស្មឹ ទារុកំ
ឯតាទិសិកាយ រត្តិយា
កោ សុ នាមម្ហេហិ បាបិយោតិ ។

---

១ ម. វជ្ជីបុត្តកោ សព្វរត្តិចារោ ។ ឱ. សព្វរត្តិចារោ ។

អ្នកប្រាជ្ញហៅបុគ្គលនោះ ថាជាអ្នកមានចិត្តស្រាល កិច្ចវត្ត
មិនសម្រេចដល់បុគ្គលនោះទេ ។

# វជ្ជីបុត្តសូត្រ ទី ៩

[២៦២] សម័យមួយ វជ្ជីបុត្តកភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ ជិតក្រុងវេសាលី ។ ក៏សម័យនោះឯង វជ្ជីបុត្តកភិក្ខុ មានការដើរលេង អស់ពេញមួយរាត្រី ក្នុងក្រុងវេសាលី ។

[២៦៣] គ្រានោះឯង ភិក្ខុនោះ បានឮសំឡេងគឹកកង នៃការវាយ និងការប្រគំតន្ត្រី ក៏ខ្សឹកខ្សួល ពោលគាថានោះ ក្នុងវេលានោះថា

យើងមកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើដែលគេ
បោលក្នុងព្រៃ ក្នុងរាត្រីប្រាកដដូច្នេះ មិនមានអ្នកណាអន់
ជាងយើងទៅទៀតទេ ។

[៦៦៤] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តស្ស ភិក្ខុនោ អនុកម្បិកា អត្ថកាមា តំ ភិក្ខុំ សំវេជេតុកាមា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ គាថាយ អជ្ឈភាសិ

ឯកកោ វ ត្វំ អរញ្ញេ វិហរសិ
អបវិដ្ឋំវ វនស្មឹ ទារុកំ
តស្ស តេ ពហុកា បិហយន្តិ
នេរយិកា វិយ សគ្គគាមិនន្តិ ។

អថខោ សោ ភិក្ខុ តាយ ទេវតាយ សំវេជិតោ សំវេគមាបាទីតិ ។

## ទសមំ សជ្ឈាយសុត្តំ

[៦៦៥] ឯកំ សមយំ អញ្ញតរោ ភិក្ខុ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន សោ ភិក្ខុ យំ សុទំ បុព្វេ អតិវេលំ សជ្ឈាយពហុលោ វិហរតិ ។ សោ អបរេន សមយេន អប្បោស្សុក្កោ តុណ្ហីភូតោ សកមាយតិ[១] ។

១ ឱ. សង្កសាយតិ ។

[២៦៤] គ្រានោះឯង ទេវតាដែលអាស្រ័យនៅ នាដងព្រៃនោះ ជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុនោះ ចង់ធ្វើភិក្ខុនោះ ឲ្យសង្វេគ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទើបពោលគាថា នឹងភិក្ខុនោះថា

លោកនៅក្នុងព្រៃតែម្នាក់ឯង ដូចជាកំណាត់ឈើដែលគេ
បោលនៅក្នុងព្រៃមែន តែមានជនច្រើនគ្នាស្រឡាញ់លោក
នោះ ដូចពពួកសត្វក្នុងឋាននរក ស្រឡាញ់ពួកទេវតា
ក្នុងឋានសួគ៌ ។

លំដាប់នោះឯង ភិក្ខុនោះ លុះទេវតានោះ ធ្វើឲ្យសង្វេគហើយ ក៏ដល់នូវសេចក្តីសង្វេគ ។

## សជ្ឈាយសូត្រ ទី ១០

[២៦៥] សម័យមួយ ភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះ កាលមុន ភិក្ខុនោះ ជាអ្នកស្វាធ្យាយច្រើនហួសពេលវេលា ។ ដល់សម័យក្រោយមក ភិក្ខុនោះ ក៏មានសេចក្តីខ្វល់ខ្វាយតិច ជាអ្នកនៅស្ងៀម ញុំាងកាលឲ្យប្រព្រឹត្តកន្លងទៅ (ដោយផលសមាបត្តិសុខ) ។

[២៦៦] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តស្ស ភិក្ខុនោ ធម្មំ អសុណន្តី យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ គាថាយ អជ្ឈភាសិ

កស្មា តុវំ ធម្មបទានិ ភិក្ខុ
នាធីយសិ ភិក្ខុហិ សំវសន្តោ
សុត្វាន ធម្មំ លភតិប្បសាទំ
ទិដ្ឋេវ ធម្មេ លភតិប្បសំសន្តិ ។

[២៦៧] អហុ បុរេ ធម្មបទេសុ ឆន្ទោ
យាវ វិរាគេន សមាគមិម្ហ
យតោ វិរាគេន សមាគមិម្ហ
យំ កិញ្ចិ ទិដ្ឋំ វ[១] សុតំ មុតំ វា
អញ្ញាយ និក្ខេបនមាហុ សន្តោតិ ។

---

១ ឱ. ទិដ្ឋំ វ សុតំ វ មុតំ ។ ម. ទិដ្ឋំ វា សុតំ វា មុតំ ។

[២៦៦] គ្រានោះឯង ទេវតាដែលអាស្រ័យនៅ នាដងព្រៃនោះ មិនបានស្តាប់ធម៌របស់ភិក្ខុនោះ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទើបពោលគាថានឹងភិក្ខុនោះ ថា

បពិត្រភិក្ខុ ព្រោះហេតុអ្វី បានជាលោកនៅរួបរួមជាមួយនឹងពួកភិក្ខុ ហើយលែងស្វាធ្យាយនូវធម្មបទ បុគ្គលអ្នកស្តាប់ធម៌ រមែងបាននូវសេចក្តីជ្រះថ្លា ឯអ្នកដែលសំដែងធម៌ រមែងបាននូវសេចក្តីសរសើរ ក្នុងបច្ចុប្បន្ន ។

[២៦៧] (ភិក្ខុនោះតបថា) ពីមុនមានសេចក្តីពេញចិត្តក្នុងធម្មបទពិតមែន តែឥឡូវនេះ យើងបានដល់វិរាគធម៌ហើយ កាលណាបើយើងបានដល់វិរាគធម៌ហើយ សប្បុរសទាំងឡាយ បានដឹងហើយ ក៏សរសើរនូវការលះបង់អារម្មណ៍ណាមួយ គឺរូបដែលឃើញហើយ ឬសំឡេងដែលឮហើយ ក្លិន រស ផោដ្ឋព្វៈ ដែលពាល់ត្រូវហើយ ។

# ឯកាទសមំ អយោនិសោមនសិការសុត្តំ

[២៦៨] ឯកំ សមយំ អញ្ញតរោ ភិក្ខុ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន សោ ភិក្ខុ ទិវាវិហារគតោ បាបកេ អកុសលេ វិតក្កេ វិតក្កេតិ សេយ្យថីទំ កាមវិតក្កំ ព្យាបាទវិតក្កំ វិហឹសាវិតក្កំ ។

[២៦៩] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តស្ស ភិក្ខុនោ អនុកម្បិកា អត្ថកាមា តំ ភិក្ខុំ សំវេជេតុកាមា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ គាថាហិ អជ្ឈភាសិ

អយោនិសោ មនសិការា
សោ វិតក្កេហិ ខជ្ជសិ[១]
អយោនិសោ[២] បដិនិស្សជ្ជ
យោនិសោ អនុវិចិន្តយ

---

១ ឱ. ភោ វិតក្កេហិ មជ្ជសិ ។ ម. ភជ្ជសិ ។ ២ ឱ. ម. អយោនឹ បដិនិស្សជ្ជ ។

# អយោនិសោមនសិការសូត្រ ទី ១១

[២៦៨] សម័យមួយ ភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះឯង ភិក្ខុនោះទៅនៅក្នុងទីសម្រាកក្នុងវេលាថ្ងៃ ត្រិះរិះវិតក្កៈទាំងឡាយ ជាអកុសលដ៏លាមក គឺកាមវិតក្កៈ ព្យាបាទវិតក្កៈ វិហឹសាវិតក្កៈ ។

[២៦៩] គ្រានោះឯង ទេវតាដែលអាស្រ័យនៅ ក្នុងដងព្រៃនោះ ជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ដល់ភិក្ខុនោះ ចង់ធ្វើភិក្ខុនោះ ឲ្យសង្វេគ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទើបពោលគាថានឹងភិក្ខុនោះថា

លោកដែលវិតក្កៈទាំងឡាយទំពាស៊ីបាន ព្រោះមិនយកចិត្ត
ទុកដាក់ដោយឧបាយប្រាជ្ញា ចូរលោកលះបង់ឧបាយមិន
មែនជាប្រាជ្ញាចេញ ហើយចូរត្រិះរិះដោយឧបាយប្រាជ្ញាវិញ

សត្ថារំ ធម្មំ អារព្ភ
សង្ឃំ សីលានិ វត្តនោ
អធិគច្ឆសិ បាមោជ្ជំ
បីតិសុខមសំសយំ
តតោ បាមុជ្ជពហុលោ
ទុក្ខស្សន្តំ ករិស្សសីតិ ។

អថខោ សោ ភិក្ខុ តាយ ទេវតាយ សំវេជិតោ សំវេគមាបាទីតិ ។

## ទ្វាទសមំ មជ្ឈន្តិកសុត្តំ

[២៧០] ឯកំ សមយំ អញ្ញតរោ ភិក្ខុ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។

[២៧១] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តស្ស ភិក្ខុនោ សន្តិកេ ឥមំ គាថំ អភាសិ

ប្រារព្ធនូវព្រះសាស្តា ព្រះធម៌ និងព្រះសង្ឃ ជាអ្នកប្រព្រឹត្ត សីល រមែងបាននូវបាមោជ្ជៈ បីតិ សុខៈ ឥតសង្ស័យ បើលោកមានបាមោជ្ជៈច្រើនជាងនេះទៅទៀត នឹងធ្វើនូវទីបំផុតទុក្ខបាន ។

គ្រានោះឯង ភិក្ខុនោះ លុះទេវតានោះ ធ្វើឲ្យសង្វេគហើយ ក៏ដល់នូវសេចក្តីសង្វេគ ។

# មជ្ឈន្តិកសូត្រ ទី ១២

[២៧០] សម័យមួយ ភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។

[២៧១] គ្រានោះឯង ទេវតាដែលនៅអាស្រ័យ ក្នុងដងព្រៃនោះ បានចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទើបពោលគាថានេះ ក្នុងសំណាក់ភិក្ខុនោះថា

ឋិតេ មជ្ឈន្តិកេ កាលេ
សន្និសិន្នេសុ បក្ខិសុ
សណតេ[១] វ ព្រហារញ្ញំ
តំ ភយំ បដិភាតិ មន្តិ ។
ឋិតេ មជ្ឈន្តិកេ កាលេ
សន្និសិន្នេសុ បក្ខិសុ
សណតេ វ ព្រហារញ្ញំ
សា រតិ បដិភាតិ មន្តិ ។

# តេរសមំ បាកតិន្ទ្រិយសុត្តំ

[២៧២] ឯកំ សមយំ សម្ពហុលា ភិក្ខូ កោសលេសុ វិហរន្តិ អញ្ញតរស្មឹ វនសណ្ឌេ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា មុដ្ឋស្សតិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា បាកតិន្ទ្រិយា ។

១ ទេវតាសំយុត្តេ បណតេវាតិ ទិស្សតិ ។ តស្ស អដ្ឋកថាយម្បន បណតេវាតិ ទិស្សតិ ។

កាលវេលាថ្ងៃត្រង់ ពួកបក្សីទំនៅស្ងប់ស្ងៀម ព្រៃធំក៏ហាក់
ដូចជាបញ្ចេញសំឡេងខ្លាំង ភ័យនោះក៏ប្រាកដដល់ខ្ញុំ ។
(ភិក្ខុនោះតបថា) កាលវេលាថ្ងៃត្រង់ ពួកបក្សីទំនៅស្ងប់
ស្ងៀម ព្រៃធំក៏ហាក់ដូចជាបញ្ចេញសំឡេង សេចក្តី
ត្រេកអរនោះ ប្រាកដដល់អាត្មា ។

# បាកតិន្ទ្រិយសូត្រ ទី ១៣

[២៧២] សម័យមួយ ភិក្ខុច្រើនរូបមានចិត្តរវើរវាយ មានមានះ ដូចជាបបុសដុះឡើងហើយ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានវាចាពោយពាយ មានស្មារតីភ្លេចភ្លាំង មិនមានសម្បជញ្ញៈ មានចិត្តតាំងនៅមិននឹង មានចិត្តវិលទៅរកខុស តែមានឥន្ទ្រិយជាប្រក្រតី អាស្រ័យនៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។

[២៧៣] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តេសំ ភិក្ខូនំ អនុកម្បិកា អត្ថកាមា តេ ភិក្ខូ សំវេជេតុកាមា យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ គាថាហិ អជ្ឈភាសិ

សុខជីវិនោ បុរេ អាសុំ
ភិក្ខូ គោតមសាវកា
អនិច្ឆា បិណ្ឌំ ឯសនា
អនិច្ឆា សយនាសនំ
លោកេ អនិច្ចតំ ញត្វា
ទុក្ខស្សន្តំ អកំសុ តេ
ទុប្បោសំ កត្វា អត្តានំ
គាមេ គាមណិកា វិយ
ភុត្វា ភុត្វា និបជ្ជន្តិ
បរាគារេសុ មុច្ឆិតា
សង្ឃស្ស អញ្ជលឹ កត្វា
ឥធេកច្ចេ វទាមហំ[១]
អបវិទ្ធា អនាថា តេ

១ ម. វន្ទាមហំ ។

[២៧៣] គ្រានោះឯង ទេវតាដែលបិតនៅ នាដងព្រៃនោះ ជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុទាំងនោះ ចង់ធ្វើពួកភិក្ខុនោះឲ្យសង្វេគ ទើបចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលគាថាទាំងឡាយ នឹងពួកភិក្ខុនោះថា

ពួកភិក្ខុជាសាវ័ក របស់ព្រះគោតម កាលពីមុន រស់នៅដោយស្រួល មិនប្រាថ្នាក្នុងការស្វែងរក នូវចង្ហាន់បិណ្ឌបាត មិនប្រាថ្នានូវទីដេក ទីអង្គុយឡើយ ភិក្ខុទាំងនោះ លុះដឹងនូវអនិច្ចតាធម៌ ក្នុងលោកហើយ ក៏ធ្វើនូវទីបំផុតទុក្ខបាន ឯពួកភិក្ខុ (ក្នុងឥឡូវនេះ) ធ្វើខ្លួនឲ្យគេចិញ្ចឹមបានដោយលំបាក ជ្រុលជ្រប់ក្នុងផ្ទះនៃបុគ្គលដទៃ ស៊ីដេក ស៊ីដេក ដូចជាមនុស្សអ្នកធំក្នុងស្រុក ខ្ញុំសូមធ្វើអញ្ជលី ចំពោះសង្ឃ ខ្ញុំនិយាយចំពោះតែភិក្ខុមួយពួក ក្នុងទីនេះ ពួកភិក្ខុណា ជាអ្នកប្រមាទ ពួកភិក្ខុនោះ គេបោះបង់ចោល ឥតមានទីពឹង

យថា បេតា តថេវ តេ
យេ ខោ មមត្តា វិហរន្តិ
តេ មេ សទ្ធាយ ភាសិតំ
យេ អប្បមត្តា វិហរន្តិ
នមោ តេសំ ករោមហន្តិ ។

អថខោ តេ ភិក្ខូ តាយ ទេវតាយ សំវេជិតា សំវេគមាបាទុន្តិ ។

# ចុទ្ទសមំ បទុមបុប្ផសុត្តំ

[២៧៤] ឯកំ សមយំ អញ្ញតរោ ភិក្ខុ កោសលេសុ វិហរតិ អញ្ញតរស្មឹ វនសណ្ឌេ ។ តេន ខោ បន សមយេន សោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ បោក្ខរណឹ ឱគាហិត្វា បទុមំ ឧបសិង្ឃតិ ។

[២៧៥] អថខោ យា តស្មឹ វនសណ្ឌេ អធិវត្ថា ទេវតា តស្ស ភិក្ខុនោ អនុកម្បិកា អត្ថកាមា តំ ភិក្ខុំ សំវេជេតុកាមា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ គាថាយ អជ្ឈភាសិ

ដូចជាពួកប្រេត ខ្ញុំពោលសំដៅតែពួកភិក្ខុនោះ ពួកភិក្ខុណាជាអ្នកមិនប្រមាទ ខ្ញុំសូមនមស្ការ ចំពោះពួកភិក្ខុនោះ ។ គ្រានោះឯង ពួកភិក្ខុនោះ លុះទេវតានោះ ធ្វើឲ្យសង្វេគហើយ ក៏ដល់នូវសេចក្តីសង្វេគ ។

# បទុមបុប្ផសូត្រ ទី ១៤

[២៧៨] សម័យមួយ ភិក្ខុមួយរូប នៅក្នុងដងព្រៃមួយ ក្នុងដែនកោសល ។ ក៏សម័យនោះឯង ភិក្ខុនោះត្រឡប់មកពីបិណ្ឌបាត (ធ្វើភត្តកិច្ចស្រេច) ក្នុងវេលាក្រោយភត្ត ក៏ចុះកាន់ស្រះបោក្ខរណី ហើយហិតផ្កាឈូក ។

[២៧៩] គ្រានោះឯង ទេវតាដែលនៅអាស្រ័យ ក្នុងដងព្រៃនោះ ជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ដល់ភិក្ខុនោះ ចង់ធ្វើភិក្ខុនោះឲ្យសង្វេគ ទើបចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ក៏ពោលគាថានឹងភិក្ខុនោះថា

យមេតំ ភារិជំ បុប្ផំ
អទិន្នំ ឧបសិង្ឃសិ
ឯកង្គមេតំ ថេយ្យានំ
គន្ធត្ថេនោសិ មារិសាតិ ។

[២៧៦] ន ហរាមិ ន ភញ្ជាមិ
អារា សិង្ឃាមិ វារិជំ
អថ កេន នុ វណ្ណេន
គន្ធត្ថេនោតិ វុច្ចតិ
យ្វាយំ ភិសានិ ខនតិ
បុណ្ឌរីកានិ ភញ្ជតិ
ឯវំ អាកិណ្ណកម្មន្តោ
កស្មា ឯសោ ន វុច្ចតីតិ ។

[២៧៧] អាកិណ្ណលុទ្ទោ បុរិសោ
អតិវេលំវ[១] មក្ខិតោ
តស្មឹ មេ វចនំ នត្ថិ
តញ្ច អរហាមិ វត្តវេ
អនង្គណស្ស ចោសស្ស

១ ឱ. ម. ធាតិចេលំវ មក្ខិតោ ។

លោកហិតផ្កា ដែលកើតក្នុងទឹកនុ៎ះ ដែលគេមិនបានឲ្យ បពិត្រលោកអ្នកនិរទុក្ខ ការហិតនុ៎ះ ជាអង្គមួយនៃការលួច លោកឈ្មោះថាជាអ្នកលួចក្លិន ។

[២៧៦] ភិក្ខុនោះ តបថា អាត្មាមិនបាននាំទៅ មិនបាន កាច់ទេ គ្រាន់តែហិតផ្កាដែលកើតក្នុងទឹក អំពីចម្ងាយទេតើ ចុះហេតុដូចម្តេច បានជាអ្នកនិយាយថា អាត្មាលួចក្លិន ចុះ បុរសដែលមានអំពើផ្តេសផ្តាស ជីកគាស់ក្រអៅឈូក កាច់ ផ្កាឈូកយ៉ាងនេះ ហេតុអ្វី ក៏អ្នកមិនថាឲ្យបុរសនុ៎ះផង[១] ។

[២៧៧] ទេវតា តបថា បុរសដែលល្មោភផ្តេសផ្តាស ជាអ្នកប្រឡាក់ (ដោយរាគាទិក្កិលេស) ហួសកំណាត់ពាក្យ របស់ខ្ញុំមិនមាន ក្នុងបុរសនោះទេ ខ្ញុំគួរនិយាយតែនឹងលោក ម្នាក់ហ្នឹង (ព្រោះ) សត្វដែលឥតមានទីទួលពោលគឺកិលេស

១ ក្នុងអដ្ឋកថាថា កាលដែលទេវតាកំពុងស្តីឲ្យភិក្ខុនោះ មានតាបសម្នាក់ចុះជីកគាស់ក្រអៅ ឈូក កាច់ផ្កាឈូក ។

និច្ចំ សុចិគវេសិនោ
វាលគ្គមត្តំ បាបស្ស
អព្ភាមតំវ ខាយតីតិ ។
[២៧៨] អទ្ធា មំ យក្ខ ជានាសិ
អថោ មំ អនុកម្បសិ
បុនបិ យក្ខ វជ្ជាសិ
យទា បស្សសិ ឯទិសន្តិ ។
[២៧៩] នេវ តំ ឧបជីវាមិ
នបិ តេ ភទ្ធកាម្ហសេ
ត្វមេវ ភិក្ខុ ជានេយ្យ
យេន គច្ឆេយ្យ សុគតិន្តិ ។

អថខោ សោ ភិក្ខុ តាយ ទេវតាយ សំវេជិតោ សំវេគមាបាទីតិ ។

វនសំយុត្តំ សមត្តំ ។

ជាអ្នកស្វែងរកសេចក្តីស្អាត អស់កាលជានិច្ច សូម្បីមានបាប ប៉ុនចុងសក់ ក៏ប្រាកដដូចជាប៉ុនមេឃ ។

[២៧៨] ភិក្ខុនោះតបថា ម្នាលទេវតា អ្នកស្គាល់អាត្មាមែន អ្នកអនុគ្រោះអាត្មាមែន ម្នាលទេវតា កាលណាបើអ្នកឃើញអាត្មាធ្វើដូច្នេះ អ្នកគប្បីនិយាយឲ្យអាត្មាទៀតចុះ ។

[២៧៩] ទេវតាតបថា ខ្ញុំមិនបានចិញ្ចឹមលោកទេ មិនមែនគ្រាន់បើជាងលោកទេ លោកគប្បីទៅកាន់សុគតិដោយកម្មណា បពិត្រភិក្ខុ លោកត្រូវដឹងកម្មនោះខ្លួនលោកចុះ ។ គ្រានោះឯង ភិក្ខុនោះ លុះទេវតានោះ ធ្វើឲ្យសង្វេគហើយ ក៏ដល់នូវសេចក្តីសង្វេគ ។

ចប់ វនសំយុត្ត ។

## តស្សុទ្ទានំ

វិវេកំ ឧបដ្ឋានញ្ច
កស្សបគោត្តេន សម្ពហុលា
អានន្ទោ អនុរុទ្ធញ្ច
នាគទត្តញ្ច កុលឃរណី
វជ្ជីបុត្តោ ច វេសាលី
សជ្ឈាយេន អយោនិសោ
មជ្ឈន្តិកាលម្ហិ បាកតិន្ទ្រិយា
បទុមបុប្ផេន ចុទ្ទស ភវេតិ ។

---

## ឧទ្ទាននៃសំយុត្តនោះ ដូច្នេះគឺ

*វិវេកសូត្រ ១ ឧបដ្ឋានសូត្រ ១ កស្សបគោត្តសូត្រ ១ សម្ពហុលសូត្រ ១ អានន្ទសូត្រ ១ អនុរុទ្ធសូត្រ ១ នាគទត្តសូត្រ ១ កុលឃរណីសូត្រ ១ វជ្ជីបុត្តសូត្រក្នុងក្រុងវេសាលី ១ សជ្ឈាយសូត្រ ១ អយោនិសោមនសិការសូត្រ ១ មជ្ឈន្តិកកាលសូត្រ ១ បាកតិន្ទ្រិយសូត្រ ១ ជា ១៤ និងបទុមបុប្ផសូត្រ ១ ។*

---

# យក្ខសំយុត្តំ

## បឋមំ ឥន្ទកសុត្តំ

[២៨០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ ឥន្ទកូដេ បព្វតេ ឥន្ទកស្ស យក្ខស្ស ភវនេ ។

[២៨១] អថខោ ឥន្ទកោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈ-ភាសិ

រូបំ ន ជីវន្តិ វទន្តិ ពុទ្ធា
កថំ ន្វយំ វិន្ទតិមំ សរីរំ
កុតស្ស អដ្ឋីយកាបិណ្ឌាមេតិ
កថំ ន្វយំ សជ្ជតិ គព្ភស្មិន្តិ ។

# យក្ខសំយុត្ត

## ឥន្ទកសូត្រ ទី ១

[២៨០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងលំនៅ របស់យក្សឈ្មោះ ឥន្ទកៈ នាភ្នំឥន្ទកូដ ជិតក្រុងរាជគ្រឹះ ។

[២៨១] លំដាប់នោះឯង ឥន្ទកយក្ស បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលគាថា នឹងព្រះមានព្រះភាគថា

ព្រះពុទ្ធទាំងឡាយ មិនពោលនូវរូបថាជីវិតទេ ចុះសត្វនេះ បានសរីរៈនេះ ដោយហេតុដូចម្តេច ឆ្អឹងនិងដុំសាច់ថ្លើម របស់សត្វនោះ បានមកពីណា ចុះសត្វនេះ ឋិតនៅក្នុងគភ៌ដូចម្តេច ។

[២៨២] បឋមំ កលលំ ហោតិ
កលលា ហោតិ អព្វុទំ[១]
អព្វុទា ជាយតេ បេសិ
បេសិយា និព្វត្តតី ឃនោ[២]
ឃនា បសាខា[៣] ជាយន្តិ
កេសា លោមា នខាបិ ច
យញ្ចស្ស ភុញ្ជតី មាតា
អន្នំ បានញ្ច ភោជនំ
តេន សោ តត្ថ យាបេតិ
មាតុកុច្ឆិគតោ នរោ ។

## ទុតិយំ សក្កសុត្តំ

[២៨៣] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។

---

១ អម្ពុទន្តិ ឥទដ្ឋកថាយំ ទិស្សតិ ។ ២ បេសិយា ជាយតេ ឃនោតិ អញ្ញត្ថ ទិស្សតិ ។ ៣ ឃនា ច សាខាតិ ឥទដ្ឋកថា ។

[២៨២] ព្រះអង្គត្រាស់ថា កលលរូបកើតជាដំបូង តពីកលលរូបមក កើតជាអព្វុទរូប តពីអព្វុទរូបមក កើតបេសិរូប តពីបេសិរូបមក កើតជាឃនរូប តពីឃនរូបមក កើតជាសាខារូប តមកទៀត ទើបកើត សក់ រោម ក្រចក ឯមាតារបស់សត្វនោះ បរិភោគភោជនណា ទោះបាយក្តី ទឹកក្តី សត្វនោះដែលឋិតនៅ ក្នុងផ្ទៃនៃមាតានោះ ក៏ញ៉ាំង អត្តភាពឲ្យប្រព្រឹត្តទៅ ដោយភោជននោះ ។

# សក្កសូត្រ ទី ២

[២៨៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។

[២៨៤] អថខោ សក្កនាមកោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

សព្វគន្ថប្បហីនស្ស
វិប្បមុត្តស្ស តេ សតោ
សមណស្ស ន តំ សាធុ
យទញ្ញមនុសាសតីតិ ។

[២៨៥] យេន កេនចិ វណ្ណេន
សំវាសោ សក្ក ជាយតិ
ន តំ អរហតិ សប្បញ្ញោ
មនសា អនុកម្បិតុំ
មនសា ចេ បសន្នេន
យទញ្ញមនុសាសតិ
ន តេន ហោតិ សំយុត្តោ
យានុកម្បា[១] អនុទ្ទយាតិ ។

១ ឱ. សានុកម្បា ។

យក្ខសំយុត្ត សក្កសូត្រ សក្កយក្សចូលទៅរកព្រះមានព្រះភាគ

[២៨២] គ្រានោះឯង យក្សឈ្មោះសក្កៈ បានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបពោលគាថា នឹងព្រះមានព្រះភាគថា

បុគ្គលប្រៀនប្រដៅបុគ្គលដទៃ ដោយពាក្យណា ពាក្យនោះ
មិនប្រពៃដល់លោកជាសមណៈ ដែលជាអ្នកលះបង់នូវគន្ថ-
ធម៌គ្រប់យ៉ាង មានចិត្តផុតស្រឡះហើយ (ចាកអាសវៈ)
ជាអ្នកស្ងប់រម្ងាប់ទេ ។

[២៨៣] ព្រះអង្គត្រាស់ថា ម្នាលសក្កៈ ការនៅជាមួយ
គ្នាកើត ដោយហេតុណាមួយ បុគ្គលអ្នកមានប្រាជ្ញា មិនគួរ
នឹងអនុគ្រោះនូវហេតុនោះ ត្រឹមតែចិត្តទេ បើបុគ្គលមានចិត្ត
ជ្រះថ្លា ប្រៀនប្រដៅបុគ្គលដទៃ ដោយពាក្យណា ទុកជា
បុគ្គលដទៃនោះ មិនប្រកបខ្លួនតាមពាក្យនេះ ការប្រៀន
ប្រដៅនោះ ក៏ឈ្មោះថាការអនុគ្រោះ ឈ្មោះថាការអា-
ណិតដែរ ។

# តតិយំ សូចិលោមសុត្តំ

[២៨៦] ឯកំ សមយំ ភគវា គយាយំ វិហរតិ ដង្កិតមញ្ចេ សូចិលោមស្ស យក្ខស្ស ភវនេ ។ តេន ខោ បន សមយេន ខរោ ច យក្ខោ សូចិលោមោ ច យក្ខោ ភគវតោ អវិទូរេ អតិក្កមន្តិ ។ អថខោ ខរោ យក្ខោ សូចិលោមំ យក្ខំ ឯតទវោច ឯសោ សមណោតិ ។ នេសោ សមណោ សមណកោ ឯសោ យាវ ជានាមិ យទិ វា សោ សមណោ យទិ វា សមណកោតិ ។

[២៨៧] អថខោ សូចិលោមោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ កាយំ ឧបនាមេសិ ។ អថខោ ភគវា កាយំ អបនាមេសិ ។ អថខោ សូចិលោមោ យក្ខោ ភគវន្តំ ឯតទវោច ភាយសិ មំ សមណាតិ ។ ន ខ្វាហន្តំ អាវុសោ ភាយាមិ អបិច តេ សម្ផស្សោ បាបកោតិ ។ បញ្ហំ តំ សមណ បុច្ឆិស្សាមិ

# សូចិលោមសូត្រ ទី ៣

[២៨៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ លើគ្រែឈ្មោះដង្កិត ជាលំនៅនៃយក្សឈ្មោះ សូចិលោមៈ ជិតស្រុកគយា ។ ក៏សម័យនោះឯង យក្សឈ្មោះ ខរៈ និងយក្សឈ្មោះ សូចិលោមៈ ដើរក្នុងទីមិនឆ្ងាយ អំពីព្រះមានព្រះភាគ ។ ទើបខរយក្សនិយាយនឹងសូចិ-លោមយក្សយ៉ាងនេះថា នុ៎ះជាសមណៈធំ ។ សូចិលោមយក្សតបវិញថា នុ៎ះមិនមែនជាសមណៈធំទេ នុ៎ះជាសមណៈតូចទេតើ ខ្ញុំស្គាល់ជាប្រាកដថា នោះជាសមណៈធំ ឬសមណៈតូច ។

[២៨៧] គ្រានោះឯង សូចិលោមយក្ស បានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបបង្អោនកាយទៅរកព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគ ដកព្រះកាយចេញ ។ គ្រានោះឯង សូចិលោមយក្ស បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រសមណៈ លោកខ្លាចខ្ញុំឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ តថាគត មិនខ្លាចអ្នកឯងទេ តែសម្ផស្សរបស់អ្នកឯង អាក្រក់ណាស់ ។ បពិត្រសមណៈ ខ្ញុំនឹងសួរប្រស្នាចំពោះលោក

២១១



សចេ មេ សមណ ន ព្យាករិស្សសិ ចិត្តំ វា តេ ខិបិស្សាមិ ហទយំ វា តេ ផាលេស្សាមិ បាទេសុ វា គហេត្វា បារគង្គាយ ខិបិស្សាមីតិ ។ ន ខ្វាហន្តំ អាវុសោ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ មេ ចិត្តំ វា ខិបេយ្យ ហទយំ វា ផាលេយ្យ បាទេសុ វា គហេត្វា បារគង្គាយ តីរេ ខិបេយ្យ អបិច ត្វំ អាវុសោ បុច្ឆ យទាកង្ខសីតិ ។

[២៨៨] រាគោ ច ទោសោ ច កុតោនិទានា
អរតី រតិ លោមហំសោ កុតោជា
កុតោ សមុដ្ឋាយ មនោវិតក្កា
កុមារកា ធង្កមិវោស្សជន្តីតិ ។

បពិត្រសមណៈ បើលោកមិនដោះស្រាយប្រាប់ខ្ញុំទេ ខ្ញុំនឹងបន្សាត់ចិត្តលោក គឺធ្វើចិត្តឲ្យខូច ឬវះហឫទ័យរបស់លោក ពុំនោះសោតទេ ខ្ញុំនឹងចាប់ជើងលោក បោះទៅត្រើយម្ខាងទន្លេគង្គា ។ ព្រះអង្គត្រាស់ថា ម្នាលអាវុសោ បុគ្គលណា បន្សាត់បង់នូវចិត្តរបស់តថាគតបាន ឬវះហឫទ័យរបស់តថាគត ពុំនោះសោត ចាប់ជើងតថាគតគ្រវែងទៅត្រើយទន្លេគង្គាខាងនាយបាន បុគ្គលនោះ តថាគត មិនដែលឃើញមានទេក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ម្នាលអាវុសោ មួយទៀត បើអ្នកឯងចង់សួរ ក៏សួរចុះ ។

[២៨៨] សូចិលោមយក្ស ទូលសួរថា រាគៈនិងទោសៈ
មានអ្វីជាហេតុ សេចក្តីអផ្សុក សេចក្តីត្រេកអរ និងសេចក្តី
ព្រឺព្រួចរោម កើតអំពីទីណា មនោវិតក្កៈ តាំងឡើងអំពី
ទីណា ហើយលែងចោលនូវចិត្តទៅវិញ ដូចកូនក្មេងចាប់
ក្អែកបោះចោល ។

[២៨៩] រាគោ ច ទោសោ ច ឥតោនិទានា
អរតី រតិ លោមហំសោ ឥតោជា
ឥតោ សមុដ្ឋាយ មនោវិតក្កា
កុមារកា ធង្កមិវោស្សជន្តិ
ស្នេហជា អត្តសម្ភូតា
និគ្រោធស្សេវ ខន្ធជា
បុថូ វិសត្តា កាមេសុ
មាលុវា(១) វិត្តតា វនេ
យេ នំ បជានន្តិ យតោនិទានំ
តេ នំ វិនោទេន្តិ សុណោហិ យក្ខ
តេ ទុត្តរំ ឱឃមិមំ តរន្តិ
អតិណ្ណបុព្វំ អបុនព្ភវាយាតិ ។

១ ឱ. ម. មាលុវាវ ។

[២៨៩] ព្រះអង្គត្រាស់ថា រាគៈនិងទោសៈ មានអត្តភាពនេះជាហេតុ សេចក្តីអផ្សុក សេចក្តីត្រេកអរ និងសេចក្តីព្រឺព្រួចពោម ក៏កើតអំពីអត្តភាពនេះ មនោវិតក្កៈ ក៏តាំងឡើងអំពីអត្តភាពនេះដែរ ហើយលែងចោលនូវចិត្តទៅវិញ ដូចកូនក្មេងចាប់ក្អែកបោះចោល វិតក្កៈដ៏លាមក កើតអំពីសេចក្តីស្រឡាញ់ កើតព្រមក្នុងខ្លួន ដូចជាពួរជ្រៃ កើតអំពីដើមជ្រៃ បាបវិតក្កៈដ៏ច្រើន រមែងធ្វើពួកសត្វឲ្យជាប់នៅក្នុងកាមទាំងឡាយ ដូចវល្លិដែលរួបរិតដើមឈើក្នុងព្រៃ ពួកបុគ្គលណា ដឹងច្បាស់នូវអត្តភាពនោះថា មានរបស់ណាជាហេតុ ពួកបុគ្គលនោះ ក៏បន្ទោបង់នូវអត្តភាពនោះបាន ម្នាលយក្ស អ្នកចូរស្តាប់ចុះ ពួកបុគ្គលនោះ រមែងឆ្លងនូវអន្លង់នេះ ដែលឆ្លងបានដោយកម្រ ដែលគេមិនដែលឆ្លង ដើម្បីមិនកើតក្នុងភពថ្មីតទៅទៀត ។

# ចតុត្ថំ មណិភទ្ទសុត្តំ

[២៩០] ឯកំ សមយំ ភគវា មគធេសុ វិហរតិ មណិមាឡកេ ចេតិយេ មណិភទ្ទស្ស យក្ខស្ស ភវនេ ។

[២៩១] អថខោ មណិភទ្ទោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

សតិមតោ សទា ភទ្ទំ
សតិមា សុខមេធតិ
សតិមតោ សុវេ សេយ្យោ
វេរា ច បរិមុច្ចតីតិ ។

# មណិភទ្ទសូត្រ ទី ៤

[២៩០] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងលំនៅរបស់យក្សឈ្មោះ មណិភទ្ទ ទៀបចេតិយឈ្មោះ មណិមាឡកៈ ក្នុងដែនមគធៈ ។*

[២៩១] *គ្រានោះឯង មណិភទ្ទយក្ស បានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា*

*សេចក្តីចម្រើន របស់បុគ្គលអ្នកមានស្មារតី រមែងមានគ្រប់កាល អ្នកមានស្មារតី រមែងដល់នូវសេចក្តីសុខ គុណដ៏ប្រសើរ របស់បុគ្គលអ្នកមានស្មារតី រមែងមានជានិច្ច អ្នកមានស្មារតី រមែងរួចចាកពៀរ ។*

[២៩២] សតិមតោ សទា ភទ្ទំ
សតិមា សុខមេធតិ
សតិមតោ សុវេ សេយ្យោ
វេរា[១] ន បរិមុច្ចតិ[២] ។
យស្ស សព្វមហោរត្តឹ
អហឹសាយ រតោ មនោ
មេត្តំសោ[៣] សព្វភូតេសុ
វេរន្តស្ស ន កេនចីតិ ។

# បញ្ចមំ សានុសុត្តំ

[២៩៣] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរិស្សា ឧបាសិកាយ សានុ នាម បុត្តោ យក្ខេន គហិតោ ហោតិ ។

[២៩៤] អថខោ សា ឧបាសិកា បរិទេវមានា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

១ ម. វេរា ច ។ ២ កត្ថចិ បោត្ថកេ ឥតិសទ្ទោ ទិស្សតិ ។ សោ ន សមេតិ (អម្ហាកំ មតិ) ។ ៣ មេត្តំ សោតិ បាឋោ ។ ឥធដ្ឋកថាយម្បិ ឯវំ ទិស្សតិ ។

[២៩២] ព្រះអង្គត្រាស់ថា សេចក្តីចម្រើន របស់បុគ្គលអ្នកមានស្មារតី រមែងមានសព្វកាល អ្នកមានស្មារតី តែងដល់នូវសេចក្តីសុខ គុណដ៏ប្រសើរ របស់បុគ្គលអ្នកមានស្មារតី រមែងមានជានិច្ច តែអ្នកមានស្មារតី មិនរួចចាកពៀរទេ ។ លុះតែបុគ្គលណា មានចិត្តត្រេកអរ ក្នុងការមិនបៀតបៀនអស់ថ្ងៃនិងយប់ទាំងអស់ មានចំណែកមេត្តាចិត្ត ចំពោះពួកសត្វទាំងពួង បុគ្គលនោះ ទើបមិនមានពៀរ ដោយហេតុនីមួយឡើយ ។

# សានុសូត្រ ទី ៥

[២៩៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង យក្សបានចាប់សានុសាមណេរ ជាបុត្តរបស់ឧបាសិកាម្នាក់ ។

[២៩៤] គ្រានោះឯង ឧបាសិកានោះ ខ្សឹកខ្សួល បានពោលគាថាទាំងនេះ ក្នុងវេលានោះថា

យក្ខសំយុត្តស្ស សានុសុត្តេ សានុវចនំ

ចាតុទ្ទសឹ បញ្ចទសឹ
យា ច បក្ខស្ស អដ្ឋមី
ចាដិហារិកបក្ខញ្ច
អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសន្តិ
ព្រហ្មចរិយំ ចរន្តិ យេ
ន តេហិ យក្ខា កីឡន្តិ
ឥតិ មេ អរហតំ សុតំ
សាទានិ អជ្ជ បស្សាមិ
យក្ខា កីឡន្តិ សានុនាតិ ។

[២៩៨] ចាតុទ្ទសឹ បញ្ចទសឹ
យា ច បក្ខស្ស អដ្ឋមី
ចាដិហារិកបក្ខញ្ច
អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសន្តិ
ព្រហ្មចរិយំ ចរន្តិ យេ
ន តេហិ យក្ខា កីឡន្តិ

ខ្ញុំបានឮព្រះអរហន្តទាំងឡាយថា បុគ្គលទាំងឡាយណា រក្សាឧបោសថប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី ១៤ ថ្ងៃទី ១៥ និង ថ្ងៃទី ៨ នៃបក្ស ទាំងបារិហារិកបក្ខផង[១] ឈ្មោះថាប្រព្រឹត្ត ព្រហ្មចរិយៈ ពួកយក្ស មិនយាយីបុគ្គលនោះឡើយ ឥឡូវ ថ្ងៃនេះ ខ្ញុំឯងឃើញពួកយក្ស យាយីសានុសាមណេរ ។

[២៩៥] យក្ស តបថា នាងបានឮពាក្យព្រះអរហន្តទាំង-ឡាយ ដោយប្រពៃថា បុគ្គលទាំងឡាយណា រក្សា ឧបោសថ ប្រកបដោយអង្គ ៨ ក្នុងថ្ងៃទី ១៤ ថ្ងៃទី ១៥ និងថ្ងៃទី ៨ នៃបក្ស ទាំងបារិហារិកបក្ខផង ឈ្មោះថា ប្រព្រឹត្តព្រហ្មចរិយៈ ពួកយក្ស មិនយាយីបុគ្គលទាំងនោះទេ

---

១ បារិហារិកបក្ខនេះ សំដៅយកថ្ងៃបដិជាគរឧបោសថ គឺថ្ងៃខាងដើមនិងថ្ងៃខាងចុងនៃបកតិ-ឧបោសថ (ថ្ងៃអមបកតិឧបោសថ) ។

សាហុ តេ អរហតំ សុតំ
សានុំ បពុទ្ធំ វជ្ជាសិ
យក្ខានំ វចនំ ឥទំ
មាកាសិ បាបកំ កម្មំ
អាវិ វា យទិ វា រហោ
សចេវ បាបកំ កម្មំ
ករិស្សសិ ករោសិ វា
ន តេ ទុក្ខា បមុត្យត្ថិ
ឧប្បច្ចាបិ បលាយតោតិ[១] ។

[២៩៦] មតំ វា អម្ម រោទន្តិ
យោ វា ជីវំ ន ទិស្សតិ
ជីវន្តំ អម្ម បស្សន្តី
កស្មា មំ អម្ម រោទសីតិ ។

[២៩៧] មតំ វា បុត្ត រោទន្តិ
យោ វា ជីវំ ន ទិស្សតិ
យោ ច កាមេ ចជិត្វាន
បុនរាគច្ឆតេ ឥធ

១ ឥមា គាថាយោ អម្ហាកំ បោត្ថកេ ច ឱ. ម. បោត្ថកេ ច អញ្ញមញ្ញំ វិរុទ្ធា យេវ ។

នាងគប្បីនិយាយប្រាប់សានុសាមណេរ ដែលភ្ញាក់ឡើងថា នេះជាពាក្យរបស់ពួកយក្ស (ប្រាប់) ថា លោកកុំធ្វើអំពើអាក្រក់ក្នុងទីចំពោះមុខ ឬទីកំបាំងមុខឡើយ បើលោកនឹងធ្វើ ឬកំពុងធ្វើ នូវអំពើលាមក លោកទុកជាហោះរត់ទៅ ក៏មិនរួចអំពីសេចក្តីទុក្ខដែរ ។

[២៩៦] សានុសាមណេរភ្ញាក់ឡើង និយាយថា ញោម ពួកជនតែងយំរកបុគ្គល ដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញ ញោម ញោមឃើញអាត្មានៅរស់នៅឡើយ ញោម ហេតុអ្វីក៏ញោមយំរកអាត្មា ។

[២៩៧] ឧបាសិកាតបថា លោកកូន ជនទាំងឡាយតែងយំរកបុគ្គល ដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញ ម្យ៉ាងទៀត បុគ្គលណា លះបង់កាមទាំង-ឡាយហើយ បែរជាត្រឡប់មករកកាម ក្នុងលោកនេះវិញ

តំ ភាបិ បុត្ត ពេធន្តិ
បុន ជីវំ មតោ ហិ សោ
កុក្កុឡា ឧព្ភតោ តាត
កុក្កុឡំ បតិតុមិច្ឆសិ
នរកា ឧព្ភតោ តាត
នរកំ បតិតុមិច្ឆសិ
អភិធាវថ ភទ្ទន្តេ
កស្ស ឧជ្ឈាបយាមសេ
អាទិត្តា និព្ភតំ ភណ្ឌំ
បុន ឌយ្ហិតុមិច្ឆសីតិ ។

# ឆដ្ឋំ បិយង្ករសុត្តំ

[២៩៨] ឯកំ សមយំ អាយស្មា អនុរុទ្ធោ សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តេន ខោ បន សមយេន អាយស្មា អនុរុទ្ធោ រត្តិយា
បច្ចូសសមយំ បច្ចុដ្ឋាយ ធម្មបទានិ ភាសតិ ។

លោកកូន សូម្បីតែបុគ្គលនោះ ក៏ពួកជនយំរកដែរ ព្រោះថា បុគ្គលនោះរស់នៅមែន តែទុកដូចជាមនុស្សស្លាប់ហើយ លោកកូន ខ្ញុំបានស្រង់លោក អំពីផេះក្តៅគឺយាវាស ហើយ លោកចង់ធ្លាក់ទៅ ក្នុងផេះក្តៅវិញ លោកកូន ខ្ញុំបានស្រង់លោកអំពីរណ្តៅហើយ លោកចង់ធ្លាក់ទៅ ក្នុងរណ្តៅវិញ លោកចូរស្ទុះចេញទៅ សេចក្តីចម្រើន ចូរមានដល់លោក ខ្ញុំនឹងប្រាប់ដល់អ្នកណាកើត លោក (ចេញអំពីឃរាវាសទៅបួសហើយ) ដូចជាគ្រឿងភណ្ឌៈ ដែលគេនាំចេញអំពីផ្ទះភ្លើងឆេះ ហើយចង់ឆេះ (ក្នុងឃរាវាស) វិញ ។

# បិយង្ករសូត្រ ទី ៦

[២៩៨] សម័យមួយ ព្រះអនុរុទ្ធមានអាយុ នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះអនុរុទ្ធមានអាយុ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយសំដែងធម្មបទ ។

[២៩៩] អថខោ បិយង្ករមាតា យក្ខិនី បុត្តកំ ឯវំ តោសេសិ

មា សទ្ទមការី បិយង្ករ
ភិក្ខុ ធម្មបទានិ ភាសតិ
អបិច ធម្មបទំ វិជានិយ
បដិបជ្ជេម ហិតាយ នោ សិយាតិ ។

[៣០០] បាណេសុ ច សញ្ញមាមសេ
សម្បជានមុសា ន ភណាមសេ
សិក្ខេម សុសីល្យមត្តនោ
អបិ មុច្ចេម បិសាចយោនិយាតិ ។

# សត្តមំ បុនព្វសុសុត្តំ

[៣០១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា ភិក្ខូ និព្វានប្បដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្ប-ហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វ-ចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។

[២៩៩] គ្រានោះឯង យក្ខិនីឈ្មោះ បិយង្ករមាតា លួងកូនតូច យ៉ាងនេះថា

ម្នាលបិយង្ករៈ ឯងកុំមាត់-កឡើយ ដ្បិតភិក្ខុកំពុងសំដែង ធម្មបទ ប្រសិនបើយើងដឹងច្បាស់នូវធម្មបទហើយ ប្រតិបត្តិ តាម ដើម្បីជាប្រយោជន៍ ប្រយោជន៍នឹងមានដល់យើង ។

[៣០០] កូនតបថា យើងនឹងសង្រួម ក្នុងសត្វទាំងឡាយ យើងកុំពោល នូវពាក្យសម្បជានមុសាវាទ យើងគួរសិក្សា នូវមារយាទ របស់ខ្លួនឲ្យល្អ ទើបយើងរួចអំពីកំណើត បិសាចបាន ។

# បុនព្វសុសូត្រ ទី ៧

[៣០១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ណែនាំពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់ យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះ និព្វាន ។ ពួកភិក្ខុនោះ ក៏ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូល មកនូវចិត្តទាំងពួង ផ្ទៀងសោតប្រសាទប្រុងស្តាប់ធម៌ ។

យក្ខសំយុត្តស្ស បុនព្វសុសុត្តេ យក្ខិនីវចនំ

[៣០២] អថខោ បុនព្វសុមាតា យក្ខិនី បុត្ត-
កំ ឯវំ តោសេសិ

តុណ្ហី ឧត្តរិកេ ហោហិ
តុណ្ហី ហោហិ បុនព្វសុ
យាវាហំ ពុទ្ធសេដ្ឋស្ស
ធម្មំ សោស្សាមិ សត្ថុនោ
និព្វានំ ភគវា អាហ
សព្វគន្ថប្បមោចនំ
អតិវេលា ច មេ ហោតិ
អស្មឹ ធម្មេ បិយាយនា
បិយោ លោកេ សកោ បុត្តោ
បិយោ លោកេ សកោ បតិ
តតោ បិយតរំ មយ្ហំ
អស្ស ធម្មស្ស មគ្គនា
ន ហិ បុត្តោ បតិ វាបិ
បិយោ ទុក្ខា បមោចយេ
យថា សទ្ធម្មស្សវនំ

យក្ខសំយុត្ត បុនព្វសុសូត្រ ពាក្យយក្ខិនី

[៣០២] គ្រានោះឯង យក្ខិនីឈ្មោះ បុនព្វសុមាតា លួងកូនតូច យ៉ាងនេះថា

ម្នាលនាងឧត្តរា ចូរឯងស្ងៀមទៅ ម្នាលបុនព្វសុ ចូរឯងស្ងៀមទៅ អញនឹងស្តាប់ធម៌ របស់ព្រះសាស្តាជាព្រះពុទ្ធដ៏ប្រសើរសិន ព្រះមានព្រះភាគ បានសំដែងនូវព្រះនិព្វានថាជាគ្រឿងរួចចាកគន្ថធម៌ទាំងពួង ម្យ៉ាងទៀត សេចក្តីប្រាថ្នាក្នុងធម៌នោះ របស់អញខ្លាំងហួសប្រមាណ កូនរបស់ខ្លួនក៏ជាទីស្រឡាញ់ក្នុងលោក ប្តីរបស់ខ្លួន ក៏ជាទីស្រឡាញ់ក្នុងលោក តែសេចក្តីប្រាថ្នាធម៌នោះ របស់អញជាទីស្រឡាញ់ក្រៃលែងជាងនោះទៅទៀត កូនក្តី ប្តីក្តី ដែលជាទីស្រឡាញ់មិនមែនដោះអញឲ្យរួចចាកទុក្ខបានទេ មានតែការស្តាប់ធម៌

ទុក្ខា មោចេតិ ចាណិនំ
លោកេ ទុក្ខបវេតស្មឹ
ជរាមរណសំយុត្តេ
ជរាមរណមោក្ខាយ
យំ ធម្មំ អភិសម្ពុធំ
តំ ធម្មំ សោតុមិច្ឆាមិ
តុណ្ហី ហោហិ បុនព្វសូតិ ។
[៣០៣] អម្ម ន ព្យាហរិស្សាមិ
តុណ្ហីភូតាយមុត្តរា
ធម្មមេវ និសាមេហិ
សទ្ធម្មស្សវនំ សុខំ
សទ្ធម្មស្ស អនញ្ញាយ
អម្ម ទុក្ខំ ចរាមសេ
ឯស ទេវមនុស្សានំ
សម្មូឡ្ហានំ បភង្ករោ
ពុទ្ធោ អន្តិមសារីរោ
ធម្មំ ទេសេតិ ចក្ខុមាតិ ។

ទើបដោះសត្វទាំងឡាយ ឲ្យរួចចាកទុក្ខបាន កាលបើសត្វ-លោក ត្រូវសេចក្ដីទុក្ខគ្របសង្កត់ ប្រកបដោយជរានិងមរណៈហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងហើយនូវធម៌ណា អញចង់ស្ដាប់ធម៌នោះ ដើម្បីរួចចាកជរានិងមរណៈ ម្នាលបុនព្វសុ ចូរឯងស្ងៀមទៅ ។

[៣០៣] បុនព្វសុកុមារ តបថា បពិត្រអ្នកម្ដាយ ខ្ញុំមិននិយាយទេ ទាំងនាងឧត្តរានេះក៏ស្ងៀមដែរ សូមអ្នកម្ដាយស្ដាប់ធម៌ចុះ ការស្ដាប់ព្រះសទ្ធម្ម នាំមកនូវសេចក្ដីសុខ បពិត្រអ្នកម្ដាយ យើងដើរទាំងទុក្ខ ព្រោះមិនបានដឹងព្រះសទ្ធម្ម ព្រះពុទ្ធនុ៎ះ ជាអ្នកធ្វើនូវពន្លឺដល់ទេវតានិងមនុស្សទាំងឡាយ ដែលវង្វេង មានព្រះសរីរៈជាទីបំផុត ព្រះអង្គមានបញ្ញាចក្ខុ ទ្រង់កំពុងសំដែងធម៌ ។

[៣០៤] សាធុ ខោ បណ្ឌិតោ នាម
បុត្តោ ជាតោ ឧរេ សយោ
បុត្តោ មេ ពុទ្ធសេដ្ឋស្ស
ធម្មសុទ្ធំ បិយាយតិ
បុនព្វសុ សុខី ហោហិ
អជ្ជាហម្ហិ សមុគ្គតា
ទិដ្ឋានិ អរិយសច្ចានិ
ឧត្តរាបិ សុណាតុ មេតិ ។

# អដ្ឋមំ សុទត្តសុត្តំ

[៣០៥] ឯកំ សមយំ ភគវា រាជគហេ វិហរតិ សីតវនេ ។ តេន ខោ បន សមយេន អនាថបិណ្ឌិកោ គហបតិ រាជគហំ អនុប្បត្តោ ហោតិ កេនចិទេវ ករ-ណីយេន ។ អស្សោសិ ខោ អនាថបិណ្ឌិកោ គហបតិ ពុទ្ធោ កិរ លោកេ ឧប្បន្នោតិ តាវទេវ ច បន ភគវន្តំ ទស្សនាយ ឧបសង្កមិតុកាមោ ហោតិ ។ អថខោ អនាថបិណ្ឌិកស្ស គហបតិស្ស ឯតទហោសិ

[៣០៤] (បុនព្វសុមាតាពោលថា) ប្រពៃណាស់ហ្ន៎ កូនកើតហើយ ដេកនៅនាទ្រូង ដែលជាបណ្ឌិត កូនរបស់អញ ស្រឡាញ់ធម៌ដ៏បរិសុទ្ធ របស់ព្រះពុទ្ធដ៏ប្រសើរ ម្នាលបុនព្វសុ ចូរឯងបានសុខស្រួល អញបានខ្ពង់ខ្ពស់ (ក្នុងសាសនា) តាំងពីថ្ងៃនេះហើយ ទាំងនាងឧត្តរា ក៏ចូរស្តាប់អរិយសច្ចទាំងឡាយ ដែលអញនិងឯងឃើញហើយចុះ ។

# សុទត្តសូត្រ ទី ៨

[៣០៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងសីតវ័ន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង អនាថបិណ្ឌិកគហបតី បានទៅដល់ក្រុងរាជគ្រឹះ ដោយកិច្ចការនីមួយ[១] ។ អនាថបិណ្ឌិកគហបតី បានឮដំណឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ក៏មានប្រាថ្នាដើម្បីចូលទៅជួប នឹងព្រះមានព្រះភាគ ក្នុងខណៈនោះឯង ។ គ្រានោះឯង អនាថបិណ្ឌិកគហបតី មានសេចក្តីត្រិះរិះ យ៉ាងនេះថា

១ កិច្ចការនីមួយក្នុងទីនេះ សំដៅយកការជួញ ។ អដ្ឋកថា ។

អកាលោ ខោ អជ្ជ ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ បដិសល្លីនោ ភគវា មនោភាវនីយានម្បិ ភិក្ខូនំ ទស្សនាយ ឧបសង្កមិតុំ យន្នូនាហំ កាលេន ភគវន្តំ ទស្សនាយ ឧបសង្កមិស្សាមីតិ ។ ពុទ្ធគតាយ សតិយា និបជ្ជិ រត្តិយា សុទំ តិក្ខត្តុំ វុដ្ឋាសិ បភាតន្តិ មញ្ញមានោ ។ អថខោ អនាថបិណ្ឌិកោ គហបតិ យេន សីវថិកទ្វារំ តេនុប-សង្កមិ ។ អមនុស្សា ទ្វារំ វិវរឹសុ ។

[៣០៦] អថខោ អនាថបិណ្ឌិកស្ស គហបតិស្ស នគរម្ហា និក្ខមន្តស្ស អាលោកោ អន្តរធាយិ អន្ធកា-រោ បាតុរហោសិ ភយំ ឆម្ភិតត្តំ លោមហំសោ ឧ-ទបាទិ ។ តតោ ច បុន និវត្តិតុកាមោ អហោសិ ។ អថខោ សិវកោ យក្ខោ អន្តរហិតោ សទ្ទំ អនុស្សាវេសិ

ថ្ងៃនេះជាកាលមិនគួរ ដើម្បីចូលទៅជួបព្រះមានព្រះភាគទេ ចាំដល់ថ្ងៃស្អែក អាត្មាអញនឹងចូលទៅជួបព្រះមានព្រះភាគ ដោយកាលគួរ ពុំខាន ។ កាលបើសតិតាំងនៅក្នុងពុទ្ធគុណហើយ គាត់ដេកក្នុងមួយរាត្រីក្រោកឡើង ៣ ដង ដោយស្មានថា ភ្លឺហើយ ។ គ្រានោះឯង អនាបិណ្ឌិកគហបតី ក៏ចូលទៅរកសីវថិកទ្វារ (ទ្វារស្មសាន) ។ ពួកអមនុស្ស ក៏បើកទ្វារឲ្យ ។

[៣០៦] គ្រានោះ កាលអនាថបិណ្ឌិកគហបតី កំពុងចេញទៅអំពីនគរ ពន្លឺក៏បាត់ទៅ ងងឹតក៏កើតប្រាកដឡើង សេចក្ដីភ័យ តក់ស្លុត និងការព្រឺរោម ក៏កើតឡើង ។ គាត់ចង់ត្រឡប់មកអំពីទីនោះវិញ ។ គ្រានោះឯង យក្សឈ្មោះសិវកៈ បំបាំងខ្លួនមិនឲ្យឃើញ ធ្វើសំឡេងឲ្យឮឡើងថា

២២៣

យក្ខសំយុត្តស្ស សុទត្តសុត្តេ សិវកយក្ខសទ្ទោ

សតំ ហត្ថី សតំ អស្សា
សតំ អស្សតរី រថា
សតំ កញ្ញាសហស្សានិ[១]
អាមុត្តមណិកុណ្ឌលា
ឯកស្ស បទវីតិហារស្ស
កលំ នាគ្ឃន្តិ សោឡសឹ
អភិក្កម គហបតិ
អភិក្កម គហបតិ
អភិក្កមនន្តេ សេយ្យោ
នោ បដិក្កមនន្តិ ។

អថខោ អនាថបិណ្ឌិកស្ស គហបតិស្ស អន្ធកា-
ពោ អន្តរធាយិ អាលោកោ បាតុរហោសិ យំ អហោ-
សិ ភយំ ឆម្ភិតត្តំ លោមហំសោ សោ បដិប្បស្សម្ភិ ។

១ សតំ កញ្ញាសហស្សានីតិ បុរិមបទានិបិ ឥមិនា វ សហស្សបទេ ន សទ្ធឹ សម្ពន្ធានិ តថេវ ហិ សតំ កញ្ញាសហស្សានិ សតសហស្សានិ ហត្ថិសតសហស្សានិ អស្សសតស-ហស្សានិ រថាតិ អយមេត្ថ អត្ថោ ។ ឥតិ ឯកេកសតសហស្សសោ ទីបិតន្តិ ឥទដ្ឋកថាយំ វុត្តំ ។

យក្ខសំយុត្ត សុទត្តសូត្រ សំឡេងរបស់សិវកយក្ស

ដំរីមួយសែន សេះមួយសែន រថទឹមដោយមេសេះអស្សតរមួយសែន នាងកញ្ញាពាក់កុណ្ឌល ជាវិការៈនៃកែវមណីមួយសែននាក់ ក៏មិនដល់ថ្ងៃមួយចំណិត នៃជំហានមួយដែលគេចែក ឲ្យជាចំណែកដប់ប្រាំមួយ ៗ ដងឡើយ ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ ការឈានទៅមុខ របស់អ្នកប្រសើរជាងឯការត្រឡប់ថយក្រោយវិញ មិនប្រសើរទេ ។

គ្រានោះឯង ងងឹតបាត់ទៅ ពន្លឺក៏កើតប្រាកដឡើង ដល់អនាថបិណ្ឌិកគហបតី ទាំងសេចក្តីភ័យ ការតក់ស្លុត និងការព្រឺរោម ក៏ស្ងប់រម្ងាប់ទៅ ។

[៣០៧] ទុតិយម្បិ ខោ អនាថបិណ្ឌិកស្ស គ-
ហបតិស្ស អាលោកោ អន្តរធាយិ អន្ធការោ បាតុរ-
ហោសិ ភយំ ឆម្ភិតត្តំ លោមហំសោ ឧទបាទិ ។ តតោ
ច បុន និវត្តិតុកាមោ អហោសិ ។ ទុតិយម្បិ ខោ
សិវកោ យក្ខោ អន្តរហិតោ សទ្ទមនុស្សាវេសិ

សតំ ហត្ថី សតំ អស្សា ។ បេ ។
កលំ នាគ្ឃន្តិ សោឡសឹ
អភិក្កម គហបតិ
អភិក្កម គហបតិ
អភិក្កមនន្តេ សេយ្យោ
នោ បដិក្កមនន្តិ ។

អថខោ អនាថបិណ្ឌិកស្ស គហបតិស្ស អន្ធកា-
រោ អន្តរធាយិ អាលោកោ បាតុរហោសិ យំ អហោសិ
ភយំ ឆម្ភិតត្តំ លោមហំសោ សោ បដិប្បស្សម្ភិ ។

[៣០៧] ពន្លឺបាត់ទៅ ងងឹតក៏កើតប្រាកដឡើង ដល់អនាថ-បិណ្ឌិកគហបតី ទាំងសេចក្តីភ័យ ការតក់ស្លុត និងការព្រឺរោម ក៏កើតឡើង អស់វារៈពីរដងទៀត ។ ឯអនាថបិណ្ឌិកគហបតី ក៏ចង់ត្រឡប់ពីទីនោះមកវិញទៀត ។ សីវកយក្ស បំបាំងខ្លួនមិនឲ្យឃើញ ក៏ធ្វើសំឡេងឲ្យឮឡើង អស់វារៈពីរដងទៀតថា

ដំរីមួយសែន សេះមួយសែន ។ បេ ។ ក៏មិនដល់ថ្ងៃមួយ
ចំណិត នៃដំហានមួយ ដែលគេចែកឲ្យជាចំណែកដប់ប្រាំ
មួយ ៗ ដងឡើយ ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ
ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ ការឈានទៅមុខ
របស់អ្នកប្រសើរជាង ឯការត្រឡប់ថយក្រោយវិញ មិន
ប្រសើរទេ ។

គ្រានោះឯង ងងឹតបាត់ទៅ ពន្លឺក៏កើតប្រាកដឡើង ដល់អនា-ថបិណ្ឌិកគហបតី ទាំងសេចក្តីភ័យ ការតក់ស្លុត និងការព្រឺរោម ក៏ស្ងប់រម្ងាប់ទៅ ។

[៣០៨] តតិយម្បិ ខោ អនាថបិណ្ឌិកស្ស គហ-
បតិស្ស អាលោកោ អន្តរធាយិ អន្ធការោ ចាតុរហោ-
សិ ភយំ ឆម្ភិតត្តំ លោមហំសោ ឧទបាទិ ។ តតោ
ច បុន និវត្តិតុកាមោ អហោសិ ។ តតិយម្បិ ខោ
សិវកោ យក្ខោ អន្តរហិតោ សទ្ទមនុស្សាវេសិ

សតំ ហត្ថី សតំ អស្សា ។ បេ ។
កលំ នាគ្ឃន្តិ សោឡសឹ
អភិក្កម គហបតិ
អភិក្កម គហបតិ
អភិក្កមនន្តេ សេយ្យោ
នោ បដិក្កមនន្តិ ។

អថខោ អនាថបិណ្ឌិកស្ស គហបតិស្ស អន្ធកា-
រោ អន្តរធាយិ អាលោកោ ចាតុរហោសិ យំ អហោសិ
ភយំ ឆម្ភិតត្តំ លោមហំសោ សោ បដិប្បស្សម្ភិ ។

យក្ខសំយុត្ត សុទត្តសូត្រ សំឡេងរបស់សិវកយក្ស

[៣០៨] ពន្លឺបាត់ទៅ ងងឹតក៏កើតប្រាកដឡើង ដល់អនាថ-បិណ្ឌិកគហបតី ទាំងសេចក្តីភ័យ ការតក់ស្លុត និងការព្រឺរោម ក៏កើតឡើង អស់វារៈបីដងទៀត ។ ឯអនាថបិណ្ឌិកសេដ្ឋី ក៏ចង់ត្រឡប់អំពីទីនោះមកវិញ ។ សិវកយក្ស បំបាំងខ្លួនមិនឲ្យឃើញ ធ្វើសំឡេងឲ្យឮឡើង អស់វារៈបីដងទៀតថា

ដំរីមួយសែន សេះមួយសែន ។ បេ ។ មិនដល់ចំណិត នៃជំហានមួយ ដែលគេចែកឲ្យជាចំណែកដប់ប្រាំមួយ ៗ ដងឡើយ ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ

ម្នាលគហបតី ចូរអ្នកឈានទៅមុខចុះ ការឈានទៅមុខរបស់អ្នកប្រសើរជាង ឯការត្រឡប់ថយក្រោយវិញ មិនប្រសើរទេ ។

គ្រានោះឯង ងងឹតបាត់ទៅ ពន្លឺក៏កើតប្រាកដឡើង ដល់អនា-ថបិណ្ឌិកគហបតី ទាំងសេចក្តីភ័យ ការតក់ស្លុត និងការព្រឺរោម ក៏ស្ងប់រម្ងាប់ទៅ ។

[៣០៩] អថខោ អនាថបិណ្ឌិកោ គហបតិ យេន សីតវនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ អព្ភោកាសេ ចង្កមតិ ។ អទ្ទសា ខោ ភគវា អនាថបិណ្ឌិកំ គហបតឹ ទូរតោវ អាគច្ឆន្តំ ទិស្វាន ចង្កមា ឱរោហិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អនាថបិណ្ឌិកំ គហបតឹ ឯតទវោច ឯហិ សុទត្តាតិ ។ អថខោ អនាថបិណ្ឌិកោ គហបតិ នាមេន មំ ភគវា អាលបតីតិ តត្ថេវ ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច កច្ចិ ភន្តេ ភគវា សុខំ វសិត្ថាតិ[១] ។

១ ឱ. សុខំ អសយិត្ថាតិ ។

[៣០៩] គ្រានោះឯង អនាថបិណ្ឌិកគហបតី ចូលទៅឯសីតវ័ន ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់តើនឡើង ក្នុងបច្ចូសសម័យ នៃរាត្រី ទៅចង្រ្កមក្នុងទីវាលស្រឡះ ។ ព្រះមានព្រះភាគ បានទតឃើញអនាថបិណ្ឌិកគហបតី កំពុងមកអំពីចម្ងាយ លុះទតឃើញហើយ ទ្រង់ចុះអំពីទីចង្រ្កមមកគង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ក៏ត្រាស់ហៅអនាថបិណ្ឌិកគហបតី យ៉ាងនេះថា ម្នាលសុទត្ត ចូរអ្នកមកអាយ ។ ទើបអនាថបិណ្ឌិកគហបតី ឱនក្បាលទៀបបាទា នៃព្រះមានព្រះភាគ ក្នុងទីនោះ ដោយគិតថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅអញចំឈ្មោះ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ គង់នៅជាសុខទេឬ ។

[៣១០] សព្វទា វេ សុខំ សេតិ
ព្រាហ្មណោ បរិនិព្វុតោ
យោ ន លិម្បតិ កាមេសុ
សីតិភូតោ និរូបធិ
សព្វា អាសត្តិយោ ឆេត្វា
វិនេយ្យ ហទយេ ទរំ
ឧបសន្តោ សុខំ សេតិ
សន្តឹ បប្បុយ្យ ចេតសាតិ ។

## នវមំ បឋមសក្កាសុត្តំ

[៣១១] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន សុក្កា ភិក្ខុនី មហតិយា បរិសាយ បរិវុតា ធម្មំ ទេសេតិ ។

[៣១២] អថខោ សុក្កាយ ភិក្ខុនិយា អភិប្បសន្នោ យក្ខោ រាជគហេ រថិកាយ រថិកំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា តាយំ វេលាយំ ឥមា គាថាយោ អភាសិ

[៣១០] ព្រះអង្គត្រាស់ថា បុគ្គលជាអ្នកបន្សាត់បង់បាប រំលត់កិលេស រមែងដេកជាសុខសព្វកាល បុគ្គលណាមាន សេចក្តីត្រជាក់ត្រជំ ឥតមានឧបធិក្កិលេស កាត់បង់តណ្ហា ទាំងអស់ បន្ទោបង់សេចក្តីក្រវល់ក្រវាយ ក្នុងហឫទ័យ មិន បានប្រឡាក់ ក្នុងកាមទាំងឡាយ បុគ្គលនោះ រមែងដល់ នូវសេចក្តីរម្ងាប់កិលេសដោយចិត្ត មានចិត្តស្ងប់រម្ងាប់ ដេក នៅជាសុខ ។

# បឋមសុក្កាសូត្រ ទី ៩

[៣១១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្ត វេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ភិក្ខុនីឈ្មោះសុក្កា មានបរិស័ទច្រើនចោមរោម កំពុងសំដែងធម៌ ។

[៣១២] គ្រានោះឯង យក្សមានសេចក្តីជ្រះថ្លាក្រៃពេក ចំពោះ សុក្កាភិក្ខុនី ក៏ចេញពីច្រកមួយ ចូលទៅកាន់ច្រកមួយ ចេញពីផ្លូវ ត្រឡែងកែងមួយ ចូលទៅកាន់ផ្លូវត្រឡែងកែងមួយ ក្នុងក្រុងរាជគ្រឹះ ហើយពោលគាថាទាំងនេះ ក្នុងវេលានោះថា

កិម្មេ កតា រាជគហេ មនុស្សា
មធុបីតាវ(១) សេយរេ
យេ សុក្កំ ន បយិរុបាសន្តិ
ទេសេន្តឹ អមតំ បទំ
តញ្ច បន អប្បដិវានីយំ
អសេចនកមោជវំ
បិវន្តិ មញ្ញេ សប្បញ្ញា
វលាហកមិវ បន្ថគូតិ ។

## ទសមំ ទុតិយសុក្កាសុត្តំ

[៣១៣] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ សុក្កាយ ភិក្ខុនិយា ភោជនំ អទាសិ ។

[៣១៤] អថខោ សុក្កាយ ភិក្ខុនិយា អភិប្បសន្នោ យក្ខោ រាជគហេ រថិកាយ រថិកំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា តាយំ វេលាយំ ឥមំ គាថំ អភាសិ

១ ឱ. មធុបីតាវ អជ្ឈរេ យេ ។

ពួកមនុស្សក្នុងក្រុងរាជគ្រឹះ ធ្វើអ្វីដល់អញ ពួកជនណា មិនចូលទៅជិតសុក្កាភិក្ខុនី ដែលកំពុងសំដែងនូវឧបាយជាគ្រឿងដល់ព្រះនិព្វាន ឈ្មោះអមតៈ (ជនទាំងនោះ) ដូចជាបុគ្គលផឹកទឹកឃ្មុំហើយដេក ពួកបុគ្គលមានប្រាជ្ញា ហាក់ដូចជាក្រេបផឹកនូវអមតនិព្វាននោះ ដែលជាធម៌មិនគួរបោះបង់ចោល មានឱជារសបានលាយទុំ ដូចជាអ្នកដំណើរផឹកទឹក ដែលហូរធ្លាក់មកអំពីចន្លោះពពក ។

# ទុតិយសក្កាសូត្រ ទី ១០

[៣១៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង មានឧបាសិកាម្នាក់ ប្រគេនភោជនដល់សុក្កាភិក្ខុនី ។

[៣១៤] គ្រានោះឯង យក្សមានសេចក្ដីជ្រះថ្លាក្រៃពេក ចំពោះសុក្កាភិក្ខុនី ក៏ដើរចេញពីច្រកមួយ ចូលទៅកាន់ច្រកមួយ ចេញពីផ្លូវត្រឡែងកែងមួយ ចូលទៅកាន់ផ្លូវត្រឡែងកែងមួយ ក្នុងក្រុងរាជគ្រឹះ ហើយពោលគាថានេះ ក្នុងវេលានោះថា

បុញ្ញំ វត បសវិ ពហុំ
សប្បញ្ញោ វតាយមុបាសកោ
យោ សុក្កាយ អទាសិ ភោជនំ
សព្វគន្ថេហិ វិប្បមុត្តាយាតិ ។

## ឯកាទសមំ ចីរាសុត្តំ

[៣១៥] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ ចីរាយ ភិក្ខុនិយា ចីវរំ អទាសិ ។

[៣១៦] អថខោ ចីរាយ ភិក្ខុនិយា អភិប្បសន្នោ យក្ខោ រាជគហេ រថិកាយ រថិកំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា តាយំ វេលាយំ ឥមំ គាថំ អភាសិ

បុញ្ញំ វត បសវិ ពហុំ
សប្បញ្ញោ វតាយមុបាសកោ
យោ ចីរាយ អទាសិ ចីវរំ
សព្វយោគេហិ វិប្បមុត្តាយាតិ ។

ឧបាសកណា បានប្រគេនភោជន ដល់សុក្កាភិក្ខុនី ដែល
មានចិត្តផុតស្រឡះ ចាកគន្ថធម៌ទាំងអស់ ឧបាសកនេះ
ឈ្មោះថា អ្នកប្រកបដោយប្រាជ្ញាពិត ហើយបានប្រទះនូវ
បុណ្យច្រើន ។

# ចីរាសូត្រ ទី ១១

[៣១៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង មានឧបាសិកាម្នាក់ បានប្រគេនចីវរ ដល់ភិក្ខុនីឈ្មោះចីរា ។

[៣១៦] គ្រានោះឯង យក្សមានសេចក្ដីជ្រះថ្លាក្រៃពេក ចំពោះចីរាភិក្ខុនី ក៏ដើរចេញពីច្រកមួយ ចូលទៅកាន់ច្រកមួយ ចេញពីផ្លូវត្រឡែងកែងមួយ ចូលទៅកាន់ផ្លូវត្រឡែងកែងមួយ ក្នុងក្រុងរាជគ្រឹះ ហើយពោលគាថានេះ ក្នុងវេលានោះថា

ឧបាសកណា បានប្រគេនចីវរ ដល់ចីរាភិក្ខុនី ដែលមានចិត្ត
រួចស្រឡះ ចាកយោគធម៌គ្រប់ប្រការ ឧបាសកនេះឈ្មោះ
ថាអ្នកមានប្រាជ្ញាពិត ហើយបានប្រទះនូវបុណ្យច្រើន ។

# ទ្វាទសមំ អាឡវកសុត្តំ

[៣១៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អាឡវិយំ វិហរតិ អាឡវកស្ស យក្ខស្ស ភវនេ ។ អថខោ អាឡវកោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច និក្ខម សមណាតិ ។ សាធាវុសោតិ ភគវា និក្ខមិ ។ បវិស សមណាតិ ។ សាធាវុសោតិ ភគវា បាវិសិ ។ ទុតិយម្បិ ខោ អាឡវកោ យក្ខោ ភគវន្តំ ឯតទវោច និក្ខម សមណាតិ ។ សាធាវុសោតិ ភគវា និក្ខមិ ។ បវិស សមណាតិ ។ សាធាវុសោតិ ភគវា បាវិសិ ។ តតិយម្បិ ខោ អាឡវកោ យក្ខោ ភគវន្តំ ឯតទវោច

# អាឡវកសូត្រ ទី ១២

[៣១៧] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមាន ព្រះភាគ ទ្រង់គង់ក្នុងលំនៅ របស់យក្សឈ្មោះអាឡវកៈ ក្នុងដែនអាឡវី ។ គ្រានោះឯង អាឡវកយក្ស ចូលទៅរកព្រះមានព្រះភាគ លុះចូល ទៅដល់ហើយ ទើបពោលនឹងព្រះមានព្រះភាគយ៉ាងនេះថា បពិត្រ សមណៈ ចូរលោកចេញទៅ ។ ព្រះមានព្រះភាគទទួលថា ម្នាលអា-វុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវកយក្ស ពោល ថា ម្នាលសមណៈ ចូរលោកមកវិញ ។ ព្រះមានព្រះភាគ ទទួល ថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចូលមកវិញ ។ អាឡ-វកយក្ស បានពោលនឹងព្រះមានព្រះភាគ យ៉ាងនេះ អស់វារៈពីរដងថា ម្នាលសមណៈ ចូរលោកចេញទៅ ។ ព្រះមានព្រះភាគ ក៏ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវកយក្ស ពោលថា ម្នាលសមណៈ ចូរលោកចូលមកវិញ ។ ព្រះមានព្រះភាគ ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះក៏ស្តេចចូលមកវិញ ។ អាឡ-វកយក្ស បានពោលនឹងព្រះមានព្រះភាគ យ៉ាងនេះ ជាគម្រប់បីដងថា

និក្ខម សមណាតិ ។ សាធាវុសោតិ ភគវា និក្ខមិ ។ បវិស សមណាតិ ។ សាធាវុសោតិ ភគវា ចាវិសិ ។

[៣១៨] ចតុត្ថម្បិ ខោ អាឡវកោ យក្ខោ ភគវន្តំ ឯតទវោច និក្ខម សមណាតិ ។ ន ខ្វាហំ អាវុសោ និក្ខមិស្សាមិ យន្តេ ករណីយំ តំ ករោហីតិ ។ បញ្ហំ តំ សមណ បុច្ឆិស្សាមិ សចេ មេ ន ព្យាករិស្សសិ ចិត្តំ វា តេ ខិបិស្សាមិ ហទយំ វា តេ ផាលេស្សាមិ ចាទេសុ វា គហេត្វា ចារគង្គាយ ខិបិស្សាមីតិ ។ ន ខ្វាហន្តំ អាវុសោ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យោ មេ ចិត្តំ វា ខិបេយ្យ ហទយំ វា ផាលេយ្យ ចាទេសុ វា គហេត្វា ចារគង្គាយ ខិបេយ្យ អបិច ត្វំ អាវុសោ បុច្ឆ យទាកង្ខសីតិ ។

*ម្នាលសមណៈ ចូរលោកចេញទៅវិញ ។ ព្រះមានព្រះភាគ ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ស្តេចចេញទៅ ។ អាឡវកយក្សពោលថា ម្នាលសមណៈ ចូរលោកចូលមកវិញ ។ ព្រះមានព្រះភាគ ទទួលថា ម្នាលអាវុសោ ប្រពៃហើយ ដូច្នេះ ក៏ទ្រង់ចូលមកវិញ ។*

[៣១៨] *អាឡវកយក្ស បានពោលនឹងព្រះមានព្រះភាគ អស់វារៈ ៤ ដងទៀតថា ម្នាលសមណៈ ចូរលោកចេញទៅវិញ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ តថាគតនឹងមិនចេញទៅទេ កិច្ចណា អ្នកឯងត្រូវធ្វើ ចូរអ្នកឯងធ្វើកិច្ចនោះចុះ ។ ម្នាលសមណៈ ខ្ញុំនឹងសួរប្រស្នាចំពោះលោក បើលោកមិនដោះប្រស្នាខ្ញុំទេ ខ្ញុំនឹងបន្សាត់ចិត្តលោក ឬវះហឫទ័យរបស់លោក ពុំនោះសោត ខ្ញុំនឹងចាប់ជើងលោកបោះទៅ ក្នុងត្រើយខាងនាយនៃទន្លេគង្គា ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអាវុសោ បុគ្គលណា បន្សាត់ចិត្តតថាគត ឬវះហឫទ័យ ឬក៏ចាប់ជើងគ្រវែងទៅ ក្នុងត្រើយខាងនាយនៃទន្លេគង្គា តថាគត មិនដែលឃើញបុគ្គលនោះសោះ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ម្នាលអាវុសោ បើដូច្នោះ ចូរអ្នកឯងសួរប្រស្នា ដែលអ្នកឯងប៉ុនប៉ងសួរចុះ ។*

[៣១៩] កឹសូធ វិត្តំ បុរិសស្ស សេដ្ឋំ
កឹសុ សុចិណ្ណំ សុខមាវហាតិ
កឹសុ ហវេ សាទុតរំ រសានំ
កថំ ជីវី ជីវិតមាហុ សេដ្ឋន្តិ ។

[៣២០] សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
សច្ចំ ហវេ សាទុតរំ រសានំ
បញ្ញាជីវី ជីវិតមាហុ សេដ្ឋន្តិ ។

[៣២១] កថំសុ តរតិ ឱឃំ
កថំសុ តរតិ អណ្ណវំ
កថំសុ ទុក្ខមច្ចេតិ
កថំសុ បរិសុជ្ឈតីតិ ។

[៣២២] សទ្ធាយ តរតិ ឱឃំ
អប្បមាទេន អណ្ណវំ
វិរិយេន ទុក្ខមច្ចេតិ
បញ្ញាយ បរិសុជ្ឈតីតិ ។

[៣១៩] អាឡវកយក្ស សួរថា អ្វីហ្ន៎ ជាទ្រព្យប្រសើរ របស់បុរសក្នុងលោកនេះ អ្វីហ្ន៎ ដែលបុគ្គលសន្សំដោយប្រពៃហើយ នាំសេចក្តីសុខមកឲ្យ របស់អ្វី ដែលមានរសឆ្ងាញ់ វិសេសជាងរសទាំងឡាយ ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដូចម្តេច ឈ្មោះថារស់នៅប្រសើរ ។

[៣២០] ព្រះអង្គត្រាស់ថា សទ្ធាជាទ្រព្យប្រសើរ របស់បុរសក្នុងលោកនេះ សុចរិតធម៌ដែលបុគ្គលសន្សំដោយប្រពៃ តែងនាំសេចក្តីសុខមកឲ្យ ពាក្យពិតជារសឆ្ងាញ់វិសេសជាងរសទាំងឡាយ ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដោយប្រាជ្ញា ឈ្មោះថារស់នៅប្រសើរ ។

[៣២១] អា បុគ្គលឆ្លងអន្លង់បាន ដោយអ្វីហ្ន៎ ឆ្លងសមុទ្របាន ដោយអ្វី បុគ្គលកន្លងសេចក្តីទុក្ខបាន ដោយអ្វី បរិសុទ្ធបាន ដោយអ្វី ។

[៣២២] ព បុគ្គលឆ្លងអន្លង់បាន ដោយសទ្ធា ឆ្លងសមុទ្របាន ដោយសេចក្តីមិនប្រមាទ កន្លងសេចក្តីទុក្ខបាន ដោយសេចក្តីព្យាយាម បរិសុទ្ធបាន ដោយប្រាជ្ញា ។

យក្ខសំយុត្តស្ស អាឡវកសុត្តេ បញ្ហាព្យាករណំ

[៣២៣] កថំសុ លភតេ បញ្ញំ
កថំសុ វិន្ទតេ ធនំ
កថំសុ កិត្តឹ បប្បោតិ
កថំ មិត្តានិ គន្ថតិ
អស្មា លោកា បរំ លោកំ
កថំ បេច្ច ន សោចតីតិ ។

[៣២៤] សទ្ទហានោ អរហតំ
ធម្មំ និព្វានបត្តិយា
សុស្សូសំ លភតេ បញ្ញំ
អប្បមត្តោ វិចក្ខណោ
បតិរូបការី ធុរវា
ឧដ្ឋាតា វិន្ទតេ ធនំ
សច្ចេន កិត្តឹ បប្បោតិ
ទទំ មិត្តានិ គន្ថតិ(១)
យស្សេតេ ចតុរោ ធម្មា
សទ្ធស្ស ឃរមេសិនោ

១ ឱ. ម. អស្មា លោកា បរំ លោកំ ឯវំ បេច្ច ន សោចតិ ។

យក្ខសំយុត្ត អាឡវកសូត្រ ការព្យាករនូវប្រស្នា

[៣២៣] អា. បុគ្គលបានប្រាជ្ញាដោយអ្វី បានទ្រព្យដោយអ្វី ដល់នូវសេចក្ដីសរសើរដោយអ្វី ចងពួកមិត្របានដោយអ្វី បុគ្គលលះលោកនេះ ទៅកាន់លោកខាងមុខ មិនសោកសៅ ក្នុងលោកខាងមុខ ដោយអ្វី ។

[៣២៤] ព. បុគ្គលជឿធម៌របស់ព្រះអរហន្តទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីដល់ព្រះនិព្វាន បុគ្គលមានប្រាជ្ញា មិនប្រមាទ កាលស្ដាប់ដោយប្រពៃ រមែងបាននូវប្រាជ្ញា បុគ្គលមានការងារសមតាមកាល មានធុរៈ (មិនទំលាក់ចោល) ជាអ្នកតស៊ូ រមែងបាននូវទ្រព្យ បុគ្គលដល់នូវសេចក្ដីសរសើរដោយសច្ចៈ បុគ្គលអ្នកឲ្យ រមែងចងពួកមិត្របាន បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះ ត្រូវមានធម៌ ៤ ប្រការនេះ

សច្ចំ ទមោ ធិតិ ចាគោ
ស វេ បេច្ច ន សោចតិ
ឥង្ឃ[១] អញ្ញេបិ បុច្ឆស្សុ
បុថូ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា
ខន្ត្យា ភិយ្យោធ វិជ្ជតីតិ ។

[៣២៥] កថំ នុ ទានិ បុច្ឆេយ្យំ
បុថូ សមណព្រាហ្មណេ
យោហំ អជ្ជ បជានាមិ
យោ អត្ថោ សម្បរាយិកោ
អត្ថាយ វត មេ ពុទ្ធោ
វាសាយាឡវិមាគមា
យោហំ អជ្ជ បជានាមិ
យត្ថ ទិន្នំ មហប្ផលំ

១ ឱ. ម. អស្មា លោកា បរំ លោកំ ឯវំ បេច្ច ន សោចតិ ។

គឺ សច្ចៈ (ពាក្យពិត) ១ ទមៈ (ការទូន្មាន) ១ ធិតិ (សេចក្តីអត់ធន់) ១ ចាគៈ (ការបរិច្ចាគ) ១ រមែងមិនសោកសៅក្នុងលោកខាងមុខដោយពិត បើដូច្នោះ ចូរអ្នកសួរពួកសមណ-ព្រាហ្មណ៍ឯទៀតឲ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះ វិសេសជាង សច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀត ។

[៣២៥] អា. ក្នុងវេលានេះ ខ្ញុំនឹងសួរពួកសមណ-ព្រាហ្មណ៍ច្រើនគ្នាដូចម្តេចបាន (ព្រោះ) ខ្ញុំទើបតែនឹងដឹងប្រ-យោជន៍ក្នុងបរលោកក្នុងថ្ងៃនេះ ដោយសារព្រះពុទ្ធស្តេចមកគង់ក្នុងដែនអាឡវីជាប្រយោជន៍ដល់ខ្ញុំ ខ្ញុំទើបតែនឹងដឹងក្នុងថ្ងៃនេះថា ទានដែលគេឲ្យចំពោះបុគ្គលណា មានផលច្រើន

យក្ខសំយុត្តស្ស អាឡវកសុត្តេ តស្សុទ្ទានំ

សោ អហំ វិចរិស្សាមិ
គាមា គាមំ បុរា បុរំ
នមស្សមានោ សម្ពុទ្ធំ
ធម្មស្ស ច សុធម្មតន្តិ ។

យក្ខសំយុត្តំ សមត្តំ ។

## តស្សុទ្ទានំ

ឥន្ទកោ សក្កសូចិ[១] ច
មណិភទ្ទោ ច សានុ ច
បិយង្ករបុនព្វសុ
សុទត្តោ ច ទ្វេ សុក្កា ចីរា
អាឡវកេន ទ្វាទសាតិ ។

១ ឱ. ឥន្ទកោ សក្កលោមោ ច ។

*ខ្ញុំនឹងចេញពីស្រុកមួយ ទៅស្រុកមួយ ចេញពីបុរីមួយ ទៅបុរីមួយ នមស្ការនូវព្រះសម្ពុទ្ធផង ព្រះធម៌ដ៏ប្រសើរផង ។*

ចប់ យក្ខសំយុត្ត ។

## ឧទ្ទាននៃយក្ខសំយុត្តនោះ គឺ

*សូត្រមាន ១២ គឺ ឥន្ទកសូត្រ ១ សក្កសូត្រ ១ សូចិលោមសូត្រ ១ មណិភទ្ទសូត្រ ១ សានុសូត្រ ១ បិយង្ករសូត្រ ១ បុនព្វសុសូត្រ ១ សុទត្តសូត្រ ១ សុក្កាសូត្រ ២ ចីរាសូត្រ ១ អាឡវកសូត្រ ១ ។*

# សក្កសំយុត្តំ

## បឋមំ សុវីរសុត្តំ

[៣៦៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគ-
វា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស
អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខ-
វោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៣៦៧] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ អ-
សុរា ទេវេ អភិយំសុ ។ អថខោ ភិក្ខវេ សក្កោ ទេវា-
នមិន្ទោ សុវីរំ ទេវបុត្តំ អាមន្តេសិ ឯតេ តាត សុវីរ អ-
សុរា ទេវេ អភិយន្តិ គច្ឆ តាត សុវីរ អសុរេ បច្ចុយ្យា-
ហីតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ សុវីរោ ទេវបុត្តោ
សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា បមាទំ អាបាទេសិ ។

# សក្កសំយុត្ត

## សុវីរសូត្រ ទី ១

[៣២៦] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ។

[៣២៧] ព្រះមានព្រះភាគ ទ្រង់ត្រាស់ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានពួកអសុរ ច្បាំងតគ្នានឹងពួកទេវតា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា បានហៅទេវបុត្តឈ្មោះសុវីរៈមកថា ម្នាលបាសុវីរៈ ពួកអសុរទាំងនុ៎ះ ច្បាំងតគ្នានឹងពួកទេវតា ម្នាលបាសុវីរៈ ចូរអ្នកទៅតតាំងនឹងពួកអសុរនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ សុវីរទេវបុត្ត ទទួលទេវបញ្ជា របស់សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយថា ព្រះករុណាថ្លៃវិសេស យ៉ាងនេះហើយ ក៏ធ្វើពួកអសុរ ឲ្យដល់នូវសេចក្តីប្រមាទ ។

ទុតិយម្បិ ខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុវីរំ ទេវបុត្តំ អាមន្តេសិ ឯតេ តាត សុវីរ អសុរា ទេវេ អភិយន្តិ គច្ឆ តាត សុវីរ អសុរេ បច្ចុយ្យាហីតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ សុវីរោ ទេវបុត្តោ សក្កស្ស ទេ-វានមិន្ទស្ស បដិស្សុត្វា ទុតិយម្បិ បមាទំ អាបាទេសិ ។ តតិយម្បិ ខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុវីរំ ទេវបុត្តំ អាមន្តេសិ ឯតេ តាត សុវីរ អសុរា ទេវេ អ-ភិយន្តិ គច្ឆ តាត សុវីរ អសុរេ បច្ចុយ្យាហីតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ សុវីរោ ទេវបុត្តោ សក្កស្ស ទេ-វានមិន្ទស្ស បដិស្សុត្វា តតិយម្បិ បមាទំ អាបាទេសិ ។

[៣២៨] អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុវីរំ ទេវបុត្តំ គាថាយ អជ្ឈភាសិ

អនុដ្ឋហំ អវាយាមំ
សុខំ យត្រាធិគច្ឆតិ
សុវីរ តត្ថ គច្ឆាហិ
មញ្ច តត្ថេវ បាបយាតិ ។

ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជ ជាធំជាងពួកទេវតា បានហៅសុវីរ-ទេវបុត្តមកអស់វារៈ ២ ដងទៀតថា ម្នាលបាសុវីរៈ ពួកអសុរទាំងនុ៎ះ ច្បាំងតគ្នានឹងពួកទេវតា ម្នាលបាសុវីរៈ ចូរអ្នកទៅតតាំងនឹងពួកអសុរចុះ ។ ម្នាលភិក្ខុទាំងឡាយ សុវីរទេវបុត្ត ទទួលទេវបញ្ជា របស់សក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស យ៉ាងនេះហើយ ក៏ធ្វើពួកអសុរឲ្យដល់នូវសេចក្ដីប្រមាទ អស់វារៈ ២ ដង ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជ ជាធំជាងពួកទេវតា បានហៅសុវីរទេវបុត្តមកអស់វារៈ ៣ ដងទៀតថា ម្នាលបាសុវីរៈ ពួកអសុរទាំងនុ៎ះ ច្បាំងតគ្នានឹងពួកទេវតា ម្នាលបាសុវីរៈ ចូរអ្នកទៅតតាំងនឹងពួកអសុរចុះ ។ ម្នាលភិក្ខុទាំងឡាយ សុវីរទេវបុត្ត ទទួលទេវបញ្ជា របស់សក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស យ៉ាងនេះហើយ ក៏ធ្វើពួកអសុរ ឲ្យដល់នូវសេចក្ដីប្រមាទ អស់វារៈ ៣ ដងទៀត ។

[៣២៨] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា បានពោលគាថានឹងសុវីរទេវបុត្តថា

បុគ្គល កាលមិនតស៊ូ មិនព្យាយាមទេ តែងបានសេចក្ដី
សុខ ក្នុងទីណា ម្នាលសុវីរៈ ចូរអ្នកទៅក្នុងទីនោះចុះ
ចូរអ្នកធ្វើអញឲ្យដល់ ក្នុងទីនោះផង ។

[៣២៩] អលស្វាយំ[១] អនុដ្ឋាតា
ន ច កិច្ចានិ ការយេ
សព្វកាមសមិទ្ធស្ស
តម្មេ សក្ក វរំ ទិសាតិ ។

[៣៣០] យត្ថាលសោ អនុដ្ឋាតា
អច្ចន្តសុខមេធតិ
សុវីរ តត្ថ គច្ឆាហិ
មញ្ច តត្ថេវ ចាបយាតិ ។

[៣៣១] អកម្មុនា ទេវសេដ្ឋ
សក្ក វិន្ទេមុ យំ សុខំ
អសោកំ អនុបាយាសំ
តម្មេ សក្ក វរំ ទិសាតិ ។

---

១ ឱ. អលសស្ស ។ ម. អលស្វស្ស ។

[៣២៩] សុវីរទេវបុត្ត ទូលថា បុគ្គលខ្ជិលច្រអូស ជាអ្នកមិនតស៊ូ មិនធ្វើកិច្ចការដែលត្រូវធ្វើ តែជាអ្នកសម្រេច នូវសេចក្តីប្រាថ្នាគ្រប់ចំពូក បពិត្រសក្កទេវរាជ សូមព្រះអង្គទ្រង់បង្ហាញ នូវកន្លែងដ៏ប្រសើរនោះ ដល់ខ្ញុំព្រះអង្គ ។

[៣៣០] សក្កទេវរាជត្រាស់ថា បុគ្គលខ្ជិលច្រអូស ជាអ្នកមិនតស៊ូ ដល់នូវសេចក្តីសុខ ដោយចំណែកមួយ ក្នុងទីណា ម្នាលសុវីរៈ ចូរអ្នកទៅក្នុងទីនោះចុះ ចូរអ្នកធ្វើអញ្ជើញឲ្យដល់ ក្នុងទីនោះផង ។

[៣៣១] សុវីរទេវបុត្ត ទូលថា បពិត្រសក្កទេវរាជដ៏ប្រសើរជាងទេវតា យើងបានសេចក្តីសុខណា ដោយមិនបាច់ធ្វើការងារ បពិត្រសក្កទេវរាជ សូមទ្រង់បង្ហាញសេចក្តីសុខដ៏ប្រសើរ ដែលមិនមានសោកសៅ មិនមានសេចក្តីចង្អៀតចង្អល់ចិត្តនោះ ដល់ខ្ញុំព្រះអង្គផង ។

[៣៣២] សចេ អត្ថិ អកម្មេន
កោចិ ក្វចិ ន ជីវតិ[១]
និព្វានស្ស ហិ សោ មគ្គោ
សុរិយំ តត្ថ គច្ឆាហិ
មញ្ចំ តត្ថេវ ចាបយាតិ ។

[៣៣៣] សោ ហិ នាម ភិក្ខវេ សក្កោ ទេវានមិន្ទោ សកំ បុញ្ញផលំ ឧបជីវមានោ ទេវានំ តាវតឹសានំ ឥស្សរិយាធិបច្ចំ រជ្ជំ ការេន្តោ ឧដ្ឋានវីរិយស្ស វណ្ណវាទី ភវិស្សតិ ។ ឥធ ខោ តំ ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ឧដ្ឋហេយ្យាថ ឃដេយ្យាថ វាយមេយ្យាថ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។

## ទុតិយំ សុសិមសុត្តំ

[៣៣៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ

១ ឱ. ជីយតិ ។

[៣៣២] សក្កទេវរាជ តបថា ប្រសិនបើបុគ្គលណាមួយ មិនរស់នៅក្នុងកន្លែងណាមួយ ដោយឥតមានការផ្សារ ផ្លូវនោះឯងហើយ ជាផ្លូវព្រះនិព្វាន ម្នាលសុវីរៈ ចូរអ្នកទៅក្នុងទីនោះចុះ ចូរអ្នកធ្វើអញឲ្យដល់ ក្នុងទីនោះផង ។

[៣៣៣] ម្នាលភិក្ខុទាំងឡាយ អម្បាលដូចយ៉ាងសក្កទេវរាជ ជាធំជាងពួកទេវតា កំពុងសោយផលបុណ្យរបស់ខ្លួន សោយរាជ្យជាឥស្សរាធិបតី ជាងពួកទេវតានៅឋានតាវត្តិង្ស ម្តេចគង់សរសើរសេចក្តីប្រឹងប្រែង និងការព្យាយាមដែរ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយធ្វើការណ៍នុ៎ះ ឲ្យល្អក្នុងធម្មវិន័យចុះ ព្រោះថា អ្នកទាំងឡាយបានបួសក្នុងធម៌វិន័យ ដែលតថាគតសំដែងហើយដោយប្រពៃយ៉ាងនេះ គួរណាស់តែរឿសរវៃ ប្រឹងប្រែង ព្យាយាម ដើម្បីដល់នូវមគ្គផល ដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវមគ្គផលដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ កុំបីអាក់ខានឡើយ ។

# សុសិមសូត្រ ទី ២

[៣៣៤] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង

ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៣៣៤] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ អសុរា ទេវេ អភិយំសុ ។ អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុសិមំ ទេវបុត្តំ អាមន្តេសិ ឯតេ តាត សុសិម អសុរា ទេវេ អភិយន្តិ គច្ឆ តាត សុសិម អសុរេ បច្ចុយ្យាហីតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ សុសិមោ ទេវបុត្តោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា បមាទំ អាបាទេសិ ។ ទុតិ-យម្បិ ខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុសិមំ ទេវបុត្តំ អាមន្តេសិ ។ បេ ។ ទុតិយម្បិ បមាទំ អាបាទេសិ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំង-ឡាយ ។ ពួកភិក្ខុនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៣៣៥] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ពីព្រេងនាយមក មានពួកអសុរ ច្បាំងតនឹងពួកទេវតា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា បានហៅសុសិមទេវបុត្តមកថា ម្នាលបាសុសិមៈ ពួកអសុរទាំងនុ៎ះ ច្បាំងនឹងពួកទេវតា ម្នាលបាសុសិមៈ ចូរអ្នកទៅតតាំងនឹងពួកអសុរចុះ ។ ម្នាលភិក្ខុទាំងឡាយ សុសិមទេវបុត្ត ទទួលទេវបញ្ជា របស់សក្កទេវរាជជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស យ៉ាងនេះហើយ ក៏ធ្វើពួកអសុរ ឲ្យដល់នូវសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជជាធំជាងពួកទេវតា ត្រាស់ហៅសុសិមទេវបុត្ត អស់វារៈ ២ ដងទៀត ។ បេ ។ ធ្វើពួកអសុរឲ្យដល់នូវសេចក្តីប្រមាទ អស់វារៈ ២ ដងទៀត ។

តតិយម្បិ ខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុសិមំ ទេវបុត្តំ អាមន្តេសិ ឯតេ តាត សុសិម អសុរា ទេវេ អភិយន្តិ គច្ឆ តាត សុសិម អសុរេ បច្ចុយ្យាហីតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ សុសិមោ ទេវបុត្តោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា តតិយម្បិ បមាទំ អាបាទេសិ ។

[៣៣៦] អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុសិមំ ទេវបុត្តំ គាថាយ អជ្ឈភាសិ

អនុដ្ឋហំ អវាយាមំ
សុខំ យត្រាធិគច្ឆតិ
សុសិម តត្ថ គច្ឆាហិ
មញ្ច តត្ថេវ បាបយាតិ ។

[៣៣៧] អលស្វាយំ អនុដ្ឋាតា
ន ច កិច្ចានិ ការយេ
សព្វកាមសមិទ្ធស្ស
តំ មេ សក្ក វរំ ទិសាតិ ។

ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជជាធំជាងពួកទេវតា ត្រាស់ហៅសុសិម-ទេវបុត្តមក អស់វារៈ ៣ ដងថា ម្នាលបាសុសិមៈ ពួកអសុរទាំងនុ៎ះ ច្បាំងនឹងពួកទេវតា ម្នាលបាសុសិមៈ ចូរអ្នកទៅតតាំងនឹងពួកអសុរចុះ ។ ម្នាលភិក្ខុទាំងឡាយ សុសិមទេវបុត្ត ទទួលទេវបញ្ជា របស់សក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស យ៉ាងនេះហើយ ក៏ធ្វើពួកអសុរ ឲ្យដល់នូវសេចក្តីប្រមាទ អស់វារៈ ៣ ដងទៀត ។

[៣៣៦] ម្នាលភិក្ខុទាំងឡាយ ទើបសក្កទេវរាជជាធំជាងពួកទេវតា បានពោលគាថា នឹងសុសិមទេវបុត្តថា

បុគ្គល កាលមិនតស៊ូ មិនព្យាយាមទេ បានសេចក្តីសុខ
ក្នុងទីណា ម្នាលសុសិមៈ ចូរអ្នកទៅក្នុងទីនោះចុះ ចូរអ្នក
ធ្វើអញឲ្យដល់ ក្នុងទីនោះផង ។

[៣៣៧] សុសិមទេវបុត្ត ទូលថា បុគ្គលខ្ជិលច្រអូស ជា
អ្នកមិនតស៊ូ មិនធ្វើកិច្ចការដែលត្រូវធ្វើ តែជាអ្នកសម្រេច
នូវសេចក្តីប្រាថ្នាគ្រប់ចំពូក បពិត្រសក្កៈ សូមព្រះអង្គទ្រង់
បង្ហាញ នូវកន្លែងដ៏ប្រសើរនោះ ដល់ខ្ញុំព្រះអង្គ ។

[៣៣៨] យត្ថាលសោ អនុដ្ឋាតា
អច្ចន្តសុខមេជតិ
សុសិម តត្ថ គច្ឆាហិ
មញ្ច តត្ថេវ ចាបយាតិ ។

[៣៣៩] អកម្មុនា ទេវសេដ្ឋ
សក្កា វិន្ទេមុ យំ សុខំ
អសោកំ អនុចាយាសំ
តំ មេ សក្កា វរំ និសាតិ ។

[៣៤០] សចេ អត្ថិ អកម្មេន
កោចិ ក្វចិ ន ជីវតិ
និព្វានស្ស ហិ សោ មគ្គោ
សុសិម តត្ថ គច្ឆាហិ
មញ្ច តត្ថេវ ចាបយាតិ ។

[៣៣៨] សក្កទេវរាជ តបថា បុគ្គលខ្ជិលច្រអូស ជាអ្នកមិនតស៊ូ ដល់នូវសេចក្តីសុខ ដោយចំណែកមួយ ក្នុងទីណា ម្នាលសុសិមៈ ចូរអ្នកទៅក្នុងទីនោះចុះ ចូរអ្នកធ្វើអញឲ្យដល់ ក្នុងទីនោះផង ។

[៣៣៩] សុសិមទេវបុត្ត ទូលថា បពិត្រសក្កទេវរាជ ដ៏ប្រសើរជាងទេវតា យើងបានសេចក្តីសុខណា ដោយមិនបាច់ធ្វើការងារ បពិត្រសក្កទេវរាជ សូមទ្រង់បង្ហាញសេចក្តីសុខដ៏ប្រសើរ ដែលមិនមានសេចក្តីសោកសៅ មិនមានសេចក្តីតឹងចិត្តនោះ ដល់ខ្ញុំព្រះអង្គផង ។

[៣៤០] សក្កទេវរាជ តបថា ប្រសិនបើអ្នកណាមួយ មិនរស់នៅក្នុងទីណាមួយ ដោយមិនធ្វើការងារទេ ផ្លូវនោះឯងហើយ ជាផ្លូវព្រះនិព្វាន ម្នាលសុសិមៈ ចូរអ្នកទៅក្នុងទីនោះចុះ ចូរអ្នកធ្វើអញឲ្យដល់ ក្នុងទីនោះផង ។

[៣៤១] សោ ហិ នាម ភិក្ខវេ សក្កោ ទេវានមិន្ទោ សកំ បុញ្ញផលំ ឧបជីវមានោ ទេវានំ តាវតឹសានំ ឥស្សរិយាធិបច្ចំ រជ្ជំ ការេន្តោ ឧដ្ឋានវីរិយស្ស វណ្ណវាទី ភវិស្សតិ ។ ឥធ ខោ តំ ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ឧដ្ឋ-ហេយ្យាថ ឃដេយ្យាថ វាយមេយ្យាថ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ ។

## តតិយំ ធជគ្គសុត្តំ

[៣៤២] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៣៤១] ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាង សក្កទេវរាជជាធំជាងពួកទេវតានេះ កំពុងសោយផលបុណ្យរបស់ខ្លួន សោយរាជ្យជាឥស្សរាធិបតីជាងទេវតាទាំងឡាយ នៅឋានតាវត្តិង្ស ម្តេចគង់សរសើរសេចក្តីប្រឹងប្រែងនិងការព្យាយាមដែរ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំង-ឡាយធ្វើការណ៍នុ៎ះឲ្យល្អ ក្នុងសាសនានេះចុះ ព្រោះថា អ្នកទាំងឡាយបានបួសក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ដោយប្រពៃយ៉ាងនេះ គួររៀសរវៃ ប្រឹងប្រែង ព្យាយាម ដើម្បីដល់នូវមគ្គផល ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវធម៌ ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ កុំបីអាក់ខានឡើយ ។

# ធជគ្គសូត្រ ទី ៣

[៣៤២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៣៤៣] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ[១] អហោសិ ។ អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ ទេវេ តាវតឹសេ អាមន្តេសិ សចេ មារិសា ទេវានំ សង្គាមគតានំ ឧប្បជ្ជេយ្យ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា មមេវ តស្មឹ សមយេ ធជគ្គំ ឧល្លោកេយ្យាថ ។ មមញ្ហិ វោ ធជគ្គំ ឧល្លោកយតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សោ បហីយិស្សតិ ។ នោ ចេ មេ ធជគ្គំ ឧល្លោកេយ្យាថ អថ បជាបតិស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ ។ បជាបតិស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សោ បហីយិស្សតិ ។ នោ ចេ បជាបតិស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ អថ វរុណស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ ។

---

១ ឱ. សមុព្ពូឡ្ហោ ។

[៣៤៣] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា សង្គ្រាមទេវតានិងអសុរ បានផ្ចុំគ្នា (ប្រទល់គ្នា) ហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតាទាំងឡាយ បានហៅពួកទេវតា ក្នុងឋានតាវត្តិង្សមកថា ម្នាលគ្នាយើង កាលបើពួកទេវតា ចូលកាន់សង្គ្រាមហើយ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម កើតឡើង ពួកអ្នកគប្បីក្រឡេកមើលចុងទង់ជ័យរបស់ខ្ញុំ ក្នុងសម័យនោះចុះ ។ ព្រោះថា កាលបើអ្នកទាំងឡាយ ក្រឡេកមើលចុងទង់ជ័យរបស់ខ្ញុំ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះមុខជានឹងស្ងប់រម្ងាប់ទៅវិញ ។ បើពួកអ្នកមិនក្រឡេកមើលចុងទង់ជ័យរបស់ខ្ញុំទេ ក៏ត្រូវតែក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះបជាបតិចុះ ។ ព្រោះថា កាលបើពួកអ្នកក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះបជាបតិ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណានឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅវិញបាន ។ បើអ្នកទាំងឡាយ មិនក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះបជាបតិទេ ក៏ត្រូវក្រឡេកមើលចុងទង់ជ័យ នៃទេវរាជ ឈ្មោះវរុណៈ ។

វរុណស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សោ បហីយិស្សតិ ។ នោ ចេ វរុណស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ អថ ឦសានស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ ។ ឦសានស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សោ បហីយិស្សតីតិ[១] ។ តំ ខោ បន ភិក្ខវេ សក្កស្ស វា ទេវានមិន្ទស្ស ធជគ្គំ ឧល្លោកយតំ បជាបតិស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ វរុណស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ ឦសានស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សោ បហីយិស្សតិ នោបិ បហីយេថ តំ កិស្ស ហេតុ សក្កោ ហិ ភិក្ខវេ ទេវានមិន្ទោ អវីតរាគោ អវីតទោសោ អវីតមោហោ ភីរុ ឆម្ភី ឧត្រាសី បលាយីតិ ។

១ កត្ថចិ បហីយិស្សតីតិ ទិស្សតិ ។

ព្រោះថា កាលបើពួកអ្នកក្រឡេកមើលចុងទង់ជ័យ នៃទេវរាជ ឈ្មោះវរុណៈ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅវិញ ។ បើពួកអ្នកមិនក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះវរុណៈទេ ត្រូវតែក្រឡេកមើលចុងទង់ជ័យនៃទេវរាជ ឈ្មោះឦសានៈ ។ ព្រោះថា កាលបើពួកអ្នកក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះឦសានៈ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកទេវតាក្រឡេកមើលចុងទង់ជ័យនោះ នៃទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតាទាំងឡាយក្តី ក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះបជាបតិក្តី ក្រឡេកមើលចុងទង់ជ័យនៃទេវរាជឈ្មោះវរុណៈក្តី ក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះឦសានៈក្តី សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ ក៏នឹងស្ងប់រម្ងាប់ ចួនកាលមិនស្ងប់រម្ងាប់ក៏មានខ្លះ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា សក្កទេវានមិន្ទ មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ជាអ្នកនៅខ្លាច នៅរន្ធត់ នៅតក់ស្លុត រត់ចេញនៅឡើយ ។

[៣៤៤] អហញ្ច ខោ ភិក្ខវេ ឯវំ វទាមិ សចេ តុម្ហាកំ ភិក្ខវេ អរញ្ញគតានំ វា រុក្ខមូលគតានំ វា សុញ្ញាគារគតានំ វា ឧប្បជ្ជេយ្យ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា មមេវ តស្មឹ សមយេ អនុស្សរេយ្យាថ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ មមំ ហិ វោ ភិក្ខវេ អនុស្សរតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សោ បហីយិស្សតិ ។ នោ ចេ មំ អនុស្សរេយ្យាថ អថ ធម្មំ អនុស្សរេយ្យាថ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ

[៣៤៤] ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បើពួកអ្នកនៅក្នុងព្រៃ ឬនៅទៀបគល់ឈើ ឬនៅក្នុងផ្ទះស្ងាត់ សេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី កើតឡើង ពួកអ្នកគប្បីរឭករឿយ ៗ នូវតថាគត ក្នុងសម័យនោះថា ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ទ្រង់ជ្រាបច្បាស់នូវលោក ព្រះអង្គប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្ស ជាព្រះពុទ្ធ ទ្រង់ចែកនូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើពួកអ្នករលឹករឿយ ៗ នូវតថាគត សេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ មុខជាស្ងប់រម្ងាប់ទៅ ។ បើពួកអ្នកមិនរឭករឿយ ៗ នូវតថាគតទេ គប្បីរឭករឿយ ៗ នូវព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ជាធម៌ដែលព្រះអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌ដែលព្រះអរិយបុគ្គល គួរហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គល គួរបង្អោនចូលមកទុកក្នុងចិត្តបាន

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ ធម្មំ ហិ វោ ភិក្ខវេ អនុស្សរតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោម-ហំសោ វា សោ បហីយិស្សតិ ។ នោ ចេ ធម្មំ អនុស្សរេយ្យាថ អថ សង្ឃំ អនុស្សរេយ្យាថ សុប្បដិ-បន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវក-សង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុ-នេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ សង្ឃំ ហិ វោ ភិក្ខវេ អនុស្សរតំ យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោម-ហំសោ វា សោ បហីយិស្សតិ តំ កិស្ស ហេតុ

ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយ រឭករឿយ ៗ នូវធម៌ សេចក្ដីខ្លាច សេចក្ដីរន្ធត់ ឬសេចក្ដីព្រឺរោម ណា នឹងកើតឡើង សេចក្ដីខ្លាចជាដើមនោះ មុខជានឹងស្ងប់រម្ងាប់ទៅបាន ។ បើអ្នកទាំងឡាយមិនរឭកនូវធម៌ទេ គប្បីរឭកនូវសង្ឃថា ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោប្រតិបត្តិហើយដោយត្រង់ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយដើម្បីព្រះនិព្វាន ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយដោយត្រឹមត្រូវ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ រាប់ជាគូនៃបុរសមាន ៤ គូ រាប់រៀងជាបុរសបុគ្គល មាន ៨ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគនុ៎ះ លោកគួរទទួលនូវគ្រឿងបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តប្រសើរបំផុត របស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើអ្នកទាំងឡាយរឭកនូវសង្ឃ សេចក្ដីខ្លាច សេចក្ដីរន្ធត់ ឬសេចក្ដីព្រឺរោម ណា នឹងកើតឡើង សេចក្ដីខ្លាចជាដើមនោះ មុខជានឹងស្ងប់រម្ងាប់ទៅបាន សេចក្ដីនោះ ព្រោះហេតុអ្វី

តថាគតោ ហិ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ វីតរាគោ វីតទោសោ វីតមោហោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយីតិ ។

[៣៤៩] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

អរញ្ញេ រុក្ខមូលេ វា
សុញ្ញាគារេ វ ភិក្ខវោ
អនុស្សរេថ សម្ពុទ្ធំ
ភយំ តុម្ហាក នោ សិយា
នោ ចេ ពុទ្ធំ សរេយ្យាថ
លោកជេដ្ឋំ នរាសភំ
អថ ធម្មំ សរេយ្យាថ
និយ្យានិកំ សុទេសិតំ
នោ ចេ ធម្មំ សរេយ្យាថ
និយ្យានិកំ សុទេសិតំ
អថ សង្ឃំ សរេយ្យាថ
បុញ្ញក្ខេត្តំ អនុត្តរំ

ម្នាលភិក្ខុទាំងឡាយ ព្រោះថា តថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចេញទេ ។

[៣៤៥] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគត ត្រាស់នូវព្រះពុទ្ធដីកានេះហើយ លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់ព្រះពុទ្ធដីកានេះ តទៅទៀតថា

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នករាល់គ្នានៅក្នុងព្រៃ ឬទៀបគល់ឈើ ឬក្នុងផ្ទះស្ងាត់ គប្បីរឭករឿយៗ នូវព្រះសម្ពុទ្ធ ភ័យនឹងមិនមានដល់ពួកអ្នកទេ បើអ្នកទាំងឡាយ មិនបានរឭកនូវព្រះពុទ្ធ ដែលជាធំបំផុតក្នុងលោក ជានរៈអង់អាចទេ គប្បីរឭកធម៌ ជាធម៌ស្រោចស្រង់សត្វ ដែលតថាគតសំដែងល្អហើយ បើអ្នកទាំងឡាយ មិនបានរឭកធម៌ ជាធម៌ស្រោចស្រង់សត្វ ដែលតថាគត សំដែងល្អហើយទេ គប្បីរឭកសង្ឃ ជាបុញ្ញក្ខេត្តប្រសើរបំផុត (របស់សត្វលោកចុះ)

ឯវំ ពុទ្ធំ សរន្តានំ
ធម្មំ សង្ឃញ្ច ភិក្ខវោ
ភយំ វា ឆម្ភិតត្តំ វា
លោមហំសោ ន ហេស្សតីតិ ។

# ចតុត្ថំ វេបចិត្តិសុត្តំ

[៣៨៦] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ បេ ។

[៣៨៧] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ ទេវាសុរសង្គាមោ សមុបព្យុឡ្ហោ អហោសិ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ អសុរេ អាមន្តេសិ សចេ មារិសា ទេវាសុរសង្គាមេ[១] សមុបព្យុឡ្ហេ អសុរា ជិនេយ្យុំ ទេវា បរាជិនេយ្យុំ យេន នំ សក្កំ ទេវានមិន្ទំ កណ្ឋបញ្ចមេហិ[២] ពន្ធនេហិ ពន្ធិត្វា មម សន្តិកេ អានេយ្យាថ អសុរបុរន្តិ ។ សក្កោបិ ខោ ភិក្ខវេ ទេវានមិន្ទោ ទេវេ តាវតឹសេ អាមន្តេសិ សចេ មារិសា ទេវាសុរសង្គាមេ សមុបព្យុឡ្ហេ ទេវា

១ ឱ. ម. ទេវានំ អសុរសង្គាមេ ។ ២ ឱ. ម. កណ្ឋេ បញ្ចមេហិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នករាល់គ្នារឭកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃយ៉ាងនេះ ភ័យក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី នឹងមិនមានឡើយ ។

## វេបចិត្តិសូត្រ ទី ៤

[៣៤៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ បេ ។

[៣៤៧] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា សង្គ្រាមទេវតានិងអសុរ បានប្រទល់គ្នាហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង អសុរិន្ទឈ្មោះវេបចិត្តិ បានហៅពួកអសុរមកថា ម្នាលពួកអ្នកនិទុំក្ខ កាលបើសង្គ្រាមពួកទេវតានឹងអសុរចួបប្រទះគ្នាហើយ ពួកអសុរឈ្នះ ពួកទេវតាចាញ់ ពួកអ្នកត្រូវចងសក្កទេវានមិន្ទនោះ ដោយចំណងទាំងឡាយ មានចំណង-កជាគម្រប់ប្រាំ ហើយនាំមកកាន់អសុរបុរី ក្នុងសំណាក់របស់ខ្ញុំ ។ ម្នាលភិក្ខុទាំង-ឡាយ ឯសក្កទេវានមិន្ទ ក៏បានហៅពួកទេវតា ក្នុងឋានតាវត្តិង្សមកថា ម្នាលពួកអ្នកនិទុំក្ខ កាលបើសង្គ្រាមទេវតានិងអសុរ ជួបប្រទះគ្នាហើយ

ជិនេយ្យុំ អសុរា បរាជិនេយ្យុំ យេន នំ វេបចិត្តឹ អសុរិន្ទំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិត្វា មម សន្តិកេ អានេយ្យាថ សុធម្មំ សភន្តិ ។ តស្មឹ ខោ បន ភិក្ខវេ សង្គាមេ ទេវា ជិនឹសុ អសុរា បរាជិនឹសុ ។ អថខោ ភិក្ខវេ ទេវា តាវត្តឹសា វេបចិត្តឹ អសុរិន្ទំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិត្វា សក្កស្ស ទេវានមិន្ទស្ស សន្តិកេ អានេសុំ សុធម្មំ សភំ ។

[៣៤៨] តត្រ សុទំ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពទ្ធោ សក្កំ ទេវានមិន្ទំ សុធម្មំ សភំ បវិសន្តញ្ច និក្ខមន្តញ្ច អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសតិ បរិភាសតិ ។

[៣៤៩] អថខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កំ ទេវានមិន្ទំ គាថាយ អជ្ឈភាសិ

ភយា នុ មឃវា(១) សក្ក
ទុព្វល្យេន(២) តិតិក្ខសិ
សុណន្តោ ផរុសំ វាចំ
សម្មុខា វេបចិត្តិនោ ។

១ ឱ. មគ្គវា សក្ក ។ ២ ឱ. ម. ទុព្វល្យានោ ។

បើពួកទេវតាឈ្នះ ពួកអសុរចាញ់ ពួកអ្នកត្រូវចងវេបចិត្តិអសុរិន្ទនោះ ដោយចំណងទាំងឡាយ មានចំណង-កជាគម្រប់ប្រាំ ហើយនាំមកកាន់សុ-ធម្មសភា ក្នុងសំណាក់របស់យើង ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសង្គ្រាមនោះ ពួកទេវតាឈ្នះ ពួកអសុរចាញ់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកទេវតាក្នុងឋានតាវត្តិង្ស ចងវេបចិត្តិអសុរិន្ទ ដោយចំណងទាំងឡាយ មានចំណង-កជាគម្រប់ប្រាំ ហើយនាំមកកាន់សុធម្មសភា ក្នុងសំណាក់សក្កទេវានមិន្ទ ។

[៣៤៨] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ បានឮថា វេប-ចិត្តិអសុរិន្ទ ដែលត្រូវពួកទេវតាចង ដោយចំណង មានចំណង-កជាគម្រប់ប្រាំ ក៏ស្រែកជេរផ្តាសាសក្កទេវានមិន្ទ ដែលស្តេចចូលមកកាន់សុធម្ម-សភា ទាំងស្តេចចេញមកវិញ ដោយវាចា ជាអសប្បុរស ដ៏អាក្រក់ ។

[៣៤៩] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង មាតលិសង្គា-ហកទេវបុត្ត បាននិយាយនឹងសក្កទេវានមិន្ទ ដោយគាថា ថា

បពិត្រមឃវសក្កទេវរាជ ព្រះអង្គឮវាចាអាក្រក់ របស់វេ-
បចិត្តិអសុរិន្ទ ក្នុងទីចំពោះព្រះភក្ត្រហើយ ទ្រង់អត់ធ្មត់បាន
តើព្រោះទ្រង់ខ្លាច ឬព្រោះទ្រង់មានកម្លាំងខ្សោយ ។

២៤១

សក្កសំយុត្តស្ស វេបចិត្តិសុត្តេ ខន្តិសោរច្ចំ

[៣៨០] នាហំ ភយា ន ទុព្វល្យា
ខមាមិ វេបចិត្តិនោ
កថញ្ហិ មាទិសោ វិញ្ញូ
ពាលេន បដិសំយុជេតិ ។

[៣៨១] ភិយ្យោ ពាលា បភិជ្ជេយ្យុំ[១]
នោ ចស្ស បដិសេធកោ
តស្មា ភុសេន ទណ្ឌេន
ធីរោ ពាលំ និសេធយេតិ ។

[៣៨២] ឯតទេវ អហំ មញ្ញេ
ពាលស្ស បដិសេធនំ
បរំ សង្កុបិតំ ញត្វា
យោ សតោ ឧបសម្មតីតិ ។

[៣៨៣] ឯតទេវ តិតិក្ខាយ
វជ្ជំ បស្សាមិ វាសវ
យទា នំ មញ្ញតិ ពាលោ
ភយា ម្យាយំ តិតិក្ខតិ

---

១ ឱ. ពាលា បកុជ្ឈេយ្យុំ ។

[៣៥០] *សក្កទេវរាជត្រាស់ថា ខ្ញុំឮវាចា របស់វេបចិត្តិ អសុរិន្ទហើយ អត់ធ្មត់បាន មិនមែនព្រោះខ្លាច មិនមែនព្រោះមានកម្លាំងខ្សោយទេ តាមពិត អ្នកយល់ការណ៍ច្បាស់ប្រហែលយ៉ាងខ្ញុំ ដូចម្តេចនឹងតបត ជាមួយបុគ្គលពាល ។*

[៣៥១] *មា. បើព្រះអង្គ មិនឃាត់ហាមបុគ្គលពាលទេ ពួកពាលនឹងរឹងរឹតតែឈ្លានពានឡើង ហេតុនោះ អ្នកប្រាជ្ញត្រូវហាមប្រាមបុគ្គលពាល ដោយអាជ្ញាដ៏ខ្លាំង ។*

[៣៥២] *ស. អ្នកណា ប្រកបដោយសតិ ដឹងថា អ្នកដទៃកំពុងក្រោធ ហើយទ្រាំអត់បាន ខ្ញុំសម្គាល់នូវអ្នកនុ៎ះឯងថា ជាអ្នកឃាត់ហាមបុគ្គលពាល ។*

[៣៥៣] *មា. បពិត្រវាសវៈ ខ្ញុំយល់ឃើញថា ការអត់ធន់នេះឯង ជាទោសវិញទេ (ព្រោះថា) បុគ្គលពាល រមែងសម្គាល់អ្នកអត់ធន់នោះថា អ្នកនេះអត់ធន់ ព្រោះខ្លាចអញ*

អជ្ឈារុហតិ ទុម្មេធោ
គោវ ភិយ្យោ បលាយិនន្តិ ។
[៣៩៤] កាមំ មញ្ញតុ វា មា វា
ភយា ម្យាយំ តិតិក្ខតិ
សទត្ថបរមា អត្ថា
ខន្ត្យា ភិយ្យោ ន វិជ្ជតិ
យោ ហវេ ពលវា សន្តោ
ទុព្វលស្ស តិតិក្ខតិ
តមាហុ បរមំ ខន្តឹ
និច្ចំ ខមតិ ទុព្វលោ
អពលន្តំ ពលំ អាហុ
យស្ស ពាលពលំ ពលំ
ពលវស្ស[១] ធម្មគុត្តស្ស
បដិវត្តា ន វិជ្ជតិ

១ ឱ. ម. ពលស្ស ។

ហេតុនោះ បានជាអ្នកឥតប្រាជ្ញា រមែងសង្កត់សង្កិនគេ ដូចជាគោ ព្រួតសង្កត់សង្កិនគោចាញ់ ដែលបោលទៅ ។

[៣៥៤] ស. បុគ្គលពាលចង់សម្គាល់ក្តី មិនសម្គាល់ក្តីថា អ្នកនេះអត់ធន់បាន ព្រោះខ្លាចអញ ក៏តាមការណ៍ចុះ តែថាប្រយោជន៍ទាំងឡាយ មានប្រយោជន៍ខ្លួនជាសំខាន់ ប្រយោជន៍អ្វី ឲ្យក្រៃលែងជាងខន្តីមិនមានទេ អ្នកណាមានកម្លាំង ជាអ្នកស្ងប់ ហើយអត់ឱន ចំពោះបុគ្គលមានកម្លាំងខ្សោយ បណ្ឌិតទាំងឡាយ សរសើរបុគ្គលនោះថា មានសេចក្តីអត់ទ្រាំដ៏ក្រៃលែង ព្រោះថា បុគ្គលមានកម្លាំងថយ តែងអត់ឱនជានិច្ច កម្លាំងរបស់ជនណាជាកម្លាំងពាល បណ្ឌិតទាំងឡាយ ហៅកម្លាំងជននោះថា មិនមែនជាកម្លាំងទេ បុគ្គលជាអ្នកតិះដៀលជនមានកម្លាំង ជាអ្នកគ្រប់គ្រងធម៌ មិនមានទេ

សក្កសំយុត្តស្ស វេបចិត្តិសុត្តេ ខន្តិសោរច្ចំ

តស្សេវ តេន បាបិយោ
យោ កុទ្ធំ បដិកុជ្ឈតិ
កុទ្ធំ អប្បដិកុជ្ឈន្តោ
សង្គាមំ ជេតិ ទុជ្ជយំ
ឧភិន្នមត្ថំ ចរតិ
អត្តនោ ច បរស្ស ច
បរំ សង្កុបិតំ ញត្វា
យោ សតោ ឧបសម្មតិ
ឧភិន្នំ តិកិច្ឆន្តានំ[១]
អត្តនោ ច បរស្ស ច
ជនា មញ្ញន្តិ ពាលោតិ
យេ ធម្មស្ស អកោវិទាតិ ។

---

១ ឱ. តិកិច្ឆន្តំ តំ ។

អ្នកណាខឹងតបនឹងបុគ្គលអ្នកខឹង សេចក្តីអាក្រក់ រមែងមាន

ដល់អ្នកនោះឯង ព្រោះសេចក្តីខឹងតបនោះ បុគ្គលអ្នកមិន

ខឹងតបនឹងបុគ្គលអ្នកខឹង ឈ្មោះថា ឈ្នះនូវសង្គ្រាម ដែល

ឈ្នះបានដោយកម្រ បុគ្គលណាមានស្មារតី ដឹងថាបុគ្គល

ដទៃខឹង ហើយទ្រាំអត់បាន (បុគ្គលនោះ) ឈ្មោះថាប្រព្រឹត្ត

នូវប្រយោជន៍ ដល់ជនទាំងពីរខាង គឺខ្លួនឯង ១ អ្នកដទៃ ១

កាលជនទាំងពីរខាង គឺខ្លួនឯង និងអ្នកដទៃ កំពុងសះជានឹង

គ្នា ពួកជនណាសម្គាល់ថា គេល្ងង់ (ពួកជននោះ)

ឈ្មោះថា មិនយល់ធម៌ច្បាស់ទេ ។

[៣៥៥] សោ ហិ នាម ភិក្ខវេ សក្កោ ទេវានមិន្ទោ សកំ បុញ្ញផលំ ឧបជីវមានោ ទេវានំ តាវត្តឹសានំ ឥស្សរិយាធិបច្ចំ រជ្ជំ ការេន្តោ ខន្តិសោរច្ចស្ស វណ្ណវាទី ភវិស្សតិ ។ ឥធ ខោ តំ ភិក្ខវេ សោភេថ យំ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ខមា ច ភវេយ្យាថ សោរតា ចាតិ ។

## បញ្ចមំ សុភាសិតជយសុត្តំ

[៣៥៦] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ។ បេ ។

[៣៥៧] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ សក្កំ ទេវានមិន្ទំ ឯតទវោច ហោតុ ទេវានមិន្ទ សុភាសិតេន ជយោតិ ។ ហោតុ វេបចិត្តិ សុភាសិតេន ជយោតិ ។ អថខោ ភិក្ខវេ

[៣៩៥] ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាងសក្កទេវានមិន្ទនោះ ទ្រង់សោយផលបុណ្យរបស់ខ្លួន សោយរាជ្យ ជាឥស្សរាធិបតី លើទេវតាទាំងឡាយ ក្នុងឋានតាវត្តិង្ស ម្តេចគង់សរសើរគុណសេចក្តីអត់ទ្រាំ និងសេចក្តីស្លូត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវញ៉ាំងហេតុនោះឲ្យល្អក្នុងសាសនានេះចុះ ព្រោះថា អ្នកទាំងឡាយ បួសក្នុងធម្មវិន័យដែលតថាគតសំដែងហើយ ដោយប្រពៃយ៉ាងនេះ គួរតែជាអ្នកអត់ធន់ផង ស្លូតបូតផង ។

# សុភាសិតជយសូត្រ ទី ៥

[៣៩៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។

[៣៩៧] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា សង្គ្រាមទេវតានិងអសុរ បានប្រទល់គ្នាហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង វេបចិត្តិអសុរិន្ទបាននិយាយនឹងសក្កទេវានមិន្ទយ៉ាងនេះថា នែទេវានមិន្ទ ជ័យជំនះ ចូរមានដោយសុភាសិតចុះ ។ សក្កទេវរាជតបថា ម្នាលវេបចិត្តិ ជ័យជំនះ ចូរមានដោយសុភាសិតចុះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង

ទេវា ច អសុរា ច បារិសជ្ជេ ឋបេសុំ ឥមេ នោ សុភាសិតំ ទុព្ភាសិតំ អាជានិស្សន្តីតិ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ សក្កំ ទេវានមិន្ទំ ឯតទវោច ភណ ទេវានមិន្ទ គាថន្តិ ។ ឯវំ វុត្តេ ភិក្ខវេ សក្កោ ទេវានមិន្ទោ វេបចិត្តឹ អសុរិន្ទំ ឯតទវោច តុម្ហេ ខ្វេត្ថ វេបចិត្តិ បុព្វទេវា ភណ វេបចិត្តិ គាថន្តិ ។

[៣៤៨] ឯវំ វុត្តេ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ ឥមំ គាថំ អភាសិ

ភិយ្យោ ពាលា បកុជ្ឈេយ្យុំ
នោ ចស្ស បដិសេធកោ
តស្មា ភុសេន ទណ្ឌេន
ធីរោ ពាលំ និសេធយេតិ ។

ភាសិតាយ ខោ បន ភិក្ខវេ វេបចិត្តិនា អសុរិន្ទេន គាថាយ អសុរា អនុមោទឹសុ ទេវា តុណ្ហី អហេសុំ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ សក្កំ ទេវានមិន្ទំ ឯតទវោច ភណ ទេវានមិន្ទ គាថន្តិ ។

ពួកទេវតានិងពួកអសុរ បានតាំងពួកបរិស័ទ (ជាសាក្សី) ថា ពួកបរិស័ទទាំងនេះ នឹងដឹងច្បាស់ នូវសុភាសិត ឬទុព្ភាសិតរបស់យើង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ វេបចិត្តិអសុរិន្ទ បាននិយាយនឹងសក្កទេវានមិន្ទយ៉ាងនេះថា នែទេវានមិន្ទ ចូលអ្នកពោលគាថានេះចុះ ។ ម្នាលភិក្ខុទាំងឡាយ កាលវេបចិត្តិអសុរិន្ទនិយាយ យ៉ាងនេះហើយ សក្កទេវានមិន្ទបាននិយាយនឹងវេបចិត្តិអសុរិន្ទ យ៉ាងនេះថា នែវេបចិត្តិ ពួកអ្នកជាទេវតា កើតមុនក្នុងឋាននេះ នែវេបចិត្តិ ចូរអ្នកពោលគាថាមុនចុះ ។

[៣៥៨] ម្នាលភិក្ខុទាំងឡាយ កាលបើសក្កទេវានមិន្ទ និយាយយ៉ាងនេះហើយ វេបចិត្តិអសុរិន្ទ បានពោលគាថានេះថា

បើបុគ្គល មិនឃាត់ហាមជនពាលទេ ពួកជនពាល នឹងរឹង
រឹតតែឈ្លានពានឡើង ហេតុនោះ អ្នកប្រាជ្ញត្រូវឃាត់ហាម
ជនពាល ដោយអាជ្ញាដ៏ខ្លាំង ។

ម្នាលភិក្ខុទាំងឡាយ ពួកអសុរ សប្បាយរីករាយនឹងគាថា ដែលវេបចិត្តិអសុរិន្ទបានពោលហើយ តែពួកទេវតានៅស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង វេបចិត្តិអសុរិន្ទ បានពោល នឹងសក្កទេវានមិន្ទយ៉ាងនេះថា នែទេវានមិន្ទ អ្នកឯងចូរពោលគាថាចុះ ។

[៣៤៩] ឯវំ វុត្តេ ភិក្ខវេ សក្កោ ទេវានមិន្ទោ ឥមំ គាថំ អភាសិ

ឯតទេវ អហំ មញ្ញេ
ពាលស្ស បដិសេធនំ
បរំ សង្កុបិតំ ញត្វា
យោ សតោ ឧបសម្មតីតិ ។

ភាសិតាយ ខោ បន ភិក្ខវេ សក្កេន ទេវានមិន្ទេន គាថាយ ទេវា អនុមោទឹសុ អសុរា តុណ្ហី អហេសុំ ។ អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ វេបចិត្តឹ អសុរិន្ទំ ឯតទវោច ភណ វេបចិត្តិ គាថន្តិ ។

[៣៦០] ឯវំ វុត្តេ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ ឥមំ គាថំ អភាសិ

[៣៥៩] ម្នាលភិក្ខុទាំងឡាយ កាលបើវេបចិត្តិអសុរិន្ទ និយាយយ៉ាងនេះហើយ សក្កទេវានមិន្ទ បានពោលគាថានេះថា

អ្នកណាមានស្មារតី ដឹងថា អ្នកដទៃក្រោធ ហើយទ្រាំអត់បាន
ខ្ញុំសម្គាល់អ្នកនុ៎ះឯង ថាជាអ្នកឃាត់ហាមបុគ្គលពាល ។

ម្នាលភិក្ខុទាំងឡាយ ពួកទេវតា សប្បាយរីករាយនឹងគាថា ដែលសក្កទេវានមិន្ទពោលហើយ តែពួកអសុរនៅស្ងៀម ។ ម្នាលភិក្ខុទាំង-ឡាយ គ្រានោះឯង សក្កទេវានមិន្ទ បានពោលនឹងវេបចិត្តិអសុរិន្ទយ៉ាងនេះថា ម្នាលវេបចិត្តិ អ្នកចូរពោលគាថាចុះ ។

[៣៦០] ម្នាលភិក្ខុទាំងឡាយ កាលបើសក្កទេវានមិន្ទ និយាយយ៉ាងនេះហើយ វេបចិត្តិអសុរិន្ទ បានពោលគាថានេះថា

ឯតទេវ   តិតិក្ខាយ
វជ្ជំ   បស្សាមិ   វាសវ
យទា   នំ   មញ្ញតិ   ពាលោ
ភយា   ម្យាយំ   តិតិក្ខតិ
អជ្ឈារូហតិ   ទុម្មេធោ
គោវ   ភិយ្យោ   បលាយិនន្តិ ។

ភាសិតាយ ខោ បន ភិក្ខវេ វេបចិត្តិនា អសុរិន្ទេន គាថាយ អសុរា អនុមោទឹសុ ទេវា តុណ្ហី អហេសុំ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ សក្កំ ទេវានមិន្ទំ ឯតទវោច ភណ ទេវានមិន្ទ គាថន្តិ ។

[៣៦១] ឯវំ វុត្តេ ភិក្ខវេ សក្កោ ទេវានមិន្ទោ ឥមា គាថាយោ អភាសិ

កាមំ   មញ្ញតុ   វា   មា   វា
ភយា   ម្យាយំ   តិតិក្ខតិ
សទត្ថបរមា   អត្ថា
ខន្ត្យា   ភិយ្យោ   ន   វិជ្ជតិ
យោ   ហវេ   ពលវា   សន្តោ

នៃវាសវៈ ខ្ញុំយល់ឃើញថា សេចក្តីអត់ធន់នុ៎ះឯង ជាទោស
វិញទេ ដ្បិតបុគ្គលពាល តែងសម្គាល់អ្នកអត់ធន់នោះថា
អ្នកនេះអត់ធន់ព្រោះតែខ្លាចអញ ហេតុនោះ បានជាបុគ្គល
ឥតប្រាជ្ញា រឹងរឹតតែសង្កត់សង្កិនគេ ដូចជាគោព្រួតសង្កត់
សង្កិនគោ ដែលចាញ់បោលទៅ ។

ម្នាលភិក្ខុទាំងឡាយ ពួកអសុរ សប្បាយរីករាយ នឹងគាថា ដែលវេបចិត្តិអសុរិន្ទពោលហើយ តែពួកទេវតានៅស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង វេបចិត្តិអសុរិន្ទបានពោល នឹងសក្កទេវានមិន្ទយ៉ាងនេះថា នៃទេវានមិន្ទ អ្នកចូរពោលគាថាចុះ ។

[៣៦១] ម្នាលភិក្ខុទាំងឡាយ កាលបើវេបចិត្តិអសុរិន្ទ និយាយយ៉ាងនេះហើយ សក្កទេវានមិន្ទ បានពោលគាថាទាំងឡាយនេះថា

បុគ្គលពាលចង់សម្គាល់ក្តី មិនសម្គាល់ក្តីថា អ្នកនេះអត់ធន់
ព្រោះតែខ្លាចអញ ក៏តាមការណ៍ចុះ តែថាប្រយោជន៍ទាំង-
ឡាយ មានប្រយោជន៍ខ្លួនជាសំខាន់ ប្រយោជន៍អ្វីឲ្យក្រៃ-
លែងជាងខន្តិមិនមានទេ ជនណាមានកម្លាំង ជាអ្នកស្ងប់

ទុព្វលស្ស តិតិក្ខតិ

តមាហុ បរមំ ខន្តឹ

និច្ចំ ខមតិ ទុព្វលោ

អពលន្តំ ពលំ អាហុ

យស្ស ពាលពលំ ពលំ

ពលវស្ស ធម្មគុត្តស្ស

បដិវត្តា ន វិជ្ជតិ

តស្សេវ តេន បាបិយោ

យោ កុទ្ធំ បដិកុជ្ឈតិ

កុទ្ធំ អប្បដិកុជ្ឈន្តោ

សង្គាមំ ជេតិ ទុជ្ជយំ

ហើយអត់ឱន ចំពោះបុគ្គលមានកម្លាំងខ្សោយ បណ្ឌិតទាំង-ឡាយ សរសើរជននោះ ថាជាអ្នកមានសេចក្តីអត់ទ្រាំដ៏ក្រៃលែង ព្រោះថា បុគ្គលមានកម្លាំងថយ តែងអត់សង្កត់ជានិច្ច កម្លាំងរបស់ជនណា ជាកម្លាំងពាល បណ្ឌិតទាំងឡាយ ពោលសំដៅកម្លាំងជននោះថា មិនមែនជាក-ម្លាំងទេ ជនអ្នកតិះដៀល ចំពោះបុគ្គលអ្នកមានកម្លាំងជាអ្នកមានធម៌គ្រប់គ្រង មិនមានទេ អ្នកណាខឹងតបនឹងបុគ្គលអ្នកខឹង សេចក្តីអាក្រក់ រមែងមានដល់អ្នកនោះឯងព្រោះសេចក្តីខឹងតបនោះ ឯបុគ្គលអ្នកមិនខឹងតបនឹងបុគ្គលអ្នកខឹង ឈ្មោះថាឈ្នះសង្គ្រាម ដែលឈ្នះបានដោយកម្រ

ឧភិន្នមត្ថំ ចរតិ
អត្តនោ ច បរស្ស ច
បរំ សង្កុបិតំ ញត្វា
យោ សតោ ឧបសម្មតិ
ឧភិន្នំ តិកិច្ឆន្តានំ
អត្តនោ ច បរស្ស ច
ជនា មញ្ញន្តិ ពាលោតិ
យេ ធម្មស្ស អកោវិទាតិ ។

ភាសិតាសុ ខោ បន ភិក្ខវេ សក្កេន ទេវានមិន្ទេន គាថាសុ ទេវា អនុមោទឹសុ អសុរា តុណ្ហី អហេសុំ ។

[៣៦២] អថខោ ភិក្ខវេ ទេវានញ្ច អសុរានញ្ច ចារិសជ្ជា ឯតទវោចុំ ភាសិតា ខោ វេបចិត្តិនា អសុរិន្ទេន គាថាយោ តា ច ខោ សទណ្ឌាវចរា សសត្ថាវចរា ឥតិ ភណ្ឌនំ ឥតិ វិគ្គហោ ឥតិ កលហោ ភាសិតា ខោ សក្កេន ទេវានមិន្ទេន គាថាយោ

បុគ្គលណាមានស្មារតី ដឹងថា បុគ្គលដទៃខឹង ហើយទ្រាំអត់បាន (បុគ្គលនោះ) ឈ្មោះថាប្រព្រឹត្តនូវប្រយោជន៍ដល់ជនទាំងពីរខាង គឺខ្លួនឯង ១ អ្នកដទៃ ១ កាលជនទាំងពីរខាង គឺខ្លួនឯងនិងអ្នកដទៃ កំពុងសះជានឹងគ្នា ពួកជនណាសម្គាល់ថាគេល្ងង់ (ពួកជននោះ) ឈ្មោះថាមិនយល់ធម៌ច្បាស់ទេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើសក្កទេវានមិន្ទ ពោលគាថាទាំងឡាយហើយ ពួកទេវតាក៏អនុមោទនា តែពួកអសុរនៅស្ងៀម ។

[៣៦២] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ពួកបរិស័ទរបស់ទេវតានិងអសុរបាននិយាយគ្នា យ៉ាងនេះថា គាថាទាំងឡាយ ដែលវេបចិត្តិអសុរិន្ទពោលហើយ គាថាទាំងនោះ សុទ្ធតែប្រកបដោយការធ្លាក់ចុះក្នុងអាជ្ញា ប្រកបដោយការធ្លាក់ចុះក្នុងសស្ត្រា ឯសេចក្តីប្រកួតប្រកាន់ ក៏ព្រោះហេតុនេះ សេចក្តីទាស់ទែងក៏ព្រោះហេតុនេះ ការឈ្លោះក៏ព្រោះហេតុនេះ ចំណែកគាថាទាំងឡាយ ដែលសក្កទេវានមិន្ទពោលហើយនោះឯង

តា ច ខោ អចណ្ឌាវចា អសត្ថាវចា ឥតិ អ-
កណ្ឌានំ ឥតិ អវិគ្គហោ ឥតិ អកាលហោ សក្កស្ស
ទេវានមិន្ទស្ស សុភាសិតេន ជយោតិ ។ ឥតិ ខោ
ភិក្ខវេ សក្កស្ស ទេវានមិន្ទស្ស សុភាសិតេន ជយោ
អហោសិ ។

## ឆដ្ឋំ កុលាវកសុត្តំ

[៣៦៣] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ ទេវា-
សុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ ។ តស្មឹ ខោ បន
ភិក្ខវេ សង្គាមេ អសុរា ជិនឹសុ ទេវា បរាជិនឹសុ ។
បរាជិតា ច ខោ ភិក្ខវេ ទេវា អបាយំស្វេវ ឧត្តរេន
មុខា អភិយំស្វេវ នេ អសុរា ។

[៣៦៤] អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ
មាតលឹ សង្គាហកំ គាថាយ អជ្ឈភាសិ

ជាគាថា មិនធ្លាក់ក្នុងអាជ្ញា មិនធ្លាក់ចុះក្នុងសស្ត្រា ឯការមិនប្រកួតប្រកាន់ក៏ព្រោះហេតុនេះ ការមិនទាស់ទែងក៏ព្រោះហេតុនេះ ការមិនឈ្លោះក៏ព្រោះហេតុនេះ សក្កទេវានមិន្ទ មានជ័យជំនះ ដោយសារសុភាសិត ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ មានជ័យជំនះ ដោយសារសុភាសិតដូច្នេះឯង ។

## កុលាវកសូត្រ ទី ៦

[៣៦៣] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា សង្គ្រាមនៃទេវតានិងអសុរ បានប្រទល់គ្នាហើយ ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសង្គ្រាមនោះឯង ពួកអសុរមានជ័យជំនះ ពួកទេវតាបរាជ័យ ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាចាញ់ហើយរត់ឈមមុខទៅទិសខាងជើង ពួកអសុរក៏ដេញតាមពួកទេវតានោះៗ ។

[៣៦៤] ម្នាលភិក្ខុទាំងឡាយ គ្រានោះ សក្កទេវានមិន្ទ បាននិយាយនឹងមាតលិសង្គាហកទេវបុត្ត ដោយគាថា ថា

២៦១

សក្កសំយុត្តស្ស កុលាវកសុត្តេ អសុរបរិវិតក្កនំ

កុលាវកា មាតលិ សិម្ពលិស្មឹ
ឦសាមុខេន បរិវជ្ជយស្សុ
កាមំ ចជាម អសុរេសុ បាណំ
មា យិមេ ទិជា វិកុលាវា[១] អហេសុន្តិ ។

ឯវំ ភទន្តវាតិ ខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា សហស្សយុត្តំ អាជញ្ញរថំ បច្ចុទាវត្តេសិ ។

[៣៦៨] អថខោ ភិក្ខវេ អសុរានំ ឯតទហោសិ បច្ចុទាវត្តោ ខោទានិ សក្កស្ស ទេវានមិន្ទស្ស សហស្សយុត្តោ អាជញ្ញរថោ ទុតិយម្បិ ខោ ទេវា អសុរេហិ សង្គាមេស្សន្តីតិ ។ អសុរា ភីតា អសុរបុរមេវ បាវិសឹសុ ។ ឥតិ ខោ ភិក្ខវេ សក្កស្ស ទេវានមិន្ទស្ស ធម្មេនេវ ជយោ អហោសីតិ ។

១ ឱ. វិកុលាវកា ។

ម្នាលមាតលិ សម្បុក (នៃពួកគ្រុឌ) នៅលើដើមរកា អ្នកចូរបំបែរមុខចន្ទោលរថចេញ ពួកយើងស៊ូលះជីវិត ចំពោះពួកអសុរដោយពិតចុះ កុំឲ្យតែពួកគ្រុឌទាំងនេះ ខ្វាត់ខ្វាយពីសម្បុកឡើយ ។

ម្នាលភិក្ខុទាំងឡាយ មាតលិសង្គាហកទេវបុត្ត បានទទួលព្រះបន្ទូលសក្កទេវានមិន្ទថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះហើយ ក៏ញាក់ត្រឡប់រថអាជានេយ្យ ដែលទឹមដោយសេះមួយពាន់ ។

[៣៦៥] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកអសុរត្រិះរិះយ៉ាងនេះថា ឥឡូវនេះ សក្កទេវានមិន្ទបត់រថអាជានេយ្យ ដែលទឹមដោយសេះមួយពាន់មកវិញហើយ ពួកទេវតានឹងតតាំងដោយពួកអសុរ ក្នុងលើកទី ២ ទៀត ។ ពួកអសុរក៏ភិតភ័យ រត់ទៅកាន់អសុរបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ បានជ័យជំនះនេះដោយធម៌ ដូច្នេះឯង ។

# សត្តមំ នន្ទិយសុត្តំ

[៣៦៦] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ សក្កស្ស ទេវានមិន្ទស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យោបិ មេ អស្ស បច្ចត្ថិកោ តស្សបាហំ ន ទុព្ភេយ្យន្តិ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ សក្កស្ស ទេវានមិន្ទស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ យេន សក្កោ ទេវានមិន្ទោ តេនុបសង្កមិ ។

[៣៦៧] អទ្ទសា ខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ វេបចិត្តឹ អសុរិន្ទំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន វេបចិត្តឹ អសុរិន្ទំ ឯតទវោច តិដ្ឋ វេបចិត្តិ គហិតោសីតិ ។ យទេវ តេ មារិស បុព្វេ ចិត្តំ តទេវ ត្វំ មារិស ជហាសីតិ ។ សបស្សុ ច មេ វេបចិត្តិ អទុព្ភាយាតិ ។

# នទុព្ភិយសូត្រ ទី ៧

[៣៦៦] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា សក្កទេវានមិន្ទទៅរកទីស្ងាត់ ពួនសម្ងំ ហើយកើតសេចក្តីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា បុគ្គលណាជាសត្រូវនឹងអាត្មាអញ អាត្មាអញ មិនត្រូវប្រទូស្តដល់សត្រូវនោះទេ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង វេបចិត្តិអសុរិន្ទដឹងនូវការត្រិះរិះ ក្នុងចិត្តរបស់សក្កទេវានមិន្ទដោយចិត្តហើយ ក៏ចូលទៅរកសក្កទេវានមិន្ទ ។

[៣៦៧] ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ បានឃើញវេបចិត្តិអសុរិន្ទ កំពុងតែដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងវេបចិត្តិអសុរិន្ទយ៉ាងនេះថា ម្នាលវេបចិត្តិ អ្នកចូរឈប់ អ្នកឯងត្រូវយើងចាប់ ។ វេបចិត្តិអសុរិន្ទពោលថា បពិត្រលោកអ្នកនិទ៌ុក្ខ ចិត្តណារបស់លោក មានក្នុងកាលមុន បពិត្រលោកអ្នកនិទ៌ុក្ខ លោកលះបង់ នូវចិត្តនោះហើយឬ ។ សក្កទេវរាជត្រាស់ថា ម្នាលវេបចិត្តិ អ្នកឯងចូរស្បថ ដើម្បីកុំឲ្យប្រទូស្តដល់យើងទៀតឡើយ ។

២៦៣



[៣៦៨] យំ មុសា ភណតោ ចាបំ
យំ អរិយូបវាទិនោ
មិត្តទ្ទុ ជា ច យំ ចាបំ
យំ ចាបំ អកតញ្ញុនោ
តមេវ ចាបំ ផុសតុ
យោ តេ ទុត្ថេ សុជម្បតីតិ ។

# អដ្ឋមំ វិរោចនាសុរិន្ទសុត្តំ

[៣៦៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អជាបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា ទិវាវិហារគតោ ហោតិ បដិសល្លីនោ ។ អថខោ សក្កោ ច ទេវានមិន្ទោ វេរោចនោ ច អសុរិន្ទោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា បច្ចេកំ ទ្វារពាហំ និស្សាយ អដ្ឋំសុ ។

[៣៧០] អថខោ វិរោចនោ អសុរិន្ទោ ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

[៣៦៨] បាបណា របស់អ្នកពោល នូវពាក្យមុសាវាទ បាបណា របស់អ្នកតិះដៀលព្រះអរិយៈ បាបណា របស់អ្នកទ្រុស្តមិត្ត បាបណា របស់បុគ្គលអកតញ្ញូ បពិត្រសុជម្បតិ អ្នកណា ប្រទូស្តដល់លោក បាបនោះ ៗ ចូរបានទៅអ្នកនោះវិញចុះ ។

# វិរោចនអសុរិន្ទសូត្រ ទី ៨

[៣៦៩] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់សម្រាកក្នុងវេលាថ្ងៃ ទ្រង់សម្ងំ (ក្នុងសមាបត្តិ) ។ គ្រានោះឯង សក្កទេវានមិន្ទ និងវិរោចនអសុរិន្ទ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរផ្អែកនឹងសន្ទឹកទ្វារម្ខាងម្នាក់ ។

[៣៧០] លំដាប់នោះឯង វិរោចនអសុរិន្ទ បានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា

វាយមេថេវ បុរិសោ
យាវ អត្ថស្ស និប្ផទា
និប្ផន្នសោភនោ អត្ថោ
វេភោចនវចោ ឥទន្តិ ។

[៣៧១] វាយមេថេវ បុរិសោ
យាវ អត្ថស្ស និប្ផទា
និប្ផន្នសោភិនោ អត្ថា
ខន្ត្យា ភិយ្យោ ន វិជ្ជតីតិ ។

[៣៧២] សព្វេ សត្តា អត្ថជាតា
តត្ថ តត្ថ យថារហំ
សំយោគបរមាត្វេវ
សម្ភោគា សព្វចាណិនំ
និប្ផន្នសោភិនោ អត្ថា
វេភោចនវាចា ឥទន្តិ ។

បុគ្គលជាបុរស (កូនប្រុស) ត្រូវតែខំប្រឹងឲ្យទាល់តែសម្រេចប្រយោជន៍ ព្រោះថា បុគ្គលជាបុរសឈ្មោះថាជាប្រយោជន៍សម្រេចល្អហើយ នេះជាពាក្យរបស់វិរោចនអសុរិន្ទ ។

[៣៧១] ព្រះមានព្រះភាគ ត្រាស់ថា បុគ្គលជាបុរសត្រូវតែខំប្រឹងឲ្យទាល់តែសម្រេចប្រយោជន៍ ប្រយោជន៍ទាំង-ឡាយ (របស់បុរស) ឈ្មោះថា សម្រេចល្អហើយ ប៉ុន្តែប្រយោជន៍អ្វី ឲ្យក្រៃលែងជាជាងខន្តិ មិនមានទេ ។

[៣៧២] វិរោចនអសុរិន្ទតបថា ពួកសត្វទាំងអស់ មានប្រយោជន៍សម្រេចហើយ តាមសមគួរដល់ការងារនោះ ៗ គ្រឿងបរិភោគ របស់ពួកសត្វទាំងអស់ មានការផ្សំ ត្រូវទុកជាសំខាន់បំផុត ប្រយោជន៍ទាំងឡាយ (របស់បុរស) ឈ្មោះថាសម្រេចល្អហើយ នេះជាពាក្យរបស់វិរោចនអសុរិន្ទ ។

[៣៧៣] សព្វេ សត្តា អត្ថជាតា
តត្ថ តត្ថ យថារហំ
សំយោគបរមាត្វេវ
សម្ភោគា សព្វចាណិនំ
និប្ពន្ទសោភិនោ អត្ថា
ខណ្ឌ្យា ភិយ្យោ ន វិជ្ជតីតិ ។

## នវមំ អារញ្ញកសុត្តំ

[៣៧៤] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ សម្ពហុលា ឥសយោ សីលវន្តោ កល្យាណធម្មា អរញ្ញាយតនេ បណ្ណកុដីសុ សម្មន្តិ ។ អថខោ ភិក្ខវេ សក្កោ ច ទេវានមិន្ទោ វេបចិត្តិ ច អសុរិន្ទោ យេន តេ ឥសយោ សីលវន្តោ កល្យាណធម្មា តេនុបសង្កមឹសុ ។

[៣៧៣] ព្រះមានព្រះភាគត្រាស់ថា ពួកសត្វទាំង-អស់ មានប្រយោជន៍សម្រេចហើយ តាមសមគួរដល់ការងារនោះ ៗ គ្រឿងបរិភោគរបស់សព្វសត្វ មានការផ្សំ ត្រូវទុកជាសំខាន់បំផុត ប្រយោជន៍ទាំងឡាយ (របស់បុរស) ឈ្មោះថា សម្រេចល្អហើយ ប៉ុន្តែប្រយោជន៍អ្វី ឲ្យក្រៃលែងជាងខន្តិ មិនមានទេ ។

# អារញ្ញកសូត្រ ទី ៩

[៣៧៤] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា ពួកឥសីច្រើនរូប ជាអ្នកមានសីល មានគុណធម៌ល្អ នៅអាស្រ័យក្នុងកុដិ ដែលប្រក់ដោយស្លឹកឈើ ក្នុងដងព្រៃ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវានមិន្ទនិងវេបចិត្តិអសុរិន្ទ ចូលទៅរកពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ ។

[៣៧៥] អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ អជលិយោ ឧចាហនា អារោហិត្វា ខគ្គំ ឱលគ្គេត្វា ឆត្តេន ធារិយមានេន អគ្គទ្វារេន អស្សមំ បវិសិត្វា តេ ឥសយោ សីលវន្តេ កល្យាណធម្មេ អបព្យាម-តោ ករិត្វា អតិក្កមិ ។ អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ អជលិយោ ឧចាហនា ឱរោហិត្វា ខគ្គំ អញ្ញេសំ ទត្វា ឆត្តំ អបនាមេត្វា ទ្វារេនេវ អស្សមំ បវិសិត្វា តេ ឥសយោ សីលវន្តេ កល្យាណធម្មេ អនុវាតំ បញ្ជលិកោ នមស្សមានោ អដ្ឋាសិ ។

[៣៧៦] អថខោ ភិក្ខវេ តេ ឥសយោ សីលវន្តោ កល្យាណធម្មា សក្កំ ទេវានមិន្ទំ គាថាយ អជ្ឈភាសឹសុ

គន្ធោ ឥសីនំ ចិរទក្ខិតានំ[១]
កាយា ចុតោ គច្ឆតិ មាលុតេន
ឥតោ បដិក្កម សហស្សនេត្ត
គន្ធោ ឥសីនំ អសុចិ ទេវរាជាតិ ។

---

១ ឱ. ធិរទិក្ខិតានំ ។

[៣៧៥] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង វេបចិត្តិអសុរិន្ទ ពាក់ស្បែកជើងដ៏ក្រាស់[១] សៀតនូវព្រះខ័ន បាំងឆត្រដើរចូលទៅកាន់អាស្រមតាមទ្វារដ៏ប្រសើរ ដើរក្បែរពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ ចម្ងាយប្រមាណមួយព្យាម ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងសក្កទេវានមិន្ទ ដោះស្បែកជើងដ៏ក្រាស់ ប្រទានព្រះខ័នដល់ពួកទេវតាឯទៀត តែមិនដំឡោះឆត្រ ស្តេចចូលទៅកាន់អាស្រមតាមទ្វារខាង បានឈរផ្ទើអញ្ជលីនមស្ការពួកឥសី អ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ ពីខាងក្រោមខ្យល់ ។

[៣៧៦] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ បានពោលនឹងសក្កទេវានមិន្ទ ដោយគាថា ថា

ក្លិនរបស់ពួកឥសី អ្នកប្រព្រឹត្តនូវវត្តដ៏យូរ រមែងឃ្វាតចេញអំពីកាយផ្សាយទៅតាមខ្យល់ បពិត្រសហស្សនេត្រ សូមព្រះអង្គចៀសចេញពីទីនេះទៅ បពិត្រទេវរាជ ព្រោះក្លិនរបស់ពួកឥសីមិនស្អាតទេ ។

១ ស្បែកជើងដ៏ក្រាស់តាំងពី ៤ ជាន់ឡើងទៅ ។

២៦៧

សក្កសំយុត្តស្ស  សមុទ្ទកសុត្តេ  ភូតបុព្វវត្ថុ

[៣៧៧] គន្ធោ ឥសីនំ ចិរទិក្ខិតានំ
កាយា ចុតោ គច្ឆតិ[១] មាលុតេន
សុចិត្របុប្ផំ សិរស្មឹវ មាលំ
គន្ធំ ឯតំ បដិកង្ខាម ភន្តេ
ន ហេត្ថ ទេវា បដិក្កូលសញ្ញិនោតិ ។

## ទសមំ សមុទ្ទកសុត្តំ

[៣៧៨] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ។ បេ ។

[៣៧៩] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ សម្ពហុលា ឥសយោ សីលវន្តោ កល្យាណធម្មា សមុទ្ទតីរេ បណ្ណកុដីសុ សម្មន្តិ ។ តេន ខោ បន សមយេន ភិក្ខវេ ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ ។ អថខោ ភិក្ខវេ តេសំ ឥសីនំ សីលវន្តានំ កល្យាណធម្មានំ ឯតទហោសិ

១ គច្ឆតូតិ កត្ថចិ ទិស្សតិ ។

[៣៧៧] ក្លិនរបស់ពួកឥសីអ្នកប្រព្រឹត្តវត្ត អស់កាលដ៏យូរ រមែងផុំចេញអំពីកាយ ផ្សាយទៅតាមខ្យល់ (ក៏ពិតមែន) បពិត្រលោកដ៏ចម្រើន តែថាយើងខ្ញុំប្រាថ្នាតែក្លិននុ៎ះ ដូចជាបុគ្គលត្រូវការកម្រងផ្កា ជាផ្កាដ៏វិចិត្រដាក់លើក្បាល ពួកទេវតា មិនសម្គាល់ក្នុងការខ្ពើមរអើម ក្នុងក្លិននេះទេ ។

# សមុទ្ទកសូត្រ ទី ១០

[៣៧៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។

[៣៧៩] ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា ពួកឥសីច្រើនរូប ជាអ្នកមានសីល មានគុណធម៌ដ៏ល្អ នៅអាស្រ័យក្នុងកុដិប្រក់ស្លឹក ទៀបឆ្នេរសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ ក៏សម័យនោះឯង សង្គ្រាមទេវតានិងអសុរប្រទល់គ្នាហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា

ជម្មិកា ខោ ទេវា អជម្មិកា អសុរា សិយាបិ ជំ អសុរតោ ភយំ យន្នូន មយំ សម្ពរំ អសុរិន្ទំ ឧបសង្កមិត្វា អភយទក្ខិណំ យាចេយ្យាមាតិ ។

[៣៨០] អថខោ ភិក្ខវេ តេ ឥសយោ សីលវន្តា កល្យាណធម្មា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ សមុទ្ទតីរេ បណ្ណកុដីសុ អន្តរហិតា សម្ពរស្ស អសុរិន្ទស្ស សម្មុខេ ចាតុរហេសុំ ។ អថខោ ភិក្ខវេ តេ ឥសយោ សីលវន្តោ កល្យាណធម្មា សម្ពរំ អសុរិន្ទំ គាថាយ អជ្ឈភាសឹសុ

ឥសយោ សម្ពរំ បត្តា
យាចន្តិ អភយទក្ខិណំ
កាមំ ករោហិ តេ ទាតុំ
ភយស្ស អភយស្ស វាតិ ។

ពួកទេវតាប្រកបដោយធម៌ ពួកអសុរមិនប្រកបដោយធម៌ទេ ភ័យអំពីពួកអសុរនោះ សមជានឹងមានដល់ពួកយើងជាប្រាកដ បើដូច្នោះ មានតែពួកយើង ត្រូវចូលទៅរកសម្ពរអសុរិន្ទ ហើយសូមនូវអភយទាន ។

[៣៨០] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ ក៏បាត់អំពីកុដិប្រក់ដោយស្លឹកទៀបឆ្នេរនៃសមុទ្រ ទៅប្រាដកក្នុងទីចំពោះមុខសម្ពរអសុរិន្ទ ដូចជាបុរសមានកម្លាំងលានូវដៃដែលបត់ ឬបត់នូវដៃដែលលា ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ទើបពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំង-នោះ បាននិយាយនឹងសម្ពរអសុរិន្ទ ដោយគាថា ថា

លោកអាចឲ្យភ័យក៏បាន ឲ្យអភ័យក៏បាន បានជាពួកឥសី

មកសូមអភយទាន អំពីសំណាក់សម្ពរអសុរិន្ទ ។

២៦៩

សក្កសំយុត្តស្ស សមុទ្ទកសុត្តេ ឥសីសាបវចនំ

[៣៨១] ឥសីនំ អភយំ នត្ថិ
ទុដ្ឋានំ(១) សក្កសេវិនំ
អភយំ យាចមានានំ
ភយមេវ ទទាមិ វោ ។

[៣៨២] អភយំ យាចមានានំ
ភយមេវ ទទាសិ នោ
បដិក្កណ្ហាម តេ ឯកំ(២)
អភយំ(៣) ហោតុ តេ ភយំ
យាទិសំ លភតេ(៤) ពីជំ
តាទិសំ លភតេ(៥) ផលំ
កល្យាណការី កល្យាណំ
បាបការី ច បាបកំ
បវុត្តំ តាត តេ(៦) ពីជំ
ផលំ បច្ចនុភោស្សសីតិ ។

១ ម. រុទ្ធានំ ។ ២ ឱ. ម. ឯតំ ។ ៣ ឱ. ម. អឃយំ ។ ៤ ឱ. ម. វប្បតេ ពីជំ ។ ៥ ហរតេ ផលំ ។ ៦ បវុត្តំ វប្បតេ ពីជំ ។

សក្កសំយុត្ត សមុទ្ទកសូត្រ ពាក្យសម្បថរបស់ពួកឥសី

[៣៨១] សម្ពរអសុរិន្ទតបថា អភ័យមិនមានដល់ពួកឥសី អ្នកកាចអាក្រក់ ជាអ្នកសេពគប់នឹងសក្កទេវរាជ កាលបើពួកឥសីសូមអភ័យ ខ្ញុំត្រឡប់ឲ្យភ័យដល់ពួកលោកវិញ ។

[៣៨២] ពួកឥសីតបថា កាលបើយើងសូមអភ័យ អ្នកបែរជាឲ្យភ័យដល់យើងវិញ យើងទទួលយកអភ័យតែម្យ៉ាងអំពីអ្នក ភ័យចូរមានដល់អ្នកចុះ គេបានពូជបែបណា គេបានផលបែបនោះដែរ អ្នកធ្វើល្អ រមែងបានផលល្អ អ្នកធ្វើអាក្រក់ រមែងបានផលអាក្រក់ ម្នាលអ្នក ពូជដែលអ្នកព្រោះហើយ អ្នកនឹងទទួលផល មិនខានឡើយ ។

អថខោ ភិក្ខវេ តេ ឥសយោ សីលវន្តោ កល្យា-
ណធម្មា សម្ពរំ អសុរិន្ទំ អភិសបេត្វា សេយ្យថាបិ
នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារិតំ
វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ សម្ពរស្ស អសុរិន្ទស្ស
សម្មុខេ អន្តរហិតា សមុទ្ទតីរេ បណ្ណកុដីសុ ចាតុ-
រហោសុំ ។

[៣៨៣] អថខោ ភិក្ខវេ សម្ពរោ អសុរិន្ទោ តេហិ
ឥសីហិ សីលវន្តេហិ កល្យាណធម្មេហិ អភិសបិតោ
រត្តិយា សុទំ តិក្ខត្តុំ ឧព្វិជ្ជតីតិ[១] ។

សុវីរវគ្គោ បឋមោ ។

---

១ ឱ. ឧព្វិជ្ជីតិ ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ បានផ្តាសាសម្ពរអសុរិន្ទហើយ ក៏បាត់អំពីទីចំពោះមុខសម្ពរអសុរិន្ទ មកប្រាកដក្នុងកុដិប្រក់ដោយស្លឹក ទៀបឆ្នេរសមុទ្រវិញ ដូចជាបុរសមានកម្លាំងលាដៃដែលបត់ ឬបត់ដៃដែលលាដូច្នោះឯង ។

[៣៨៣] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សម្ពរអសុរិន្ទត្រូវពួកឥសីអ្នកមានសីល មានគុណធម៌ដ៏ល្អទាំងនោះ បានផ្តាសាហើយ ក៏តែងតែភ្ញាក់ ក្នុងរាត្រី អស់វារៈ ៣ ដង ។

ចប់ សុវីរវគ្គ ទី ១ ។

២៧១

សក្កសំយុត្តស្ស សុវីរសុត្តេ ឧទ្ទានំ

## តស្សុទ្ទានំ

សុវីរំ សុសិមញ្ចេវ
ធជគ្គំ វេបចិត្តិនោ
សុភាសិតំ ជយញ្ចេវ
កុលាវកំ នទុព្ភិយំ
វិរោចនអសុរិន្ទោ
ឥសយោ អរញ្ញកញ្ចេវ
ឥសយោ ច សមុទ្ទកាតិ ។

---

# ឧទ្ទាននៃសុវីរវគ្គនោះ គឺ

*សុវីរសូត្រ ១ សុសិមសូត្រ ១ ធជគ្គសូត្រ ១ វេបចិត្តិសូត្រ ១ សុភាសិតជយសូត្រ ១ កុលាវកសូត្រ ១ នទុព្ភិយសូត្រ ១ វិរោចនអសុរិន្ទសូត្រ ១ ពួកឥសីក្នុងអរញ្ញកសូត្រ ១ ពួកឥសីក្នុងសមុទ្ទកសូត្រ ១ ។*

# ទេវវគ្គោ

## បឋមំ បឋមទេវសុត្តំ

[៣៨៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ។ បេ ។

[៣៨៥] ភគវា ឯតទវោច សក្កស្ស ភិក្ខវេ ទេវានមិន្ទស្ស បុព្វេ មនុស្សភូតស្ស សត្ត វត្តបទានិ សមត្តានិ សមាទិន្នានិ អហេសុំ យេសំ សមាទិន្នត្តា សក្កោ សក្កត្តំ អជ្ឈគា ។ កតមានិ សត្ត ។ យាវជីវំ មាតាបេតិភរោ អស្សំ យាវជីវំ កុលេ ជេដ្ឋាបចាយី អស្សំ យាវជីវំ សណ្ហវាចោ អស្សំ យាវជីវំ អបិសុណវាចោ អស្សំ យាវជីវំ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសេយ្យំ មុត្តចាគោ បយតបាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ យាវជីវំ សច្ចវាចោ

# ទេវវគ្គ

## បឋមទេវសូត្រ ទី ១

[៣៨៤] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។*

[៣៨៥] *ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានសមាទានរក្សាវត្តបទទាំង ៧ ប្រការបរិបូណ៌ ព្រោះតែបានសមាទានវត្តបទទាំង ៧ ប្រការនោះ បានជាសក្កទេវរាជ បានដល់នូវភាពនៃខ្លួនជាសក្កៈ ។ វត្តបទទាំង ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសក្កទេវរាជបានសមាទានថា អាត្មាអញត្រូវជាអ្នកចិញ្ចឹមមាតាបិតា អស់មួយជីវិត ១ ត្រូវគោរពបុគ្គលជាច្បងក្នុងត្រកូល អស់មួយជីវិត ១ ត្រូវមានវាចាល្អិតទន់ អស់មួយជីវិត ១ មិនត្រូវមានវាចាញុះញង់ អស់មួយជីវិត ១ ត្រូវមានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល មានទានបរិច្ចាគហើយ មានដៃលាង (ចាំស្ងួម) ហើយត្រេកអរក្នុងការលះបង់ ជាអ្នកគួរគេសូមបាន ត្រេកអរក្នុងការឲ្យនិងការចែករំលែក នៅគ្រប់គ្រងផ្ទះអស់មួយជីវិត ១ ត្រូវមានសំដីទៀងទាត់*

អស្សំ យាវជីវំ អក្កោធនោ អស្សំ សចេបិ មេ កោធោ ឧប្បជ្ជេយ្យ ខិប្បមេវ នំ បដិវិនេយ្យន្តិ ។ សក្កស្ស ភិក្ខវេ ទេវានមិន្ទស្ស បុព្វេ មនុស្សភូតស្ស ឥមានិ សត្ត វត្តបទានិ សមត្តានិ សមាទិន្នានិ អហេសុំ យេសំ សមាទិន្នត្តា សក្កោ សក្កត្តំ អជ្ឈគាតិ ។

[៣៨៦] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

មាតាបេតិភរំ ជន្តុំ
កុលេ ជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ
បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ
សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតឹសា
អាហុ សប្បុរិសោ ឥតីតិ ។

អស់មួយជីវិត ១ មិនត្រូវមានសេចក្តីក្រោធ បើទុកជាសេចក្តីក្រោធកើតឡើងដល់អាត្មាអញ អាត្មាអញត្រូវតែប្រញាប់បន្ទោបង់ នូវសេចក្តីក្រោធនោះចេញ អស់មួយជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្ស ក្នុងជាតិមុន បានសមាទានវត្តបទទាំង ៧ ប្រការនេះឯងបរិបូណ៌ ព្រោះតែសមាទានវត្តបទទាំង ៧ ប្រការនេះ ទើបសក្កទេវរាជបានដល់នូវភាពនៃខ្លួនជាសក្កៈ ។

[៣៨៦] ព្រះមានព្រះភាគ បានត្រាស់សូត្រនេះហើយ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបត្រាស់គាថាពន្ធនេះតទៅទៀតថា

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា
អ្នកកោតក្រែងបុគ្គលជាច្បង ក្នុងត្រកូល មានវាចាល្អិតទន់
និយាយតែពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកប
ក្នុងការលះបង់សេចក្តីកំណាញ់ មានសំដីទៀងទាត់ ជាជន
គ្របសង្កត់សេចក្តីក្រោធនោះឯង ថា ជាសប្បុរស ។

# ទុតិយំ ទុតិយទេវសុត្តំ

[៣៨៧] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ ។ បេ ។

[៣៨៨] ភគវា ឯតទវោច សក្កោ ភិក្ខវេ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ មឃោ នាម មាណវោ អហោសិ តស្មា មឃវាតិ វុច្ចតិ ។ សក្កោ ភិក្ខវេ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ បុរេ ទានំ អទាសិ តស្មា បុរិន្ទទោតិ វុច្ចតិ ។ សក្កោ ភិក្ខវេ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ សក្កច្ចំ ទានំ អទាសិ តស្មា សក្កោតិ វុច្ចតិ ។ សក្កោ ភិក្ខវេ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ អាវសថំ អទាសិ តស្មា វាសវោតិ វុច្ចតិ ។ សក្កោ ភិក្ខវេ ទេវានមិន្ទោ សហស្សម្បិ អត្ថានំ មុហុត្តេន ចិន្តេតិ តស្មា

# ទុតិយទេវសូត្រ ទី ២

[៣៨៧] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ។ បេ ។

[៣៨៨] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន ជាមាណពឈ្មោះមឃៈ ហេតុនោះ បានជាគេហៅថា មឃវៈ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្ស ក្នុងជាតិមុន បានឲ្យទានមុនគេ ហេតុនោះ បានជាគេហៅថា បុរិន្ទទៈ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានឲ្យទានដោយគោរព ហេតុនោះ បានជាគេហៅថា សក្កៈ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្ស ក្នុងជាតិមុន បានឲ្យទីសម្រាប់សំណាក់ ព្រោះហេតុនោះ បានជាគេហៅថា វាសវៈ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ គិតឃើញហេតុសូម្បីទាំងពាន់ ដោយមួយរំពេចបាន ហេតុនោះ

សហស្សក្ខោតិ វុច្ចតិ ។ សក្កស្ស ភិក្ខវេ ទេវាន-
មិន្ទស្ស សុជា នាម អសុរកញ្ញា បជាបតី[១] តស្មា
សុជម្បតីតិ វុច្ចតិ ។ សក្កោ ភិក្ខវេ ទេវានមិន្ទោ
ទេវានំ តាវតឹសានំ ឥស្សរិយាធិបច្ចំ រជ្ជំ ការេតិ
តស្មា ទេវានមិន្ទោតិ វុច្ចតិ ។

[៣៨៩] សក្កស្ស ភិក្ខវេ ទេវានមិន្ទស្ស បុព្វេ
មនុស្សភូតស្ស សត្ត វត្តបទានិ សមត្តានិ សមាទិន្នានិ
អហេសុំ យេសំ សមាទិន្នត្តា សក្កោ សក្កត្តំ អជ្ឈ-
គា ។ កតមានិ សត្ត ។ យាវជីវំ មាតាបេតិភរោ អស្សំ
យាវជីវំ កុលេ ជេដ្ឋាបចាយី អស្សំ យាវជីវំ សណ្ហវា-
ចោ អស្សំ យាវជីវំ អបិសុណវាចោ អស្សំ យាវជីវំ វិគ-
តមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសេយ្យំ មុត្តចាគោ
បយតចាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភា-
គរតោ យាវជីវំ សច្ចវាចោ អស្សំ យាវជីវំ អក្កោធនោ

---

១ ឱ. បជាបតី អហោសិ ។

បានជាគេហៅថា សហស្សក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ អសុរកញ្ញាឈ្មោះនាងសុជា ជាមហេសីរបស់សក្កទេវានមិន្ទ ហេតុនោះ បានជាគេហៅថា សុជម្បតិ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ បានសោយរាជ្យជាឥស្សរាធិបតី លើពួកទេវតាជាន់តាវត្តិង្ស ហេតុនោះ បានជាគេហៅថា ទេវានមិន្ទ ។

[៣៨៩] ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានសមាទានវត្តបទទាំង ៧ ប្រការបរិបូណ៌ ព្រោះហេតុតែបានសមាទានវត្តបទទាំង ៧ ប្រការនោះ បានជាសក្កទេវរាជមាននាមថា សក្កៈ ។ វត្តបទទាំង ៧ ប្រការ តើដូចម្តេចខ្លះ ។ (សក្កទេវរាជបានសមាទាន) ថា អាត្មាអញត្រូវចិញ្ចឹមមាតាបិតា អស់មួយជីវិត ១ ត្រូវគោរពបុគ្គលជាច្បងក្នុងត្រកូល អស់មួយជីវិត ១ ត្រូវមានពាក្យល្អិតទន់ អស់មួយជីវិត ១ ត្រូវមានវាចាមិនញុះញង់ អស់មួយជីវិត ១ ត្រូវមានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល ជាអ្នកចែករំលែកនូវទាន ជាអ្នកលាងដៃដើម្បីឲ្យទាន ជាអ្នកត្រេកអរក្នុងការលះបង់ ជាអ្នកគួរគេសូមទានបាន ត្រេកអរ ក្នុងការឲ្យនិងការចែករំលែក ហើយនៅគ្រប់គ្រងផ្ទះ អស់មួយជីវិត ១ ត្រូវមានវាចាទៀងទាត់ អស់មួយជីវិត ១ មិនត្រូវមានសេចក្តីក្រោធ

អស្សំ សចេបិ មេ កោធោ ឧប្បជ្ជេយ្យ ខិប្បមេវ នំ បដិវិនេយ្យន្តិ ។ សក្កស្ស ភិក្ខវេ ទេវានមិន្ទស្ស បុព្វេ មនុស្សភូតស្ស ឥមានិ សត្ត វត្តបទានិ សមត្តានិ សមាទិន្នានិ អហេសុំ យេសំ សមាទិន្នត្តា សក្កោ សក្កត្តំ អជ្ឈគាតិ ។

[៣៩០] ឥធមវោច ។ បេ ។

មាតាបេតិភរំ ជន្តុំ
កុលេ ជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ
បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ
សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតឹសា
អាហុ សប្បុរិសោ ឥតីតិ ។

បើទុកជាសេចក្តីក្រោធកើតឡើង ដល់អាត្មាអញ ត្រូវតែអាត្មាអញបន្ទោ-បង់សេចក្តីក្រោធនោះមួយរំពេច អស់មួយជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ កាលកើតជាមនុស្ស ក្នុងជាតិមុន បានសមាទានវត្តបទ ទាំង ៧ ប្រការនេះបរិបូណ៌ ព្រោះហេតុតែបានសមាទានវត្តបទទាំង ៧ ប្រការនោះ ទើបសក្កទេវរាជ បានដល់នូវភាពនៃខ្លួនជាសក្កៈ ។

[៣៩០] ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះហើយ ។ បេ ។

ពួកទេវតានៅឋានតាវត្តិង្ស បានហៅបុគ្គលអ្នកចិញ្ចឹមមាតាបិតា
អ្នកកោតក្រែង ចំពោះបុគ្គលជាច្បង ក្នុងត្រកូល មានវាចា
ល្អិតទន់ និយាយពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់
ប្រកបតែក្នុងការកម្ចាត់បង់សេចក្តីកំណាញ់ មានសំដីទៀង
ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯងថា ជាសប្បុរស ។

# តតិយំ  តតិយទេវសុត្តំ

[៣៩១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ មហាលី លិច្ឆវី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហាលី លិច្ឆវី ភគវន្តំ ឯតទវោច ទិដ្ឋោ វោ[១] ភន្តេ សក្កោ ទេវានមិន្ទោតិ ។ ទិដ្ឋោ ខោ មេ មហាលិ សក្កោ ទេវានមិន្ទោតិ ។ សោ ហិ នូន ភន្តេ សក្កប្បដិរូបកោ ភវិស្សតិ ទុទ្ទសោ ហិ ភន្តេ សក្កោ ទេវានមិន្ទោតិ ។

[៣៩២] សក្កញ្ចាហំ មហាលិ បជានាមិ សក្ក-ករណេ ច ធម្មេ យេសញ្ច ធម្មានំ សមាទិន្នត្តា សក្កោ សក្កត្តំ អជ្ឈគា តញ្ច បជានាមិ ។ សក្កោ មហាលិ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ មឃោ នាម មាណវោ អហោសិ តស្មា

១ ឱ. ទិដ្ឋោ នោ ។

# តតិយទេវសូត្រ ទី ៣

[៣៩១] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងកូដាគារសាលា ក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ លំដាប់នោះឯង ស្តេចលិច្ឆវី ព្រះនាមមហាលី បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះស្តេចលិច្ឆវីព្រះនាមមហាលីគង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់បានឃើញសក្កទេវានមិន្ទដែរឬ ។ បពិត្រមហាលី តថាគត បានឃើញសក្កទេវានមិន្ទដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្រែងសក្កទេវានមិន្ទ គ្រាន់តែជារូបប្រៀបរបស់សក្កៈទេដឹង បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា សក្កទេវានមិន្ទ គេមិនងាយនឹងឃើញទេ ។

[៣៩២] ព្រះមានព្រះភាគត្រាស់ថា បពិត្រមហាលី តថាគតស្គាល់ច្បាស់នូវសក្កទេវរាជផង នូវធម៌ធ្វើសត្វឲ្យបានជាសក្កៈផង មួយទៀត សក្កទេវរាជ បានដល់នូវភាវៈនៃខ្លួនជាសក្កៈ ព្រោះតែសមាទានធម៌ណា តថាគត ក៏ដឹងច្បាស់ធម៌នោះផង ។ បពិត្រមហាលី សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន ជាមាណពឈ្មោះមឃៈ ហេតុនោះ

មឃវាតិ វុច្ចតិ ។ សក្កោ មហាលិ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ បុរេ ទានំ អទាសិ តស្មា បុរិន្ទទោតិ វុច្ចតិ ។ សក្កោ មហាលិ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ សក្កច្ចំ ទានំ អទាសិ តស្មា សក្កោតិ វុច្ចតិ ។ សក្កោ មហាលិ ទេវានមិន្ទោ បុព្វេ មនុស្សភូតោ សមានោ អាវសថំ អទាសិ តស្មា វាសវោតិ វុច្ចតិ ។ សក្កោ មហាលិ ទេវានមិន្ទោ សហស្សម្បិ អត្ថានំ មុហុត្តេន ចិន្តេតិ តស្មា ស-ហស្សក្ខោតិ វុច្ចតិ ។ សក្កស្ស មហាលិ ទេវានមិន្ទស្ស សុជា នាម អសុរកញ្ញា បជាបតី តស្មា សុជម្បតីតិ វុច្ចតិ ។ សក្កោ មហាលិ ទេវានមិន្ទោ ទេវានំ តាវត្តឹសានំ ឥស្សរិយាធិបច្ចំ រជ្ជំ ការេតិ តស្មា ទេវានមិន្ទោតិ វុច្ចតិ ។

[៣៩៣] សក្កស្ស មហាលិ ទេវានមិន្ទស្ស បុព្វេ មនុស្សភូតស្ស សត្ត វតបទានិ សមត្តានិ សមាទិន្នានិ អហេសុំ យេសំ សមាទិន្នត្តា សក្កោ

បានជាគេហៅថា មឃវៈ ។ បពិត្រមហាលី សក្កទេវានមិន្ទ កាលកើត ជាមនុស្សក្នុងជាតិមុន បានឲ្យទានមុនគេ ហេតុនោះ បានជាគេហៅថា បុរិន្ទទៈ ។ បពិត្រមហាលី សក្កទេវានមិន្ទ កាលកើតជាមនុស្ស ក្នុងជាតិមុន បានឲ្យទានដោយគោរព ហេតុនោះ បានជាគេហៅថា សក្កៈ ។ បពិត្រមហាលី សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានឲ្យទីសម្រាប់សំណាក់ ហេតុនោះ បានជាគេហៅថា វាសវៈ ។ បពិត្រមហាលី សក្កទេវានមិន្ទ គិតឃើញហេតុ សូម្បីទាំងពាន់ ដោយមួយរំពេចបាន ហេតុនោះ បានជាគេហៅថា សហស្សក្ខៈ ។ បពិត្រមហាលី អសុរកញ្ញាឈ្មោះនាងសុជា ជាមហេសីនៃសក្កទេវានមិន្ទ ហេតុនោះ បានជាគេហៅថា សុជម្បតិ ។ បពិត្រមហាលី សក្កទេវានមិន្ទ សោយរាជ្យជាឥស្សរាធិបតីលើពួកទេវតាជាន់តាវត្តិង្ស ហេតុនោះ បានជាគេហៅថា ទេវានមិន្ទ ។

[៣៩៣] បពិត្រមហាលី សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានសមាទានវត្តបទទាំង ៧ ប្រការដ៏បរិបូណ៌ ព្រោះហេតុតែសមាទានវត្តបទទាំង ៧ ប្រការនេះ បានជាសក្កទេវរាជ

សក្កត្តំ អជ្ឈគា ។ កតមានិ សត្ត ។ យាវជីវំ មាតាបេតិភរោ អស្សំ យាវជីវំ កុលេ ជេដ្ឋាបចាយី អស្សំ យាវជីវំ សណ្ហវាចោ អស្សំ យាវជីវំ អបិ-សុណវាចោ អស្សំ យាវជីវំ វិគតមលមច្ឆេរេន ចេត-សា អគារំ អជ្ឈាវសេយ្យំ មុត្តចាគោ បយតចាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ យាវជីវំ សច្ចវាចោ អស្សំ យាវជីវំ អក្កោធនោ អស្សំ សចេបិ មេ កោធោ ឧប្បជ្ជេយ្យ ខិប្បមេវ នំ បដិវិ-នេយ្យន្តិ ។ សក្កស្ស មហាលិ ទេវានមិន្ទស្ស បុព្វេ មនុស្សភូតស្ស ឥមានិ សត្ត វត្តបទានិ សមត្តានិ សមាទិន្នានិ អហេសុំ យេសំ សមាទិន្នត្តា សក្កោ សក្កត្តំ អជ្ឈគាតិ ។

បានដល់នូវភាវៈនៃខ្លួនជាសក្កៈ ។ វត្តបទទាំង ៧ នោះ តើដូចម្ដេច ។ (សក្កទេវរាជ បានសមាទាន) ថា អាត្មាអញ ត្រូវចិញ្ចឹមមាតាបិតា អស់មួយជីវិត ១ ត្រូវកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល អស់មួយជីវិត ១ ត្រូវមានវាចាល្អិតទន់ អស់មួយជីវិត ១ មិនត្រូវមានវាចាញុះញង់ អស់មួយជីវិត ១ ត្រូវមានចិត្តប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល ជាអ្នកមានការបរិច្ចាគរួសរាន់ មានដៃលាងហើយដើម្បីនឹងឲ្យនូវទាន ត្រេកអរក្នុងការលះបង់ ជាអ្នកគួរគេសូមទានបាន ត្រេកអរក្នុងការឲ្យ និងការចែករំលែកទាន ហើយនៅគ្រប់គ្រងផ្ទះ អស់មួយជីវិត ១ ត្រូវមានវាចាទៀងទាត់ អស់មួយជីវិត ១ មិនត្រូវមានសេចក្ដីក្រោធ បើទុកជាសេចក្ដីក្រោធ កើតឡើងដល់អាត្មាអញ អាត្មាអញត្រូវបន្ទោបង់ នូវសេចក្ដីក្រោធនោះមួយរំពេច អស់មួយជីវិត ១ ។ បពិត្រមហាលិ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានសមាទានវត្តបទទាំង ៧ ប្រការនេះបរិបូណ៌ ព្រោះហេតុតែសមាទានវត្តបទទាំង ៧ ប្រការ នេះ ទើបសក្កទេវរាជ បានដល់នូវភាពនៃខ្លួនជាសក្កៈ ។

[៣៩៦] ឥទមវោច ។ បេ ។
មាតាបេតិភរំ ជន្តុំ
កុលេ ជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ
បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ
សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតឹសា
អាហុ សប្បុរិសោ ឥតីតិ ។

# ចតុត្ថំ ទឡិទ្ទសុត្តំ

[៣៩៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៣៩៤] ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ។ បេ ។ ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា គោរពកោតក្រែងបុគ្គលជាច្បង ក្នុងត្រកូល មានវាចាល្អិត ទន់ និយាយសំដីផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកប តែក្នុងការកម្ចាត់បង់សេចក្តីកំណាញ់ មានវាចាទៀងទាត់ ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯង ថាជាសប្បុរស ។

## ទឡិទ្ទសូត្រ ទី ៤

[៣៩៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុង វត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៣៩៦] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ អញ្ញតរោ បុរិសោ ឥមស្មឹយេវ រាជគហេ មនុស្ស-ទលិទ្ទោ អហោសិ មនុស្សកបណោ មនុស្សវរាកោ ។ សោ តថាគតប្បវេទិតេ ធម្មវិនយេ សទ្ធំ សមាទិយិ សីលំ សមាទិយិ សុតំ សមាទិយិ ចាគំ សមាទិយិ បញ្ញំ សមាទិយិ ។ សោ តថាគតប្បវេទិតេ ធម្មវិនយេ សទ្ធំ សមាទិយិត្វា សីលំ សមាទិយិត្វា សុតំ សមាទិយិត្វា ចាគំ សមាទិយិត្វា បញ្ញំ សមាទិយិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិ ទេវានំ តាវត្តឹសានំ សហព្យតំ ។ សោ អញ្ញេ ទេវេ អតិរោចតិ វណ្ណេន ចេវ យសសា ច ។

[៣៩៧] តត្រ សុទំ ភិក្ខវេ ទេវា តាវត្តឹសា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ អយំ ហិ ទេវបុត្តោ បុព្វេ មនុស្សភូតោ សមានោ មនុស្សទលិទ្ទោ អហោសិ មនុស្សកបណោ មនុស្ស-វរាកោ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នោ ទេវានំ តាវត្តឹសានំ សហព្យតំ

[៣៩៦] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានបុរសម្នាក់ នៅក្នុងក្រុងរាជគ្រឹះនេះឯង ជាមនុស្សកំសត់ មនុស្សកំព្រា ជាមនុស្សថោកទាប ។ បុរសនោះបានសមាទានសទ្ធា សមាទានសីលៈ សមាទានសុតៈ សមាទានចាគៈ សមាទានបញ្ញា ក្នុងធម៌វិន័យ ដែលព្រះតថាគតបានសំដែងហើយ ។ លុះបុរសនោះ សមាទានសទ្ធា សមាទានសីលៈ សមាទានសុតៈ សមាទានចាគៈ សមាទានបញ្ញា ក្នុងធម៌វិន័យ ដែលព្រះតថាគតសំដែងហើយ បែកធ្លាយរាង្គកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ទេវបុត្រនោះ មានសម្បុរនិងយសរុងរឿងលើស ជាងពួកទេវតាដទៃ ។

[៣៩៧] ម្នាលភិក្ខុទាំងឡាយ បានឮមកក្នុងរឿងនោះថា ពួកទេវតាជាន់តាវត្តិង្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា អស្ចារ្យណាស់ហ្ន៎ ចំឡែកណាស់ហ្ន៎ ព្រោះថា ទេវបុត្តនេះ កាលកើតជាមនុស្ស ក្នុងជាតិមុន ជាមនុស្សកំសត់ ជាមនុស្សកំព្រា ជាមនុស្សថោកទាបសោះ បុរសនោះ លុះបែកធ្លាយរាង្គកាយស្លាប់ទៅ បានមកកើតក្នុងសុគតិ សួគ៌ ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស

សោ អញ្ញេ ទេវេ អតិរោចតិ វណ្ណេន ចេវ យ-
សសា ចាតិ ។ អថខោ ភិក្ខវេ សក្កោ ទេវាន-
មិន្ទោ ទេវេ តាវត្តឹសេ អាមន្តេសិ មា ខោ តុម្ហេ
មារិសា ឯតស្ស ទេវបុត្តស្ស ឧជ្ឈាយិត្ថ ឯសោ
ខោ មារិសា ទេវបុត្តោ បុព្វេ មនុស្សភូតោ សមានោ
តថាគតប្បវេទិតេ ធម្មវិនយេ សទ្ធំ សមាទិយិ សីលំ
សមាទិយិ សុតំ សមាទិយិ ចាគំ សមាទិយិ បញ្ញំ
សមាទិយិ សោ តថាគតប្បវេទិតេ ធម្មវិនយេ សទ្ធំ
សមាទិយិត្វា សីលំ សមាទិយិត្វា សុតំ សមាទិ-
យិត្វា ចាគំ សមាទិយិត្វា បញ្ញំ សមាទិយិត្វា
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបន្នោ ទេវានំ តាវត្តឹសានំ សហព្យតំ សោ អញ្ញេ
ទេវេ អតិរោចតិ វណ្ណេន ចេវ យសសា ចាតិ ។

[៣៩៨] អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ
ទេវេ តាវត្តឹសេ អនុនយមានោ តាយំ វេលាយំ ឥមា
គាថាយោ អភាសិ

ទេវបុត្តនោះ មានសម្បុរនិងយសរុងរឿង លើសទេវតាដទៃ ។ ម្នាល ភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវានមិន្ទ បានហៅពួកទេវតាជាន់តាវត្តិង្សមកថា ម្នាលពួកអ្នកនិទ៌ុក្ខ អ្នកទាំងឡាយ កុំពោលទោសទេវ-បុត្តនុ៎ះឡើយ ម្នាលពួកអ្នកនិទ៌ុក្ខ ទេវបុត្តនុ៎ះ កាលកើតជាមនុស្ស បាន សមាទានសទ្ធា សមាទានសីលៈ សមាទានសុតៈ សមាទានចាគៈ សមាទានបញ្ញា ក្នុងធម៌វិន័យ ដែលព្រះតថាគតសំដែងហើយ លុះ ទេវបុត្តនោះ បានសមាទានសទ្ធា សមាទានសីលៈ សមាទានសុតៈ សមាទានចាគៈ សមាទានបញ្ញា ក្នុងធម៌វិន័យ ដែលព្រះតថាគតសំដែង ហើយ បែកធ្លាយរាងកាយស្លាប់ទៅ បានមកកើតក្នុងសុគតិ សួគ៌ ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស បានជាទេវបុត្តនោះ មានសម្បុរនិងយសរុងរឿង ជាងពួកទេវតាឯទៀត ។

[៣៩៨] ម្នាលភិក្ខុទាំងឡាយ កាលដែលសក្កទេវានមិន្ទ ពន្យល់ពួកទេវតាជាន់តាវត្តិង្សហើយ បានពោលគាថាទាំងឡាយនេះ ក្នុងវេលានោះថា

យស្ស សទ្ធា តថាគតេ
អចលា សុបតិដ្ឋិតា
សីលញ្ច យស្ស កល្យាណំ
អរិយកន្តំ បសំសិតំ
សង្ឃេ បសាទោ យស្សត្ថិ
ឧជុភូតញ្ច ទស្សនំ
អទលិទ្ទោតិ តំ អាហុ
អមោឃំ តស្ស ជីវិតំ
តស្មា សទ្ធញ្ច សីលញ្ច
បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី
សរំ ពុទ្ធាន សាសនន្តិ ។

# បញ្ចមំ រាមណេយ្យកសុត្តំ

[៣៩៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សក្កោ ទេវានមិន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

*សទ្ធារបស់បុគ្គលណា មិនកម្រើក បានតម្កល់ដោយប្រពៃ ក្នុងព្រះតថាគត ទាំងសីលរបស់បុគ្គលណាដ៏ល្អ ជាទីត្រេក-អរនៃព្រះអរិយៈ ដែលលោកសរសើរហើយ សេចក្តីជ្រះថ្លា របស់បុគ្គលណាមានក្នុងសង្ឃ ទាំងទស្សនៈក៏ត្រឹមត្រូវ ពួកបណ្ឌិតហៅបុគ្គលនោះថា មិនមែនជាមនុស្សក្រខ្សត់ខ្សោយទេ ជីវិតរបស់អ្នកនោះ មិនមែនជាមោឃៈទេ ព្រោះហេតុនោះ បណ្ឌិត កាលបើនឹកនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ គួរប្រកបរឿយ ៗ នូវសទ្ធាផង សីលផង សេចក្តីជ្រះ-ថ្លាផង ការឃើញនូវធម៌ផង ។*

# រាមណេយ្យកសូត្រ ទី ៥

[៣៩៩] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯងសក្កទេវានមិន្ទ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ*

ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សក្កោ ទេវានមិន្ទោ ភគវន្តំ ឯតទវោច កឹ នុ ខោ ភន្តេ ភូមិរាមណេយ្យកន្តិ ។

[៤០០] អារាមចេត្យា វនចេត្យា
បោក្ខរញ្ញា សុនិម្មិតា
មនុស្សរាមណេយ្យស្ស
កលំ នាគ្ឃន្តិ សោឡសឹ
គាមេ វា យទិ វារញ្ញេ
និន្នេ វា យទិ វា ថលេ
យត្ថ អរហន្តោ វិហរន្តិ
តំ ភូមិរាមណេយ្យកន្តិ ។

## ឆដ្ឋំ យជមានសុត្តំ

[៤០១] ឯកំ សមយំ ភគវា រាជគហេ វិហ-រតិ គិជ្ឈកូដេ បព្វតេ ។ អថខោ សក្កោ ទេវានមិន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ

ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះសក្កទេវានមិន្ទឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទីដែលគួរត្រេកអរ តើដូចម្តេច ។

[៤០០] ព្រះមានព្រះភាគ ត្រាស់ថា អារាមដែលគេគោរព ព្រៃដែលគេគោរព ស្រះបោក្ខរណីដែលគេតាក់តែងល្អហើយ នៅមិនទាន់ដល់មួយចំណិត នៃទីដែលមនុស្សគួរត្រេកអរ ជាចំណិតគេចែកជាចំណែកដប់ប្រាំមួយ ៗ ជង ដែលជាទីពួកព្រះអរហន្តគង់នៅ ទោះជាស្រុកឬជាព្រៃ ជាទីទំនាប ឬជាទីទួល ទីនោះជាភូមិគួរត្រេកអរ ។

# យជមានសូត្រ ទី ៦

[៤០១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង សក្កទេវានមិន្ទ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក៏ថ្វាយបង្គំ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

[៤០២] ឯកមន្តំ ឋិតោ ខោ សក្កោ ទេវាន-
មិន្ទោ ភគវន្តំ គាថាយ អជ្ឈភាសិ
យជមានានំ មនុស្សានំ
បុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ
កត្ថ ទិន្នំ មហប្ផលន្តិ ។
[៤០៣] ចត្តារោ ច បដិបន្នា
ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ
បញ្ញាសីលសមាហិតោ
យជមានានំ មនុស្សានំ
បុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ
សង្ឃេ ទិន្នំ មហប្ផលន្តិ ។

សក្កសំយុត្ត យជមានសូត្រ ទានមានផលច្រើន

[៤០២] លុះសក្កទេវានមិន្ទ ឋិតនៅ ក្នុងទីដ៏សមគួរហើយ បាន ក្រាបទូលព្រះមានព្រះភាគ ដោយគាថា ថា

ទាន គឺពួកមនុស្សអ្នកបូជា ជាសត្វប្រាថ្នាបុណ្យ កាល នឹងធ្វើបុណ្យ ដែលឲ្យផលក្នុងបច្ចុប្បន្ន តើឲ្យដល់បុគ្គលណា ទើបជាទានមានផលច្រើន ។

[៤០៣] ព្រះមានព្រះភាគ ត្រាស់ថា បុគ្គល ៤ ពួក ប្រតិបត្តិ (ដើម្បីផល) បុគ្គល ៤ ពួក ឋិតនៅក្នុងផល បុគ្គលទុំះ គឺសង្ឃជាអ្នកត្រឹមត្រង់ ប្រកបដោយបញ្ញានិង សីល ឯទាន គឺពួកមនុស្សអ្នកបូជា ជាសត្វប្រាថ្នាបុណ្យ កាលនឹងធ្វើបុណ្យ ដែលឲ្យផលក្នុងបច្ចុប្បន្ន បានឲ្យដល់ សង្ឃនោះ ទើបជាទានមានផលច្រើន ។

## សត្តមំ វន្ទនសុត្តំ

[៤០៤] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា ទិវាវិហារគតោ ហោតិ បដិសល្លីនោ ។ អថខោ សក្កោ ច ទេវានមិន្ទោ ព្រហ្មា ច សហម្បតិ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា បច្ចេកំ ទ្វារពាហំ និស្សាយ អដ្ឋំសុ ។

[៤០៥] អថខោ សក្កោ ទេវានមិន្ទោ ភគវន្តំ សន្តិកេ ឥមំ គាថំ អភាសិ

ឧដ្ឋាហិ វីរ វិជិតសង្គាម
បន្នភារ អនណ វិចរ លោកេ
ចិត្តញ្ច តេ សុវិមុត្តំ
ចន្ទោ យថា បន្នរសាយ រត្តិន្តិ ។

# វន្ទនសូត្រ ទី ៧

[៤០៤] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់សម្រាកក្នុងវេលាថ្ងៃ សម្ងំនៅក្នុងឈាន-សមាបត្តិ ។ គ្រានោះឯង សក្កទេវានមិន្ទនិងសហម្បតិព្រហ្ម បាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឋិតអែប នឹងសន្ទះទ្វារ ម្នាងម្នាក់ ។*

[៤០៥] *គ្រានោះឯង សក្កទេវានមិន្ទ បានពោលគាថានេះ ក្នុង សំណាក់នៃព្រះមានព្រះភាគថា*

*បពិត្រព្រះអង្គជាវីរបុរស ជាអ្នកឈ្នះសង្គ្រាម សូមព្រះ*
*អង្គក្រោកឡើង បពិត្រព្រះអង្គអ្នកដាក់ភារៈចុះហើយ មិន*
*ចំពាក់បំណុលគឺកិលេស សូមព្រះអង្គស្តេចទៅក្នុងលោក*
*ព្រោះហឫទ័យរបស់ព្រះអង្គ រួចស្រឡះហើយ ដូចជា*
*ព្រះចន្ទ្រក្នុងរាត្រីទី ១៥ កើត ។*

[៤០៦] ន ខោ ទេវានមិន្ទ តថាគតា ឯវំ វន្ទិតព្វា ។ ឯវញ្ច ខោ ទេវានមិន្ទ តថាគតា វន្ទិតព្វា

ឧដ្ឋាហិ វីរ វិជិតសង្គាម
សត្ថវាហ អនណា វិចរ លោកេ
ទេសេតុ ភគវា ធម្មំ
អញ្ញាតារោ ភវិស្សន្តីតិ ។

## អដ្ឋមំ បឋមសក្កនមស្សនសុត្តំ

[៤០៧] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ មាតលឹ សង្គាហកំ អាមន្តេសិ យោជេហិ សម្ម មាតលិ សហស្សយុត្តំ អាជញ្ញរថំ ឧយ្យានភូមឹ គច្ឆាម សុភូមឹ ទស្សនាយាតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា សហស្សយុត្តំ អាជញ្ញរថំ យោជេត្វា

[៤០៦] ព្រះអង្គត្រាស់ថា នែទេវានមិន្ទ ព្រះតថាគតទាំង-ឡាយ គេមិនគួរថ្វាយបង្គំយ៉ាងនេះទេ ។ នែទេវានមិន្ទ ព្រះតថាគតទាំងឡាយ គេគួរថ្វាយបង្គំ យ៉ាងនេះថា

បពិត្រព្រះអង្គជាវីរបុរស ជាអ្នកឈ្នះសង្គ្រាម សូមព្រះអង្គក្រោកឡើង បពិត្រព្រះអង្គអ្នកដឹកនាំពួកសត្វ ទ្រង់គ្មានបំណុលគឺកិលេស សូមព្រះអង្គស្តេចទៅក្នុងលោក សូមព្រះមានព្រះភាគសំដែងធម៌ ពួកបុគ្គលអ្នកត្រាស់ដឹង គង់នឹងមាន ។

# បឋមសក្កនមស្សនសូត្រ ទី ៨

[៤០៧] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយសក្កទេវានមិន្ទ បានហៅមាតលិសង្គាហកៈមកប្រាប់ថា ម្នាលមាតលិសំឡាញ់ អ្នកចូរទឹមរថអាជានេយ្យ ដែលទឹមសេះមួយពាន់ យើងនឹងទៅកាន់ឧយ្យានភូមិ ដើម្បីមើលនូវភូមិដ៏សប្បាយ ។ ម្នាលភិក្ខុទាំងឡាយមាតលិសង្គាហកទេវបុត្ត ទទួលស្តាប់ពាក្យសក្កទេវានមិន្ទថា សូមទ្រង់ព្រះមេត្តាប្រោស ហើយទឹមរថអាជានេយ្យ ដែលទឹមសេះមួយពាន់

សក្កស្ស ទេវានមិន្ទស្ស បដិវេទេសិ យុត្តោ ខោ តេ មារិស សហស្សយុត្តោ អាជញ្ញរថោ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ វេជយន្តបាសាទា ឱរោហន្តោ អញ្ជលឹ កត្វា សុទំ បុថុទ្ទិសា នមស្សតិ ។

[៤០៨] អថខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កំ ទេវានមិន្ទំ គាថាយ អជ្ឈភាសិ

តំ នមស្សន្តិ តេវិជ្ជា
សព្វេ ភុម្មា ច ខត្តិយា
ចត្តារោ ច មហារាជា
តិទសា ច យសស្សិនោ
អថ កោ នាម សោ យក្ខោ
យំ ត្វំ សក្ក នមស្សសីតិ ។

ក្រាបទូលដល់សក្កទេវានមិន្ទថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ រថអាជា-
នេយ្យ ដែលទឹមសេះមួយពាន់ ខ្ញុំព្រះអង្គបានទឹមបម្រុងព្រះអង្គហើយ
សូមទ្រង់សម្គាល់នូវកាលគួរនឹងស្ដេចទៅ ក្នុងកាលឥឡូវនេះចុះ ។ ម្នាល
ភិក្ខុទាំងឡាយ លំដាប់នោះឯង សក្កទេវានមិន្ទ ស្ដេចចុះចាកវេជយន្ត-
ប្រាសាទ ធ្វើអញ្ជលីនមស្ការគ្រប់ទិស ។

[៤០៨] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មាតលិសង្គាហក-
ទេវបុត្ត បានក្រាបទូលសួរសក្កទេវានមិន្ទ ដោយគាថាថា

ពួកអ្នកមានវិជ្ជាបីផង ពួកក្សត្រិយ៍ទាំងអស់ ដែលគង់នៅលើ
ផែនដីផង ពួកមហារាជទាំងបួនផង ពួកទេវតាមានយស
ក្នុងឋានតាវត្តិង្សផង តែងថ្វាយបង្គំព្រះអង្គ បពិត្រសក្ក-
ទេវរាជ កាលបើយ៉ាងនេះ ព្រះអង្គនឹងថ្វាយបង្គំអ្នកណា
អ្នកនោះ ជាបុគ្គលគួរបូជា តើជាអ្នកណា ។

សក្កសំយុត្តស្ស បឋមសក្កនមស្សនសុត្តេ សក្កស្ស នមក្ការោ

[៤០៩] មំ[១] នមស្សន្តិ តេវិជ្ជា
សព្វេ ភុម្មា ច ខត្តិយា
ចត្តារោ ច មហារាជា
តិទសា ច យសស្សិនោ
អហញ្ច សីលសម្បន្នេ
ចិររត្តសមាហិតេ
សម្មា បព្វជិតេ វន្ទេ
ព្រហ្មចរិយបរាយនេ
យេ គហដ្ឋា បុញ្ញករា
សីលវន្តោ ឧបាសកា
ធម្មេន ទារំ បោសេន្តិ
តេ នមស្សាមិ មាតលីតិ ។

[៤១០] សេដ្ឋា ហិ កិរ លោកស្មឹ
យេ ត្វំ សក្ក នមស្សសិ
អហម្បិ តេ នមស្សាមិ
យេ នមស្សសិ វាសវាតិ ។

---
១ យន្តិបិ បាឋោ ។

[៤០៩] សក្កទេវរាជ ត្រាស់ថា ពួកអ្នកមានវិជ្ជាបីផង ពួកក្សត្រិយ៍ទាំងអស់ ដែលគង់នៅលើផែនដីផង ពួកមហារាជទាំងបួនផង ពួកទេវតាមានយស ក្នុងឋានតាវត្តិង្សផង តែងថ្វាយបង្គំខ្ញុំពិតមែន ឯខ្ញុំថ្វាយបង្គំដោយប្រពៃ ចំពោះពួកបព្វជិត ដែលបរិបូណ៌ដោយសីល មានចិត្តតម្កល់មាំ អស់រាត្រីដ៏យូរអង្វែង មានព្រហ្មចារ្យជាទីប្រព្រឹត្តទៅ ក្នុងខាងមុខ ពួកគ្រហស្ថណាជាអ្នកធ្វើបុណ្យ ជាឧបាសកមានសីល ចិញ្ចឹមកូនប្រពន្ធដោយធម៌ ម្នាលមាតលិ ខ្ញុំក៏ថ្វាយបង្គំចំពោះពួកគ្រហស្ថនោះដែរ ។

[៤១០] មាតលិ ទូលថា បពិត្រសក្កទេវរាជ ព្រះអង្គថ្វាយបង្គំពួកបុគ្គលណា ពួកបុគ្គលនោះប្រសើរបំផុត ក្នុងលោកដោយពិត បពិត្រវាសវៈ ព្រះអង្គថ្វាយបង្គំពួកបុគ្គលណា ខ្ញុំព្រះអង្គក៏ថ្វាយបង្គំពួកបុគ្គលនោះដែរ ។

[៤១១] ឥធំ វត្វាន មឃវា
ទេវរាជា សុជម្បតិ
បុថុទ្ទិសា នមស្សិត្វា
បមុខោ រថមារុហីតិ ។

## នវមំ ទុតិយសក្កនមស្សនសុត្តំ

[៤១២] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ មាតលឹ សង្គាហកំ អាមន្តេសិ យោជេហិ សម្ម មាតលិ សហស្សយុត្តំ អាជញ្ញរថំ ឧយ្យានភូមឹ គច្ឆាម សុភូមឹ ទស្សនាយាតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា សហស្សយុត្តំ អាជញ្ញរថំ យោជេត្វា សក្កស្ស ទេវានមិន្ទស្ស បដិវេទេសិ យុត្តោ ខោ តេ មារិស សហស្សយុត្តោ អាជញ្ញរថោ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ វេជយន្តបាសាទា ឱរោហន្តោ អញ្ជលឹ កត្វា សុធំ[១] ភគវន្តំ នមស្សតិ ។

១ ឱ. បញ្ជលិកោ សុខំ ។

[៤១១] លុះមឃវទេវរាជ ព្រះនាមសុជម្បតិ ជាប្រធានរបស់ទេវតា បានពោលពាក្យនេះហើយ ក៏ថ្វាយបង្គំគ្រប់ទិស រួចឡើងគង់លើរថទៅ ។

## ទុតិយសក្កនមស្សនសូត្រ ទី ៩

[៤១២] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ សក្កទេវានមិន្ទ បានហៅមាតលិសង្គាហកទេវបុត្ត មកប្រាប់ថា ម្នាលមាតលិសំឡាញ់ ចូរអ្នកទឹមរថអាជានេយ្យ ដែលទឹមសេះមួយពាន់ យើងនឹងទៅកាន់ឧយ្យានភូមិ ដើម្បីមើលទីដ៏សប្បាយ ។ ម្នាលភិក្ខុទាំង-ឡាយ មាតលិសង្គាហកទេវបុត្ត ទទួលស្តាប់សក្កទេវានមិន្ទថា ព្រះករុណាថ្លៃវិសេស សូមព្រះអង្គមានសេចក្តីចម្រើន ហើយទឹមរថអាជានេយ្យ ដែលទឹមសេះមួយពាន់ ហើយក្រាបទូលដល់សក្កទេវានមិន្ទថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ រថអាជានេយ្យ ដែលទឹមសេះមួយពាន់ ខ្ញុំព្រះអង្គបានទឹមបម្រុងព្រះអង្គហើយ សូមព្រះអង្គសម្គាល់នូវកាលគួរនឹងស្តេចទៅឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សក្កទេវានមិន្ទ កាលយាងចុះចាកវេជយន្តប្រាសាទ ក៏ធ្វើអញ្ជលីនមស្ការព្រះមានព្រះភាគ ។

[៤១៣] អថខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កំ ទេវានមិន្ទំ គាថាយ អជ្ឈភាសិ

យំ ហិ ទេវា មនុស្សា ច
តំ នមស្សន្តិ វាសវ
អថ កោ នាម សោ យក្ខោ
យំ ត្វំ សក្ក នមស្សសីតិ ។

[៤១៤] យោ ឥធ សម្មាសម្ពុទ្ធោ
អស្មឹ លោកេ សទេវកេ
អនោមនាមំ សត្ថារំ
តំ នមស្សាមិ មាតលិ
យេសំ រាគោ ច ទោសោ ច
អវិជ្ជា ច វិរាជិតា
ខីណាសវា អរហន្តោ

[៤១៣] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មាតលិសង្គាហកទេវបុត្ត បានពោលនឹងសក្កទេវានមិន្ទ ដោយគាថា ថា

បពិត្រវាសវៈ សេចក្ដីពិតថា ពួកទេវតានិងមនុស្ស តែងនមស្ការចំពោះព្រះអង្គ បពិត្រសក្កទេវរាជ កាលបើយ៉ាងនេះ ទ្រង់នឹងនមស្ការ ចំពោះអ្នកណា អ្នកនោះជាបុគ្គលគួរគេបូជា តើជាអ្នកណា ។

[៤១៤] សក្កទេវរាជត្រាស់ថា ម្នាលមាតលិ ក្នុងលោកនេះ ព្រះសាស្ដាអង្គណាជាសម្មាសម្ពុទ្ធ ខ្ញុំនមស្ការចំពោះព្រះសាស្ដាអង្គនោះ ដែលមានព្រះនាមមិនថោកទាប ក្នុងលោកនេះ ព្រមទាំងទេវលោក ពួកបុគ្គលណាកម្ចាត់បង់រាគៈ ទោសៈ និងអវិជ្ជា អស់អាសវៈហើយ ជាព្រះអរហន្ត

តេ នមស្សាមិ មាតលិ

យេ ភាគេ ោសវិនយា

អវិជ្ជាសមតិក្កមា

សេក្ខា អប្បចយារាមា

អប្បមត្តានុសិក្ខរេ

តេ នមស្សាមិ មាតលីតិ ។

[៤១៥] សេដ្ឋា ហិ កិរ លោកស្មឹ

យេ ត្វំ សក្ក នមស្សសិ

អហម្បិ តេ នមស្សាមិ

យេ នមស្សសិ វាសវាតិ ។

[៤១៦] ឥទំ វត្វាន មឃវា

ទេវរាជា សុជម្បតិ

ភគវន្តំ នមស្សិត្វា

បមុខោ រថមារុហីតិ ។

ម្នាលមាតលិ ខ្ញុំនមស្ការ ចំពោះពួកបុគ្គលនោះ ពួកបុគ្គលណា បន្ទោបង់រាគៈនិងទោសៈ កន្លងបង់នូវអវិជ្ជា ជាសេក្ខបុគ្គល ជាអ្នកត្រេកអរ ក្នុងកិរិយាកម្ចាត់បង់នូវវដ្តៈ ជាអ្នកមិនប្រមាទ សិក្សារឿយៗ (ក្នុងអរិយវិន័យ) ម្នាលមាតលិ ខ្ញុំនមស្ការ ចំពោះពួកបុគ្គលនោះ ។

[៤១៥] មាតលិតបថា បពិត្រសក្កទេវរាជ សេចក្តីពិតថា ទ្រង់នមស្ការ ចំពោះពួកបុគ្គលណា ពួកបុគ្គលនោះប្រសើរបំផុតក្នុងលោក បពិត្រវាសវៈ ទ្រង់នមស្ការ ចំពោះបុគ្គលណា ខ្ញុំព្រះអង្គក៏នមស្ការ ចំពោះបុគ្គលនោះដែរ ។

[៤១៦] លុះមឃវទេវរាជ ព្រះនាមសុជម្បតិ ជាប្រធានរបស់ទេវតា ពោលគាថានេះហើយ ក៏នមស្ការ ចំពោះព្រះមានព្រះភាគ ហើយទ្រង់ឡើងគង់លើរថទៅ ។

# ទសមំ តតិយសក្កនមស្សនសុត្តំ

[៤១៧] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ មាតលឹ សង្គាហកំ អាមន្តេសិ យោជេហិ សម្ម មាតលិ សហស្សយុត្តំ អាជញ្ញរថំ ឧយ្យានភូមឹ គច្ឆាម សុភូមឹ ទស្សនាយាតិ ។ ឯវំ ភទ្ទន្តវាតិ ខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា សហស្សយុត្តំ អាជញ្ញរថំ យោជេត្វា សក្កស្ស ទេវានមិន្ទស្ស បដិវេទេសិ យុត្តោ ខោ តេ មារិស សហស្សយុត្តោ អាជញ្ញរថោ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ ភិក្ខវេ សក្កោ ទេវាន-មិន្ទោ វេជយន្តបាសាទា ឱរោហន្តោ អញ្ជលឹ កត្វា សុទំ ភិក្ខុសង្ឃំ នមស្សតិ ។

[៤១៨] អថខោ ភិក្ខវេ មាតលិ សង្គាហកោ សក្កំ ទេវានមិន្ទំ គាថាយ អជ្ឈភាសិ

# តតិយសក្កនមស្សនសូត្រ ទី ១០

[៤១៧] *សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ សក្កទេវានមិន្ទ ត្រាស់ហៅមាតលិសង្គាហកទេវបុត្តមកប្រាប់ថា ម្នាលមាតលិសំឡាញ់ ចូរអ្នកទឹមរថអាជានេយ្យ ដែលទឹមសេះមួយពាន់ យើងនឹងទៅកាន់ឧយ្យានភូមិ ដើម្បីមើលនូវទីដ៏សប្បាយ ។ ម្នាលភិក្ខុទាំងឡាយ មាតលិសង្គាហកទេវបុត្ត ទទួលស្ដាប់សក្កទេវានមិន្ទថា ព្រះករុណាថ្លៃវិសេស សូមព្រះអង្គមានសេចក្ដីចម្រើន ហើយទឹមរថអាជានេយ្យ ដែលទឹមសេះមួយពាន់ រួចក្រាបទូលសក្កទេវានមិន្ទថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ រថអាជានេយ្យ ដែលទឹមសេះមួយពាន់ ខ្ញុំព្រះអង្គទឹមបម្រុងចាំព្រះអង្គរួចហើយ សូមទ្រង់សម្គាល់នូវកាលគួរនឹងស្ដេចទៅ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សក្កទេវានមិន្ទ ស្ដេចចុះអំពីវេជយន្តប្រាសាទ ធ្វើអញ្ជលីនមស្ការ ចំពោះព្រះភិក្ខុសង្ឃ ។*

[៤១៨] *ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មាតលិសង្គាហកទេវបុត្ត បានពោលនឹងសក្កទេវានមិន្ទ ដោយគាថា ថា*

តំ ហិ ឯតេ នមស្សេយ្យុំ
បូតិទេហសយា នរា
និមុគ្គា កុណបស្មេតេ[១]
ខុប្បិបាសា សមប្បិតា
កឹ នុ តេសំ បិហយសិ
អនាគារាន វាសវ
អាចារំ ឥសិនំ ព្រូហិ
តំ សុណោម វចោ តវាតិ ។

[៤១៩] ឯតំ តេសំ បិហយាមិ
អនាគារាន មាតលិ
យម្ហា កាមា បក្កមន្តិ
អនបេក្ខា វជន្តិ តេ
ន តេសំ កោដ្ឋេ ឱបេន្តិ
ន កុម្ភេ ន កឡោបិយំ
បរនិដ្ឋិតមេសនា

---
១ ឱ. កុណបេស្វេតេ ។ ម. កុណបម្ហេតេ ។

សេចក្ដីពិតថា ពួកជនទាំងនោះ ដេកនៅក្នុងរាងកាយមាតា ជំស្អុយ គួរតែថ្វាយបង្គំ ចំពោះព្រះអង្គវិញ ព្រោះពួកជនទាំងនុ៎ះ មុជចុះក្នុងសាកសពគឺផ្ទៃមាតា ពេញដោយការឃ្លាននិងការស្រេក បពិត្រវាសវៈ ព្រះអង្គស្រឡាញ់សេចក្ដីប្រព្រឹត្ត របស់ពួកអ្នកបួសនោះ ដូចម្ដេច សូមទ្រង់ប្រាប់សេចក្ដីប្រព្រឹត្តរបស់ពួកអ្នកបួស យើងខ្ញុំនឹងស្ដាប់ពាក្យនោះរបស់ព្រះអង្គ ។

[៤១៩] សក្កទេវរាជមានព្រះបន្ទូលថា ម្នាលមាតលិ ខ្ញុំស្រឡាញ់ត្រង់សេចក្ដីប្រព្រឹត្ត របស់ពួកអ្នកបួសនោះ ព្រោះពួកអ្នកបួសទាំងនោះ វៀរចាកកាមណា មិនអាល័យកាមនោះសោះ អ្នកបួសទាំងនោះ មិនទុកស្រូវក្នុងជង្រុក មិនទុកស្រូវក្នុងក្អមមិនទុកស្រូវក្នុងកញ្ជ្រែង ស្វែងរកតែអាហារដែលអ្នកដទៃសម្រេច

តេន យាបេន្តិ សុព្វតា

សុមន្តមន្តិនោ ធីរា

តុណ្ហីភូតា សមញ្ចរា

ទេវា វិរុទ្ធា អសុរេហិ

បុថុមច្ចា ច មាតលិ

អវិរុទ្ធា វិរុទ្ធេសុ

អត្តទណ្ឌេសុ និព្វុតា

សាទានេសុ អនាទានា

តេ នមស្សាមិ មាតលីតិ ។

[៤២០] សេដ្ឋា ហិ កិរ លោកស្មឹ

យេ តុំ សក្ក នមស្សសិ

អហម្បិ តេ នមស្សាមិ

យេ នមស្សសិ វាសវាតិ ។

ហើយញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅដោយអាហារនោះ ជាអ្នកមានវត្តល្អ និយាយតែពាក្យជាសុភាសិត ជាអ្នកស្ងប់ស្ងៀម ប្រព្រឹត្តធម៌ស្មើ ម្នាលមាតលិ អម្បាលដូចជាពួកទេវតានៅឈ្លោះគ្នានឹងពួកអសុរ ពួកសត្វជាច្រើនក៏នៅឈ្លោះគ្នាដែរ កាលបើពួកសត្វកំពុងឈ្លោះគ្នា ពួកអ្នកបួសនោះ មិនឈ្លោះគ្នាសោះ ជាអ្នករំលត់ក្នុងពួកសត្វ ដែលមានអាជ្ញាដល់ខ្លួន កាលពួកសត្វប្រកបដោយសេចក្ដីប្រកាន់ លោកមិនមានសេចក្ដីប្រកាន់ទេ ម្នាលមាតលិ ខ្ញុំថ្វាយបង្គំចំពោះពួកអ្នកបួសនោះ ។

[៤២០] បពិត្រសក្កទេវរាជ ទ្រង់ថ្វាយបង្គំ ចំពោះពួកបុគ្គលណា ពួកបុគ្គលនោះប្រសើរបំផុត ក្នុងលោកពិតហើយ បពិត្រវាសវៈ ទ្រង់ថ្វាយបង្គំ ចំពោះពួកបុគ្គលណា ខ្ញុំព្រះអង្គក៏ថ្វាយបង្គំ ចំពោះពួកអ្នកនោះដែរ ។

[៤២១] ឥទំ វត្វាន មឃវា
ទេវរាជា សុជម្បតិ
ភិក្ខុសង្ឃំ នមស្សិត្វា
បមុខោ រថមារុហីតិ ។

ទេវវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

វត្តបទេន[១] តយោ វុត្តា
ទលិទ្ទញ្ច រាមណេយ្យកំ
យជមានញ្ច វន្ទនា
តយោ សក្កនមស្សនាតិ ។

---
១ ឱ. ម. ទេវា បន ។

[៤២១] លុះមឃវទេវរាជ ព្រះនាមសុជម្បតិ ជាប្រធានរបស់ពួកទេវតា ពោលពាក្យនេះហើយ ក៏នមស្ការ ចំពោះព្រះភិក្ខុសង្ឃ ហើយឡើងគង់លើរថទៅ ។

ចប់ ទេវវគ្គ ទី ២ ។

# ឧទ្ទាននៃទេវវគ្គនោះ គឺ

ទេវសូត្រ ៣ ព្រះមានព្រះភាគ សំដែងដោយវត្តបទ ទឡិទ្ទសូត្រ ១ រាមណេយ្យសូត្រ ១ យជមានសូត្រ ១ វន្ទនសូត្រ ១ សក្កនមស្សនសូត្រ ។

---

# សក្កបញ្ហកំ

## បឋមំ ឃត្វាសុត្តំ

[៤២២] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សក្កោ ទេវានមិន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

[៤២៣] ឯកមន្តំ ឋិតោ ខោ សក្កោ ទេវានមិន្ទោ ភគវន្តំ គាថាយ អជ្ឈភាសិ

កឹសុ ឃត្វា[១] សុខំ សេតិ
កឹសុ ឃត្វា ន សោចតិ
កិស្សស្ស ឯកធម្មស្ស
វធំ រោចេសិ គោតមាតិ ។

១ ឱ. ម. កឹសុ ឆេត្វា ។

# សក្កបញ្ចកៈ

## យក្ខាសូត្រ ទី ១

[៤២២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង សក្កទេវានមិន្ទ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតក្នុងទីដ៏សមគួរ ។

[៤២៣] លុះសក្កទេវានមិន្ទ ឋិតក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ ដោយគាថា ថា

បុគ្គលសម្លាប់អ្វី ទើបដេកជាសុខ សម្លាប់អ្វី ទើបមិនសោកសៅ បពិត្រព្រះគោតម ព្រះអង្គគាប់ព្រះហឫទ័យ ចំពោះការសម្លាប់ធម៌អ្វី ដែលជាធម៌ឯក ។

[៤២៤] កោធំ ឆេត្វា សុខំ សេតិ
កោធំ ឆេត្វា ន សោចតិ
កោធស្ស វិសមូលស្ស
មធុរគ្គស្ស វាសវ
វធំ អរិយា បសំសន្តិ
តំ ហិ ឆេត្វា ន សោចតីតិ ។

# ទុតិយំ ទុព្វណ្ណិយសុត្តំ

[៤២៥] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ អញ្ញតរោ យក្ខោ ទុព្វណ្ណោ ឱកោដិមកោ សក្កស្ស ទេវានមិន្ទស្ស អាសនេ និសិន្នោ អហោសិ ។ តត្រ សុទំ ភិក្ខវេ ទេវា តាវតឹសា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ អយំ យក្ខោ ទុព្វណ្ណោ ឱកោដិមកោ សក្កស្ស ទេវានមិន្ទស្ស អាសនេ និសិន្នោតិ ។ យថា យថា ខោ ភិក្ខវេ ទេវា តាវតឹសា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ តថា តថា សោ យក្ខោ អភិរូបតរោ ចេវ ហោតិ ទស្សនីយតរោ ច បាសាទិកតរោ ច ។

[៤២៤] ព្រះមានព្រះភាគត្រាស់ថា បុគ្គលសម្លាប់សេចក្តីក្រោធបាន ទើបដេកជាសុខ សម្លាប់សេចក្តីក្រោធបាន ទើបមិនសោកសៅ ម្នាលវាសវៈ ពួកព្រះអរិយៈ តែងសរសើរការសម្លាប់សេចក្តីក្រោធ ដែលមានគល់ជាពិស មានចុងដ៏ផ្អែម ព្រោះថា បុគ្គលសម្លាប់សេចក្តីក្រោធនោះបាន ទើបមិនសោកសៅឡើយ ។

# ទុព្វណ្ណិយសូត្រ ទី ២

[៤២៥] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានយក្ស ១ សម្បុរអាក្រក់ ខ្លួនតឿ ពោះកំប៉ោង បានអង្គុយលើអាសនៈ របស់សក្កទេវានមិន្ទ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីដំណាលក្នុងរឿងនោះថា ពួកទេវតាក្នុងឋានតាវត្តិង្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា អស្ចារ្យណាស់ហ្ន៎ ចំឡែកណាស់ហ្ន៎ យក្សមានសម្បុរអាក្រក់ ខ្លួនតឿ ពោះកំប៉ោងនេះ ហ៊ានអង្គុយលើអាសនៈរបស់សក្កទេវានមិន្ទ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកទេវតាក្នុងឋានតាវត្តិង្ស ពោលទោស តិះដៀល បន្តុះបង្អាប់ ដោយហេតុណា ៗ យក្សនោះ ក៏រឹតតែមានរូបល្អផង គួរជាទីពិតពិលរមិលមើលក្រៃពេកផង រឹតតែជ្រះថ្លាផង ដោយហេតុនោះ ៗ ។

[៤២៦] អថខោ ភិក្ខវេ ទេវា តាវត្តឹសា យេន សក្កោ ទេវានមិន្ទោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សក្កំ ទេវានមិន្ទំ ឯតទវោចុំ ឥធ តេ មារិស អញ្ញតរោ យក្ខោ ទុព្វណ្ណោ ឱកោដិមកោ តុម្ហាកំ អាសនេ និសិន្នោ ។ តត្រ សុទំ មារិស ទេវា តាវត្តឹសា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ អយំ យក្ខោ ទុព្វណ្ណោ ឱកោដិមកោ សក្កស្ស ទេវានមិន្ទស្ស អាសនេ និសិន្នោតិ យថា យថា ខោ មារិស ទេវា តាវត្តឹសា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ តថា តថា សោ យក្ខោ អភិរូបតរោ ចេវ ហោតិ ទស្សនីយតរោ ច បាសាទិកតរោ ចាតិ សោ ហិ នូន មារិស កោធភក្ខោ យក្ខោ ភវិស្សតីតិ ។

សក្កសំយុត្ត ទុព្វណ្ណិយសូត្រ ពួកទេវតាចូលគាល់សក្កទេវរាជ

[៤២៦] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ពួកទេវតាក្នុងឋាន តាវត្តិង្ស ចូលទៅគាល់សក្កទេវានមិន្ទ លុះចូលទៅដល់ហើយ បានក្រាបទូលសក្កទេវានមិន្ទយ៉ាងនេះថា បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ឥឡូវនេះ មានយក្ស ១ សម្បុរអាក្រក់ ខ្លួនតឿ ពោះកំប៉ោង អង្គុយលើអាសនៈរបស់ព្រះអង្គ ។ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ក្នុងរឿងនោះឮថា ពួកទេវតាក្នុងឋានតាវត្តិង្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា អស្ចារ្យណាស់ហ្ន៎ ចំឡែកណាស់ហ្ន៎ យក្សមានសម្បុរអាក្រក់ ខ្លួនតឿ ពោះកំប៉ោងនេះហ៊ានអង្គុយលើអាសនៈ របស់សក្កទេវានមិន្ទ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខទោះបីពួកទេវតាឋានតាវត្តិង្ស ពោលទោស តិះដៀល បន្តុះបង្អាប់យ៉ាងណា ៗ ក៏យក្សនោះ រឹតតែមានរូបល្អឡើងផង គួរជាទីពិតពិលរមិលមើលក្រៃពេកផង រឹតតែគួរជ្រះថ្លាផង បពិត្រព្រះអង្គអ្នកនិទុ៌ក្ខយក្សនោះពិតជាឈ្មោះកោធភក្ស (មានសេចក្តីក្រោធជាអាហារ) ហើយ ។

[៤២៧] អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ យេន សោ កោធភក្ខោ តេនុបសង្កមិ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណជាណុមណ្ឌលំ បឋវិយំ និហត្វា[១] យេន សោ កោធភក្ខោ យក្ខោ តេនញ្ជលិម្បណាមេត្វា តិក្ខត្តុំ នាមំ សាវេតិ សក្កាហំ មារិស ទេវានមិន្ទោ... សក្កាហំ មារិស ទេវានមិន្ទោតិ ។ យថា យថា ខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ នាមំ សាវេតិ តថា តថា សោ យក្ខោ ទុព្វណ្ណតរោ ចេវ អហោសិ ឱកោដិមកតរោ ច ទុព្វណ្ណតរោ ចេវ ហុត្វា ឱកោដិមកតរោ ច តត្ថេវន្តរធាយិ ។

[៤២៨] អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ សកេ អាសនេ និសីទិត្វា ទេវេ តាវតឹសេ អនុនយមានោ តាយំ វេលាយំ ឥមា គាថាយោ អភាសិ

១ ឱ. និហន្ត្វា ។ ម. និហន្តា ។

[៤២៧] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវានមិន្ទ ចូលទៅរកកោធភក្ខយក្ស លុះចូលទៅដល់ហើយ ធ្វើសំពត់ឆៀងស្មាម្ខាង លុតព្រះជានុមណ្ឌលខាងស្តាំលើប្រឹថពី ប្រណម្យអញ្ជលី ចំពោះកោធភក្ខយក្សនោះ ហើយបញ្ចេញព្រះនាមឲ្យឮបីដងថា នែអ្នកនិទុក្ខ ខ្ញុំជាសក្កទេវានមិន្ទ... នែអ្នកនិទុក្ខ ខ្ញុំជាសក្កទេវានមិន្ទ ។ ម្នាលភិក្ខុទាំងឡាយ សក្កទេវានមិន្ទ បញ្ចេញព្រះនាម ដោយហេតុណា ៗ យក្សនោះ ក៏ត្រឡប់ជាមានសម្បុររឹតតែអាក្រក់ផង រឹតតែមានខ្លួនតឿ ពោះកំប៉ោងផង ដោយហេតុនោះ ៗ លុះមានសម្បុររឹតតែអាក្រក់ និងមានខ្លួនរឹតតែតឿ ពោះកំប៉ោងហើយ ក៏បាត់ក្នុងទីនោះទៅ ។

[៤២៨] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវានមិន្ទ គង់លើអាសនៈរបស់ខ្លួន ពន្យល់ពួកទេវតាឋានតាវត្តិង្ស ហើយបានពោលគាថាទាំងឡាយនេះ ក្នុងវេលានោះថា

៣០១



ន សូបហតចិត្តោម្ហិ
នាវដ្ដេន សុវានយោ
ន ចិរាហំ កុជ្ឈាមិ
កោធោ មយិ នាវតិដ្ឋតិ
កុទ្ធាហំ ន ផរុសំ ព្រូមិ
ន ច ធម្មានិ កិត្តយេ
សន្និគ្គណ្ហាមិ អត្តានំ
សម្បស្សំ អត្ថមត្តនោតិ ។

## តតិយំ មាយាសុត្តំ

[៤២៩] សាវត្ថីនិទានំ ។ ភូតបុព្វំ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ អាពាធិកោ អហោសិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ យេន វេបចិត្តិ អសុរិន្ទោ តេនុបសង្កមិ គិលានបុច្ឆកោ ។ អទ្ទសា ខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ សក្កំ ទេវានមិន្ទំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន សក្កំ ទេវានមិន្ទំ ឯតទវោច

ខ្ញុំមិនឲ្យទោសបៀតបៀនបានទេ ទាំងមិនឲ្យធម៌ជាគ្រឿងនាំត្រឡប់ចិត្ត គឺសេចក្តីក្រោធចូលមកបាន ដោយងាយទេ ខ្ញុំមិនក្រោធមកយូរហើយ សេចក្តីក្រោធ មិនដក់នៅក្នុងខ្លួនខ្ញុំទេ បើខ្ញុំខឹង ខ្ញុំមិននិយាយពាក្យអាក្រក់ផង មិនសំដែងធម៌ទាំងឡាយផង ខ្ញុំសំឡឹងឃើញប្រយោជន៍ខ្លួន បានជាខ្ញុំសង្កត់សង្កិនខ្លួនខ្ញុំ ។

## មាយាសូត្រ ទី ៣

[៤២៩] សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ វេបចិត្តិអសុរិន្ទ មានអាពាធជាទម្ងន់ ដល់នូវទុក្ខវេទនា ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សក្កទេវានមិន្ទ ចូលទៅសួរជំងឺវេបចិត្តិអសុរិន្ទ ។ ម្នាលភិក្ខុទាំងឡាយ វេបចិត្តិអសុរិន្ទ បានឃើញសក្កទេវានមិន្ទ កំពុងមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងសក្កទេវានមិន្ទ យ៉ាងនេះ

តិកិច្ច មំ នេវានមិច្ឆាតិ ។ វាចេហិ មំ វេបចិត្តិ សម្ពរិមាយន្តិ ។ ន តាវាហំ វាចេមិ យាវាហំ មារិស អសុរេ បដិបុច្ឆាមីតិ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ អសុរេ បដិបុច្ឆិ វាចេមហំ មារិសា សក្កំ ទេវានមិន្ទំ សម្ពរិមាយន្តិ ។ មា ខោ ត្វំ មារិស វាចេសិ សក្កំ ទេវានមិន្ទំ សម្ពរិមាយន្តិ ។

[៤៣០] អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ សក្កំ ទេវានមិន្ទំ គាថាយ អជ្ឈភាសិ

មាយាវី មឃវា សក្ក

ទេវរាជ[១] សុជម្បតិ

ឧបេតិ និរយំ ឃោរំ

សម្ពរោវ សតំ សមំ ។

---

១ ទេវរាជ ឥតិបិ ទិស្សតិ ។

បពិត្រទេវានមិន្ទ សូមទ្រង់រក្សាខ្ញុំផង ។ សក្កទេវានមិន្ទតបថា ម្នាលវេបចិត្តិ អ្នកចូរប្រាប់កលល្បិចដល់ខ្ញុំ ។ វេបចិត្តិអសុរិន្ទតបថា បពិត្រអ្នកនិទុ៌ក្ខ ខ្ញុំមិនទាន់ប្រាប់ទេ ចាំខ្ញុំសាកសួរពួកអសុរសិន ។ ម្នាលភិក្ខុទាំងឡាយ វេបចិត្តិអសុរិន្ទ សាកសួរពួកអសុរថា ម្នាលពួកអ្នកនិទុ៌ក្ខ ខ្លួនខ្ញុំនឹងប្រាប់កលល្បិច ដល់សក្កទេវានមិន្ទទៅឬ ។ ពួកអសុរតបថា បពិត្រអ្នកនិទុ៌ក្ខ ព្រះអង្គកុំប្រាប់កលល្បិច ដល់សក្កទេវានមិន្ទឡើយ ។

[៤៣០] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង វេបចិត្តិអសុរិន្ទ បានពោលនឹងសក្កទេវានមិន្ទ ដោយគាថា ថា

បពិត្រមឃវសក្កទេវរាជ ព្រះនាមសុជម្បតិ បុគ្គលមាន
កលល្បិច តែងទៅកើតក្នុងនរកដ៏ពន្ទឹក ដូចជាសម្ពរអសុរិន្ទ
ប្រកបដោយកលល្បិច ក៏ឆេះក្នុងនរកអស់មួយរយឆ្នាំគត់ ។

# ចតុត្ថំ អច្ចយសុត្តំ

[៤៣១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ទ្វេ ភិក្ខូ សម្បយោជេសុំ ។ តត្រេកោ ភិក្ខុ អច្ចសរា ។ អថខោ សោ ភិក្ខុ តស្ស ភិក្ខុនោ សន្តិកេ អច្ចយំ អច្ចយតោ ទេសេតិ ។ សោ ភិក្ខុ នប្បដិគ្គណ្ហាតិ ។

[៤៣២] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ ទ្វេ ភិក្ខូ សម្បយោជេសុំ តត្រេកោ ភិក្ខុ តស្ស អច្ចសរា អថខោ ភន្តេ សោ ភិក្ខុ តស្ស ភិក្ខុនោ សន្តិកេ អច្ចយំ អច្ចយតោ ទេសេតិ សោ ភិក្ខុ នប្បដិគ្គណ្ហាតីតិ ។

# អច្ចយសូត្រ ទី ៤

[៨៣១] សម័យមួយ ព្រះមានព្រះភាគ គង់នៅ ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុពីររូបទាស់ទែងគ្នា ។ បណ្ដាភិក្ខុពីររូបនោះ ភិក្ខុមួយរូបនិយាយ រំលោភហួស ។ គ្រានោះឯង ភិក្ខុនោះ សំដែងទោស តាមសមគួរដល់ ទោស ក្នុងសំណាក់ភិក្ខុនោះ ។ តែភិក្ខុនោះ ក៏មិនទទួល ។

[៨៣២] គ្រានោះឯង ពួកភិក្ខុជាច្រើនរូប ចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ ពីររូបក្នុងសាសនានេះ កើតទាស់ទែងគ្នា បណ្ដាភិក្ខុទាំងពីររូបនោះ ភិក្ខុ មួយរូប និយាយរំលោភហួស បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ភិក្ខុ នោះ សំដែងទោស តាមសមគួរដល់ទោស ក្នុងសំណាក់ភិក្ខុនោះ តែភិក្ខុ នោះ មិនទទួល ។

[៤៣៣] ទ្វេមេ ភិក្ខវេ ពាលា ។ យោ ច អច្ចយំ អច្ចយតោ ន បស្សតិ យោ ច អច្ចយំ ទេសេន្តស្ស យថាធម្មំ ន បដិគ្គណ្ហាតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពាលា ។ ទ្វេ មេ ភិក្ខវេ បណ្ឌិតា ។ យោ ច អច្ចយំ អច្ចយតោ បស្សតិ យោ ច អច្ចយំ ទេសេន្តស្ស យថាធម្មំ បដិគ្គណ្ហាតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បណ្ឌិតា ។

[៤៣៤] ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុធម្មាយំ សភាយំ ទេវេ តាវត្តឹសេ អនុនយមានោ តាយំ វេលាយំ ឥមំ គាថំ អភាសិ

កោធោ វោ វសមាយាតុ
មា ច មិត្តេ ហិ វោ ជរា
អគរហិយំ មា គរហិត្ថ
មា ច ភាសិត្ថ បេសុណំ
អថ បាបជនំ កោធោ
បព្វតោវាភិមទ្ទតីតិ ។

[៤៣៣] ព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនេះ មានពីរពួក ។ គឺបុគ្គលដែលមិនឃើញទោសតាមទោស ១ បុគ្គលដែលគេកាលសំដែងទោស មិនទទួលតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង បុគ្គលពាលពីរពួក ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលជាបណ្ឌិតនេះ ក៏មានពីរពួក ។ គឺបុគ្គលដែលឃើញទោសតាមទោស ១ បុគ្គលដែលកាលគេសំដែងទោស ទទួលតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង បណ្ឌិតមានពីរពួក ។

[៤៣៤] ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ សក្កទេ-វានមិន្ទ ពន្យល់ពួកទេវតានៅឋានតាវត្តិង្ស ក្នុងរោងប្រជុំឈ្មោះ សុធម្មា បានពោលគាថានេះ ក្នុងវេលានោះថា

សេចក្តីក្រោធចូរមក ក្នុងអំណាច របស់អ្នកទាំងឡាយ
សេចក្តីប្រែប្រួល របស់អ្នកទាំងឡាយ កុំកើតក្នុងមិត្តធម៌
ពួកអ្នកកុំតិះដៀលបុគ្គល ដែលមិនគួរតិះដៀល ទាំងកុំ
និយាយពាក្យស៊កសៀតឡើយ ព្រោះសេចក្តីក្រោធ ដូច
ជាភ្នំសង្កត់សង្កិនជនអាក្រក់ ។

# មញ្ជមំ អក្កោធសុត្តំ

[៤៣៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារា-មេ ។ តត្រ ខោ ភគវា ភិក្ខូ ។ បេ ។

[៤៣៦] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ សុធម្មាយំ សភាយំ ទេវេ តាវត្តឹ-សេ អនុនយមានោ តាយំ វេលាយំ ឥមំ គាថំ អភាសិ

មា វោ កោធោ អជ្ឈភវិ
មា ច កុជ្ឈិត្ថ កុជ្ឈតំ
អក្កោធោ អវិហឹសា ច
អរិយេសុ វសតី សទា[១]
អថ បាបជនំ កោធោ
បព្វតោវាភិមទ្ទតីតិ ។

សក្កបញ្ចកំ ។

---

១ ម. អរិយេសុ ច បដិបទា ។

# អក្កោធសូត្រ ទី ៥

[៤៣៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ។ បេ ។

[៤៣៦] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ សក្កទេវានមិន្ទ ពន្យល់ពួកទេវតាឋានតាវត្តិង្ស ក្នុងរោងប្រជុំឈ្មោះ សុធម្មា បានពោលគាថានេះ ក្នុងវេលានោះថា

សេចក្តីក្រោធ កុំគ្របសង្កត់អ្នកឡើយ មួយទៀត អ្នកកុំខឹង
នឹងពួកបុគ្គលដែលកំពុងខឹងឡើយ សេចក្តីមិនខឹងក្តី សេចក្តី
មិនបៀតបៀនក្តី រមែងមាននៅក្នុងពួកព្រះអរិយៈសព្វកាល
ប៉ុន្តែ សេចក្តីក្រោធដូចជាភ្នំ តែងញាំញីនូវជនអាក្រក់ ។

ចប់ សក្កបញ្ចកៈ ។

# តត្រុទ្ទានំ

យត្វា ទុព្វណ្ណិយមាយា
អច្ចយេន អក្កោធេនោ
ទេសិតំ ពុទ្ធសេដ្ឋេន
ឥទំ សក្កបញ្ចកំ ។

សក្កសំយុត្តំ សមត្តំ ។

# ឯកាទសសំយុត្តំ

ទេវតា ទេវបុត្តោ ច
រាជា មារោ ច ភិក្ខុនី
ព្រហ្មា ព្រាហ្មណវង្គីសោ
វនយក្ខេន វាសវោតិ ។

សគាថវគ្គោ និដ្ឋិតោ ។

## ឧទ្ទានក្នុងសក្កបញ្ចកៈនោះ គឺ

*សក្កបញ្ចកៈនេះ ដែលព្រះពុទ្ធជាបុគ្គលប្រសើរ សំដែងហើយ ដោយឃត្វាសូត្រ ១ ទុព្វណ្ណិយសូត្រ ១ មាយាសូត្រ ១ អច្ចយសូត្រ ១ អកោធសូត្រ ១*

ចប់ សក្កសំយុត្ត ។

## ក្នុងសគាថវគ្គមានសំយុត្ត ១១ គឺ

*ទេវតាសំយុត្ត ១ ទេវបុត្តសំយុត្ត ១ រាជៈគឺកោសលសំយុត្ត ១ មារសំយុត្ត ១ ភិក្ខុនីសំយុត្ត ១ ព្រហ្មសំយុត្ត ១ ព្រាហ្មណ-សំយុត្ត ១ វង្គីសសំយុត្ត ១ វនសំយុត្ត ១ យក្ខសំយុត្ត ១ វាសវៈគឺសក្កសំយុត្ត ១ ។*

ចប់ សគាថវគ្គ ។

---

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស សគាថវគ្គោ

# ទុតិយោ ភាគោ

# ភិក្ខុនីសំយុត្តំ

## មាតិកា *អង្កេ*


បឋមំ អាឡវិកាសុត្តំ ........ ១

ទុតិយំ សោមាសុត្តំ ........ ៣

តតិយំ គោតមីសុត្តំ ........ ៥

ចតុត្ថំ វិជយាសុត្តំ ........ ៧

បញ្ចមំ ឧប្បលវណ្ណាសុត្តំ ........ ១០

ឆដ្ឋំ ចាលាសុត្តំ ........ ១២

សត្តមំ ឧបចាលាសុត្តំ ........ ១៤

អដ្ឋមំ សីសុបចាលាសុត្តំ ........ ១៦

នវមំ សេលាសុត្តំ ........ ១៨

ទសមំ វជិរាសុត្តំ ........ ២០

# សុត្តន្តបិដក

# សំយុត្តនិកាយ  សគាថវគ្គ

# ទុតិយភាគ

# ភិក្ខុនីសំយុត្ត

## មាតិកា

លេខទំព័រ


អាឡវិកាសូត្រ  ទី ១ ........................................ ១

សោមាសូត្រ  ទី ២ ........................................ ៣

គោតមីសូត្រ ទី ៣ ........................................ ៥

វិជយាសូត្រ  ទី ៤ ........................................ ៧

ឧប្បលវណ្ណាសូត្រ  ទី ៥ ........................................ ១០

ចាលាសូត្រ  ទី ៦ ........................................ ១២

ឧបចាលាសូត្រ  ទី ៧ ........................................ ១៤

សីសុបចាលាសូត្រ  ទី ៨ ........................................ ១៦

សេលាសូត្រ  ទី ៩ ........................................ ១៨

វជិរាសូត្រ  ទី ១០ ........................................ ២០

៣០៩

## មាតិកាបន្តាន់

# ព្រហ្មសំយុត្តំ

# បឋមោ អាយាចនវគ្គោ

## មាតិកា *អង្កេ*


បឋមំ អាយាចនសុត្តំ ........ ២៩
ទុតិយំ គារវសុត្តំ ........ ៣១
តតិយំ ព្រហ្មទេវសុត្តំ ........ ៣៦
ចតុត្ថំ ពកសុត្តំ ........ ៤០
បញ្ចមំ អបរាទិដ្ឋិសុត្តំ ........ ៤៥
ឆដ្ឋំ បមាទសុត្តំ ........ ៥១
សត្តមំ បឋមកោកាលិកសុត្តំ ........ ៥៥
អដ្ឋមំ តិស្សកសុត្តំ ........ ៥៦
នវមំ តុទុព្រហ្មសុត្តំ ........ ៥៧
ទសមំ ទុតិយកោកាលិកសុត្តំ ........ ៥៩


# ព្រហ្មបញ្ចកំ


បឋមំ សនង្កុមារសុត្តំ ........ ៦៧
ទុតិយំ ទេវទត្តសុត្តំ ........ ៦៨

# សង្ខឹកាចង្អុលប្រាប់មាតិកា

# ព្រហ្មសំយុត្ត

# អាយាចនវគ្គ ទី ១

## មាតិកា

លេខទំព័រ


អាយាចនសូត្រ ទី ១ ........ ២៥

គារវសូត្រ ទី ២ ........ ៣១

ព្រហ្មទេវសូត្រ ទី ៣ ........ ៣៦

ពកសូត្រ ទី ៤ ........ ៤០

អបរាទិដ្ឋិសូត្រ ទី ៥ ........ ៤៥

បមាទសូត្រ ទី ៦ ........ ៥១

បឋមកោកាលិកសូត្រ ទី ៧ ........ ៥៥

តិស្សកសូត្រ ទី ៨ ........ ៥៦

តុទុព្រហ្មសូត្រ ទី ៩ ........ ៥៧

ទុតិយកោកាលិកសូត្រ ទី ១០ ........ ៥៩


# ព្រហ្មបញ្ចកៈ


សនង្កុមារសូត្រ ទី ១ ........ ៦៧

ទេវទត្តសូត្រ ទី ២ ........ ៦៨

# មាតិកាបត្តានិ

## មាតិកា *អង្កេ*


តតិយំ អន្ធកវិន្ទសុត្តំ ........ ៦៩

ចតុត្ថំ អរុណវតីសុត្តំ ........ ៧១

បញ្ចមំ បរិនិព្វានសុត្តំ ........ ៧៨


# ព្រាហ្មណសំយុត្តំ

## បឋមោ អរហន្តវគ្គោ


បឋមំ ធនញ្ជានីសុត្តំ ........ ៨៣

ទុតិយំ អក្កោសកសុត្តំ ........ ៨៧

តតិយំ អសុរិន្ទកសុត្តំ ........ ៩១

ចតុត្ថំ ពិលង្គិកសុត្តំ ........ ៩៣

បញ្ចមំ អហឹសកសុត្តំ ........ ៩៥

ឆដ្ឋំ ជដាសុត្តំ ........ ៩៦

សត្តមំ សុទ្ធិកសុត្តំ ........ ៩៨

អដ្ឋមំ អគ្គិកសុត្តំ ........ ៩៩

នវមំ សុន្ទរិកសុត្តំ ........ ១០២

ទសមំ ពហុធិតិសុតំ ........ ១០៩

# សង្ខឹកាចង្អុលច្រាប់មាតិកា

## មាតិកា

លេខទំព័រ

អន្ធកវិន្ទសូត្រ ទី ៣ ........ ៦៩
អរុណវតីសូត្រ ទី ៤ ........ ៧១
បរិនិព្វានសូត្រ ទី ៥ ........ ៧៨

# ព្រាហ្មណសំយុត្ត

## អរហន្តវគ្គ ទី ១

ធនញ្ជានីសូត្រ ទី ១ ........ ៨៣
អក្កោសកសូត្រ ទី ២ ........ ៨៧
អសុរិន្ទកសូត្រ ទី ៣ ........ ៩១
ពិលង្គិកសូត្រ ទី ៤ ........ ៩៣
អហឹសកសូត្រ ទី ៥ ........ ៩៥
ជដាសូត្រ ទី ៦ ........ ៩៦
សុទ្ធិកសូត្រ ទី ៧ ........ ៩៨
អគ្គិកសូត្រ ទី ៨ ........ ៩៩
សុន្ទរិកសូត្រ ទី ៩ ........ ១០២
ពហុធិតិសូត្រ ទី ១០ ........ ១០៩

# មាតិកាបត្តានិ

# ទុតិយោ ឧបាសកវគ្គោ

## មាតិកា

*អង្គេ*


បឋមំ កសិសុត្តំ ........ ១១៦

ទុតិយំ ឧទយសុត្តំ ........ ១១៨

តតិយំ ទេវហិតសុត្តំ ........ ១២១

ចតុត្ថំ មហាសាលសុត្តំ ........ ១២៤

បញ្ចមំ មានត្ថទ្ធសុត្តំ ........ ១២៩

ឆដ្ឋំ បច្ចនិកសុត្តំ ........ ១៣៣

សត្តមំ នវកម្មិកសុត្តំ ........ ១៣៥

អដ្ឋមំ កដ្ឋហារសុត្តំ ........ ១៣៦

នវមំ មាតុបោសកសុត្តំ ........ ១៤០

ទសមំ ភិក្ខកសុត្តំ ........ ១៤២

ឯកាទសមំ សង្គារវសុត្តំ ........ ១៤៣

ទ្វាទសមំ ខោមទុស្សសុត្តំ ........ ១៤៦

# សង្ខឹកាចង្អុលប្រាប់មាតិកា

# ឧបាសកវគ្គ ទី ២

## មាតិកា

លេខទំព័រ


កសិសូត្រ ទី ១ ........ ១១៦

ឧទយសូត្រ ទី ២ ........ ១១៨

ទេវហិតសូត្រ ទី ៣ ........ ១២១

មហាសាលសូត្រ ទី ៤ ........ ១២៤

មានត្ថទ្ធសូត្រ ទី ៥ ........ ១២៩

បច្ចនិកសូត្រ ទី ៦ ........ ១៣៣

នវកម្មិកសូត្រ ទី ៧ ........ ១៣៥

កដ្ឋហារសូត្រ ទី ៨ ........ ១៣៦

មាតុបោសកសូត្រ ទី ៩ ........ ១៤០

ភិក្ខកសូត្រ ទី ១០ ........ ១៤២

សង្គារវសូត្រ ទី ១១ ........ ១៤៣

ខោមទុស្សសូត្រ ទី ១២ ........ ១៤៦

៣១២

## មាតិកាបត្តានិ

# វង្គីសសំយុត្តំ

## មាតិកា *អង្កេ*


បឋមំ និក្ខន្តសុត្តំ............................................ ១៤៩
ទុតិយំ អរតិសុត្តំ............................................ ១៥២
តតិយំ បេសលាតិមញ្ញនាសុត្តំ............................................ ១៥៥
ចតុត្ថំ អានន្ទសុត្តំ ............................................ ១៥៧
បញ្ចមំ សុភាសិតសុត្តំ............................................ ១៥៩
ឆដ្ឋំ សារីបុត្តសុត្តំ ............................................ ១៦២
សត្តមំ បវារណាសុត្តំ............................................ ១៦៤
អដ្ឋមំ បរោសហស្សសុត្តំ............................................ ១៦៩
នវមំ កោណ្ឌញ្ញសុត្តំ ............................................ ១៧៣
ទសមំ មោគ្គល្លានសុត្តំ ............................................ ១៧៦
ឯកាទសមំ គគ្គរាសុត្តំ............................................ ១៧៨
ទ្វាទសមំ វង្គីសសុត្តំ ............................................ ១៨០

# សង្ខឹកាចង្អុលប្រាប់មាតិកា

# វង្គីសសំយុត្ត

## មាតិកា

លេខទំព័រ


និក្ខន្តសូត្រ ទី ១ ........................................ ១៤៩

អរតិសូត្រ ទី ២ ........................................ ១៥២

បេសលាតិមញ្ញនាសូត្រ ទី ៣ ........................................ ១៥៥

អានន្ទសូត្រ ទី ៤ ........................................ ១៥៧

សុភាសិតសូត្រ ទី ៥ ........................................ ១៥៩

សារីបុត្តសូត្រ ទី ៦ ........................................ ១៦២

បវារណាសូត្រ ទី ៧ ........................................ ១៦៤

បរោសហស្សសូត្រ ទី ៨ ........................................ ១៦៩

កោណ្ឌញ្ញសូត្រ ទី ៩ ........................................ ១៧៣

មោគ្គល្លានសូត្រ ទី ១០ ........................................ ១៧៦

គគ្គរាសូត្រ ទី ១១ ........................................ ១៧៨

វង្គីសសូត្រ ទី ១២ ........................................ ១៨១

# មាតិកាបត្តានិ

# វនសំយុត្តំ

## មាតិកា អង្គេ


បឋមំ វិវេកសុត្តំ ........ ១៨៣

ទុតិយំ ឧបដ្ឋានសុត្តំ ........ ១៨៥

តតិយំ កស្សបគោត្តសុត្តំ ........ ១៨៧

ចតុត្ថំ សម្ពហុលសុត្តំ ........ ១៨៨

បញ្ចមំ អានន្ទសុត្តំ ........ ១៩០

ឆដ្ឋំ អនុរុទ្ធសុត្តំ ........ ១៩១

សត្តមំ នាគទត្តសុត្តំ ........ ១៩៣

អដ្ឋមំ កុលឃរណីសុត្តំ ........ ១៩៥

នវមំ វជ្ជីបុត្តសុត្តំ ........ ១៩៦

ទសមំ សជ្ឈាយសុត្តំ ........ ១៩៧

ឯកាទសមំ អយោនិសោមនសិការសុត្តំ ........ ១៩៩

ទ្វាទសមំ មជ្ឈន្តិកសុត្តំ ........ ២០០

តេរសមំ បាកតិន្ទ្រិយសុត្តំ ........ ២០១

ចុទ្ទសមំ បទុមបុប្ផសុត្តំ ........ ២០៣

# សង្ខឹកាចង្អុលប្រាប់មាតិកា

# វនសំយុត្ត

## មាតិកា

លេខទំព័រ


វិវេកសូត្រ ទី ១ ........................................ ១៨៣

ឧបដ្ឋានសូត្រ ទី ២ ........................................ ១៨៥

កស្សបគោត្តសូត្រ ទី ៣ ........................................ ១៨៧

សម្ពហុលសូត្រ ទី ៤ ........................................ ១៨៨

អានន្ទសូត្រ ទី ៥ ........................................ ១៩០

អនុរុទ្ធសូត្រ ទី ៦ ........................................ ១៩១

នាគទត្តសូត្រ ទី ៧ ........................................ ១៩៣

កុលឃរណីសូត្រ ទី ៨ ........................................ ១៩៤

វជ្ជីបុត្តសូត្រ ទី ៩ ........................................ ១៩៦

សជ្ឈាយសូត្រ ទី ១០ ........................................ ១៩៧

អយោនិសោមនសិការសូត្រ ទី ១១ ........................................ ១៩៩

មជ្ឈន្តិកសូត្រ ទី ១២ ........................................ ២០០

បាកតិន្ទ្រិយសូត្រ ទី ១៣ ........................................ ២០១

បទុមបុប្ផសូត្រ ទី ១៤ ........................................ ២០៣

៣១៤

## មាតិកាបត្តានិ

# យក្ខសំយុត្តំ

## មាតិកា *អង្គ្គេ*


បឋមំ ឥន្ទកសុត្តំ...... ២០៧

ទុតិយំ សក្កសុត្តំ...... ២០៨

តតិយំ សូចិលោមសុត្តំ...... ២១០

ចតុត្ថំ មណិភទ្ទសុត្តំ...... ២១៣

បញ្ចមំ សានុសុត្តំ...... ២១៥

ឆដ្ឋំ បិយង្ករសុត្តំ...... ២១៧

សត្តមំ បុនព្វសុសុត្តំ...... ២១៨

អដ្ឋមំ សុទត្តសុត្តំ...... ២២៣

នវមំ បឋមសុក្កាសុត្តំ...... ២២៧

ទសមំ ទុតិយសុក្កាសុត្តំ...... ២២៨

ឯកាទសមំ ចីរាសុត្តំ...... ២២៩

ទ្វាទសមំ អាឡវកសុត្តំ...... ២៣០

# សង្ខឹកាចង្អុលប្រាប់មាតិកា

# យក្ខសំយុត្ត

## មាតិកា

លេខទំព័រ

ឥន្ទកសូត្រ ទី ១ ........ ២០៧

សក្កសូត្រ ទី ២ ........ ២០៨

សូចិលោមសូត្រ ទី ៣ ........ ២១០

មណិភទ្ទសូត្រ ទី ៤ ........ ២១៣

សានុសូត្រ ទី ៥ ........ ២១៤

បិយង្ករសូត្រ ទី ៦ ........ ២១៧

បុនព្វសុសូត្រ ទី ៧ ........ ២១៨

សុទត្តសូត្រ ទី ៨ ........ ២២៣

បឋមសុក្កាសូត្រ ទី ៩ ........ ២២៧

ទុតិយសុក្កាសូត្រ ទី ១០ ........ ២២៨

ចីរាសូត្រ ទី ១១ ........ ២២៩

អាឡវកសូត្រ ទី ១២ ........ ២៣០

# មាតិកាបត្តានិ

# សក្កសំយុត្តំ

## មាតិកា *អង្កេ*


បឋមំ សុវីរសុត្តំ ........ ២៣៦

ទុតិយំ សុសិមសុត្តំ ........ ២៣៩

តតិយំ ធជគ្គសុត្តំ ........ ២៤៣

ចតុត្ថំ វេបចិត្តិសុត្តំ ........ ២៤៩

បញ្ចមំ សុភាសិតជយសុត្តំ ........ ២៥៤

ឆដ្ឋំ កុលាវកសុត្តំ ........ ២៦០

សត្តមំ នទុព្ភិយសុត្តំ ........ ២៦២

អដ្ឋមំ វិរោចនាសុរិន្ទសុត្តំ ........ ២៦៣

នវមំ អារញ្ញកសុត្តំ ........ ២៦៥

ទសមំ សមុទ្ទកសុត្តំ ........ ២៦៧


## ទេវវគ្គោ ទុតិយោ


បឋមំ បឋមទេវសុត្តំ ........ ២៧២

ទុតិយំ ទុតិយទេវសុត្តំ ........ ២៧៤

តតិយំ តតិយទេវសុត្តំ ........ ២៧៧

# សង្ខឹកាចង្អុលច្រាប់មាតិកា

# សក្កសំយុត្ត

## មាតិកា

លេខទំព័រ


សុវីរសូត្រ ទី ១ ........................................ ២៣៦

សុសិមសូត្រ ទី ២ ........................................ ២៣៩

ធជគ្គសូត្រ ទី ៣ ........................................ ២៤៣

វេបចិត្តិសូត្រ ទី ៤ ........................................ ២៤៩

សុភាសិតជយសូត្រ ទី ៥ ........................................ ២៥៤

កុលាវកសូត្រ ទី ៦ ........................................ ២៦០

នទុព្ភិយសូត្រ ទី ៧ ........................................ ២៦២

វិរោចនាសុរិន្ទសូត្រ ទី ៨ ........................................ ២៦៣

អារញ្ញកសូត្រ ទី ៩ ........................................ ២៦៥

សមុទ្ទកសូត្រ ទី ១០ ........................................ ២៦៧


## ទេវវគ្គ ទី ២


បឋមទេវសូត្រ ទី ១ ........................................ ២៧២

ទុតិយទេវសូត្រ ទី ២ ........................................ ២៧៤

តតិយទេវសូត្រ ទី ៣ ........................................ ២៧៧

# មាតិកាបត្តានិ

## មាតិកា                                                                     *អង្កេ*

ចតុត្ថំ ទឡ្ហិទ្ធសុត្តំ ........ ២៨០

បញ្ចមំ រាមណេយ្យកសុត្តំ ........ ២៨៣

ឆដ្ឋំ យជមានសុត្តំ ........ ២៨៤

សត្តមំ វន្ទនសុត្តំ ........ ២៨៦

អដ្ឋមំ បឋមសក្កនមស្សនសុត្តំ ........ ២៨៧

នវមំ ទុតិយសក្កនមស្សនសុត្តំ ........ ២៩០

ទសមំ តតិយសក្កនមស្សនសុត្តំ ........ ២៩៣

## សក្កបញ្ចកំ

បឋមំ យត្វាសុត្តំ ........ ២៩៧

ទុតិយំ ទុព្វណ្ណិយសុត្តំ ........ ២៩៨

តតិយំ មាយាសុត្តំ ........ ៣០១

ចតុត្ថំ អច្ចយសុត្តំ ........ ៣០៣

បញ្ចមំ អក្កោធសុត្តំ ........ ៣០៥

# សង្ខេបចង្អុលប្រាប់មាតិកា

## មាតិកា

លេខទំព័រ

ទឡ្ហិទូសូត្រ ទី ៤ ........ ២៨០

វាមណេយ្យកសូត្រ ទី ៥ ........ ២៨៣

យជមានសូត្រ ទី ៦ ........ ២៨៤

វន្ទនសូត្រ ទី ៧ ........ ២៨៦

បឋមសក្កនមស្សនសូត្រ ទី ៨ ........ ២៨៧

ទុតិយសក្កនមស្សនសូត្រ ទី ៩ ........ ២៩០

តតិយសក្កនមស្សនសូត្រ ទី ១០ ........ ២៩៣

## សក្កបញ្ចកៈ

ឃត្វាសូត្រ ទី ១ ........ ២៩៧

ទុព្វណ្ណិយសូត្រ ទី ២ ........ ២៩៨

មាយាសូត្រ ទី ៣ ........ ៣០១

អច្ចយសូត្រ ទី ៤ ........ ៣០៣

អក្កោធសូត្រ ទី ៥ ........ ៣០៥

